# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចេញផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

---

## បញ្ជីរឿង

### ផ្នែកអក្សរសាស្ត្រ

ទំព័រ

ឃុនឧត្ដមប្រីជា ជាប-ពិន . . . ប្រស្នាត្រៃមន្ត្រី . . . . . . . . . . . . . ៣៣៩
លោក ហាន់-យេង . . . . . . . រឿងកំពូលកំសត់ (តមក) . . . . . . . . . ៣៤៩
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ប្រជុំសុភាសិតខ្មែរ តាមលំដាប់អក្សរ (តមក) ៣៦០
លោក ញ៉ុក-នូ . . . . . . . ច្បាប់ក្រមបរិយាយ (តមក) . . . . . . . ៣៦៨
ព្រះសមុហ៍ឃោសាចារ្យយូរ-ប៊ុណ្ណ សុវណ្ណសាមជាតក ពាក្យកាព្យ (តមក) . . ៣៧៣

### ផ្នែកសាសនា

ព្រះគ្រូសុវណ្ណញាណ សូរ-ហាយ. ចរិយាយសិប្បកថា (តមក) . . . . . . ៣៨០
ហ្លួងនិពន្ធមន្ត្រី ញ៉ុក_ថែម . . . ឯកភាគ នៃមិលិន្ទបញ្ហា (តមក) . . . . ៣៨៦

---

ឆ្នាំទី ១៦ – លេខ ៧ ខែអស្សុជ ឆ្នាំ ១៩៤៤ – ដំឡៃជាវៈ ១ ឆ្នាំ ១៥ រៀល ។

M.S 1461

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire: Luong Nibandhamantri Nhok-Thêm, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse: Preah kru Paññalikhito Kao-Sim, Surveillant général de l'École Supérieure de Pāli.

## *TABLE DES MATIÈRES*

### Partie littéraire:



| | | Pages |
|---|---|---|
| K un Ŏtdămpreichea Chap-Pinn . . . . . . | Prăsna Trăimontrei . . . . . . . | 339 |
| Monsieur Han-Yêng . . .. | Kămpul kămsăt, roman (suite) . . | 349 |
| Luong nîponmontrei Nhok-Thêm. . . . . . | Recueil de proverbes cambodgiens classés par ordre alphabétique (suite) . . . . . . . . . . . | 360 |
| Monsieur Nheuk-Nou. . .. | Chbăp krămborīyay (suite). . . . | 365 |
| Prăah sămŭk'ôsachar You-Ponn . . . . . . . | Suvannasāmajātaka, poème (suite) | 373 |



### Partie religieuse:



| | | |
|---|---|---|
| Prĕah kru Suvaddhañāna So-Hay. . . . . . . . | Pariyāyasippakathā (suite). . . . | 380 |
| Luong Nîponmontrei Nhok-Thêm. . . . . . | Ekabhāga Milindapañhā (suite) . . | 386 |



16e année — No 7. Juillet 1943 — Abonnement: un an 15$00.

# ប្រស្នាត្រៃមន្ត្រី

## របស់ ឃុនឧត្តមប្រីជា ចាប-ពិន

### ក្រុមពុទ្ធសាសនបណ្ឌិត្យ

វេលាមួយ ជាវេលាចូលឆ្នាំថ្មី, អស់ពួកមន្ត្រីរាជការគ្រប់តំណែង បានព្រះរាជានុញ្ញាតឈប់សម្រាក ៣ ថ្ងៃ ដើម្បីធ្វើបុណ្យចូលឆ្នាំថ្មីតាមទំនៀមស្រុក ៗ ឱកាសនោះ ក្នុងផ្ទះឧកញ៉ាឧត្តមសម្បត្តិ នៅក្រុងភ្នំពេញ មានកិច្ចធ្វើទក្ខិណានុប្បទានឧទ្ទិសផលជូនលោកអ្នកមានគុណដែលធ្វើមរណកាល, បានរៀបចំតាក់តែងតុតាំងកៅអី កម្រាលព្រំពៀមចំក្បាច់ផ្កាជាច្រើន, និមន្តព្រះសង្ឃជាច្រើនរូបមកទទួលភត្ត ។ មានអស់លោកមន្ត្រី និងពួកឧបាសកឧបាសិកា ជាញាតិមិត្រនៅជិតខាង មកជួយចាត់ចែងជាច្រើន ។

វេលាវេរភត្តឧទ្ទិសផលរួចសព្វគ្រប់ ប្រគេនចង្ហាន់ព្រះសង្ឃ, ព្រះសង្ឃកំពុងឆាន់ដោយរៀបរយ; ក្នុងវេលានោះ, ហ្លួងប្រជានុស័ក្ដិ ធ្វើនិយាយសំណេះសំណាលប្រឹក្សាក្បួនច្បាប់នឹងឃុនរក្សាកោសលថា: យើងទាំងអស់គ្នាជាឃរាវាសដែលមានកូនប្រុសស្រី សុទ្ធតែត្រូវរៀបចំឲ្យមានគូស្រករតែរៀងខ្លួន, ចំណែកខាងលោក បើនឹងរៀបកូនស្រីឲ្យមានស្វាមី តើលោកចូលចិត្តឲ្យទៅមនុស្សបែបណា ?

ប្រស្នានេះខ្ញុំបាទពិបាកជំរាបណាស់លោក! មិនងាយទេ, ព្រោះគំ-
និតមនុស្សយើងដែលប៉ងប្រាថ្នា ជួនកាលក៏បានសំរេច ជួនកាលមិន
បានសំរេចដូចបំណងទេ ៗ យុនពេហារកោសល តប.

បាទ, ដែលលោកមានប្រសាសន៍ថាពិបាក នោះពិតណាស់
ហើយ, ប៉ុន្តែទោះបីពិបាកយ៉ាងម៉េច ក៏យើងត្រូវតែគិត ខានពុំបាន,
បើយើងមិនគិតសោះ ចេះតែឲ្យដោយប្រថុយប្រថានទៅ ក៏មិនកើត
ដែរ, ក្រែងដល់ទៅថ្ងៃខាងមុខ កើតសេចក្ដីមិនស្រួលដល់កូនស្រីយើង;
តែកើតរឿងមិនស្រួលឡើង កូនស្រីយើងចាប់ទោសយើងបាន, ព្រោះ
ហេតុនេះ បានជាមានបុរាណសុភាសិតថា "ធ្វើស្រែឲ្យមើលស្មៅ ទុក
ដាក់កូនទៅ មើលផៅសន្ដាន" ៗ ចំណែកខ្ញុំបាទរើសបន្តិចហើយ
មិនងាយប្រថុយទេ ខាងលោកតើរើសយ៉ាងណា ឬលោកមិនរើសទេ ?
ហ្លួងប្រជានុសិដ្ឋសួរ.

ខ្ញុំបាទក៏រើសដូចលោកដែរ មិនមែនចេះតែប្រថុយទេ, តែការនេះ
ស្រេចលើសំណាងកូនខ្ញុំបាទផង ដ្បិតបុរាណលោកពោលថា "នាង
ត្រូវនឹងអ្នក មេខាតលក្ខណ៍ត្រូវនឹងអាកំបាក់ខ ឡូ, គូគេបមិនរួច អាយុ
មិនអស់មិនស្លាប់"; ព្រេងសំណាងកូនខ្ញុំបាទមិនដឹងជាដូចម្ដេចដែរ, ខ្ញុំ
បាទជាឪពុកគ្រាន់តែជួយជ្រើសប៉ុណ្ណោះ ៗ យុនពេហារកោសល តប.

នៅឱកាសដែលមន្ត្រីពីរនាក់ កំពុងប្រឹក្សាគ្នាមិនទាន់ដាច់ស្រេច, ស្រាប់តែឧកញ៉ាធម្មានុសារសក៍ ជាមន្ត្រីក្រមការដបណ្ឌិត ចូលមកអង្គុយក្នុងទីប្រជុំនោះដែរ, ហ្លួងប្រជានុសិដ្ឋ ក៏លើកយកប្រឹក្សានឹងឧកញ៉ាធម្មានុសារសក៍ថា: ឱ! ដំណើរដែលលោកអញ្ជើញមកនេះជាការប្រពៃណាស់, ព្រោះខ្ញុំបាទជាមួយនឹងឃុនពេហារកោសល កំពុងពិភាក្សាគ្នាពីរឿងរៀបចំកូនចៅឲ្យមានគូស្រករ មិនទាន់ដាច់ស្រេច; សូមលោកជាអ្នកប្រាជ្ញជួយវិនិច្ឆ័យសេចក្ដីនេះឲ្យត្រឹមត្រូវផង, មើចទៅលោក! ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង ទ្រង់បានសំដែងពីរឿងរៀបចំកូនស្រីឲ្យមានស្វាមីដែរឬទេ ?

ព្រះសម្មាសម្ពុទ្ធឥតមានធុរៈ ក្នុងរឿងរៀបចំកូនចៅឲ្យមានគូស្រករទេ, ព្រះអង្គមានព្រះអធ្យាស្រ័យតែខាងបម្រុងសត្វឲ្យឆ្លងកាត់វាលវដ្តសង្សារទៅកាន់ឋានព្រះនិព្វានតែមួយយ៉ាងទេតើលោក! ។ ឧកញ៉ាធម្មានុសារសក៍តប .

បាទ, ព្រះពុទ្ធជាម្ចាស់ មានព្រះអធ្យាស្រ័យដូចលោកបានប្រសាសន៍នោះមែនហើយ, តែក្រែងមានខរឿងជាតកនិទានអំពីបុគ្គលណាទុកដាក់កូនចៅដែរឬគ្មានសោះ? ហ្លួងប្រជានុសិដ្ឋសួរ.

បាទ, មានខ្លះដែរ, ឧកញ៉ាធម្មានុសារសក៍ឆ្លើយ– ខ្ញុំបាទឃើញក្នុងសាធុសីលជាតក អដ្ឋកថាខុទ្ទកនិបាត និទានអំពីរឿងព្រាហ្មណ៍ម្នាក់ថា:

កាលព្រះសម្មាសម្ពុទ្ធទ្រង់ប្រថាប់គង់វត្តជេតពន, មានព្រាហ្មណ៍ម្នាក់មានកូនក្រមុំ ៤ នាក់ ។ គ្រានោះ មានប្រុស ៤ នាក់ ម្នាក់រូបល្អ, ម្នាក់ចាស់, ម្នាក់ជាតិខ្ពស់, ម្នាក់មានសីល, មកដណ្តឹងកូនព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍គិតថា " នឹងឲ្យទៅអ្នកណាទើបគាប់ប្រសើរ " ។ កាលបើគាត់មិនដឹងថាខាងណាស្រួល ក៏ចូលទៅគាល់ព្រះបរមសាស្តា ចំណាលរឿងនុះក្រាបទូលសួរព្រះអង្គ ។

ព្រះសម្មាសម្ពុទ្ធត្រាស់ថា : ម្នាលព្រាហ្មណ៍ , កាលពីព្រេងនាយ មានអ្នកប្រាជ្ញឆ្លើយប្រស្នានេះប្រាប់អ្នកដែរ, តែអ្នកភ្លេចទៅ ព្រោះភពបិទបាំង ។ ព្រាហ្មណ៍សុំអារាធនា ព្រះអង្គក៏ទ្រង់នាំអតីតនិទានមកសំដែងថា :

ក្នុងកាលកន្លងរំលងទៅហើយ, តថាគតជាពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ នៅក្នុងក្រុងពារាណសី, កាលបឋមវ័យបានទៅរៀនសិល្បសាស្ត្រឯនគរតក្កសិលា, លុះត្រឡប់មកស្រុកកំណើតវិញ, បានជាអាចារ្យទិសាបាមោក្ខ (ជាប្រធានក្នុងទិស) មានសិស្សពីស្រុកតូចធំនិគមជនបទផ្សេងៗ មករៀនជាច្រើន ។ គ្រានោះ អ្នកកើតជាព្រាហ្មណ៍ម្នាក់ មានកូនក្រមុំ ៤ នាក់ ដូចកាលឥឡូវនេះដែរ, មានប្រុស ៤ នាក់មកដណ្តឹងដូចគ្នា ។ អ្នកមិនដឹងជាឲ្យទៅអ្នកណាស្រួល ក៏ចូលទៅរក

អាចារ្យទិសាបាមោក្ខ, ដំណាលរឿងនោះសព្វគ្រប់ សួរលោកជា
គាថាថា :

មនុស្សរូបល្អ, ចាស់, និងខ្ពស់ជាតិ, មនុស្សមានសីលស្អាត ៤ នេះពិត
ខ្ញុំសូមសួរលោកឲ្យពិនិត្យ តើលោកចូលចិត្តមនុស្សយ៉ាងម៉េច?
បើលោកចូលចិត្តមនុស្សបែបណា មេត្តាប្រោសប្រាប់មួយរំពេច
ឲ្យខ្ញុំបានដឹងសព្វសេចក្រេច លោកថាយ៉ាងម៉េចខ្ញុំជឿតាម ។

អាចារ្យទិសាបាមោក្ខឆ្លើយជាគាថាថា :

មនុស្សមានរូបល្អពេកកន្លង អ្នកផងស្រឡាញ់ចង់សេពគប់,
មនុស្សមានវ័យចាស់គេគោរព, មនុស្សជាតិខ្ពស់លុះគេកោតក្រែង ។
តែបើខាងខ្ញុំចូលចិត្ត អ្នកមានសីលពិតល្អក្រៃលែង
ព្រោះមនុស្ស ៣ ពួកក្រៅនោះឯង រមែងមានគេតិះដៀលបាន ។
ឯអ្នកមានសីលល្អចំណាប់ កាន់ច្បាប់គ្រិហស្ថខ្ពស់ចំណាន
ពុំដែលឲ្យកើតរនស្អួន អ្នកផងពុំបានរង្កៀសឡើយ ។

ព្រាហ្មណ៍បានស្ដាប់អាចារ្យទិសាបាមោក្ខពោលដូច្នោះហើយ, ក៏ផ្ដុំកូនក្រមុំទាំង ៤ នាក់ឲ្យមានប្ដីសុទ្ធតែជាអ្នកមានសីលគ្រប់គ្នា ។

ដែលលោកមានប្រសាសន៍រឿងសាធុសីលជាតកមកនេះ, ខ្ញុំបានស្ដាប់បានថា : អាចារ្យទិសាបាមោក្ខជាន់ដើមសរសើរអ្នកមានសីល, ព្រាហ្មណ៍ក៏ឲ្យកូនទៅអ្នកមានសីលតាមនោះ បានសេចក្ដីសុខសេចក្ដីចំរើន; យើងជាន់ឥឡូវ ក៏គួរឲ្យកូនទៅអ្នកមានសីលដូចព្រាហ្មណ៍នោះដែរ ព្រោះយើងក៏ចង់ឲ្យកូនបានសេចក្ដីសុខដូចគ្នា តែលោកមិនទាន់អធិប្បាយឲ្យច្បាស់លាស់ថា "អ្នកមានសីលនោះ ជាមនុស្សមានកិរិយា

ប្រព្រឹត្តដូចម្ដេចនោះឡើយ", បើដូច្នេះ សូមអញ្ជើញលោកអធិប្បាយបន្តិចទៅទៀតមើល ចាំពេលព្រះសង្ឃឆាន់បង្អាន់រួច; ដូចម្ដេចទៅលោក! ដែលហៅថា មនុស្សមានសីល? ហ្នឹងប្រជាទុសិដ្ឋសួរ.

សូមជំរាបលោក, ដែលហៅថាមនុស្សមានសីលនោះ បើនិយាយដោយពិស្ដារ បានដល់មនុស្សដែលរក្សាសីល៥ គម្រប់១០ បើនិយាយដោយសង្ខេបក៏គឺមនុស្សដែលមានកាយ វាចា សណ្ដាប់ធ្នាប់ត្រឹមត្រូវ មានគំនិតមារយាទល្អ ស្លូតបូត មិនព្រហើនកោងកាច ជាមនុស្សខំរកស៊ីធ្វើការ មិនដើរលេងថ្ងៃថ្ងា មិនលេងស្រី មិនផឹកស្រា ទំាងមិនលេងល្បែងភ្នាល់ ជាដើម ៗ ឧកញ៉ាឥន្ទានុសារ សក់ឆ្លើយ.

ខ្ញុំបាទសុំទោសលោក, បើលោកបើកឱ្យ ខ្ញុំបាទសុំសួរដេញដោលតទៅទៀត ដើម្បីកំចាយប្រស្នានេះឲ្យឆ្ងាយឡើង ៗ ហ្នឹងប្រជា-ទុសិដ្ឋ តប.

បាទ, មិនអីទេលោក! ខ្ញុំបាទបើកឱកាសជូនបាន តែបានតាមប្រមាណ ដ្បិតខ្ញុំបាទចេះដឹងតិចដែរ, ក្នុងគម្ពីរពុទ្ធសាសនាមានសំដែងច្រើនណាស់អំពីលក្ខណៈអ្នកមានសីល ខ្ញុំបាទចេះមិនសព្វទេ សុំឆ្លើយជូនលោកតែយ៉ាងសង្ខេបខ្លី ៗ តាមទំនងដែលចេះដឹងខ្លះ ៗ ឧកញ៉ាឥន្ទានុសារ សក់តប.

បាទ, មិនអីទេ ខ្ញុំក៏ខ្ញុំចុះ ព្រោះពេលយើងក៏ខ្ញុំដែរ, លោកបាំងអី

លោក បានជាខ្ញុំបាទឈ្លោះឈ្លីពេញពោលដូច្នេះ ព្រោះធម្មតាមនុស្ស ប្រុសកម្លោះដែលចង់បានកូនក្រមុំរបស់ត្រកូលណា បើដឹងថាត្រកូលនោះគេចូលចិត្តបែបណា ក៏ប្រព្រឹត្តខ្លួនជាមនុស្សបែបនោះដែរ ខ្សៀប-ឡបអបអងគេ ដើម្បីឲ្យគេផុងតំនិតឲ្យកូនមកខ្លួន, បើមេបារបស់ត្រកូលនោះមិនសង្កេតឲ្យល្អិតល្អន់ទេ ភ្ជាក់គំនិតឲ្យកូនទៅ, ដល់ទៅថ្ងៃមុខ មិនយូរប៉ុន្មាន ក៏ទៅជាអ្នកលេងស្រី ផឹកស្រា លេងល្បែងភ្នាល់ ធ្វើឲ្យកើតទុក្ខវេទនាយ៉ាងខ្លាំងដល់កូនស្រីរបស់ខ្លួន; កាលបើដូច្នោះ ម្តាយឪពុកតែងបានសេចក្តីបន្ទោសអំពីកូនស្រីថា "ទាស់តែពីម៉ែឪ បានជាកូនពិបាកដល់ម្ល៉េះ" ម្តាយឪពុកក៏មិនដឹងធ្វើដូចម្តេច, ព្រោះខ្លួនមិនបានពិនិត្យពិច័យមែន; ហេតុនេះ បើយើងចូលចិត្តឲ្យកូនទៅអ្នកមានសីល យើងត្រូវពិនិត្យឲ្យល្អិតសិនសិមឲ្យ, រឿងអ្នកមានសីលនេះ តើយើងត្រូវសង្កេតយ៉ាងណាទៅលោក! ទើបដឹងប្រាកដថាជាអ្នកមានសីលមែន ? ហ្លួងប្រជានុសិដ្ឋស្សរ .

ឱ! លោក, រឿងសង្កេតរកមនុស្សអ្នកមានសីលនោះពិបាកណាស់ មិនងាយទេ, ឧកញ៉ាធម្មានុសាសក៍ឆ្លើយ - ក្នុងគម្ពីរពុទ្ធសាសនាមានសំដែងថា: បើចង់ដឹងមនុស្សអ្នកមានសីល ត្រូវពិសោធដោយការនៅរួម-ជាមួយគ្នា ឬនៅជិតគ្នាយូរៗ ទើបដឹងបាន, ជួបគ្នាតែមួយភ្លែត ឬគ្រាន់តែ

ពុំសំពី មិនទាន់ប្រាកដទេ, ដូចចង់ដឹងមនុស្សអ្នកមានប្រាជ្ញ ត្រូវពិសោធក្នុងពេលដែលមានគេសាកសួរជេញជោល, ចង់ដឹងមនុស្សអ្នកមានកម្លាំង ត្រូវពិសោធក្នុងពេលដែលមានគ្រោះថ្នាក់, បើមិនទាន់បានពិសោធមើលទេ កុំគាល់ជឿ, សេចក្ដីនេះយ៉ាងណា; ការជ្រើសរើសគូរក្រមាំងសីល ក៏ដូចគ្នា ទំនងជឿប្រញាប់ភ្លាមៗ ពេកមិនបានទេ, លុះតែគយឃាំចាំមើលពុតជោយខ្លួនឯង ឬស៊ើបសួរអ្នកផងដែលជាមនុស្សសុចរិត ឬក៏ធ្លាប់ដឹងធ្លាប់ស្គាល់គ្នាជាយូរៗ មកហើយថាជាមនុស្សមានសីលពិតប្រាកដមែនសឹមជឿ; មួយទៀតស៊ើបសួរកេត្ដពង្សវង្សត្រកូលរបស់អ្នកនោះជាយម៉ឹងម៉ាត់ បើឃើញថា សុទ្ធតែជាមនុស្សកេសរុំធ្វើការ មានសីលាចារ មានគំនិតមារយាទល្អគប់គ្នា មិនសូវវឹលខូច សឹមជឿយកជាការ ព្រោះធម្មតាមនុស្ស បើពូជពង្សវង្សត្រកូលល្អហើយគង់មិនបោលខ្ញែកពីវង្សត្រកូលប៉ុន្មាន; សមដូចសុភាសិតបុរាណថា "ផ្លែឈើជ្រុះមិនឆ្ងាយពីគល់" ព្រោះហេតុនេះបានជាចាស់ៗពីបុរាណតែងពោលថា "ធ្វើស្រែឲ្យមើលស្មៅ ចុកជាក់កូនទៅមើលទៅសម្ពានតីមើលពូជ" នោះឯង. បើមិនទាន់បានពិសោធចាំងសារម្ចុន ទំនងពូជពង្សទេ កុំគាល់ចុកចិត្តឲ្យសោះ ព្រោះមនុស្សយើងមានពុកត្បូតច្រើនបែបច្រើនយ៉ាងណាស់ ចួនកាលបានរៀនសូត្រធម៌គាថាបេះដងច្រើន បានឈ្មោះថាជាអាចារ្យហើយ ក៏គង់តែជាមនុស្ស

ឥតស៊ីលទៅបាន. បើយើងបានពិនិត្យតាំងសាមីខ្លួន តាំងពូជពង្សវង្ស ត្រកូលឃើញថា ជាអ្នកមានសីលាចារកិរិយាមារយាទល្អត្រឹមត្រូវ ហើយសីមទៀប, បើទៅតែមិនស្រួល នោះយើងក៏ល្មមអស់ចិត្តដែរ កូនស្រីយើងក៏រាបទោសយើងពុំបាន ធ្វើម៉េចជាកម្មរបស់យើងទាំងកម្មរបស់គាត់, យើងគោរពគិតដល់កម្មទាំងផលរបស់កម្មផង ទើបស្រាលចិត្ត ។

ណ្ហើយលោក! យើងល្មមបញ្ចប់ប្រស្នាប៉ុណ្ណឹងចុះ, បើលោកមិនអស់ចិត្ត ចាំថ្ងៃក្រោយ បើមានពេលសូមយើងប្រឹក្សាគ្នាម្ដងទៀត ឬលោកអញ្ជើញទៅប្រឹក្សានឹងលោកអ្នកប្រាជ្ញផងណាទៀតក៏បាន, ពេលនេះល្មមសន្ទនាប៉ុណ្ណឹងហើយ ។

សាធុ! សាធុ! ល្អហើយ! ល្អហើយ! លោក, ខ្ញុំបាទអស់ចិត្ត ហើយរឿងរកកូនប្រសាប្រុសនេះ, ទៅតែរឿងរកកូនប្រសាស្រី មិនទាន់បានដឹងសោះ, ខ្ញុំបាទចង់សួរលោកតទៅទៀត តើបានឬទេ? ហ្ន៎ ប្រជានុសិដ្ឋទទួលអំណរដោយសេចក្ដីរីករាយ!

ណ្ហើយលោក! កុំអាលសួរ, ចាំក្រោយបើមានឱកាសសូមយើងប្រឹក្សាគ្នាទៀត; ពេលនេះ ល្មមប៉ុណ្ណឹងចុះ ព្រោះដល់ពេលបាយហើយ; មិនអីទេលោក! បើប្រស្នាក្រោយនោះធូរៗ ល្មមនឹងប្រាជ្ញខ្ញុំបាទ ខ្ញុំបាទឆ្លើយជូនបានទៀត កុំព្រួយ!! ឧកញ៉ាធម្មានុសាសន៍ តប.

កាលអស់លោកត្រៃមន្ត្រីគឺឃុនពេហារកោសល, បានប្រជាធុសិដ្ឋ នឹងឧកញ្ញាធម្មានុសាសក៍ ប្រឹក្សាធម៌គាថាក្បួនច្បាប់ ព្រមព្រៀងគ្នា ហើយ ដល់វេលាព្រះសង្ឃឆាន់រួចល្មម, ឧកញ្ញាឧត្តមសម្បត្តិ ក៏ចាត់ចែងអាហារដ៏ផ្ចិតផ្ចង់ ជូនអស់លោកត្រៃមន្ត្រី ព្រមទាំងឧបាសកឧបាសិកា ពិសាឆ្អែតស្កប់ស្កល់គ្រប់គ្រាន់. លុះអស់លោកត្រៃមន្ត្រីនឹងឧបាសកឧបាសិកាទាំងនោះ ពិសាភោជនាហាររួចហើយ ក៏ជូនពរសព្ទសាធុការដល់ឧកញ្ញាឧត្តមសម្បត្តិព្រមទាំងគ្រួសារ ហើយលាចេញទៅនេហដ្ឋានរៀងខ្លួន ។

---

## កំពូលកំសត់

## លោកហាក់ - ឈេង *តែងនិងរៀបរៀង*

(តមក)

"បាទ ការត្រង់ណេះខ្ញុំបាទហ៊ានសន្យាជូន បើកាលណាហើយខ្ញុំបាទប្រព្រឹត្តបទល្មើសឯណាមួយលើនាង សូមឲ្យលោកផ្ដន្ទាទោសរបស់ខ្ញុំបាទជាៗក្រដ្ឋចុះ គឺខ្ញុំបាទសុខចិត្តចុះបញ្ចេញតែខ្លួនទទេ ប្រគល់ទ្រព្យសម្បត្តិផ្ទះសម្បែងជូននាងទាំងអស់ ត្រង់ណេះគួរលោកៈជឿចុះ ខ្ញុំបាទមិនដែលពោលពាក្យមុសាវាទទេ ដូចលោកបានប្រសព្វនឹងខ្ញុំបានស្គាល់គំនិតមារយាទស្រាប់ហើយ" ។

"លោក! មិនបាច់លោកសន្យាក៏ខ្ញុំជឿចិត្តលោកដែរ បានជាខ្ញុំគឹងតែងបន្តិចនោះ គឺពីព្រោះអាណិតដល់នាងប៉ុណ្ណោះទេតើ តែការនេះខ្ញុំមិនហ៊ានសម្រេចដោយខ្លួនខ្ញុំដែរ ចាំខ្ញុំសួរចិត្តក្មួយខ្ញុំមើល បើនាងព្រមនោះក៏ប្រសើរហើយ បើនាងមិនព្រមខ្ញុំក៏មិនដឹងធ្វើដូចម្ដេចដែរ" ។

យប់មួយជាឱកាសល្អ វត្តនារីមានមុខស្រស់បស់ មារបស់នាងក៏និយាយជាមួយនឹងនាងថា "មេចៅក្មួយ! ក្មួយបានដំណឹងពីសុកិខ្មែដែរឬអ្វី?

"ចាះទេ! គ្មានបានដំណឹងអ្វីបន្តិចបន្តួចមកសោះ ខ្ញុំហាក់ឆ្ងល់អស់យ៉ាងហើយ" ។

"ចុះសោកគិតទៅកែការបានអ្វី? ឯប្រពន្ធថ្មីរបស់គេ នៅតែស្រស់ស្រាយដូចម្តេច ?

"មើលទៅប្រហែលជានៅដដែលហើយលោកគ្រូ" ។

"ចុះឯងលែងខឹងសោកគិតទៀតហើយឬយ៉ាងដូចម្តេច ?

"ចា៎ះ លែងខឹងហើយដាក់តាមប្រសាសន៍លោកគ្រូ ជាតិនេះខ្ញុំបានជាផលហួសទៅហើយ ជាតិក្រោយ ៗ ខ្ញុំលែងជួបនឹងគាត់ទៀតហើយ ចំណែកសុកិច្ចខ្ញុំមិនឲ្យទៅចាប់ពោះនឹងអ្នកដទៃទេ" ។

ម្ចាស់នាងដកដង្ហើមធំមួយសន្ទុះ ទើបនិយាយទៀតថា "ណ្ហើយក្មួយ! ក្មួយឯងកុំព្រួយពេកនាំតែស្តាយទេ បើក្មួយស្រឡាញ់គ្នានោះ ទោះក្មួយកើតឯណាមួយជួយឲ្យមានកំឡាំងកំហែង កុំឲ្យគ្មានកើតទុក្ខ ដល់បានជួបមុខគ្នា ក្មួយកុំស្មានថាមិនបានជួបគ្នាថ្ងៃណាមួយនោះ ព្រោះដីមូលវិលចុះវិលឡើងគង់តែប្រទះគ្នាទេ" ។

"ខ្ញុំក៏គិតឃើញដូច្នោះដែរ តែមិនដឹងគិតដូចម្តេច" ។

"បើដូច្នោះក្មួយតាមមាទេ បើមារកសេចក្តីសុខឲ្យក្មួយបាន ?

"ចុះលោកគ្រូឲ្យក្មួយតាមបងណា មានប្រសាសន៍មកចុះក្មួយនឹងធ្វើតាម បើក្មួយអាចនឹងធ្វើតាមបាន" ។

"ក្មួយស្គាល់លោកទៅក្រមសាលាដំបូងទេ? -ស្គាល់- លោកនោះមានគំនិតខាងយោគល្អណាស់ ហើយមានសម្បត្តិក៏ច្រើនក្រែល លោក

ពេញចិត្តនឹងឯងណាស់ ហើយសន្យានឹងថានឹងឲ្យឯងបានសេចក្តីសុខ តែឯងយល់ដូចម្តេច ?

នាងក៏ឆ្លើយតែក្នុងពឹងថា . . . ពានហ្វាងសាលាជំប៉ូងមានសម្បត្តិស្តុកស្តម្ភ អាចឲ្យសេចក្តីសុខដល់នាង ចំពោះនាងដែលព្រាត់ប្រាសចាកកូនសម្លាញ់. . . ។

"ម៉េចកូន កូនយល់ព្រមឬ?

នាងក៏បើកភ្នែកឡើង មានទឹកភ្នែកហូរហៀរ ជោកថ្ពាល់ទាំងគូ ហើយនាងខ្សឹកខ្សួលមួយសន្ទុះ បាននិយាយឡើងថា "ទេ! ទេ! លោកពូ . . . កុំមានប្រសាសន៍អំពីរឿងនេះទៀត ព្រោះចិត្តខ្ញុំជាចិត្តម្តាយដែលស្រឡាញ់កូន មិនត្រូវគិតអ្នកដទៃក្រៅអំពីកូនឡើយ ឱ! សុកគ្រូ មាសម្តាយអើយ . . . !! ។

បទទី ១០

## បារីស្មោះត្រង់នឹងចៅហ្វាយនាយ

មានល្ងាចមួយ រ័ត្នានារីប្រាថ្នានឹងជិះស៊ីក្លូយកខ្យល់អាកាស ទើបនាងផ្លាស់សំលៀកបំពាក់ហើយក៏ចុះចេញពីផ្ទះដើរទៅក្រៅ ចួនជាស៊ីក្លូមួយមកដល់ នាងក៏ឡើងជិះឲ្យគេបរតាមផ្លូវ "កេនរោត្តម" ។

ឯត្រើយនាយខាងណោះ ផ្ទុយចង្វាទៅសួនវែងទៅឆ្ងាយ មានសេចក្តីនឹកគ្រប់ផណ្តាប់ជុំជិតដោយអន្ទោ មានក្តីងអត្តិសទក្លាព្រាង

ត្រោតបាំងទៅក្នុងទឹក ជាសណ្ឋានសសរក្មេងរៀបៗតាមក្រសែទឹក ដែលហូរស្រឡមធ្លាក់ចុះទៅទន្លេធំ ៗ ខាងលើពពកសក្បុះភ្នំចិញ្ចាច រួចមានពពកខ្មៅ បាំងព្រះចន្ទ្ររៀបនឹងរះជិតនៅតែមួយចំហៀង ក្រឡេកមើលទៅឃើញព្រានៗ តែងចុះទៅក្នុងទន្លេឲ្យដាលប្រាត់បាន ៗ កណ្តាលផ្ទៃមេឃ មានផ្កាយភ្លឺផ្លេកផ្លូចជាត្បូងពេជ្រ ពីផ្កាយយាមខន្ទ័ល ដែលទៀងជិតផ្កាយសេះនឹងផ្កាយកូនមាន់ មានពន្លឺប្រឡះគួរឲ្យគន់ គួរឲ្យចង់ចាប់លេង គួរឲ្យស្នេហាត្រេកត្រអាល ៗ

ឯត្រើយខាងអាយភ្លឺចាំងដោយគោមគេះឯង ទៅត្រង់កំពង់ធំ ស្រឡះអណ្តែតលើប៉ោតដែកធំៗ ជាច្រើន ហើយមានស្ពានដែកកាត់ចាំងប៉ែកផ្ទង់ទន្លេឲ្យទឹងមិនឲ្យឃ្លេងឃ្លោង មានកប៉ាល់មួយធំបញ្ឆេងស្ងាត់ឈឹង ពីរបំពង់ក្មេងផ្សែងខ្មៅហុយរុំយៗឡើងទៅលើខាងណោះ ទូកនាវាជាច្រើនបោះយុថ្កាចតនៅទឹងឥតកំរើក ពេលនោះស្ងាត់ច្រៀបឥតឮសូរអ៊ូរក្រៅអំពីសត្វលោក ដែលបោកលើច្រាំងលាន់គ្រៀកៗ ពិរោះផល់ត្រចៀកពន់ពេក គួរឲ្យនឹកសង្វេគងាពត្រីកាលនោះណាស់ យូរៗមានទូកតូចមួយលយចាត់វិកទៅបាត់ក្នុងសេចក្តីងងឹតទៅ ឮសូរតែបង្វាក់ចែវដែលកាយទឹកព្រមៗគ្នា ស្រាប់តែបន្លិចលេចចេញពីកណ្តាលទន្លេនូវសព្ទចំរៀងយូនផងត្រីពិរោះលន្លោចល្វងល្វើយ មានបទសមនឹងយប់ខែភ្លឺនោះឯង ៗ

ឯអាកាស សេចក្ដីសៅសោក សេចក្ដីសម័យក្ញើតក្ញើន សេចក្ដីស្ងាត់កំបាំងលាយឡំគ្នាទីងលំអរបស់ធម្មជាតិ ហាក់ដូចជាប្រហាក់ប្រហែលឃើញមិនច្បាស់ទំហោយមិនកើត ដែលសមដល់ទឹកចិត្ដរបស់រ័ត្ននារីនាវេលាគ្រានោះ ។

នាងក៏បានស្បៀយទុក្ខបណ្ដោយឲ្យអានុភាពគ្រាកាលនោះ គ្រប់គ្រងកាយនិងវិញ្ញាណរបស់នាង ហើយនាងផ្អែកខ្លួនទៅខឹងពូកស៊ីក្លូដេចភ្នែកព្រឹមៗ ព្រោះនាងមានសេចក្ដីទំនុកទុកចិត្ដដល់ជោគវាសនាទៀតវិញហើយ នាងភ្លេចគិតថានាងនៅលើស៊ីក្លូ ចង់អ្នកធាក់បរទៅដល់ទីណានាងក៏មិនដឹង ស្រាប់តែអ្នកស៊ីក្លូនោះស្រែកប្រាប់នាងឡើងថា "អ្នក ដល់ផ្ទះហើយ ល្មមអញ្ជើញទៅសម្រាន្ដចុះយប់កាន់តែត្រជាក់ ហើយក្រែងបែរជាមិនស្រួល" ។

នាងក៏ភ្ញាក់ព្រើតដើរចុះចេញពីស៊ីក្លូ ទឹកឆ្ងល់ណាស់ ចុះអ្នកហ្នឹងមកពីណាមក បានជាយកចិត្ដទុកដាក់ដល់រូបនាង នាងអត់ទ្រាំមិនបាន ក៏សួរឡើងថា "នែអ្នកស៊ីក្លូ អ្នកឯងនៅទីតំបន់ណា បានជាចិត្ដល្អដល់ខ្ញុំម្ល៉េះ? ហ៎! យកថ្លៃឈ្នួលទៅ" ។

អ្នកនោះទទួលយកហើយ ក៏សើចបន្តិចៗ ថា "អ្នកមិនស្គាល់ខ្ញុំបាទទេឬ?

"ចាះទេ" ។

"អ្នកភ្លេចហើយ ចៅប្រុសរបស់អ្នកដែលតែងជូនសុក្រខ្ញុំទៅរៀនអក្សររៀងរាល់ថ្ងៃ ខានតែថ្ងៃព្រហស្បតិ៍និងអាទិត្យប៉ុណ្ណោះ" ។

"ឱ! ចាំខ្ញុំនឹកមើលសិន តាព្រំ! តាព្រំ! មែនហើយ ចុះតានៅឯណាសព្វថ្ងៃ ដូចម្តេចក៏ឃ្លាតមកដល់ស្រុកនេះ មកយូរហើយឬអី?

"បាទបាន! ខ្ញុំបាទតាំងពីមានហេតុមក ខ្ញុំបាទក៏វិលទៅផ្ទះវិញ តែគ្រូអាករខ្ញុំបាទគ្មាន បានជាស៊ីកាត់ស្រុកមករកទទួលទានជាអ្នកជាក់ស៊ីក្លូ នីមួយថ្ងៃខ្ញុំបាទរកបានបួនប្រាំរៀលដែរ ត្រាន់នឹងចិញ្ចឹមតែពោះ ហើយនឹងទុកសន្សំខ្លះ តែយាបំណាស់ការនេះ គោងតែរត់ទាំងថ្ងៃត្រង់ បែកញើសជោគខ្លួន ខ្ទេចអស់ហើយបានជាបេះតែទាំទៅ នាំឲ្យខ្ញុំនឹកដល់ព្រះគុណម្ចាស់ថ្លៃ ដល់ត្រង់ណោះ តាព្រំក៏លើកដៃជូនស្ទួនឡើង "កាលខ្ញុំបាទនៅជាមួយនឹងអ្នកនោះ ខ្ញុំបាទបានសេចក្តីសុខគ្រប់ប្រការ ហើយទុកជាខ្ញុំបាទឃ្លាតមកឆ្ងាយក៏ខ្ញុំបាទនៅតែស៊ើបសួរ អំពីចៅហ្វាយបានដឹងសព្វគ្រប់" រួចតាព្រំក៏ផ្តើមយំជាទុក្ខ ។

ចំណែកកញ្ញានារីកាលបើស្គាល់ថាជាបាវចាស់របស់នាងហើយ នាងក៏មានសេចក្តីត្រេកអរឥតឧបមា អង្វរតាព្រំឲ្យលែងជាក់ស៊ីក្លូឲ្យមកនៅនឹងនាងដូចដើមវិញ តាព្រំក៏ព្រមតាម តាំងពីថ្ងៃនោះមក នាងតែង

ហៅតាព្រឹមកនិយាយតែពីរឿងសុកិទ្រ ដែលនាំឲ្យនាងបានសប្បាយរីករាយចិត្ត ។

ថ្ងៃមួយរ័ត្ននារីហៅតាព្រឹចូលមកហើយនិយាយថា "តា ខ្ញុំទុកចិត្ត តាណាស់ ដោយហេតុនេះខ្ញុំនឹងប្រគល់សំបុត្រមួយច្បាប់នេះហើយនឹងកញ្ចប់នេះមួយ ក្នុងកញ្ចប់នេះមានប្រាក់ចំនួន ១១០០រ.០០ ហើយនឹងប្រាក់ ២០០រ.០០ ទៀតជាសោហ៊ុយតាជិះឡាន តាការណ៍តនាំរបស់ទាំងនេះយកទៅឲ្យកូនរបស់ខ្ញុំផង តាយកតែបុណ្យចុះណាក់ណា តែតាប្រយ័ត្នកុំឲ្យអាពុកវាដឹង ក្រែងខូចការទៅ" ។

កុំព្រួយអីអ្នក បើជីវិតខ្ញុំនៅរស់ត្រឹមណា ខ្ញុំធានានឹងយករបស់នេះឲ្យដល់កូនរបស់អ្នកឲ្យទាល់តែបាន ទុកជាចង្អៀតចង្អល់ជួបម្តេចក៏ខ្ញុំបានស៊ូប្តូរជីវិតត្រឹមណោះដែរ ព្រោះអ្នកមានគុណនឹងខ្ញុំច្រើនណាស់ ៗ មួយវិញទៀត ខ្ញុំបានក៏ស្រឡាញ់សុកិទ្រច្រើនណាស់ដែរ ព្រោះខ្ញុំបានបីពកាំងពីតូចក្រចង្ការមក ហើយបាននាំទៅសាលារៀនផង ៗ

រួចតាព្រឹក៏លារ័ត្ននារី រៀបចំប្រដាប់របស់ខ្លួនរួចដាក់ក្នុងក្រមាយួរ ចុះទៅជិះឡាន លុះដល់កំពង់ធំកាលណា តាព្រឹក៏ចុះកណ្តាលផ្លូវបង្ការកុំឲ្យសោភិតដឹង ហើយដើរចូលទៅលេងផ្ទះសម្លាញ់ "ហេ! អ្នក-កំឡោះបាត់មុខមាត់យូរណាស់ហើយមិនឃើញ អញស្មានថាទៅជាផ្សសឹងហើយគេ ម៉េចការសម្លាញ់ឯងសប្បាយជាទេ?

"អើអា! អញសប្បាយជាទេ អញនៅឯភ្នំពេញឯណោះ សព្វថ្ងៃធាក់ស៊ីក្លូបានកំរៃគួរសមដែរ ចុះអាសំឡាញ់ឯងនៅប្រមឹកស្រាឬអា? ក្បាលចាស់ហើយម្តេចក៏មិនគិតគេះគ្រួសារ ឬឯងនឹកឃើញថាខ្លួននៅជាកំលោះនៅឡើយ" ។

"ទេអា! អញឈប់ផឹកឈប់ស៊ីហើយ ឥឡូវអញចូលវត្តអាពមុ ហើយ ចុះអាមានការធ្វើអ្វីបានជាមក?

"អញលើកអាសំឡាញ់ឯងបានជាមក ម៉េចអាមិនលើកអញទេឬអ្វី?

"ម៉េចឯងនិយាយយ៉ាងហ្នឹង?

ជាហើយសំឡាញ់ក៏ស្ទុះមកឱបតាព្រំហើយអង្អែលក្បាលលេង តាព្រំក៏សាកសួរដំណើរអំពីសុគន្ធ តែមិនបានប្រាប់សំឡាញ់អំពីគំរូដែលត្រូវបំពេញ ជាប់និយាយជាមួយនឹងសំឡាញ់នោះទាល់តែយប់ជ្រៅ បានតាព្រំលាសំឡាញ់ "ណ្ហើយអា! យើងនិយាយគ្នាប៉ុណ្ណឹងចុះ យប់ជ្រៅណាស់ហើយ ក្រែងអ្នកផ្ទះគាត់គេថ្ងន់គេ អញលាសិនហើយ ចាំថ្ងៃក្រោយយើងជួបគ្នាទៀត" ។

"ម៉េចអញចឹងអាសំឡាញ់ មកដល់ផ្ទះអញហើយក៏ទៅឯណាទៀត នៅដេកនឹងគ្នាមួយយប់ហើយគ្នាលើកណាស់" ។

"ទេអា! អញមានការប្រញាប់ណាស់នៅមិនបានទេ" ។

"ចុះឯងមានផ្ទះសម្បែងឯណាក៏ទៅតាំងយប់ កុំធ្វើដូច្នេះរ៉ៃយ អីក៏ដូម្ល៉េះ អញមិនឲ្យឯងទៅទេ" ។

តាព្រំនឹកអាណិតចង់នៅដេកនៅនោះ តែនឹកដល់កិច្ចរបស់ខ្លួនក៏កាត់ចិត្តលាសំឡាញ់ តែសំឡាញ់នោះនៅតែទទូចឲ្យនៅ "ឯងមិនព្រមក៏ហាហើយទៅចុះ តែយប់នឹងទៅក្រែងមានគ្រោះថ្នាក់ ស្រុកឥឡូវមិនល្អដើរយប់ព្រៅតែឯងទេ" ។

តាព្រំអង្វរថា "ណ្ហើយអាសំឡាញ់ ឯងកុំព្រួយខឹងអញអី គ្នាមានកិច្ចធំណាស់ ហើយកិច្ចនោះមិនឲ្យអ្នកណាដឹងមួយជាតិផង ឯងកុំខឹងអី ស្អែកអញមកវិញទេ" ។

រួចតាព្រំក៏ដើរកាត់សេចក្តីងងឹតទាំងកណ្តាលយប់ទៅ ព្រោះដឹងថាពេលព្រឹកពីព្រលឹមស៊ុកទ្រីតែងក្រោកដាំបបរ ហើយទៅពេលនោះគ្មាននរណាម្នាក់ ជាឱកាសល្អគួរប្រគល់របស់វត្ថុនារីឲ្យស៊ុកទ្រី ទៅប្រហែល ១០០ ម៉ែត្រប៉ុណ្ណោះ បានដល់ផ្ទះសោភិតហើយ តាព្រំក៏ខំដើរឲ្យលឿន! ។

ស្រាប់តែឮសូរមនុស្សច្រើននាក់តែពីមុខមក តាព្រំក៏ឱបក្រមាជាប់ រួចក៏ឃើញមនុស្សបួននាក់ស្លៀកខោខ្មៅពាក់ខ្មៅ ចូលជិតហើយចោមតាព្រំ រួចម្នាក់ក៏ហែងសួរឡើងថា "នែតាកំៗ ឯងទៅណាមកណាមានលុយកាក់ទេ ?

ប្រជុំសុភាសិតខ្មែរតាមលំដាប់អក្សរ

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

រួបរួម

## អក្សរ ប (តទៅ)

៙ បាយត្រជាក់ឲ្យតែសម្លក្តៅ ស្រែឆ្ងាយៗ ចុះឲ្យតែនៅក្បែរ ។

៙ បើកាចៗ ឲ្យគេខ្លាច បើឆោតៗ ឲ្យគេអាណិត ។

៙ បើចង់ចំណេញកុំខ្លាចខាត បើចង់ស្អាតកុំខ្លាចយូរ ។

៙ បើមិនជួយចូក ជួយចែវ, កុំយកជើងរាទឹក ។

៙ បើឮស្គរផ្គរ, កុំអាលចាក់ទឹកបំពង់ចោល ។

៙ បើលួចគេកាត់ត្រាន់, ប្រយ័ត្នតែគេទាន់កាត់ត្រល ។

៙ បើស៊ីត្រីណា កុំដុះត្រីនោះ ។

៙ បើស៊ីកុំតាមឃ្លាន គិតប្រមាណអស់គ្នា ។

៙ បើទិញសេះៗ ឲ្យតាប់ បើទិញឆ្មាប់ៗ ឲ្យឃ្លួ ។

៙ បើអាក្រក់ៗ ចុះឲ្យតែល្អ បើក្រៗ ចុះឲ្យតែមាន ។

៙ បែកមិត្រ កុំឲ្យយកជាមិត្រ ។

៙ បំណាច់ទឹងទេះៗ គោឲ្យគេកោត, បំណាច់ទឹងឆោតៗ ឲ្យគេអាណិត ។

៙ បំណាច់ទឹងបាប គោងឲ្យផ្អាបមាត់ ។

៙ បំណាច់ទឹងខ្លួន ឲ្យបានការ, បំណាច់គេថាគោងឲ្យស្មើមមាត់ ។

៙ ប្រពន្ធពីរ គោបី ដំរីមួយ នាំឲ្យព្រួយចិត្ត ។

៙ ប្រពន្ធល្អច្រើនចាញ់ប្តី ពាក្យច្រើនកូតចាញ់អាត្មា ។

៙ ប្រមាត់ដាច់ឡើងទ្រើង ។

៙ ប្រហែសរាំបាត់ ប្រយ័ត្នរាំគង់ ។

៙ ប្រាក់កំបង់ ចង់កំណាច ឬ ប្រាក់កែបង់ ចង់តែដាច គូថតែកាច កូនតែកើត ។

៙ ប្រាជ្ញកុំស្មើពុក, ប្រើលំអុតកុំស្មើក្តីកាប់, មានគុណកុំស្មើមានភ័ព្វ ។

៙ ប្រាជ្ញមិនស្មើប្រែប បំរើស្លឹកត្រចៀកខ្វិច មិនស្មើអាឡេមឡឺម ។

៙ ប្រាជ្ញចុះរណ្តៅ ខ្លៅឡើងសួគ៌ ។

៙ ប្រាជ្ញអាងប្រាជ្ញា, រមាសអាងបន្ទា, ខ្លាអាងព្រៃ, ដំរីអាងរនាម, ត្រីអាងទឹក, ទាហានអាងសឹក, ប្រមឹកអាងតែង ។

៙ ប្រាសពីផងរែក, ទៅផ្អែកលើពួក ស៊ីសម្លសាច់ជ្រូក បាយស្ងួនអង្ករដើម ។

៙ បើត្រាប់សត្វក្ងោក, កុំបីត្រាប់ពុតទន្សាយ ។

៙ បើត្រាប់កុកសាច់, កុំបីត្រាប់កុកស ។

៙ បើត្រាប់ឫស្សី, កុំបីត្រាប់ស្វាយកន្ទ្រាញ ។

៙ បើត្រាប់អ្នកប្រាជ្ញប្រាយ, កុំបីត្រាប់ខ្លៅសាមាន្យ ។

៙ បើទៅជាត្បូងចិញ្ចៀន, ក្រវេលក្រវៀនជាយៀនកាំបិត ។

## អក្សរ ផ

៙ ផឹកស្រាក្មាសំដី ។

៙ ផ្ទុករទេះតាមចំណុះ ។

៙ ផ្លូវវៀចកុំបោះបង់, ផ្លូវណាត្រង់កុំដើរហោង, ដើរដោយស្នាមគន្លង, ជម្រាយអ្នកចាស់បុរាណ ។

៙ ផ្លែត្រឡាចគង់មានបណ្ដូល, មនុស្សពាលមូលគង់មានចិត្ត ។

៙ ផ្លែឈើចាញ់សត្វក ត្រីច្រើនទឹកល្អក់ពុំជា ទ្រព្យច្រើនព្រួយក្រោ ទ្រព្យតិចណាព្រួយរំគិត ។

## អក្សរ ព

៙ ពងមាន់កុំជល់នឹងថ្ម, ប្ដូពងមាន់សោត, កុំប្រះឡាតជល់នឹងថ្ម ។

៙ ពងមាន់ក្នុងសំបុកលោតទៅទាំងអ្នក, កន្ត្រកអាចម៍គោលោតទៅទាំងស់វែត, ត្រកួនសវ្រែកត្រីវែងទាំងថ្ម ។

◎ ពាក្យខុសកុំឲ្យស្ដាប់, សេចក្ដីគាប់ឲ្យរិះគ្យាន ។

◎ ពាក្យក្រកុំអាលប្រាប់, ពាក្យឥតសព្វកុំអាលថ្លែង ។

◎ ពាក្យគ្រើតែងរឹង, ពាក្យពិតតែងស្លូន ។

◎ ពាក្យពិតកុំឲ្យថែង, ពាក្យពិតស្លូនពុំគួរលាក់ ។

◎ ពាក្យព្រេងលោកស្រដី, ជាកុំបីចិញ្ចឹមខ្វា ។

◎ ពាក្យស្លូនកុំស្អប់, ពាក្យគាប់ឲ្យយក ។

◎ ពាក្យម្ដាយ, ទំនាយគ្រូ ។

◎ ពិសាក្រណាទឹងឃ្លាន, ភាក្រក់ប៉ុន្មានក្រណាទឹងស្រឡាញ់ ។

◎ ពុកគ្រូកុំត្រាប់, ច្បាប់គ្រូឲ្យយក ។

◎ ពូជគោជ្រលែង, ពូជស្រីបក្ដីភេរង. ពូជស៊ីស្រគ្រូបី, ពូជខ្ញុំ-បង់ម្ចាស់ ។

◎ ពួនតែមុខទុកគូថនៅកណ្ដាលវាល ។

◎ ពេទ្យគោល្ងូន, មេមត់ស្លាប់កូន, សុភាចាញ់ក្ដី, ថ្មពេទ្យគោ-ល្ងូន, មេមត់ស្លាប់កូន សុភាចាញ់ក្ដី, ក្រពើលង់ទឹក, ម្រឹគជាប់ព្រៃ ។

◎ ពោះជាទេវទត្ត, មាត់ជាទេវតា ។

◎ ព្រះមិនសម, ព្រហ្មមិនជួយ ។

◎ ពោះគោ, ពោះក្របី ។

## អក្សរ ភ

៙ ភ្នួតនៅហោរ, ពោរនៅជាងខាង ។

៙ ភ្លើងឆេះមកតែពីសម្រាម ។

៙ ភ្លេភ្លើ ដូចក្រពើរង្គួនចិន ។

## អក្សរ ម

៙ មនុស្សកុំមើលងាយមនុស្ស ។

៙ មនុស្សខឹងកុំឲ្យលាងចាន, មនុស្សឃ្លានកុំឲ្យដាំបាយ ។

៙ មនុស្សខ្ជិលទុកធ្វើរបង, មនុស្សកាចទុកជាខ្នង, មនុស្សកោងទុកជាសម្រាស់, មនុស្សស្លូតទុកជាទនាំង ។

៙ មនុស្សឆ្លាតគេថាឆោត, មនុស្សល្អគេថាល្ងង់, ចេះគេថាកាច, ប្រាជ្ញគេថាព្រាល ។

៙ មនុស្សចាប់រើសធ្វើខ្លួន, ក្រឡាយស់តែពីស្អុតឥទ, ខ្លាចតែដើរធ្វើបាន, គ្មានប្រាជ្ញាតែពីស្អុតចេះ ។

៙ មនុស្សទើសប្រាក់, យក្សទើសសាច់ ។

៙ មាត់មានគ្រប, ដបមានឆ្នុក ។

៙ មាត់តែប្រកែក, កម្រែមកតែទទួល ។

៙ មាត់ពិរោះ ពោះកាត់ក ។

(មានត)

# ច្បាប់ក្រមបរិយាយ

## លោកញឹក-នូ គ្រូបង្រៀនជំនួយ

### នៅវិទ្យាល័យស៊ីសុវត្ថិ

(តមក)

ត្រង់លោកខ្ទានថា "ចិត្តនោះឲ្យហ៊ាន បំពេញព្រះផ្នួស" ហេតុដូចម្តេចក៏ចាំបាច់ថា "ហ៊ាន" ទើបបានបួសបាន? ថាធម្មតាគឺមនុស្សយុវជននេះ តែងប្រកបដោយកិលេស គឺសេចក្តីសៅហ្មងនៅក្នុងចិត្ត ជាមនុស្សពាលអាក្រក់ នឹងគិតពុំយល់ផ្លូវសុខនិងទុក្ខ ។ កាលខ្លួននៅក្នុងវង្វេងទៅ ដោយសេចក្តីសប្បាយច្រើនប្រការ ប្រាថ្នានូវកាមគុណជាអារម្មណ៍ ម្ល៉ោះហើយនឹងដកខ្លួន ឲ្យរួចរបូតអំពីអន្លង់នេះបានដោយក្រ ព្រោះសេចក្តីជាប់ក្នុងកាមនេះមកគ្របសង្កត់ មានទម្ងន់ធ្ងន់ពន់ប្រមាណណាស់ ។ ខ្លះជាប់ជំពាក់នឹងសម្បត្តិទ្រព្យ បុត្រភរិយា ខ្លះជំពាក់ក្នុងសប្បាយនឹងបុណ្យស័ក្តិ, ខ្លះខ្លាចថានឹងទ្រទ្រង់ធម៌វិន័យពុំបាន ព្រោះឃើញថា បើចូលទៅបួស ត្រូវឲ្យគ្នាហានលះបង់នូវអំពើកាមគុណ ឲ្យជ្រះស្រឡះអស់អំពីចិត្ត, នេះឃើញថាក្រៃណាស់ នឹងលះមិនបានទេ ក៏ត្រាញចិត្តមិនហ៊ានបួស អត់ធន់ដេកត្រាកងលាមកទៅវិញទៅក៏មាន ។

១ ទៀត បើអ្នកណាបានបួសជាបព្វជិតហើយ ត្រូវកាន់ក្រិត្យតាមវិន័យ ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងទុកមកថា ភិក្ខុសាមណេរ

គប្បីធ្វើខ្លួនឲ្យបរិសុទ្ធល្អ កុំឲ្យខុសធម៌ ខុសវិន័យ, ឲ្យលះបង់អំពើទុច្ចរិតលាមកឲ្យអស់ចេញ កុំឲ្យមានសេសសល់ជាមន្ទិលដល់តិចឡើយ គឺលះ លោភៈ ទោសៈ មោហៈ នេះឯងជាដើម ។

ដ្បិតជនទុជ្ជន នៅក្នុងលោកិយនេះ គឺមានច្រើនមកហើយដែលជាមនុស្សអន្ធពាល ពុំសូវមានគំនិតគិតគែប្រមាណហេតុឲ្យល្អឡើងវិញបាន, ដូចអ្នកលេងល្បែង ជក់អាភៀនផឹកស្រានិងល្បែងភ្នាល់ជាដើម នោះក៏ម្រមានអ្នកលះបង់បានដោយងាយឡើយ, ខំលេងទាល់តែចាស់ ជក ទាល់តែក្រអស់ធនធានក៏មិនឈប់ ។

ឯពួកអ្នកមានទ្រព្យ និងបុណ្យស័ក្តិ បើមានសទ្ធាសេចក្ដីជ្រះថ្លា បានត្រឹមបរិច្ចាគទ្រព្យរបស់ធ្វើទានប៉ុណ្ណោះ តែមិនលះយកកេសទៅបួសពុំបានឡើយ ។

ដូច្នេះ ការលះកាមគុណនិងសម្បត្តិទ្រព្យនិងបុណ្យស័ក្តិ ហើយចូលទៅបួស ប្រតិបត្តិធម៌វិន័យ ជាការក្រៃបំផុត, ដែលគេបាន ក៏បានដោយពិបាក ។

ប៉ុណ្ណោះលុះយល់បានថា អ្នកបួសសុទ្ធសឹងតែជាបុគ្គលលះយកកេសបានដោយក្លាហាន ហើយញ៉ាំងចិត្តឲ្យមូលចូលទៅកាន់ការស្ងប់រំងាប់ជាដើម ។

៩៤- ម្ដាយឪពុកណាសោកណា ស្រឡាញ់ស្ងួនភ្ងា
ហៅក្នុងសង្សារ អាចមកបំបួស ហេតុចង់សម្ភារ
ប្រើបង់អន្ធពាល រៀនដោយក្រមច្បាប់ ។

ធម្មជាតិជាឪពុកម្ដាយ រមែងមានធម៌សប្បុរសស្រឡាញ់ គ្រប់គ្រងថែរក្សាបុត្រ ប្រកបដោយព្រហ្មវិហារធម៌ ៤ ប្រការគឺ មេត្តា, ករុណា, មុទិតា, ឧបេក្ខា ។ លោកទាំងពីរនេះ មានចិត្តសោមនស្សត្រេកអរ តាំងតែពីថ្ងៃដែលដឹងថា កូនមកចាប់បដិសន្ធិក្នុងគភ៌ម្ដាយ ម្ដាយបានលំបាកយ៉ាងណា ក៏ខំធន់ទ្រាំថែទាំខ្លួនឲ្យល្អ ដោយប្រាថ្នាឲ្យកូននោះមានជីវិតគង់នៅ ។ លុះកូនសម្រាលមកកាលណា មាតាបិតាក៏ប្រឹងបីបាច់រក្សាទារកនោះ ដោយព្រហ្មវិហារធម៌ មានចិត្តអំណរនឹងកូន បានសុខចំរើន នឹងផ្សាយសេចក្ដីស្នេះស្មើទៅរកកូន ដោយអំណាចចិត្តស្រឡាញ់ អាណិតកូនយ៉ាងនេះ កាលកូនចំរើនធំពេញរូបរាង ហើយក៏យកទៅបំបួសក្នុងព្រះពុទ្ធសាសនា ព្រោះ "ហេតុចង់សម្ភារ" បានសេចក្ដីថា មាតាបិតា ខ្លាចក្រែងកូនពុំស្គាល់បុណ្យខុសបាប ពុំស្គាល់អំពើសុចរិតនិងទុច្ចរិត, ទើបឲ្យបួស ដើម្បីនឹងជុកឲ្យនូវកងកុសល នឹងសុចរិតធម៌ កុំឲ្យធ្លាក់ទៅកាន់អបាយភូមិទាំង ៤ ហើយប្រើឲ្យរៀននូវក្រមច្បាប់ ប្រយោជន៍ឲ្យលះបង់អំពើអន្ធពាល ។

(កាព្យទៀត លោកទូន្មានថា)

សង្វាតសរសេរ អស់អ្នកកុំខ្ជិល ហើយចាំងផាតាប់
សង្វាតស្វែងរៀន ដោយត្រូវប្រញាប់ កុំធ្វើលេលាប់
ដោយចិត្តមាត់ងាយ ។

គឺឱ្យកូនខ្វល់ខ្វាយខ្នះខ្នែង រៀនធម៌ចំរើនមេត្តាករុណា ជាផ្លូវទៅកាន់សេចក្ដីសុខ ដ្បិតឃើញថាបណ្ដាអ្នកជាពហុស្សូត ជាអ្នកចេះដឹងច្រើន តែងស្គាល់ខុសនិងត្រូវ ចៀសវាងបាបកម្ម ឲ្យរួចផុតអំពីអំពើពាលា, ចេះច្បាប់ព្រះពុទ្ធ ហើយប្រព្រឹត្តបដិបត្តិតាម ឥតលំអៀង, ក្នុងនោះនឹងបានជាមនុស្សវិសេសក្នុងលោកនេះ និងលោកឯមុខ ដោយផលដែលចេះដឹង គាបសង្កត់ការពារក្រោក អស់ចេញអំពីសន្ដានចិត្ត ។

មិនតែប៉ុណ្ណោះទេ ទូន្មានឲ្យហាត់សង្វាតរៀនតាមត្រូវប្រញាប់ ឲ្យខំហាត់សរសេរអក្សរតាមវិធីអក្ខរៈ ឲ្យត្រឹមត្រូវតាមក្បួនខ្នាត, ហាមមិនឲ្យខ្ជិលច្រអូស មិនឲ្យធ្វើឡេះឡោះប្រមាថមាក់ងាយហ្នឹងតាំងនោះឡើយ, សង្ឃឹមថាបើកូនមានសុភាព ទទួលធ្វើតាមពាក្យប្រដៅទាំងនោះបាន ហើយ កូននឹងបានជាគាប់ ពេញចិត្តជាបណ្ឌិតជាតិ ១ ដែលគេតែងកោតរាប់អានគ្នា ។

ម្ល៉ោះឃើញថាអាពុកម្ដាយ ស្រឡាញ់អាណិតកូនខំយកយោគកូនឲ្យរួចអំពីទុក្ខសោកណាមក ហើយនឹងបានសុខទាំងជាតិនេះនិងជាតិមុខ ។

៩៤- ហៃអស់សាមណេរ ម្ដាយមកបន្ទោរ អ្នកជាចាបក្សាយ សង្កាត់ស្ងួតរៀន ដូចលោកទាំងឡាយ កុំធ្វើពាលេះពាយ ដូចនៅគ្រហស្ថ ។

បទនេះបានសេចក្ដីថា កាលពីព្រះពុទ្ធអង្គគង់ព្រះជន្មនៅ ហេតុកើតបដកបមក ពួកពុទ្ធបរិស័ទដែលមានបញ្ញាទិស្ស័យទាំងព្រះរតន-ត្រ័យ តែងតែនាំកូនចៅទៅបួស ពីក្មេងកុមាររហូតអាយុពី ៧ ឆ្នាំទៅ ទល់នឹងអាយុ ១៩ ឆ្នាំ ឲ្យបួសជាសាមណេរ, បើអាយុគ្រប់ ២០ ឆ្នាំបរិបូណ៌ហើយ ប្ដូរប្រែងកើនឡើងទៅ ឲ្យបួសជាភិក្ខុ ។

កាលកូនបួសជាសាមណេរហើយ ត្រូវពួកកូនទោះថា "ហៃអស់សាមណេរ ម្ដាយមកបន្ទោរ អ្នកជាចាបក្សាយ" បានសេចក្ដីថា សាមណេរអើយ! អ្នកបួសជាសាមណេរហើយ ម្ដាយយកអ្នកមកបន្ទោរ ប្រគេនលោកគ្រូអាចារ្យបង្ហាយ សូមឲ្យលោកមេត្តាឧបត្ថម្ភអ្នក, លោកទទួលភារៈបង្ហាត់បង្ហាញ ឲ្យចំណេះវិជ្ជាផ្សេងៗ ដូច្នេះ ចូរសាមណេរ "សង្កាត់ស្ងួតរៀន ដូចលោកទាំងឡាយ កុំធ្វើពាលេះពាយ ដូចនៅគ្រហស្ថ" បទខាងចុងនេះ គឺគ្រូដាស់តឿនថែមទៀតថា ឲ្យកូនសិស្សខំព្យាយាមប្រឹងប្រែងរៀនសូត្រ ដូចលោកបរិស័ទទាំងឡាយ ដែលជាអ្នកបួសនៅអាកាសជង់គ្នា ឲ្យយកជំពប់តាម

កុំធ្វេសប្រហែសខ្វះប្រាណ ក្នុងកិច្ចគ្រប់ជំពូក កុំប្រព្រឹត្តក្រៅចាកសិក្ខា កុំគប្បីធ្វើខ្លួនដូចទៅជាគ្រហស្ថនោះ ។

ប៉ុណ្ណេះក៏ពុំស្រេច គ្រូនៅមានសេចក្ដីករុណា ដែលកូនសិស្សពុំលុះតាមដំបូន្មាន ក៏ប្រដៅថែមទៀតថា ។

កុំធ្វើកាយមាយ ដឹងគ្រូធាឆ្ងាយ ខុសតាស្មើអម្ចាស់
សង្វាតសរសេរ សូត្ររៀនឲ្យណាស់ ប្រាជ្ញាយល់ច្បាស់
នាំញាតិទាំងឆ្ងាយ ។

បានសេចក្ដីថា គ្រូហាមប្រាមប្រាប់កូនសិស្ស កុំឲ្យព្រហើនធ្វើឫកពា គម្ហើនជាក្មេងមាក់ទឹងគ្រូធាឆ្ងាយ ត្រូវគោរពប្រណិប័តន៍លោក ខុសស្មើនាយហៅព្រាយ ហើយឲ្យសង្វាតខំឃ្មាតរៀនសូត្រ អំពីសំណាក់លោកឲ្យបានច្រើន ដើម្បីឲ្យកើនចំណេះ ចេះដឹងឲ្យច្បាស់លាស់បែកបញ្ញា យល់ការខុសត្រូវ ប្រសប់ឆ្លាតវៃ ក្នុងកិច្ចទាំងពួងជាប្រយោជន៍ដល់ " នាំញាតិទាំងឆ្ងាយ " ។

៤ សំដីតាន់ចុងខេះ មានដំណើរសេចក្ដីទៅថា បើកូនសិស្សណារៀនពេះ បានចំណេះគ្រប់គ្រាន់ ទាំងគតិលោកនិងគតិធម៌ ហើយញាតិទាំងឆ្ងាយនឹងបានជាទីពឹងទីអាស្រ័យ ដោយប្រយោជន៍យ៉ាងសំខាន់ពីរប្រការ ១- នឹងមានអ្នកចេះដឹងនេះហើយជាអ្នកនាំមុខ យកយោនិ

ពន្យល់ មិនឲ្យគណញាតិប្រព្រឹត្តល្មើស ព្រោះជាបញ្ញត្តិឲ្យបានសុខក្នុងនាបច្ចុប្បន្ន ដែលមានជីវិតរស់នៅ ។

២- គឺខ្លួនាន ញាតិឲ្យស្គាល់បាបបុណ្យគុណទោសខុសត្រូវ តាមពុទ្ធានុសាសនី លុះរំលាយខន្ធទៅ នឹងបានទៅកាន់សុគតិ ។

ហេតុនេះយុវជនទាំងឡាយ គប្បីខំប្រឹងប្រតិបត្តិកុំឲ្យឃ្លាតឡើយ អំពីពាក្យខ្លួនាន ។

៩៦- អាស្សូរមេធា ចិញ្ចឹមរក្សា ពុំឲ្យអន្តរាយ អាចយកមកធ្វើ នឹងត្រូវបាត្យាយ ហេតុបង់ពណ្ណរាយ ប្រយោជន៍ទាំងពីរ ។

ពាក្យដែលថា "អាស្សូរមេធា ចិញ្ចឹមរក្សា ពុំឲ្យអន្តរាយ" ដូច្នេះជាដើមបទនេះ គឺលោកថាឲ្យកូនសិស្សយកចិត្តអាណិតអាសូរករុណាអាពុកម្តាយ ដែលជាបុព្វការី បីបាច់ថែទាំចិញ្ចឹមរក្សា តាំងពីកើតមកដល់ធំប៉ុណ្ណេះ ឲ្យបុត្រមានសេចក្តីកតញ្ញូ ដឹងគុណនូវអង្គ ផ្ចង់ចិត្តប្រព្រឹត្តតាមទូន្មានដែលលោកប្រដៅមកទាំងប៉ុន្មាន កុំឲ្យអន្តរាយភ្លេចភ្លាត់បាត់អសារឥតការទៅឡើយ ។

តមកទៀតលោកប្រាប់ថា "អាចយកមកធ្វើ នឹងត្រូវបាត្យាយ ហេតុបង់ពណ្ណរាយ ប្រយោជន៍ទាំងពីរ" ពាក្យនេះពន្យល់បង្ហាញកូនសិស្សឲ្យឃើញនូវបំណង ដែលម្តាយប្រាថ្នាហើយ ហ៊ានយកកូនមក

ទុកឲ្យនៅនឹងលោកគ្រូអាចារ្យ ក៏ព្រោះចង់ឲ្យកូនបានចម្រើនរុងរឿង មានកិត្តិសព្ទកិត្តិយស ល្បីខ្ចរខ្ចាយសាយសុះទៅ ដោយកូនមានចំណេះវិជ្ជាយ៉ាងក្រាស់ក្រែល ទើបបានបម្រើនូវប្រយោជន៍ទាំង ៣ ប្រការក្នុងលោកិយនេះ គឺឲ្យចេះច្បាប់នេះ ១, ឲ្យមានប្រាជ្ញាឆ្លាតវៃនេះ ២, ឲ្យមានបារមីនេះ ៣ ។ (ប្រយោជន៍ទាំង ៣ នេះ ទើបនិយាយទៅខាងក្រោយ) យកសេចក្ដីតាំងពីដើមមកត្រឹមណោះ រួបរួមគ្នាឡើងឃើញថាមាតាបិតាជាមគ្គនាយករបស់បុត្រធីតា ព្រោះលោកប្រកបដោយសប្បុរសធម៌ គ្រប់គ្រងកូនគ្រប់ជំពូកឥតឲ្យខូច ចង់ឲ្យតែកូនបានជាធំ ចង់ឲ្យតែកូនបានសុខ ទើបត្រេកអរ បើដឹងថាកូនណា បានសេចក្ដីទុក្ខវេទនា ម្ដាយឪពុករមែងមានទុក្ខទោមនស្សតាម ជួនមានទាំងជលនេត្រហូរហោមលោកយំដោយសារតែកូន ។

យ៉ាងនេះ ប្អូនទាំងឡាយ កុំគប្បីទទឹងទទែងពាក្យរបស់មាតាបិតាពោលប្រដៅនោះឡើយ ទោះបីជួបបែកយ៉ាងណា ក៏សុខចិត្តជាកាតាភេហារដើម្បីបម្រើទាំងអស់ ។

ទី ៧ – មួយចង់ក្ដីច្បាស់ ឲ្យបានខ្លួនគាប់ ទៅ
ជាលោកិយ មួយចង់ប្រាជ្ញា មិនឲ្យអប្រិយ៍ មួយ
ចង់ទាំងទី នាំញាតិទាំងឡាយ ។

(មានត)

សុវណ្ណសាមជាតក ពាក្យកាព្យ

ព្រះសមុហ៍ឃោសាចារ្យ យូរ-ប៊ុណ្ណ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

(តមក)

ហើយទើបស្រែកស្នូរថា ឱលោកណាអើយមកផ្តាច់ ជីវិតខ្ញុំឲ្យដាច់ ខាន
ចិញ្ចាច់អ្នកមានគុណ ៗ អ្នកជាក្សត្រឬព្រាហ្មណ៍ មានគោត្រនាមឬ
អ្នកបុណ្យ មកនៅទីនេះមុន សូមព្រះគុណប្រាប់ឲ្យច្បាស់ ៗ ខ្លួនខ្ញុំ
ជាតិជាមនុស្ស មិនដែលប្រទូស្តដល់គេឯណាស់ ទាំងសត្វព្រៃច្រើនណាស់
ឥតមានទាស់ដល់ថ្នាំងថ្នាក់ ៗ ឥឡូវលោកមកបាញ់ គួនសំឡាញ់
ជនពីរនាក់ សុទ្ធតែជាអ្នកខ្វាក់ ធ្វើឲ្យអាក់ក្តីព្យាយាម ៗ ឬមួយលោក
ត្រូវការ នូវអាហារត្រង់សាច់ឈាម ម្តេចឡើយមកបាញ់សាម មិន
ត្រូវតាមគន្លងធម៌ ៗ លោកអើយលោកឈ្មោះអ្វី ចូរស្រដីដោយស្មោះ
សរ ប្រាប់មកតាមនាមករណ៍ ខ្ញុំត្រេកអរសោទរក្រៃ ៗ ឯស្តេចបិលិ-
យក្ស មានយសស័ក្តិវិសេសថ្លៃ ទើបចេញចាកពីព្រៃ ត្រាស់តបវៃ
យ៉ាងនេះថា ៗ ខ្លួនយើងនេះជាស្តេច គេសម្រេចតាមវាចា ជាគួអគ្គ
ក្សត្រា បិតុនៅនាដែនកាសី ៗ ចេញចាកពោលនគរ ព្រោះរីករវៃ
ចំណី ស្វែងរកសត្វបក្សី ចោលបុរីមិនទឹកទា ៗ ចេះសិល្បធ្នូប្រាកដ
តាមបែបបទផ្លូវវិជ្ជា ដើរបាញ់សត្វនានា ដូចប្រាថ្នាចិត្តប៉ុនប៉ង ៗ

ទោះសត្វនោះតូចក្តី ឬដំរីដ៏ខម្យង ، សត្វណាឯទៀតផង តាមបំណង
យើងព្រាថា ។ ឥឡូវយើងសួរអ្នក ស្រស់ស្រលក្ខណ៍ ឈ្មោះអ្វីថា តាំង
មាតាបិតា នៅទីណាជិតឬឆ្ងាយ ។ កាលនោះពោធិសត្វ បុរសត្រូ
បង្គំថ្វាយ ទូលស្តេចតាមបរិយាយ តាំងនាងកាយដេកផ្ទាល់ដី ។
ទូលបង្គំជាខ្ញុំ បុត្រឧត្តមនៃឥសី គេហៅតាំងប្រុសស្រី ដោយមេត្រី
ជាសាមា ។ បិតាទូលបង្គំ នៅជួបជុំនឹងមាតា អាស្រ័យកុដិសាលា
មាននេត្រាសូន្យតែម្នាក់ ។ ឥឡូវពេលណាក៏បាន តាំងពីព្រាណព្រួយផត
អាក់ មានតែកូនមួយនាក់ ត្រាន់ទីផ្ទាក់ជួមបំរើ ។ ថ្ងៃនេះព្រះអង្គ
បាញ់ កូនសំឡាញ់ស្លាប់ហើយតើ បានអ្នកណាបំរើ ព្រាតជរោស្ពើដួច
ជាខ្ញុំ ។ សូមទ្រង់ទតមើលចុះ ខ្លួនផ្កាយជុះឈាមជុំៗ ត្រង់សារម្ទល
ត្រសុំម ពិសពាប់ព័ទ្ធវិញខ្លួនហើយ ។ ព្រះមហាសត្វថ្ងៃថ្ងា ឈឺខ្លាច
ផ្សាទុក្ខឥតស្បើយ ថាខ្លួនអញសើយ ថ្ងៃនេះហើយស្លាប់មិនខាន ។

## ពិរេះបស្សិណ្ណភាម

ពាក្យ ៧

ព្រះពាក់បិតាលើយ ពាំនេះហោះហើយអស់ទំរង់ ត្រូវណាននះ
ណាជាតិទី ពំនាក់ក្រាន់ក៏ទំលៅថ្ងៃមុខ ៖ ពីះដឹមភ្នំកូននៅបម្រើ

រកផ្លែមើមឈើសន្សំទុក ជាគ្រឿងអាហារមានគ្រប់មុខ ឆាន់តែអផ្សុក សោះព្រួយព្រាណ ។ ទឹកស្រង់ទឹកនាំមិនខ្វះខាត ទីសឹងសំអាតមិនសល់ខាន ពេលថ្ងៃកូនរៀបចំសម្រាន្ត ពេលយប់កូនបានគក់ច្របាច់ ។ ថ្ងៃនេះកូនដល់មរណាហើយ ទុម្ហាស់ថ្ងៃអើយកម្មមកផ្តាច់ ឲ្យខានធ្វើកិច្ចការបំបាច់ ឥឡូវកូនត្រាច់ចោលកន្ទេង ។ ម្ល៉េះសមតាត់ចាំមើលផ្លូវកូន មកបាក់ឈើងសួនរើងចម្បើង ស្រែកហៅរកកូនញ្ញក្តងៗ ប្រឹងស្ទួបដើរ ស្វែងរកគ្រប់ច្រក ។ តាំងពីរសៀលដល់ព្រលប់ ឥតមានឈរឈប់ ទំរុករក តាមផ្លូវដែលធ្លាប់ដើរទៅមក ទីងទីធ្លាប់ដែករកគ្មានសល់ ។ ឱម្ល៉េះសមតាត់ព្រួយលំបាក ប្រឹងរកមិនស្រាកទុក្ខកង្វល់ អធ្រាត្រយប់ ស្ងាត់យំសោកដល់ កូនប្រុសទំនួលមិនឃើញមក ។ ឱម្ល៉េះសមតាត់ ស្លាប់អសារ ព្រោះអត់អាហារគ្មានអ្នករក សង្សឹមពួកញាតិគ្មានមក ផែក ទីងហៅរកប់រកជួយការពារ ។ ខ្ញុំអញនេះស្លាប់មិនសូវស្តាយ ព្រួយឪពុកម្តាយអន្ធការ ពីថ្ងៃនេះទៅអត់អាហារ ផ្តាច់ចោលសង្ខារ ជាមិនខាន ។ ឱលោកណាទៅទីនេះអើយ ឥតពីខ្ញុំហើយសូមស្មោះស្មាន មេត្តាសង្គ្រោះជនពីរប្រាណ ឲ្យលោកស្រាកស្រាន្តស្បើយទុក្ខា ។ អស់ពួកទេវតារក្សាព្រៃ បើកនេត្ររំពៃដោយមេត្តា សូមលោកជួយថែទាំរក្សា មាតាបិតាខ្ញុំឲ្យបាន ។

## បទព្រហ្មគីតិ

កាលនោះស្តេចបិលយក្ស ចិត្តស្មោះស្ម័គ្រដោយមេត្រី លុះឮពាក្យសំដី ត្រាស់ទៅទ្វីចាសាមអើយ ៗ ចូរអ្នកកុំបារម្ភ កិច្ចនេះខ្ញុំធានាហើយ បំរើមិនគោះគើយ ឲ្យបានស្បើយដូចប្រាថ្នា ៗ អ្នកប្រាប់ទីលំនៅ បិតាពៅនៅត្រង់ណា នឹងព្រះវរមាតា ខ្ញុំយាត្រាត្រង់ទីនោះ ៗ ព្រះម៉ហាសត្វថ្លៃថ្លា បើកនេត្រាមើលចំពោះ ឮថាស្តេចសង្គ្រោះ ទូលទៅផ្ដោះប្រាប់កន្លែង ៗ បពិត្រព្រះកជា ស្តេចលីលាផ្លូវនេះឯង មិនមានត្រៃវៀងកែង ផ្លូវត្រង់វែងចុះដើងម្នាក់ ៗ បើស្តេចយាងទៅដល់ ទ្រង់ពន្យល់ឲ្យដឹងជាក់ កុំឲ្យលោកអន់អាក់ ខ្លាចភ័យក្បាក់ដល់កក់ស្លុត ៗ កិច្ចការទាំងប៉ុន្មាន ទ្រង់ស្មោះស្មានធ្វើចំផុត រំពឹងលើមមកុដ ឲ្យបរិសុទ្ធផុតសង្ស័យ ៗ ហើយសូមទ្រង់មេត្តាដឹកបថាកូនក្សីណក្សយ កុំឲ្យតូចព្រះទ័យ ទឹកអាល័យបុត្រកំសត់ ៗ កូនសូមបង្គំលា ទំងមរណាជាប្រាកដ ថ្ងៃនេះដល់កំណត់ សូមលោកអត់ទោសឲ្យទាន ៗ

## ពិហេបស្តេចបិលយក្ស

### ពាក្យ ៧

គ្រានោះព្រះបាទបិលយក្ស កើតព្រះត្រៃលក្ខណ៍ក្នុងសន្តាន យល់ច្បាស់ថាឥសត្វពល់ប្រាណ មុខតែនឹងបានចាស់ឈឺស្លាប់ ៗ

ទើបស្តេចខ្ញុំទ្រង់ព្រះកន្សែង ទឹកដល់ខ្លួនឯងធ្វើមិនគាប់ កាលដើមរៀនមកមិនដែលធ្លាប់ ដឹងថាសត្វស្លាប់ជាធម្មតា ។ ឥឡូវមកឃើញសាមបណ្ឌិត នេះត្រូវឲ្យគិតដល់អាត្មា នឹងរស់នៅហើយបានត្រឹមណា ស្លាប់ពោលកាយានោះទៅវិញ ។ ដូចជាសុវណ្ណសាមកុមារ ទើបនឹងថ្ងៃនេះការណ៍អម្បាញ់មិញ ឥឡូវគាត់ស្លាប់បាត់ទៅវិញ រកទ្រព្យលោះវិញក៏ពុំបាន ។ អាត្មាអញធ្វើកម្មអាក្រក់ នឹងទៅនរកធ្ងន់ពុំខាន សោយទុក្ខវេទនាឥតស្រាកស្រាន្ត ព្រោះចិត្តក្លាហានដោយមោហា ។ បើខ្លួនអញនៅក្នុងនគរ ពួកមនុស្សឈ្មួញគេពោលថា មិនសមបើអង្គព្រះក្សត្រា ធ្វើកម្មពេកយ៉ាងនេះសោះ ។ ចុះបើមកនៅក្នុងព្រឹក្សព្រៃ គ្មានអ្នកដទៃពោលចំពោះ ឲ្យអញបានឮពាក្យពិរោះ ឬពាក្យទ្រគោះនោះសោះឡើយ ។

## និយាយពីនាងទេពធីតា បទព្រហ្មគីតិ

គ្រានោះទេពធីតា(១) ឋិតនៅនាគន្ធមាទន៍ ដឹងថាស្តេចពិយាជទូវជនជាតិមនុស្សព្រៃថ្វា ។ ទើបត្រាច់ពីទីនោះ មុខចំពោះមកក្សត្រា ពោលទូវបទគាថា ដោយរាប់យ៉ាងនេះឯង ។ បពិត្រព្រះរាជា បានឮថាទ្រង់ឥតក្រែង ធ្វើបាបមិនស្រប់ស្រែង សព្វគ្រែងឥតលស់លា ។

១ នាងទេពធីតានេះ ធ្លាប់ជាមាតាពោធិសត្វក្នុងបុព្វជាតិទី ៧, លុះដល់ច្យុតមកកើតក្នុងទីនេះ តែងរក្សាពោធិសត្វសព្វ ៗ ថ្ងៃតរៀងមក ។

ដូចយើងផងបីនាក់ គ្មានថ្នាំងថ្នាក់ក្នុងចិត្ត ជាផងគ្នាតែគោសា ម្ដេច ក្សត្រាមកសម្លាប់ ៗ បើដូច្នោះសូមព្រះអង្គ យាងត្រាច់ត្រង់ទៅប្រញាប់ ធ្វើបុណ្យឲ្យតាប់ៗ ខ្ញុំនឹងប្រាប់ទូវស្នួត ៗ បំភ្លាយពួកជនខ្លាក់ ទាំងពីរនាក់ឲ្យដូចជា សុវណ្ណសាមបុត្រក្លា ទើបក្សត្រាចាកអបាយ ៗ ព្រះរាជាអង្គនោះ ក៏ត្រូវត្រៀមត្រោះទ្រង់សោកស្ដាយ ពោធិសត្វទើតចាយ មានរូបកាយស្រស់ប្រិមប្រិយ ៗ ករុណាត្រកួមយាងទៅ ឆ្ពោះសំដៅត្រង់គុជ ស្ដួរដើងថ្នូនឥតបី ទំយ្លាតខ្វីដល់សាលា ៗ ទើបទុកូលបណ្ឌិត ទំពិតិត្យស្ងួរទៅថា សន្ធឹកដើងនេណា មកប្រាថ្នាដើម្បីអ្វី ៗ ដើរនេះតាមទំនើង មិនមែនដើងក្នុងពិសី ជាតិជាមនុស្សមកថ្មី ចូរស្រដីប្រាប់ខ្ញុំផង ៗ ស្ដេចតបទៅវិញថា ខ្ញុំនេះណាជាចម្បង លើសអស់ពួកអ្នកផង នៅត្រប់ត្រងដែនកាសី ៗ លះបោលរាជសម្បត្តិ ស្វែងរកសត្តុគងអដវី បរិភោគផាចំណី ពោលសីរមិនទឹកនា ៗ ឯទុកូលបណ្ឌិត អសីសិទ្ធចិត្តមេត្តា ឮហើយកើតជ្រះថ្លា ចង់ប្រាថ្នាធ្វើកុសល ៗ ទើបទូលបន្ទំថា ព្រះករុណាសូមសោយផល ដែលខ្ញុំបានដំកល់បម្រុងដល់ពេលខាងមុខ ៗ ពាក់ប៉ែនមៀនស្រគំ ទន្ទាប់ទុំប្រមូលទុក ស្វាយបេកពាន់គ្រប់មុខ សោយឲ្យសុខតាមសប្បាយ ៗ ព្រះរាជាសួរថា ផ្លែណាផងទាំងឡាយ អ្នកណានាំពីឆ្ងាយ មកដល់កាយរៀបទុកដាក់ ៗ បើលោកទាំងពីរប្រាណ ទៅមិនបានសុទ្ធតែខ្លាក់

ម្តេចឡើយទើបដឹងជាក់ បេះបានផាក់ក្ងកញ្ជើ ៗ ទុក្ខលបណ្ឌិតថា សាមបុត្រាបេះទទេតើ ផ្លែឈើទឹងមើមឈើ ដើររុករើក្នុងព្រៃក្បែរព្រៃ ៗ ទៅរកមិនដែលខាន សន្សំបានតែកល់ថ្ងៃ មកទុកគ្រាន់សំរៃ ជាគង្វៃទៅពេលព្រឹក ៗ កាលបុត្រវិលមកដល់ ទំនាយខ្វល់ទៅដងទឹក សម្រាប់ទឹងផ្លូតផឹក តាមចិត្តទឹកបង់ពេលណា ៗ ឥឡូវកូនមិននៅ កាន់ក្អមទៅឯអគ្គា រសៀលតាបសុរិយា ផិតវេលាវិលវិញហើយ ៗ ព្រះកជាអគ្គនោះ តបចំពោះជាលោកអើយ លោកកុំព្រួយចិត្តឡើយ ខ្ញុំនេះហើយទឹងរក្សា ៗ រីឯសាមបណ្ឌិត រូបល្អពិតគួរទស្សនា ខ្ញុំបានផ្តាច់ជីវ៉ា ជួលដេកនាលើផ្លូវខ្សាច់ ៗ ឯនាងបារិកា បានឮថាកូនបីបាច់ ជីវិតស្តេចបានផ្តាច់ ញ័រសព្វសាច់អស់អង្គា ៗ ស្ទុះមកកាន់អាស្រម ឥសីសមនិយាយថា ខ្ទួនយើងរស់ពីណា ស្លាប់តាមគ្នាទៅគ្រាន់បើ ៗ កូនយើងបាត់ទៅហើយ រស់ថ្វីឡើយឥតអំពើ មិនមានអ្នកណាធ្វើ កិច្ចបំរើដល់យើងខ្វាក់ ៗ ទុក្ខលតបទៅថា នែបារិកាកុំអន់អាក់ បង្អើតចិត្តថ្នាំងថ្នាក់ ឲ្យចំពាក់កម្មវេរា ៗ ព្រះអគ្គគានបំណាំង ទឹងប៉ុនប៉ងផ្តាច់ជីវ៉ា បុត្រប្រុសស្រស់ព្រំផា ដោយពាលាចិត្តកំហឹង ៗ ឥឡូវមកប្រាថ្នា អគ្គលោកថាទឹងទំព្រឹង បីបាច់ជាពំនឹង ឲ្យយើងពឹងមួយជីវិត ៗ នែនាងបារិកា បុត្រថ្លៃថ្លាយើងកុំគិត កុំឲ្យខូចគំនិត ត្រែងបណ្ឌិតលោកខន្តី ៗ (មានត)

## បរិយាយសិប្បកថា

## ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ រៀបរៀង

(តមក)

១-ហត្ថិសិប្បៈ សិល្បៈក្នុងវិធីបង្ហាត់ដំរី ត្រួតត្រាខាងពលដំរី ។

២-អស្សសិប្បៈ សិល្បៈក្នុងវិធីទូន្មានសេះ ត្រួតត្រាខាងពលសេះ ។

៣-រថសិប្បៈ សិល្បៈក្នុងការធ្វើរថ ត្រួតត្រាខាងពលរថ ។

៤-ធនុសិប្បៈ សិល្បៈក្នុងការបាញ់ធ្នូ ប្រសប់ខាងការធ្នូ ។

៥-ថរុសិប្បៈ សិល្បៈក្នុងការប្រើអាវុធ កសាងអាវុធ ។

៦-មុទ្ទាសិប្បៈ សិល្បៈក្នុងការពប់កាញ់គ្នាដោយដៃទទេ ។

៧-គណនាសិប្បៈ សិល្បៈក្នុងការកាន់បញ្ជីកត់ត្រាកប់ចំនួនមនុស្សទីនគរផ្សេងៗ ។

៨-សង្ខានសិប្បៈ សិល្បៈក្នុងការប្រើឧបាយប្រាជ្ញាក្នុងផ្លូវសាសនោបាយ ។

៩-លេខាសិប្បៈ សិល្បៈក្នុងការសរសេរទាំងវិធីប្រើអក្សរត្រូវតាមច្បាប់អក្សរសាស្ត្រ ។

១០-កាវេយ្យសិប្បៈ សិល្បៈក្នុងការតែងពាក្យកាព្យឃ្លោងនិងប្រវត្តិសាស្ត្រផ្សេងៗ ។

១១- លោកាយតសិប្បៈ  សិល្បៈក្នុងផ្លូវលោកមានវិជ្ជាពេទ្យ  ទីនវិជ្ជាមើលលក្ខណៈផ្សេងៗ ជាដើមព្រមទាំងបរមត្ថវិជ្ជា  ទំនងវិធីផ្សំធាតុញែកធាតុរកដើមកំណើតឲ្យឃើញប្រាកដ ។

១២- ខត្តិវិជ្ជាសិប្បៈ សិល្បៈក្នុងក្រសួងរដ្ឋបាល-តុលាការ ច្បាប់ត្រួតត្រាប្រជារាស្ត្រ ។

សិល្បៈ ទាំង ១២ យ៉ាងនេះ គេលើកថាជាវិជ្ជាជាន់ខ្ពស់ក្នុងសាលាទិសាបាមោក្ខ សម្រាប់ប្រទេសជាតិរបស់គេ ព្រោះគេយល់ច្បាស់ថា ប្រទេសជាតិដែលបានចំរើនរុងរឿងឡើង ក៏ព្រោះអាស្រ័យសិល្បៈទាំងនេះឯង, មួយទៀតសិល្បៈនេះជាផ្លូវសម្រាប់រក្សាគ្រប់គ្រងប្រទេស ឬជាជាលំអរបស់ប្រទេស ។ សិល្បៈក្រៅពីនេះក៏នៅមានច្រើនបែបទៀតណាស់ ប៉ុន្តែគេរាប់ថាជាសិល្បៈសាធារណៈ ខាងផ្លូវពាណិជ្ជកម្ម សម្រាប់របរចិញ្ចឹមជីវិតផ្ទាល់ខ្លួនម្នាក់ៗ ប៉ុណ្ណោះ ។

សិល្បសាធារណៈមាន៩យ៉ាងគឺ

១- ទារុសិប្បៈ សិល្បៈខាងគ្រឿងឈើ គឺការឈ្លូសវៃក្នុងការចាំងឈ្លូសផ្ដាក់ក្រឡឹងខ្នាតបន្ទាត់ ធ្វើផ្ទះសម្បែងទំនងប្រដាប់តាក់តែងផ្ទះមានតុតាំងជាដើម ។

២- ចិត្តកម្មសិប្បៈ សិល្បៈខាងការគូរគំនូរផ្សេងៗ មានគំនូររូបមនុស្សជាដើម ។

៣- សុធាកន្ទសិប្បៈ  សិល្បៈខាងការជាងកំបោរដីឥដ្ឋគឺប្រសប់ក្នុងការរៀបចំផ្សំផ្គុំដោយគ្រឿងកំបោរដីឥដ្ឋ ធ្វើបានទាំងថ្មកសាងពង់ប្រាសាទចេតិយថ្នូរ  ខាងចល្លិក្ការលិត្តកម្ម គឺការលាបបូកឲ្យជិតស្និទ្ធឲ្យមានទពណ៌ណិទាំងខាងក្នុងខាងក្រៅ, ខាងវេទនកម្ម គឺការឆ្លាក់ក្បាច់ក្បូរផ្សេងៗ ។

៤- លោហធាតុសិប្បៈ  សិល្បៈខាងការលោហធាតុ គឺប៉ិនប្រសព្វក្នុងការស្លលកផ្សំធាតុដែក ស្ពាន់ លង្ហិន សំណ ប្រាក់ មាស, កាចយកលោហធាតុទាំងនោះមកផ្សំ ស្ល រំលាយ ដំ វៃ សិត ស្ងួន ក្រឡឹង ប្រើរៀបចំផ្សំផ្គុំផ្ទុំសព្វគ្រឿងយន្ត ឬធ្វើបរិក្ខារសម្រាប់ប្រើប្រាស់ដោយលោហធាតុ ។

៥- វត្ថសិប្បៈ  សិល្បៈខាងការត្បាញសំពត់សៀកពាក់រលេបពណ៌ច្រើនបែបគឺស្ទាត់ជំនាញក្នុងតន្តុវាយកម្ម ការត្បាញវៃអំបោះសូត្រ, ឆេទនកម្ម ការវែកកាត់, សិព្វនកម្ម ការដេរប៉ាក់, រជនកម្ម ការជ្រលក់ឲ្យមានពណ៌គ្រប់យ៉ាងតាមប្រាថ្នា ។

៦- ចម្មសិប្បៈ សិល្បៈខាងការរំស្បែក គឺវិធីសំលាប់ស្បែកឲ្យមានសាច់ទន់ស្អាតល្អ ធ្វើបរិក្ខារសម្រាប់ប្រើប្រាស់ដោយស្បែកសត្វផ្សេងៗ ។

៧- នហាបិតសិប្បៈ សិល្បៈខាងការកាត់សក់ លាបសក់ គក់ តែងសក់ឲ្យល្អតាមសម័យ ។

៨- មណិការសិប្បៈ សិល្បៈខាងវិធីធ្វើគ្រឿងគឺចេះប្រែសប់ខាងការច្នៃត្បូង-ពេជ្រ, ស្មូកែវផ្សេងៗ មានកែវមណីជាដើម ។

៩- តិលញ្ឆសិប្បៈ សិល្បៈខាងរបៀបគម្សាញកន្ទួល, ផែន ឬល្អីបន្ទើរជាដើម ។

សិល្បៈទាំងអស់ដូចសំដែងមកនេះ ហាក់ដូចជាកំភោចកំភោចប៉ុណ្ណោះ ប៉ុន្តែមិនមែនដូច្នោះទេ គឺជាវិជ្ជាសម្រាប់ដៃរបស់គ្រហស្ថ បម្រុងផល់ការចិញ្ចឹមជីវិតឬជាជាលំអរបស់គ្រួសារ; សិល្បវិជ្ជាទាំងនេះ, បើជនជាគ្រហស្ថ ឥតគិតទិតមិនបានគិតសិក្សាឬជាមនុស្សខ្ជិលច្រអូសក៏មិនអាច នឹងបានចេះជំនាញសិល្បៈណាមួយឡើយ ។ បុគ្គលជាគ្រហស្ថប្រុសស្រី ដែលមានចិត្តប៉ុនប៉ងក្នុងការស្វែងរកទ្រព្យ ឬប្រុសដែលមានចិត្តចំពាក់ក្រោបក្រាញទៅក្នុងយកកាសសម្បត្តិ ក៏ត្រូវតែស្វះស្វែងរករៀនសិល្ប-វិជ្ជាណាមួយឲ្យបានចេះជំនាញស្ទាត់ប្រាកដក្នុងខ្លួន ដើម្បីជាស្នាដៃ ជាអលង្ការជាលំអរបស់បុរសស្ត្រីក្នុងត្រកូលនីមួយៗ, ព្រោះថាបុរសស្ត្រីដែលមានរូបឆោមស្រស់បស់ល្អយ៉ាងណាក៏ដោយ តែបើគ្មានវិជ្ជាក្នុងខ្លួនហើយនឹងកប់ថាល្អពុំបានឡើយ ប្រៀបដូចជាមនុស្សកំបុតដៃជើងឬដូចជាមនុស្សគ ឬក៏ដូចជាមនុស្សអាក្រាតកាយទទេ ។ សិល្បៈនេះទុក

ជាធុរៈមួយ សម្រាប់ត្រកូលគ្រហស្ថត្រូវទទួលសិក្សា; ឯបុរសស្ត្រីដែល គ្រាន់តែល្អរូបប៉ុណ្ណោះ តែបើមិនមានសិល្បវិជ្ជាផងទេ ក៏គង់មិនល្អខ្ពង់ខ្ពស់ដល់ត្រកូលបាន សមដូចគាថាសុភាសិតថា

"រូបយោព្វនសម្បន្នា វិសាលកុលសម្ភវា

វិជ្ជាហីនា ន សោភន្តិ និគ្គន្ធា ឥវ កឹសុកា" ។

សេចក្ដីថា "បុគ្គលកើតក្នុងត្រកូលខ្ពង់ខ្ពស់ បរិបូណ៌ដោយរូបនិងវ័យនៅក្មេងក៏ដោយ តែបើសាបសូន្យចាកវិជ្ជាហើយ មិនឈ្មោះថាល្អទេ ដូចជាផ្កាចារ (គ្រាន់តែមានពណ៌ក្រហមច្រាល) តែឥតក្លិនក្រអូប" ។

មួយទៀត សិល្បៈនេះទុកដូចជាទ្រព្យធនដើមទុនដែលចាយក៏យ មិនចេះអស់ ភ្លើងក៏មិនឆេះ ទឹកក៏មិនលិច ចាំងចោរក៏លួចប្លន់យកមិនបាន, សមដូចគាថាសុភាសិតលោកនីតិថា

"សិប្បសមំ ធនំ នត្ថិ សិប្បំ ចោរា ន គណ្ហរេ

ឥធលោកេ សុចំ មិត្តំ បរលោកេ សុខាវហំ" ។

សេចក្ដីថា "ទ្រព្យស្មើដោយសិល្បៈ មិនមានទេ ចោរទាំងឡាយក៏លួចយកសិល្បៈមិនបាន សិល្បៈជាមិត្តសំឡាញ់នាំមកនូវសុខក្នុងលោកនេះផង នាំមកនូវសុខក្នុងបរលោកផង" ។

ក្នុងគម្ពីរមង្គលត្ថទីបនី មានរឿងដំណាលថា បីឋសប្បិ (បុរសខ្វិន) ម្នាក់ ចេះស្ទាត់ប្រាកដក្នុងសាស្ត្រសិប្បៈ គឺវិជ្ជាផ្ទាត់គ្រួស អាចផ្ទាត់

ដុំក្រួសត្រូវស្លឹកឈើឲ្យមានរូបដូចជារូបសត្វអ្វីៗ បានទាំងអស់, បុរសខ្វិននោះមានឈ្មោះឮល្បីខ្ទរខ្ទាយ ដោយគ្រាន់តែចេះសិល្បៈផ្ទាត់ក្រួសប៉ុណ្ណោះ, ដំណាលថា ស្ដេចក្នុងនគរនោះ មានបុរោហិតម្នាក់ ជាអ្នកមាត់រឹងនិយាយច្រើនមិនខស្ងូរចេះឈប់, លុះស្ដេចបានជ្រាបហើយក៏ចាត់រាជបុរសឲ្យទៅនាំយកបុរសខ្វិននោះមកដើម្បីឲ្យផ្ទាត់អាចម៍ពពែ ដាក់មាត់បុរោហិត ដែលមានសំដីរឹងនោះធ្វើឲ្យរាងចាល, លុះរាជបុរសនាំមកដល់ហើយ ស្ដេចក៏ឲ្យលាក់បំពួនបុរសខ្វិននោះក្នុងកន្លែងជិតស្ដេចរួចឲ្យហៅបុរោហិតមក ហើយនាំឲ្យនិយាយ, លុះបុរោហិតហាមាត់និយាយឡើង, បុរសខ្វិនក៏បានឱកាសផ្ទាត់អាចម៍ពពែចូលចំមាត់ម្ដងៗ រាល់តែម៉ាត់ដែលបុរោហិតហានិយាយ, ផ្ទាត់ឲ្យចូលរហូតដល់ពោះ ទាល់តែពេញពោះព្រាលឡើងមកដល់ដើមកនិយាយលែងកើត, ស្ដេចក៏ទ្រង់មានព្រះអំណររួចទ្រង់ប្រទានរង្វាន់ជាច្រើន ព្រមទាំងស្រុកសួយ ៤ ស្រុកថែមទៀត; បុរសខ្វិននោះក៏បានឡើងទៅជាអ្នកមានទ្រព្យស្ដុកស្ដម្ភគ្រាន់បើមួយរំពេច ដោយវិជ្ជាសិល្បៈផ្ទាត់ក្រួសនោះឯង ។

គ្រានោះ មហាមាត្យជាបណ្ឌិតរបស់ស្ដេច បានសំដែងសរសើរអានិសង្សរបស់សិល្បៈចំពោះព្រះភក្ត្រស្ដេច ក្នុងវេលាដែលចូលគាល់នោះ ដោយគាថាសុភាសិតថា:

“សាធុ ខោ សិប្បកំ នាម អបិ យាទិសិកីទិសំ
បស្ស អជប្បហារេន លទ្ធា គាមា ចតុទ្ទិសា”ៗ (មានត)

ឯកសារភាគមិលិន្ទបញ្ហា

ហ្លួងនិពន្ធមន្ត្រីញ៉ុក-ថែម រៀបរៀង

(តមក)

## អង្គ ២ របស់សត្វក្អែកៈ

១- មានសេចក្ដីរង្កៀសសង្ស័យជុំខ្លួនប្រយ័ត្នខ្លួនដើរហើររកស៊ី ។

២- ជួបប្រទះចំណីណាមួយ គឺសាកសពឬសេសអាហារចំណី គឺស្រែកហៅពួកញាតិជាតិក្អែកនេះគ្នាមកស៊ីជាមួយគ្នា ។

(ព្រ)បដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការ គឺ:

១- មានសេចក្ដីរង្កៀសរង្វើមអំពើទុច្ចរិតសង្រួមឥន្ទ្រីយដោយសតិដ៏ជាប់ខ្លួន គាំងចិត្តរក្សាការពារទ្វារទាំង ៦ គ្រប់ឥរិយាបថ ។

២- បានលាភសក្ការៈយ៉ាងណាៗ ដែលប្រកបដោយធម៌ ដែលកើតឡើងដោយធម៌ ដោយហោចទៅគ្រាន់តែដុំបាយក្នុងបាត្ររបស់ខ្លួន ក៏គាប់ចិត្តចែងចែកលាភនោះៗ ដល់ពួកសព្រហ្មចារីដ៏មានសីលទាំង-ឡាយ មិនហួងហែងបរិភោគតែម្នាក់ឯង ។

## អង្គ ២ របស់ស្វាៈ

១- កាលស្រ័យនៅនឹងទីទំនេរដូចជាដើមឈើធំ ដ៏ស្ងប់ស្ងាត់ មានមែកធាងត្រឈឹងត្រឈៃសាយចេញទៅ ជាលំនៅល្អមការពារសេចក្ដីភិតភ័យរបស់ខ្លួនបាន ។

២ – ដើរក្រោកអង្គុយនៅចំពោះផ្ទួរដើមឈើណា លុះវេលាព្រលប់យប់ក៏ឈប់ដេកនៅទីដើមឈើនោះឯង ។

របៀបដូចបុគ្គលដែលប្រកបដោយអង្គសម្បត្តិ ២ ប្រការ ៖

១ – នឹងនៅចំណាទីមួយ គប្បីសេពគប់សព្រហ្មចារី ដែលមានខ្មាស មានសីលជាទីស្រឡាញ់ មានកល្យាណធម៌ ជាពហុស្សូត្រ ទ្រង់ធម៌មុខគួរស្រឡាញ់ គួរគោរព គួរសរសើរ ដែលនាំប្រៀនប្រដៅឲ្យស្គាល់ល្អស្គាល់អាក្រក់ សំដែងគុណនឹងទោសតាមពិតដឹកនាំក្នុងផ្លូវល្អឲ្យមានចិត្តក្លាហានរែកពយក្នុងផ្លូវប្រតិបត្តិ កាលបើបានមិត្តសព្រហ្មចារីបែបនេះទើបសេពគប់ទុកជាកល្យាណមិត្តនៅអាស្រ័យជាមួយផង ។

២ – បែរមុខសំដៅព្រៃណា ក៏គប្បីឈរដើរចង្ក្រម ដេក អង្គុយ ចំរើនសតិបដ្ឋាននៅក្នុងព្រៃនោះ ។

## អង្គ ២ របស់ពូជស្រូវ ៖

១ – ពូជស្រូវមានប្រមាណតិច ដែលបុគ្គលព្រោះសាបទុកក្នុងស្រែមានដីដីជាតិល្អ មានភ្លៀងធ្លាក់ចុះមកធ្វើឲ្យជោកឫសនឹងសន្ទឹកជានិច្ច ពូជស្រូវនោះក៏បង្កើតផលជាច្រើន ។

២ – ពូជស្រូវដែលបុគ្គលព្រោះសាបទុកក្នុងស្រែដែលបានគាស់ករល្អហើយ រមែងដុះលូតលាស់ល្អដោយរួសរាន់ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការៈ

១- សីលដែលគេរក្សាល្អហើយ ជាអនុបុព្វបដិបទាដែលអាចឲ្យផលជាច្រើនតាំងអំពីមនុស្សសម្បត្តិ សម្បត្តិសួគ៌ ហើយជាបច្ច័យឲ្យបានសម្បត្តិព្រះនិព្វាន តាមសមគួរដល់ការប្រតិបត្តិនោះៗផង ។

២- ទប់កំណត់ចិត្តទុក នៅក្នុងទីស្ងាត់ ដម្រះចិត្តឲ្យស្អាតថ្លាដោយសតិបដ្ឋាន គឺដឹកលំចិត្តទុកឲ្យខ្ជាប់នៅក្នុង កាយ, វេទនា, ចិត្តនិងធម៌ ហើយខំស្រាវពិចារណាឲ្យឃើញតាមសភាពពិត ទាល់តែចិត្តស្ងប់កើតបញ្ញា ជាហេតុនាំមកនូវផល ដ៏ល្អប្រពៃដោយឆាប់ដូចពូជស្រូវដែលគេបានព្រោះសាបក្នុងដីស្រែដែលមានដីជាតិល្អ ដូច្នោះ ។

## អង្គ ២ របស់ទូកគៀងក្នុងសមុទ្រ

១- ទូកដែលគៀងក្នុងមហាសមុទ្រ ដែលមានផ្ទៃទឹកញាប់ញ័រគឹកកងៈដោយរលកតូចធំក៏ជាប់ណែនទៅមិនរបូតទៅទិសផ្សេងៗឡើយ ។

២- អណ្តែតឡើងលើមិនបាន តែលិចស្រើបទៅក្នុងទឹកជ្រៅ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការៈ

១- ទប់កំណត់ចិត្តដែលមានរាគៈ ទោសៈ មោហៈ ដូចខ្សែរលកទឹកមកគ្របសង្កត់ហើយច្រើនតែធ្លាក់ទៅក្នុងអំណាចអកុសលវិតក្ក ដឹកលំចិត្តខ្ជាប់ខ្ជួនក្នុងកុសលវិតក្កទាំងឡាយមិនឲ្យរសាប់រសល់ទៅមក ។

២-កាលគ្រាមាន លាភ, យស, សរសើរ សុខ, ជាដើមក៏មិនឡើងជោរគោម ដល់គ្រាសាបសូន្យចាកលាភ,យសជាដើម ក៏មិនអន់ចិត្ត គប្បីតាំងចិត្តឲ្យខ្ជាប់ខ្ជួន មិនរញ្ជួយទៅតាមអំណាចឥដ្ឋារម្មណ៍និងអនិដ្ឋារម្មណ៍ ។

## អង្គ ២ របស់ឆ្មា:

១ - សម្ងំនៅក្នុងទីណាក្តី ដូចក្នុងគុហា ច្រកភ្នំឬទីផ្ទះសំបែង ក៏តែងតែស្ងៀមរកតែកណ្តុរប៉ុណ្ណោះក្នុងទីនោះៗ ។

២- ស្ងៀមរកអាហារស៊ីតែក្នុងទីជិតៗ ប៉ុណ្ណោះ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការ:

១- ទោះនៅក្នុងទីណាៗ ជាដើម គឺក្នុងព្រៃព្រឹក្សក្តី គល់ឈើក្តី, គុហាលាក់លក្តី ក្នុងផ្ទះស្ងាត់ក្តី គប្បីមិនប្រមាទក្នុងទីនោះៗ ចំរើនកាយគតាសតិជានិច្ច ដូចជាឆ្មាតែងស្ងៀមរកអាហារជានិច្ច ។

២- មានឧទយព្វយានុបស្សនាធម៌ជាគ្រឿងនៅ គឺខំស្វាហ៍ពិចារណាសេចក្តីកើតនិងរលត់នៃបញ្ចក្ខន្ធជាបច្ចុប្បន្ន រាល់តែកើតចក្ខុគឺដួងភ្នែកមើលឃើញហេតុកើតនិងរលត់នៃបញ្ចក្ខន្ធនោះតាមដោយពិត ហើយបានចេះប្រើបញ្ចក្ខន្ធឲ្យជាប្រយោជន៍ អាចចាប់យកប្រយោជន៍ទាំង ៣ គឺប្រយោជន៍ក្នុងលោកនេះ ប្រយោជន៍ក្នុងលោកខាងមុខនិងប្រយោជន៍ដ៏ធំបំផុតគឺព្រះនិព្វាន ព្រោះអាស្រ័យនូវឧទយព្វយានុបស្សនាធម៌នេះឯង ។

## អង្គ ២ របស់សត្វបបក:

១- បានអាហារហើយ មិនត្រឹមស៊ីគាល់តែឆ្អែត ។

២- បានអាហារមកហើយ មិនរើសថាល្អឬអាក្រក់ ស៊ីបានទាំងអស់ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការ:

១— បានអាហារមកហើយមិនស្អប់ត្រឹម បរិភោគតែល្មមញុំាងអត្តភាពឱ្យប្រព្រឹត្តទៅបានប៉ុណ្ណោះ ។

២— លុះបានអាហារមកហើយ មិនរើសថាល្អឬអាក្រក់ ត្រូវមាត់ឬមិនត្រូវមាត់ រមែងមានចិត្តត្រេកអរតាមមានតាមបាន ។

## អង្គ ២ របស់ជ្រូកព្រៃ:

១- កាលដល់រដូវក្តៅ ដែលមានកំដៅខ្លាំង តែងចុះប្រឡុកទៅតែកន្លែងទឹក ។

២- ប្រទះទឹកឥតកក់បាច់ ក៏យកច្រមុះញីញក់ដីធ្វើឱ្យទៅជាកក់បាច់ ហើយចុះដេកត្រាំ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិពីរប្រការគឺ:

១- កាលចិត្តកើតអផ្សុកក្រមៅ ក៏ចំរើនមេត្តាភាវនា ដ៏ជាធម៌ត្រជាក់ផ្សេងផង ។

២- ចំរើនកាយគតាសតិខ្ជាប់មាំនៅក្នុងចិត្ត ហាមកំរិតអារម្មណ៍ ខាងក្រៅមិនឲ្យគ្របសង្កត់ចិត្ត ។

## អង្គ ២ របស់សត្វមៀមៈ

១- ជាសត្រូវនឹងក្អែក វេលាយប់តែងហើរទៅរកហ្វូងក្អែក ហើយ ចឹកដល់ហ្វូងក្អែកពេញបន្ទុក ។

២- លាក់ខ្លួនពួនសំងំនៅក្នុងព្រៃយ៉ាងស្ងប់ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការគឺៈ

១ - ជាសត្រូវនឹងអវិជ្ជា ទៅក្នុងទីស្ងាត់តែម្នាក់ឯង ប្រហារ អវិជ្ជាឲ្យដាច់ខាតដកបដល់ឫស ។

២- មានការគេចចេញទៅពួនសំងំជាទីត្រេកអរ ហើយពេញ ចិត្តទៅពួនសំងំចំរើនសមណធម៌នៅក្នុងព្រៃស្ងាត់ ។

## អង្គ ២ របស់សត្វប្រចៀវៈ

១- ហើរចូលទៅក្នុងផ្ទះណាទីមួយហើយ ក៏ហើរចេញមកវិញ មិនមានការឡោះអាល័យនឹងផ្ទះនោះឡើយ ។

២- កាលទៅនៅនឹងផ្ទះអ្នកដទៃ មិនធ្វើឲ្យខូចខាតដល់ម្ចាស់ផ្ទះ នោះឡើយ ។

របៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការគឺៈ

១— ត្រាច់ទៅបិណ្ឌបាតក្នុងលំនៅផ្ទះតាមលំដាប់ច្រក ទោះបីបានក៏ដោយ មិនបានក៏ដោយ ក៏ត្រូវត្រឡប់មកវិញ មិនជាប់ចិត្តនៅនឹងផ្ទះនោះៗ ។

២— ចូលទៅកាន់ត្រកូលណានីមួយ មិនបង្កសេចក្តីក្តៅក្រហាយដល់ត្រកូលនោះៗ ដូចជាហៅសុំច្រើន, ជាងពាក្យ, មិនបំផ្លាញការងាររបស់គេ, មានតែធ្វើឲ្យគេបានសេចក្តីចំរើនឡើងតាមទំនងគន្លងធម៌ ។

## អង្គ ២ របស់ព្រានសន្ទូច

១ – ស្ទូចត្រីដោយសន្ទូច ។

២ – ខ្ទូចបង់នុយតែបន្តិច បានត្រីធំ ។

របៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការ គឺៈ

១– បានសម្រេចសាមញ្ញផលដ៏ឧត្តមដោយញាណដែលទុកដូចជាសន្ទូចស្ទូចត្រី ។

២– លះបង់លោកាមិសដូចជានុយ ដែលជារបស់បន្តិចបន្តួចក៏បានសម្រេចនូវសាមញ្ញផលដ៏បរិបូណ៌ ។

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

### ផ្នែកអក្សរសាស្ត្រ

ទំព័រ


ឧកញ៉ាទេពពិទូរ ក្រសេម . . . ព្រះរាជប្រវត្តិ សម្ដេចព្រះវត្តិយកល្បាណ៍រាជ-សុតាភគវតី . . . . . . . . . . . . . ៣៩៣

លោកគ្រូចៅអធិការ ឯក-ញឹម . ធម្មិកោវាទ ពាក្យកាព្យ . . . . . . . . . ៣៩៦

លោក ហាន់-យេង . . . . . . . រឿងកំពូលកំសត់ (តមក) . . . . . . . . ៤១១

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ប្រជុំសុភាសិតខ្មែរ តាមលំដាប់អក្សរ (តមកនិងចប់) . . . . . . . . . . . . . ៤២៣

លោក ញ៉ុក-នូ . . . . . . ច្បាប់ក្រមបរិយាយ (តមក) . . . . . . . ៤៣០


### ផ្នែកសាសនា


ដំណឹងអំពីក្រសួងធម្មការ . . . អំពីតាំងចៅអធិការនិងមន្ត្រីសង្ឃ . . . . . . ៤៣៧

ព្រះគ្រូសុវណ្ណញាណ សូរ-ពោយ. បរិយាយសិប្បកថា (តមកនិងចប់) . . . . ៤៤២

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Luong Nibandhamantri Nhok-Thêm, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Preah kru Paññalikhito Kao-Sim, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

**Partie littéraire:**

| | | Pages |
|---|---|---|
| Oknha Tép Pĭtou Krasem | Biographie de S. A. R. la princesse Sutharot . . . . . . . . . . | 393 |
| Vénérable Chau At'ĭkar Ek-Nhim. . . . . . . | Dhammikovāda, poème. . . . . . | 396 |
| Monsieur Han-Yéng. . . . | Kămpul kămsăt, roman (suite) . . | 411 |
| Luong nĭponmontrei Nhok-Thêm. . . . . . | Recueil de proverbes cambodgiens classés par ordre alphabétique (suite et fin) . . . . . . . . . | 423 |
| Monsieur Nheuk-Nou. . . | Chbăp krĭmborĭyay (suite). . . . | 430 |

**Partie religieuse:**

| | | |
|---|---|---|
| Communiqué du département des Cultes . . . | Nominations de Chau at'ĭkar et Montrei săng . . . . . . . . . | 487 |
| Prĕah kru Suvaddhaññāna So-Hay. . . . . . . . | Pariyāyasippakathā (suite et fin) . | 442 |

16e année — No 8, Aout 1944 — Abonnement: un an 15$00.

## ព្រះរាជប្រវត្តិ

# សម្តេចព្រះខត្តិយកល្យាណ៍រាជសុតាភគវតី

## ព្រះរាជអយ្យិកា

ទ្រង់ប្រសូតនៅថ្ងៃអង្គារ ខែកត្តិកឆ្នាំចឆស័ក ព. ស. ២៤១៧ (គ. ស. ១៨៧៤)

ទ្រង់សុគតនៅវេលារសៀលម៉ោង ៤ ជប់បីម៉ឺនុតគត់ថ្ងៃពុធ ១៣ កើតខែស្រាពណ៍ឆ្នាំវកឆស័ក ព. ស. ២៤៩៧ (២ ក៊ីត ១៩៥៤) ដោយព្រះរោគខ្យល់ ដំណឹងនេះជាទីសោកសោកនៃព្រះរាជវង្សានុវង្ស និងនាហ្មឺនសព្វមុខមន្ត្រីនូវប្រជារាស្ត្រទាំងពួងជាយ៉ាងក្រៃពេក ៗ

សម្តេចព្រះរាជអយ្យិកាព្រះនាមដើម "ផ្អាំ អ៊ឹម" ជាព្រះបិយៈធីតានៃព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តមបរមទេវាវតារ ព្រះចៅក្រុងកម្ពុជាធិបតី និងលោកយាយទៅបមាតាសុជាតបុប្ផា (នាម ឌួខ) នៅថ្ងៃ – ខែ – ឆ្នាំដូចបានពោលមកហើយ ៗ លុះចំរើនវ័យឡើងហើយបានទ្រង់សមរស និងសម្តេចព្រះរាជអយ្យកោវរបរណាទិន្ន នរោត្តម-សុធារស កាលពីគ្រឹស ព. ស. ២៤៣៧ គ. ស. ១៨៩៤ មានព្រះរាជបុត្រព្រះរាជធីតារួមទាំងអស់ ៧ អង្គ តែគង់ព្រះជន្មនៅសព្វថ្ងៃនេះតែ ២ ព្រះអង្គគឺ :

១– ព្រះរាជបុត្រ: សម្តេចព្រះវររាជបិតា វិសុទ្ធិខត្តិយវង្ស ន. សុរាម្រិត ដែលជាព្រះរាជបិតានៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

វេជ្ជកាលបច្ចុប្បន្ន ។ (ក្នុងពេលមុនដែលព្រះករុណាបានឡើងសោយរាជ-សម្បត្តិ ទ្រង់ធ្វើការដំណែងជាសេនាបតី ទីឧកញ៉ា (ក្រឡាហោម) ។

៤- ព្រះរាជធីតា: សម្ដេចព្រះបិតុច្ឆាស្ដ្រី សោភ័ណ ។

## អំពីព្រះបរិយាសម្បត្តិ នូវព្រះគុណសម្បត្តិ

ពោលដោយសង្ខេប: សម្ដេចព្រះរាជអយ្យិកានេះមានព្រះបរិយាសុភាពស្រគត់ស្រគំមានព្រះហឫទ័យត្រជាក់ត្រជុំ-ទូលាយ តែងទ្រង់ព្រះមេត្តាប្រោសរាប់អានទីពឹងទំនុកបម្រុងព្រះរាជវង្សានុវង្ស នូវនាហ៊ឺនសព្វមុខមន្ត្រី ព្រមទាំងប្រជារាស្ត្រ អ្នកទីទ័លក្រឲ្យបានសេចក្ដីសុខចុះទៅ ទ្រង់មានព្រះអធ្យាស្រ័យរីករាយ គួរជាទីត្រេចផឹកដោយចិត្តរបស់អ្នកដែលបានឃើញ ឬសមាគមផង ទ្រង់ជាមហាសប្បុរសមានសីលវត្តដ៏ល្អ តែងទ្រង់ព្រះសណ្ដាប់ព្រះធម្មទេសនា និងបរិច្ចាគទានក្នុងបវរពុទ្ធ-សាសនាជានិច្ច ព្រមទាំងទក្ខិណាគតិម្យដែលជាទីគន់ជាទីគោរពទៅមកបរហែមិនដែលដាច់នៃព្រះសង្ឃសក្យបុត្រទាំងឡាយ ។

ក្រៅអំពីព្រះគុណសម្បត្តិផ្ទាល់ព្រះអង្គទាំងនេះ ទ្រង់បានផ្ដើមបង្កើតសាលាបង្រៀនកុមារី ហៅថា "សាលាសម្ដេចក្សត្រីសុធារស" (P. Sutharoth) នៅក្នុងភ្នំពេញ ជាទីបណ្ដុះបណ្ដាលចំណេះវិជ្ជាដល់កុមារីទាំងឡាយក្នុងព្រះនគរ ទ្រង់បានយកព្រះហឫទ័យទុកដាក់ចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គជាច្រើនទំនុកបម្រុងសាលានេះឲ្យបានសេចក្ដី

ចំរើនផលភាពមកដល់សព្វថ្ងៃនេះ ទាំងទ្រង់បានទទួលដំណែងជាសមាជិកកាមទ្វីសម្រាលបុត្រសម្រាប់ជាតិខ្មែរ ជាមួយនឹងលោកស្រីឌូសក់ មួយអន្លើទៀតជាដើម សឹងកប់ថាជាប្រយោជន៍ដល់ស្រីខ្មែរជាអនេក-ប្រការ ។

ដោយទ្រង់បំពេញ អត្តហិត ប្រយោជន៍ផ្ទាល់ព្រះអង្គនឹងបរ-ហិតប្រយោជន៍ដល់អ្នកដទៃ នឹងដល់រាជការដូច្នេះ ទើបមានជនានុជនក្នុងព្រះនគរនិយមគោរពរាប់អានឡើងទៅ ទ្រង់បានទទួលព្រះកិត្តិយសខ្ពស់ គឺជាសម្តេចព្រះខត្តិយកល្យាណីរាជសុភាគវតី តាំងពីក្នុងរជ្ជកាលព្រះករុណាបរមខត្តិយកោដ្ឋ មកក្នុងរជ្ជកាលបច្ចុប្បន្ននេះ ទ្រង់បានឡើងព្រះកិត្តិយសជាសម្តេចព្រះរាជអយ្យិកាខត្តិយកល្យាណីរាជសុភាគវតី ទាំងរាជការរាណាព្យាបាលក៏បានថ្វាយគ្រឿងឥស្សរិយយស ១ សំដែងសេចក្តីអំណរគុណចំពោះដែលទ្រង់យកព្រះហឫទ័យទុកដាក់ធ្វើករណីយកិច្ចផ្សេងៗ សឹងជាប្រយោជន៍ក្នុងព្រះនគរជាបច្ចេក ។

ជម្ពីរភាគ ៩

# ព្រះអាចារ្យ ឯក-ញឹម ធម្មិស្សរោ

ចៅអធិការវត្តធម្មិស្សរោរាម ស្រុកសូទ្រនិគម ខេត្តសៀមរាប

រៀបរៀង

ក្បាច់ធម៌ក្នុងសៀវភៅនេះ យើងខ្ញុំ ធម្មិស្សរោ (ឯក-ញឹម) ចៅអធិការនៃវត្តធម្មិស្សរោរាមរៀបរៀងឡើងជាពាក្យឃ្លោង សម្រាប់ក្មេងរៀននៃវត្តធម្មិស្សរោរាម នៅថ្ងៃពុធ ៩ កើត ខែស្រាពណ៍ ឆ្នាំមមែបញ្ចស័ក ព.ស. ២៤៨៦ ។

ក្បាច់ធម៌ទាំងអស់ដែលយើងខ្ញុំដកស្រង់មករៀបរៀងនេះ នៅមានសេចក្តីពិស្តារក្នុងសង្គីតលោកទសូត្រ ។

ឯរបៀបធម៌ក្នុងសូត្រនោះ មិនមែនបែបនេះទេ ប៉ុន្តែយើងខ្ញុំអ្នកគិតយល់ថាគួររៀបចំឡើងជារបៀបថ្មី ដើម្បីដម្រូវតាមចំនងបុព្វការីជនគតញ្ញូកតវេទីបុគ្គល ដែលជាបុគ្គលរកបានដោយក្រម ២ យ៉ាងក្នុងលោក ។

លុះយើងខ្ញុំរៀបចំរួចហើយ បានយកក្បាច់នេះបង្រៀនដល់ពួកកុលបុត្រអ្នកបួសថ្មីៗ ក្នុងវត្តរបស់យើងខ្ញុំ ប៉ុន្តែកាលបង្រៀននោះ យើងខ្ញុំបានយកបាលីមកដាក់ទុកជាគោល បង់ជាឃ្លាដាក់ឡើងតាមស្ពាន ហើយឲ្យមានព្រមទាំងសេចក្តីប្រែជាពាក្យឃ្លោងនេះផង ។

ក៏មកមានពុទ្ធបរិស័ទជាច្រើនគ្នា ជ្រះថ្លាចង់បានធម៌នេះ ទើបនាំគ្នាចាត់ការបោះពុម្ពផ្សាយចែកជាធម្មទានក្នុងឱកាសបុណ្យបញ្ចុះសីមាវត្តនោះ នៅថ្ងៃអាទិត្យ ១១ កើតខែមិគសិរឆ្នាំកែនស័ក ព.ស. ២៤៨៧ ប៉ុន្តែដោយហេតុក្រដាសរកបានដោយកម្រណាស់ ក្នុងសម័យសព្វថ្ងៃនេះ ទើបយើងខ្ញុំយកមកជូនពុទ្ធសាសនបណ្ឌិត្យ ដើម្បីចាត់ចែងបោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយានេះ ។

យើងខ្ញុំសូមសេចក្ដីសុខចំរើន ចូរមានដល់ព្រះពុទ្ធសាសនានិងលោកអ្នកសិក្សាទាំងឡាយផង ដល់នគរក្រុងកម្ពុជា និងមហានគរបារាំងសែស ដែលបានជួយឧបត្ថម្ភ ដល់ពុទ្ធសាសនា និងប្រទេសជាតិផង តទៅអស់កាលជាអង្វែង ។

## ទិសានមស្សការធម៌ ៦ យ៉ាង

### បទ.ពាក្យប្រាំពីរ

ទី ១– ខាងកើតទិសបុព្វា    ទុកជាមាតាបិតា
ដែលបង្កើតបុត្រក្នុងលោកា    ត្វារក្ខនស្នេហាអស់ពីចិត្ត ។
ត្រូវប្រតិបត្តិលោកដោយធម៌ប្រាំ    ដែលអ្នកប្រាជ្ញផ្ដាំមានចាំរក
កន្រ្ទៃថ្លៃគុណលោកអាណិត    ដោយមេត្តាចិត្តជួយក្ខនថ្លៃ ។
ទី ២– ខាងត្បូងទិសទក្ខិណា    ទុកជាអាចារ្យយើងសព្វថ្ងៃ
ដែលបង្រៀនធម៌ល្អថ្លាថ្លៃ    ឲ្យបានវិស័យទៅនិព្វាន ។
ត្រូវប្រតិបត្តិលោកដោយធម៌ប្រាំ    ដែលអ្នកប្រាជ្ញផ្ដាំទុកទូន្មាន
គឺពាក្យជាច្បាប់ឧកទាន    ទាំងនោះត្រូវមានចិត្តជ្រះថ្លា ។

ទី៣– ខាងលិចទិសបច្ឆិមា | នោះលោកទុកជាបុត្តភរិយា
ដែលបនោះក្រោយខ្នងយើងរាល់គ្នា | នោះគឺជាក្រោមបង្អប់ខ្លួន ។
ត្រូវធ្វើសង្គ្រោះដោយធម៌ប្រាំ | ដែលអ្នកប្រាជ្ញផ្តាំផ្តាច់មាំមួន
ជាត្រូវមានចិត្តអាណិតស្ងួន | កុំមានគុំគួនឬញាន់ខ្ញាញ់ ។
ទី៤– ខាងជើងទិសឧត្តរ | លោកទុកជាជាមិត្រសំឡាញ់
ដែលមានចិត្តស្មើគតគ្នាលង្វាញ់ | រាប់អានស្រឡាញ់ឥតអាក់ឡើយ ។
ត្រូវប្រតិបត្តិគ្នាដោយធម៌ប្រាំ | ដែលអ្នកប្រាជ្ញផ្តាំផ្តាច់មកហើយ
បើមិត្រមានទុក្ខជួយឲ្យស្បើយ | កុំខានសោះឡើយទើបត្រូវធម៌ ។
ទី៥– ខាងក្រោមទិសហេដ្ឋា | លោកទុកជាទាសកម្មករ
ដែលជួយធ្វើការអាក្រក់ល្អ | ដោយចិត្តស្មោះសរនឹងបោហ្វាយ ។
ត្រូវធាយសង្គ្រោះដោយធម៌ប្រាំ | ដែលអ្នកប្រាជ្ញផ្តាំឲ្យខ្វល់ខ្វាយ
បើមានឈឺចាប់មិនសប្បាយ | ត្រូវឲ្យពេទ្យហ្វាយថែរក្សា ។
ទី៦– ខាងលើទិសឧទ្ធៈ | ទុកជាសមណៈនិងព្រាហ្មណា
ដែលយើងខាយកទាយិកា | មានចិត្តជ្រះថ្លាហើយធ្វើទាន ។
ត្រូវប្រតិបត្តិលោកដោយធម៌ប្រាំ | ដែលអ្នកប្រាជ្ញផ្តាំទុកខ្ញុំខ្លាន
លោកអ្នកប្រាប់ផ្លូវសួគ៌និព្វាន | ជាទៅដោយយានគឺសីលអើយ ។

# ច្បាប់មាតាបិតាសង្គ្រោះកូន ៥ យ៉ាង

*បទពាក្យប្រាំពីរ*

ទី១– ត្រូវឃាត់កូនទាំងឡាយ | កុំឲ្យខ្វល់ខ្វាយក្នុងការបាប
សម្លាប់លួចប្លន់តាំគុំនជាប | អំពើជាបាបឃាត់ឲ្យខាន ។
ទី២– ត្រូវនាំកូនធ្វើបុណ្យ | អំពើជាគុណជាប់កល្យាណ
កាន់សីលជាដើមដែលនាំប្រាណ | បានសុខក្សេមក្សាន្តឥតទុក្ខភ័យ ។
ទី៣– នាំកូនរៀនសិល្បសាស្ត្រ | ឲ្យចេះដឹងច្បាស់ទាំងប្រុសស្រី
រៀនទាំងផ្លូវធម៌ផ្លូវលោកិយ | កុំឲ្យសល់អ្វីសព្វវិជ្ជា ។

ទី៤– ត្រូវរៀបកូនប្រុសស្រី ឲ្យមានស្វាមីឬភរិយា
សមគួរដល់ជាតិធនវ័យភ កុំឲ្យខុសគ្នាតាំអភ័ព្វ ។
ទី៥– ត្រូវបែងចែកធនធាន តាមដោយខ្លួនមានឲ្យគួរគាប់
ឲ្យកូនបានធ្វើជាដើមទ្រព្យ ជាកេរ្តិ៍គួរគាប់បំផុតអើយ ។

## ច្បាប់កូនប្រតិបត្តិមាតាបិតា ៥ យ៉ាង

ទី១– ត្រូវចិញ្ចឹមរក្សា មាតាបិតាដោយតបគុណ
ដែលលោកធ្វើមកលើខ្លួនមុន ចូរកុំភ្លេចគុណធ្ងន់នោះឡើយ ។
ទី២– បើលោកមានការងារ ត្រូវជួយធ្វើការលោកឲ្យហើយ
បើការស្ទួនគួរជួយឲ្យស្បើយ ឬជួយឲ្យហើយក៏គួរគាប់ ។
ទី៣– រក្សាវង្សត្រកូល ចងបាច់ប្រមូលគ្នាឲ្យជាប់
ទោះមានទោះក្រត្រូវតែរាប់ រក្សាជាតិទ្រព្យកុំឲ្យបាត់ ។
ទី៤– បើបានទ្រព្យធនធាន ដែលលោកឲ្យទានកុំឲ្យខ្ចាត់
ធ្វើខ្លួនឲ្យគួរដល់សម្បត្តិ មតិកលោកបាត់ចែកមកឲ្យ ។
ទី៥– ត្រូវធ្វើបុណ្យជូនផល ផ្សាយជូនទៅដល់លោកញយ៉ម
ទោះរស់ទោះស្លាប់ត្រូវធ្វើឲ្យ កុំភ្លេចគុណ ឡើបរណាកូនអើយ ។

## ច្បាប់គ្រូអាចារ្យសង្គ្រោះសិស្ស៥ យ៉ាង

*បទព្រហ្មគីតិ*

១– ខ្លួនខ្មានប្រដៅ សិស្សដែលទៅរៀនធម៌
ចេះច្បាប់រៀបរយល្អ ការណាក្រឲ្យភាងវៃ ។
២– ឲ្យសិស្សសិក្សា ដោយភាពដ៏ប្រពៃ
បង្ហាត់ឲ្យឈ្លាសវៃ ឲ្យយល់ន័យសព្វវិជ្ជា ។
៣– ឲ្យសិស្សសិក្សា សិល្បសាស្ត្រផងនានា
ឲ្យចេះគ្រប់វិជ្ជា កុំភាំងភឬលាក់ទុក ។

៤— បើអាមាត្យ គ្រូ　　　មានមកជិតត្រូវលើកទុក
ថ្លែងគុណ៖ ស្បូសូមសុខ　　　ឲ្យគេទុកចិត្តជឿបាន ។
៥— ប្រាប់អក្ខរវិជ្ជា　　　ធ្វើការពារសព្វទិសស្ថាន
គេសួរសិស្សឆ្លើយបាន　　　មិនរំខានចិត្តសិស្សស្បើយ ។

## ប្រាប់សិស្សប្រតិបត្តិគ្រូអាចារ្យ ៥ យ៉ាង

១— ទទួលដំណើរ　　　ឬជូនដើរត្រឡប់ទៅ
ទីឋានដែលលោកនៅ　　　នេះជាផ្លូវត្រូវគួរសម ។
២— ចូលទៅបំរើ　　　តាមកាលធ្វើឲ្យឧត្តម
បោសឋានបំរើធំ　　　លោកនិយាយយកពេលបី ។
៣— ជឿស្តាប់ពាក្យគ្រូ　　　កុំឲ្យទូកើតអប្រិយ
ឧបទេសសំដី　　　ត្រូវតែប្រកាន់ហ្មត់ចត់ ។
៤— បំរើប្រព្រឹត្តិ　　　ធ្វើការអ្វីតកំណត់
ពេលណាមិនប្រាកដ　　　នេះជាបទបំរើគួច ។
៥— លោកប្រាប់សិល្បសាស្ត្រ　　　ស្តាប់ឲ្យច្បាស់ធ្វើឲ្យខ្ជាប់
រក្សាកុំឲ្យខូច　　　ទាំងធំតូចត្រូវគោរព ។

## ប្រាប់ស្វាមីសង្គ្រោះភរិយា ៥ យ៉ាង

១— រាប់អានភរិយា　　　ដោយវាចាទន់ភ្លន់
បើពោលទៅប្រពន្ធ　　　ពាក្យនោះទន់គួរជាប់ចិត្ត ។
២— មិនមានមើលងាយ　　　មិនជេរវាយដោយអាណាកិត
បេះដូងរក្សាចិត្ត　　　ដោយអាណិតនាងភរិយា ។
៣— មិនបានក្បត់ចិត្ត　　　ទៅប្រព្រឹត្តស្រីនានា
ពាធះដោយល្បែងពាល　　　ឲ្យភរិយាក្តៅក្រហាយ ។
៤— បានប្រគល់យស　　　យ៉ាងខ្ពង់ខ្ពស់ឲ្យសប្បាយ
យសស្រីផងទាំងឡាយ　　　គំទ្រល់ខ្ចាយជើងក្រានថ្នាំង ។

៥— ផ្គាក់ផ្គង់ប្រដាប់ មានសម្រាប់យ៉ាងសម្រាំង<br>
គ្រឿងអប់គ្រឿងតែងតាំង តាមកំលាំងធន់ខ្លួនអើយ ។

## ច្បាប់ភរិយាប្រតិបត្តិស្វាមី ៥ យ៉ាង

១— ចាត់ចែងការងារ ឥតរួញរាដោយផ្ចិតផ្ចង់<br>
ចាយព្រឹកចាយថ្ងៃត្រង់ មិនបង្អង់ខុសវេលា ។

២— ពួកញាតិស្វាមី ទាំងប្រុសស្រីក្មេងវ័ន្លា<br>
សង្គ្រោះស្មើមុខគ្នា ដូចញាតិការខ្លួនស្មោះស្មើ ។

៣— ចេះថែទាំទុក ទ្រព្យដោយមុខតាមដំណើរ<br>
ទ្រព្យអន់ទ្រព្យប្រសើរ ប្រសិនបើស្វាមីឲ្យ ។

៤— មិនបានប្រព្រឹត្ត កន្លងចិត្តស្វាមីឡើយ<br>
ដោយប្រុសដទៃហើយ ដែលនាំឲ្យកើតអន់អាក់ ។

៥— ឈ្លាសព្រមក្នុងការ ហើយឧស្សាហ៍ធ្វើឥតស្រាក់<br>
ជាស្រីវៃគ្រប់ថ្នាក់ មិនមានទាក់ទើសទាល់ឡើយ ។

## ច្បាប់កុលបុត្រសង្គ្រោះមិត្រ ៥ យ៉ាង

១— ឲ្យទ្រព្យគ្នាឲ្យ មិត្រញយៗ ដោយចិត្តជា<br>
ឥតមានគិតរួញរា ស្រឡាញ់គ្នាដោយចិត្តស្មោះ ។

២— បើពោលវាចា ពោលពាក្យណាដែលពីរោះ<br>
រាប់រកគ្នាឥតឈ្លោះ ហើយសង្គ្រោះរក្សាចិត្ត ។

៣— បានធ្វើប្រយោជន៍ គិតយ៉ាងហោចឲ្យដល់មិត្រ<br>
បើមានការជួយគិត ឲ្យតែមិត្របានប្រសើរ ។

៤— បានធ្វើខ្លួនប្រាណ ជាអ្នកមានចិត្តស្មោះស្មើ<br>
មិនមានកិច្ចសើរើ តាមដំណើរមិត្រកល្យាណ ។

៥— មិនក្លែងកុហក ពាក្យអាក្រក់ពាចសាមាន្យ<br>
ឲ្យមិត្រកើតរំខាន ទោះមិនបានពោលសោះឡើយ ។

## ច្បាប់មិត្រប្រតិបត្តិកុលបុត្រ ៥ យ៉ាង

១– កុលបុត្រប្រមាទ　　មិនសំអាតអង្គអាត្មា
　ភ្លាត់កាយភ្លាត់វាចា　　ជួយរក្សាក្តីវិបត្តិ ។
២– បានជួយការពារ　　ជួយរក្សាជួយប្រយ័ត្ន
　បើធ្វេសក្នុងសម្បត្តិ　　ជួយប្រយ័ត្នយ៉ាងមុះមុត ។
៣– បានធ្វើទីពឹង　　ជាពុំនឹងដល់កុលបុត្រ
　គ្រាមានភ័យតក់ស្លុត　　មិនរន្ធត់រត់ចោលគ្នា ។
៤– មិនបានលះបង់　　យកតែអង្គឯកអាត្មា
　វិបត្តិជួយរក្សា　　ក្នុងគ្រាណាដែលតក់ស្លុត ។
៥– រាប់អានកូនចៅ　　នូវអស់ដោយពង្សកុលបុត្រ
　ដោយចិត្តស្នេហាផុត　　ត្រកូលបុត្រគិតសល់ឡើយ ។

## ច្បាប់ចៅហ្វាយនាយសង្គ្រោះទាសកម្មករ ៥ យ៉ាង

១– ដាក់មុខការឲ្យធ្វើ　　តាមអំពើនិងកំលាំង
　លៃលកតាមខ្សោយខ្លាំង　　ហើយសមតាំងឲ្យទទួល ។
២– ឲ្យបាយអាហារ　　នឹងថ្លៃការដល់ពួកឈ្នួល
　មិនបានកែកាត់មួល　　ឲ្យតាមគួរបេ្តជ្ញា ។
៣– បើមានឈឺចាប់　　ស្ទុះប្រញាប់ទៅមើលម្នា
　ជួយមើលថែភេសា　　រក្សាគ្នាមិនលះបង់ ។
៤– បានចែកអាហារ　　ឆ្ងាញ់ពិសាល្អផ្ទុំពន្លំ
　បំពេញតាមបំណាន់　　គ្រប់រូបអង្គពិតរូញរា ។
៥– ឲ្យឱកាសឈប់　　សម្រាកគ្រប់កាលវេលា
　គួរតាមសម័យភា　　ដែលមានការត្រូវឈប់អើយ ។

## ច្បាប់ទាសកម្មករប្រតិបត្តិចៅហ្វាយនាយ ៥ យ៉ាង

១— ក្រោកឡើងចំធ្វើ    ការសំពើផងនានា
មិនបាច់ចាំតៀនថា    ទៅធ្វើការកំមុននាយ ។
២— ពេលឈប់ធ្វើការ    គល់វេលាក្រោយចៅហ្វាយ
របស់ផងទាំងឡាយ    ចេះខ្វល់ខ្វាយយកទុកដាក់ ។
៣— យកតែទ្រព្យណា    នាយអាណាឲ្យស្មោះស្ម័គ្រ
មិនបានយកលួចលាក់    ធាំឲ្យទាក់កើតទោសទុក្ខ ។
៤— បើធ្វើការណា    ចិត្តឧស្សាហ៍ចង់បានសុខ
ផ្ចិតផ្ចង់ប្រឹងពេញមុខ    យកចិត្តទុកដាក់ក្នុងការ ។
៥— ប.នតាំគុណនាយ    ទៅទីឆ្ងាយពោលវាចា
សរសើរនាយអញ្ញា    ប្រាប់គេថាល្អណាស់អើយ ។

## ច្បាប់សមណព្រាហ្មណ៍សង្គ្រោះគ្រហស្ថ ៦ យ៉ាង

១ — ការណាជាបាប    ត្រូវប្រាមប្រាប់ហាមត្រឹមមុខ
ព្រោះជាកម្មនាំទុក្ខ    កុំទៅមុខមានវេរា ។
២ — ការជាកុសល    ជួយនាំផ្តល់ផ្តើមសទ្ធា
សាងទានសីលភាវនា    ដើម្បីជាទីពឹងប្រាណ ។
៣ — បានជួយសង្គ្រោះ    ចិត្តចំពោះធម៌កល្យាណ
មិនធ្វើឲ្យវិនាស    ជួយប្រោសប្រាណដោយស្មោះសរ ។
៤ — បើមិនដែលស្តាប់    នូវស្នូរស័ព្ទធម៌បវរ
ដឹកនាំឲ្យស្តាប់ធម៌    ណាដែលល្អប្រសើរគាប់ ។
៥ — ជួយប្រាប់ពន្យល់    ធម៌ដែលធ្លល់ឲ្យយល់ជាប់
ធម៌ណាដែលធ្លាប់ស្តាប់    ក៏ជួយប្រាប់ឲ្យយល់ឆ្ងាយ ។
៦ — ជួយប្រាប់ផ្លូវធម៌    ណាដែលល្អកើតសប្បាយ
ឲ្យបានផលទាំងឡាយ    ស្តាប់បរិយាយនៃខ្លួនអើយ ! ។

# ច្បាប់គ្រហស្ថប្រតិបត្តិសមណព្រាហ្មណ៍ ៥ យ៉ាង

១ — មានកាយកម្ម ប្រកបព្រមដោយមេត្តា
បានយកកាយអាត្មា ជួយធ្វើការជាប្រក្រតី ។
២ — មានវចីកម្ម ប្រកបព្រមដោយមេត្រី
បើពោលពាក្យសំដី គួរគប្បីកើតស្នេហា ។
៣ — មានមនោកម្ម ប្រកបព្រមដោយមេត្តា
តាំងនៅក្នុងចិត្តា តែងជ្រះថ្លាក្រាបសំពះ ។
៤ — មានចិត្តសទ្ធា មិនបិទទ្វារបង្អួចផ្ទះ
ធនធានមានហើយលះ ដោយចិត្តជ្រះថ្លាធ្វើទាន ។
៥ — ឧបត្ថម្ភទុក ត្រៀងគ្រប់មុខការស្រេកឃ្លាន
អាមិសដែលខ្លួនមាន លះធ្វើទានឥតអាក់ឡើយ ។

## មិត្តាមិត្តកថា

សំដែងអំពីបាបមិត្រ គឺមិត្រអាក្រក់ និងកល្យាណមិត្រ គឺមិត្រ
ល្អ ឯបាបមិត្រ មិត្រអាក្រក់នោះ គោលដើមមាន ៤ ពួកដូច្នេះ:

### បទពាក្យប្រាំពីរ

១— មិត្រគិតតែពីចង់បាន របស់ធនធានអំពីមិត្រ
ប្រយោជន៍ខ្លួនឯងចេះតែគិត ប្រយោជន៍ខាងមិត្រឲ្យខាតបង់ ។
២ — មិត្រល្អត្រឹមតែវាចា បើពោលពាក្យណាឥតពិតត្រង់
មាត់ឲ្យទ្រព្យមិត្រចិត្តឥតចង់ គេបកែអែអង់ឥតបានឲ្យ ។
៣ — មិត្របានខាងតែអែបអប ចុះឥរិយាយប្រាប់ជាក់បណ្ដោយ
ប្រចុចឲ្យមិត្រមានឫស់ឡោយ ធ្លាក់យសសក្តិដោយសំដីខ្លួន ។

៤– មិត្រនាំឲ្យកើតអន្តរាយ ទ្រព្យធនទាំងឡាយបង់ខ្លួន ។
វិនាសព្រមទ្រព្យឬជីវិតខ្លួន ដោយក្ដីចូលបង្គប់មិត្របាប ។
មិត្រ ៤ ពួកនេះមិនមែនមិត្រ ត្រូវកុំនៅជិតជាដរាប
តែចូលទៅជិតនឹងជាប់បាប ខ្លួននឹងជួបជាប់អន្តរធាន ។

ឯមិត្រ ៤ ពួកនេះ ក្នុងមិត្រមួយៗ បែកជាបួនៗ តទៅទៀត

(ក) មិត្រគិតតែពីបង់បាន មាន ៤ ពួកគឺ

១– មិត្រគិតតែពីបង់បាន ប្រយោជន៍ផ្ទាល់ប្រាណគេឥតគិត
២– ឲ្យតិចយកច្រើនអំពីមិត្រ ដោយមានគំនិតគិតរុករួន ។
៣– បើមានភ័យទើបចេញមុខ ជួយការមិត្រទុកឲ្យជួយខ្លួន
៤– គប់ជាមិត្រគិតរុករួន រកប្រយោជន៍ខ្លួនឲ្យបានច្រើន ។
មិត្រ ៤ ពួកនេះមិត្របង់បាន ប្រយោជន៍ផ្ទាល់ប្រាណគិតចំរើន
ចូរចាំភាសិតច្រើនក្រើន រំឭកដាស់តឿនកុំភ្លេចឡើយ ។

(ខ) មិត្រល្អត្រឹមតែវាចា មាន ៤ ពួកគឺ

១– ជួបមុខមិត្រពោលវាចា ថាខ្លួនប្រាថ្នាឲ្យរបស់
២– ពោលតែមាត់ឥតសប្បុរស ថាឆ្នាំនេះអស់ចាំឆ្នាំក្រោយ ។
៣– បើមិត្រធ្វើអ្វីៗណា ក៏ពោលវាចាចាក់បណ្ដោយ
៤– ល្អត្រូវមុខអាក្រក់ក្រោយ មិត្រនេះនាំឲ្យថ្លស់អស់ខ្លួន ។
មិត្រទាំង ៤ នេះល្អតែមាត់ ចិត្តឥតទៀងទាត់អត់ក្ដីស្មូន
កុំទៅសេពគប់នៅជួបជួន នាំឲ្យថ្លស់ខ្លួនខ្លួនអសារ ។

(គ) មិត្របានខាងឯបែបអប មាន ៤ ពួកគឺ

១– បើមិត្រធ្វើអំពើបាប ក៏ព្រមហើយប្រាប់ថាត្រូវហើយ
២– បើធ្វើបុណ្យគាំពោះតើយ ក៏ថាល្អហើយត្រូវធ្វើទៅ ។

៣ — សរសើរគុណមិត្រទៅមុខ    ធ្វើហាក់រួមទុក្ខសុខពេកក្រៃ
៤ — និយាយដើមកេរ្តិ៍អាស្រូវ    ក្នុងពេលមិត្រទៅបាត់ពីមុខ ។
មិត្រទាំង ៤ នេះមិនមែនមិត្រ    កុំឈមឈរជិតនាំមានទុក្ខ
មានទោសដល់ខ្លួនឥតបានសុខ    ត្រៀបផ្ចិតផ្ចង់ផុតត្រូវវៀរចេញ ។

## (ឃ) មិត្រនាំឲ្យអន្តរាយមាន ៤ ពួកគឺ ៖

១ — មិត្រនាំឲ្យផឹកសុរា    ដែលជាហេតុការណ៍កើតឧបទ្រព
២ — មិត្រនាំឲ្យដើរលេងយប់    តាមច្រកល្ហកគ្រប់ទីកន្លែង ។
៣ — មិត្រនាំដើរមើលមហោស្រព    នាំឲ្យខ្លួនជាប់ចិត្តក្នុងល្បែង
៤ — មិត្រនាំខ្លួនដើរស្វះស្វែង    ទៅរកលេងល្បែងភ្នាល់ស៊ីសង ។
មិត្រ ៤ ពួកនេះមិនមែនមិត្រ    សេពគប់ខូចចិត្តខាតទ្រព្យផង
កុំរួមសុខទុក្ខខុសបំណង    បំណាច់ខ្លួនប៉ងយកសុខហើយ ។

# កល្យាណមិត្រ មិត្រល្អគោលដើមមាន ៤ ពួក

## បទពាក្យប្រាំពីរ

១ — មិត្រមានឧបការៈ    គឺមិត្រជាអ្នកជួយឧបត្ថម្ភ
បើខ្លួនភ្លាត់ភ្លាំងក្នុងបាបកម្ម    រំឭកឲ្យចាំជាក់ទៀងបាន ។
២ — មិត្ររួមរួមក្តីសុខទុក្ខ    គឺមិត្រចេញមុខមកផ្ទាល់ប្រាណ
ជួយរក្សាខ្លួនសព្វភូមិឋាន    ហៅមិត្រកល្យាណរកបានក្រ ។
៣ — មិត្រណែនាំប្រាប់ប្រយោជន៍    ច្រើនតិចដោយហោចឲ្យតែល្អ
ប្រយោជន៍ផ្លូវលោកឬផ្លូវធម៌    មិត្រនេះរកក្រកំដរខ្លួន ។
៤ — មិត្រមានក្តីអនុគ្រោះ    ចិត្តស្មោះចំពោះពេញបំពួន
បានជួយស្រោចស្រង់សង្គ្រោះខ្លួន    មិត្រមានក្តីស្ងួនយ៉ាងចំណាប់ ។
មិត្រ ៤ ពួកនេះចំណានល្អ    ត្រឹមត្រូវតាមធម៌មិត្រពេញច្បាប់
បើមានទីណាគួរប្រញាប់    យកជាមិត្រជាប់កុំខានឡើយ ។

## លក្ខណមិត្រ ៤ ពួក

### ក) ក្នុងមិត្រមួយៗ ចែកជាបួនៗ តទៅទៀត

១– បើឃើញមិត្រភ្ញាក់ភ្ញាំងកាយ ចូលមកខ្វល់ខ្វាយថែរក្សា
២– បើមិត្រធ្វេសក្នុងទ្រព្យណា នោះជួយរក្សាទ្រព្យមិត្រឲ្យ ។
៣– បើមិត្រមានភ័យតក់ស្លុត ក៏មិនបានរត់ចោលគ្នាឡើយ
៤– មិត្រត្រូវការរកទ្រព្យហើយ គ្មានគេចកែឡើយយកឲ្យមិត្រ ។
មិត្រទាំង ៤ នេះមិត្រប្រសើរ មានហើយគួរដើរចូលទៅជិត
រាប់អានស្រឡាញ់គ្នាយ៉ាងស្និទ្ធ យកធ្វើជាមិត្រកុំខានឡើយ ។

### ខ) មិត្ររួមសុខទុក្ខមាន ៤ ពួកគឺ:

១– ប្រាប់ការណ៍កំបាំងជិត ដល់ជនជាមិត្រឲ្យដឹងផង
២– បិទការណ៍ដែលមិត្របាន ប្រាប់ដល់ខ្លួនប្រាណប្រុងការពារ ។
៣– បើការក្រមានដល់មិត្រ មិនមានគំនិតលះបង់គ្នា
៤– បានចេញមុខជួយការពារ ប្ដូរសាច់ឈាមគ្នាប្រយោជន៍មិត្រ ។
មិត្រទាំង ៤ នេះមិត្រមាំមួន គួរតែងប្ដូរខ្លួនប្ដូរជីវិត
យកធ្វើជាមិត្រយ៉ាងជិតស្និទ្ធ ថែរក្សាចិត្តគ្នាទើបហោង ។

### គ) មិត្រណែនាំប្រាប់ប្រយោជន៍មាន ៤ ពួកគឺ:

១– ហាមមិត្រខ្លួនមិនឲ្យធ្វើ នូវកម្មអំពើជាបាប
២– នាំឲ្យធ្វើបុណ្យទាន ដែលជាអំពើបុណ្យកុសល ។
៣– បាននាំស្ដាប់ធម៌ទេសនា ដែលមិត្តអាត្មាមិនដែលស្ដាប់
៤– ប្រាប់ផ្លូវសួគ៌ផ្លូវមគ្គផល ឲ្យបានដឹងដល់ពួកមិត្រនោះ ។
មិត្រទាំង ៤ នេះមិត្រថ្លាថ្លៃ មិត្រប្រសើរក្រៃជួយសង្គ្រោះ
ណែនាំប្រយោជន៍យ៉ាងខ្ពង់ខ្ពស់ គួរសេពមិត្រនោះកុំខានឡើយ ។

### ឃ) មិត្តមានសេចក្ដីអនុគ្រោះមាន ៤ ពួកគឺ:

១– ឮថាមិត្របង់របស់ ចិត្តគ្មានសោមនស្សត្រេកអរឡើយ
២– ឮថាមិត្រចំរើនហើយ ចិត្តគ្មានកន្ដើយជួយត្រេកអរ ។
៣– បានហាមមនុស្សថ្លែងទោសមិត្រ មិនឲ្យប្រព្រឹត្តនិយាយក
៤– សរសើរគេថាចិត្តល្អ ដែលឮគេសរសើរគុណមិត្រ ។
មិត្រទាំង ៤ នេះមានសង្គ្រោះ គួរស្មោះចំពោះអស់ពីចិត្ត
ត្រូវបងស្នេហាឲ្យបានស្និទ្ធ យកធ្វើជាមិត្រតទៅហោង ។

ចប់កល្យាណមិត្រតែប៉ុណ្ណេះ ។

## អបាយមុខ ធម៌ជាប្រធាននៃសេចក្ដីវិនាស ៦ យ៉ាង

### បទពាក្យប្រាំពីរ

១– ផឹកសុរាឬមេរ៉ៃ រឿយៗ សព្វថ្ងៃដែលជាបាប
ជាហេតុទីតាំងក្ដីប្រមាទ នាំឲ្យមិនស្អាតកើតឧបទ្រព ។
២– ដើរលេងយប់គ្រប់កន្លែង ស្វះស្វែងខ្វះខ្វែងដើរពិតយប់
តាមដោយច្រកល្ហកវេហាយប់ នាំខ្លួនឧបទ្រពកើតសៅហ្មង ។
៣– ដើរមើលល្បែងមហោស្រព នាំឲ្យខាតទ្រព្យខូចចិត្តផង
កុំកុំមើលល្បែងតែងសៅហ្មង- កើតទោសទុក្ខផងផល់អាត្មា ។
៤– បានលេងល្បែងភ្នាល់ស៊ីសង នាំចិត្តមួហ្មងកើតវេរ
ដោយទោសព្រោះលេងល្បែងនានា ជាហេតុពាលាធ្លាក់ទៅមុខ ។
៥– សេពគប់តែនឹងមិត្រពាល ដែលនាំឱនជាប់អន្លង់ឲ្យទុក្ខ
ឲ្យទោសច្រើនក្រៃតទៅមុខ ពុំដែលបានសុខខ្លួនសោះឡើយ ។
៦– ប្រកបខ្លួនក្នុងកិច្ចខ្ជិល ជាហេតុបង់លែងគ្រប់មុខហើយ
បានការ ហេតុនេះមានសើយ មិនការកែកទៅយជាឆ្ងាយ ។

# អបាយមុខ គោលដើម ៦ នេះ

ក្នុងអបាយមុខមួយៗ បែកជាប្រាំមួយៗ តទៅទៀត

## ក) ផឹកសុរាមេរ័យមានទោស ៦ យ៉ាង

| | |
|---|---|
| ១ — វិនាសអស់ទ្រព្យធនធាន | អ្នកផឹកស្រាបានឃើញភ្លែកឯង |
| ២ — កើតប្រកែកឈ្លោះទាស់ទែង | ចំរើនច្រើនស្តែងជាអនេក ។ |
| ៣ — បណ្តាលជារោគនានា | មានកើតឡើងជាងនឹកភ្លែក |
| ៤ — កើតនិន្ទាជាអនេក | គេត្មះតាមភ្នែកគេឃើញនោះ ។ |
| ៥ — កេរ្តិ៍ខ្មាសដែលខ្លួនធ្លាប់លាក់ | ក៏បង្ហាញដាក់ភ្នែកគេស្មេះ |
| ៦ — កំលាំងប្រាជ្ញាថមថយអស់ | នេះទោសរបស់អ្នកផឹកស្រា ។ |

## ខ) ដើរលេងយប់គ្រប់កន្លែង មានទោស ៦ យ៉ាង

| | |
|---|---|
| ១ — អ្នកដែលដើរលេងខុសកាល | មិនបានអភិបាលខ្លួនអាត្មា |
| ២ — អ្នកដើរលេងខុសវេលា | បុត្តភរិយាខានគ្រប់គ្រង ។ |
| ៣ — មិនបានថែរក្សាទ្រព្យ | នាំឲ្យអភ័ព្វកើតសៅហ្មង |
| ៤ — គេរង្កៀសនឹងខ្លួនផង | នាំមានសៅហ្មងច្រើនប្រការ ។ |
| ៥ — ពាក្យពោលក្លែងបង្កាប់ខ្លួន | ប្រកាន់តាមជួនមានហេតុណា |
| ៦ — មានទោសច្រើនប្រការ | ព្រោះតែអាត្មាដើរលេងយប់ ។ |

## គ) ដើរមើលល្បែងមហោស្រព មានទោស ៦ យ៉ាង

| | |
|---|---|
| ១ — មានលេងល្បែងរាំទីណា | ក៏ត្រាច់យាត្រាទៅទីនោះ |
| ២ — និងស្វះស្វែងដើរចំពោះ | ទៅទីណានោះមានចម្រៀង ។ |
| ៣ — មានប្រគំភ្លេងទីណា | ត្រាច់ចរយាត្រាទៅទីនោះ |
| ៤ — មានរឿងព្រេងស្វែងចំពោះ | ទៅទីណានោះស្តាប់រឿងព្រេង ។ |
| ៥ — ចម្រៀងទះដៃទីណា | នោះត្រាច់យាត្រាទៅមើលលេង |
| ៦ — បើឮស្គរស័ព្ទភ្លេង | គេលេងទីណាទៅទីនោះ ។ |

### ឃ) លេងល្បែងភ្នាល់ស៊ីសង មានទោស ៦ ប្រការ

១ – អ្នកឈ្នះល្បែងតែងអួតយក ទ្រព្យធនគេមកពីកោតក្រែង
២ – អ្នកលេងចាញ់លង់ក្នុងល្បែង នោះនឹងស្វះស្វែងចងពៀរទុក ។
៣ – វិនាសអស់ទ្រព្យធន អ្នកលេងគង់គន់ឃើញទុក្ខមុខ
៤ – ពាក្យអ្នកលេងគេមិនទុក ចិត្តយកជាមុខស្មរបន្ទាល់ ។
៥ – មិត្រដែលគេមិនលេងល្បែង គេលះបង់ឯងលែងធ្វើស្គាល់
៦ – ពួកអ្នកលេងល្បែងភ្នាល់ លុះដល់ខ្លួនកាលហើយលួចលាក់ ។

### ង) សេពគប់តែនឹងមិត្របាប មានទោស ៦ យ៉ាង

១ – អ្នកលេងល្បែងស៊ីសង ចូលចិត្តតែចងមិត្រពួកល្បែង
២ – អ្នកល្បែងស្រីរកគ្នាឯង ជាអ្នកលេងល្បែងស្រីផ្ទួនគ្នា ។
៣ – ពួកអ្នកលេងល្បែងស៊ីផឹក គប់រកប្រមឹកស្រាពាលា
៤ – អ្នកឆបោកជននានា គប់ក៏រកគ្នាអ្នកបោកក្លែង ។
៥ – អ្នកក្លែងបោកចំពោះមុខ យកចិត្តដាក់ទុកនឹងគ្នាឯង
៦ – អ្នកដក់បរកទ្រព្យស្ដែង រិតទំខ្ទះខ្វែងគប់រកគ្នា ។

### ច) ប្រកបខ្លួនក្នុងកិច្ចខ្ជិល មានទោស ៦ យ៉ាង

១ – មិនធ្វើការដោយអាងថា ពេលនេះរងាខ្លាំងពេកណាស់
២ – បើថ្ងៃក្ដៅមេឃស្រឡះ ក៏ថាក្ដៅណាស់ត្រូវតែឈប់ ។
៣ – ថាពេលនេះល្ងាចពេកហើយ កុំអាលធ្វើឡើយក្រែងលោយប់
៤ – ថាព្រឹកពេកបង្អង់ឈប់ ចាំល្ងាចព្រលប់សឹមកងើយ ។
៥ – ថាឃ្លានពេកត្រូវស៊ីសិន ឥឡូវបាយឆ្អិនកុំកន់ឡើយ
៦ – ស្រេកពេកចាំផឹកហើយ កុំប្រញាប់ឡើយធ្វើការនេះ ។

ចប់អបាយមុខ ៦ ប្រការប៉ុណ្ណេះ ។

កាំពួលកាំសត់

# លោកហាន់-យេង តែងនិងរៀបរៀង

(តមក)

## បទទី ១១

## សាលី យំសោក

លុះនាងហុតបបរមានទឹកឡាំងកំហែងហើយ ទើបនាងអង្វរឪពុកឲ្យជូនទៅឯផ្ទះបងចិញ្ចឹមរបស់នាង ព្រោះនាងសទ្ធិះក្នុងចិត្តណាស់ ក្រែងមានគ្រោះថ្នាក់ធ្លាក់ដល់សុកិន្ទ្រ ទើបពីរនាក់ឪពុក-និងកូនចុះពីលើផ្ទះមកតាំងព្រលឹមស្រាង ៗ ដើរតាមផ្លូវងងឹតឃើញព្រឹល ៗ បុប្ផានានាកែកយពេញតាំងសួនត្រជាក់ដោយដំណក់សន្សើម បង្ហោនខ្ទង់មកយ៉ាងគោរពប្រាថ្នាឲ្យនាងបេះ តែនាងបេះតែដើរទៅគ្មានចិត្តគិតដល់ផ្កាតាំងនោះទៀយ ប្រឹងដើរឲ្យលឿនរត់បណ្តើរផង ព្រោះគិតដល់បងខ្លាំង ៗ

ដល់មាត់ទ្វារបងផ្ទះសោកិត ក្រឡេកទៅឃើញបង្អួចបន្ទប់សុ-កិន្ទ្របំហា នាងក៏ភ័យរន្ធត់រត់យ៉ាងលឿនចូលទៅស្រាប់តែឃើញពនមនុស្សដេកស្ដឹងស្ដូកផ្កាប់មុខលើគ្រែបពី នាងក៏ធ្លាក់ថ្លើមក្ដុក ស្រែកទីងខ្យល់ចាប់លាំផ្លូលទៅត្រង់ណោះក៏លុតជង្គង់ចុះ! បើកមុខអ្នកនោះមើលឱពុទ្ធោភម្ចាស់អើយ! សុកិន្ទ្របងនាងទេតើ នាងក៏លូកដៃទុបបងចិញ្ចឹមរន្ធត់ញាប់ញ័រអស់តាំងអង្គប្រាណអាក់អួលរំជួលខ្លាំងបផ្សា ហៀបទឹងចំលាយសន្ធារបាកលោកទៅ រួចក៏ខ្សែកខ្សួលយំរៀបរាប់ថា:

"ឱបងអើយ ម្ដេចបងមកចាកចោលប្អូនទៅឥតស្រណោះយ៉ាងនេះ ពីព្រឹកមិញយើងប្រឡែងគ្នាលេងទេតើ បងបាននិយាយមករកប្អូន បានប្រឹងស្ដាប់ពាក្យប្អូនឆ្លើយតបទៅវិញ ម្ដេចឥឡូវបងបាត់ស្ងាត់មិននិយាយស្ដី មិនបើកភ្នែកមើលប្អូនផង មិនញញឹមមករក ប្អូននិយាយយ៉ាងណាក៏មិនឮ គួរឲ្យទេវតាអើយ!" ។

នាងយំសោកសំរក់ទឹកភ្នែកជាច្រើន យកដៃអង្រួនខ្លួនបងហើយស្រែកថា "បងអើយបង"!! ក្រោកឡើងកុំសំកុកដួយពេក មិនអាណិតប្អូនផងទេឬ មិនឮប្អូនហៅទេឬអ្វី បងស្រដីមករកប្អូនបានមួយមាត់ផងមើល ... ឱ ... ព្រះឥន្ទ្រអើយ ជួយប្រោសបងខ្ញុំឲ្យរស់ឡើងវិញ ។

អ្នកជិតខាងឮនាងសាលីយំទួញថ្ងូរតាំងព្រលឹមដូច្នោះ ក៏ទ្រាំមិនបានចុះចាកឋានមក លុះឃើញភាពគួរអនិច្ចាហើយ ក៏អត់សង្វេគពុំបានសឹងយំទាំងអស់គ្នា អាណិតដល់ក្មេងកំព្រាទាំងពីរនាក់ ទំជួយបន់ស្រន់អារក្សទេព្វរក្សអ្នកតា ឲ្យមេត្តាចុះមកជួយប្រោសស្រង់ជីវិតកុមារទាំងពីរនោះផង ។

ចំណែកសោភិតភ្ញាក់ឡើងចេញមកក្រៅ ឃើញទ្វារចំហក៏ភិតភ័យចុះមកដី ឃើញប្អូនដេកស្ដូកស្ដឹងដូចកំណាត់ឈើ ទឹកអាណិតខ្លោចចិត្តអត់ទ្រាំស្រក់ទឹកភ្នែកទឹងសំដីនាងសាលីពុំបានកើតទុក្ខប្រាកដឆាំមាត់

មិនទិយាយស្តី ព្រោះពេលនោះគាត់ហៀបនឹងដាច់ខ្យល់ដែរ ដោយសោយសេ្នហ៍ទឹកឃើញគ្រប់សព្វ ។

អ្នកទាំងអស់គ្នានៅទីនោះ ឈរទ្រើងពុំហ៊ានមាត់ក ខ្វះក៏យកក្រមាជូតទឹកភ្នែកទឹកសំបោរ ញើសតិចៗ មិនឲ្យឮខ្លាំង ម៉្លោះហើយអាកាសក្រង់ណោះក៏ស្ងាត់ព្រៀបគួរបម្បែរចិត្ត ឮសូរតែសំឡេងនាងសាលីអណ្តឺតអណ្តកលើទ្រូងបងចិញ្ចឹម យូរៗ ងើបឡើងរៀបរាប់ថា "នេះហេតុតែកម្មផងខ្ញុំ បានជាបងអាយុខ្លីដូច្នេះ ទឹកថានឹងបានសុខផងគ្នា ទុកជាកើតទុក្ខក៏ស៊ូទុកជាមួយ ឥឡូវបងមកស្លាប់ចោលខ្ញុំទៅដូច្នេះ សា-លីនឹងរស់ទៅទៀតមិនបានទេ បងកិទ្រអើយ មក...មក យកសាលីទៅជាមួយផង ណាណាកិទ្រណា !!

ហើយនាងក៏បោកខ្លួនលើសុកិទ្រកុមារ ដែលត្រូវអន្ទ្រីនយ៉ាងខ្លាំងដូច្នោះ គួរឲ្យអស្ចារ្យណាស់ ស្រាប់តែបើកភ្នែកឡើងញញឹមកេបួនរបស់ខ្លួន នាងសាលីឃើញដូច្នោះក៏ត្រេកអរ លោតបកបង់យ៉ាងសប្បាយស្រែកថា "បងដឹងខ្លួនមានជីវិតឡើងវិញហើយ" អ្នកឯទៀតក៏យំឡើងព្រមគ្នាដោយសេចក្តីត្រេកអរ មានមុខញញឹមញញែមមករកគ្នា ។

ពេលនោះ ក្តារក្រាលផ្ទះរំពង់ឡើងដោយសូរជើងដើរ គឺសុវណ្ណ-បុប្ផារត់ចុះមកប្រញាប់ប្រញាល់ សស្ទើតសស្ទក់ដំរង់រកប្តីនិយាយមិន

ចង់ចេញ "អូក ! បងអើយ ចោរវាលួចអីវ៉ាន់យើងអស់ពីខ្ទូរលើងទៅហើយ" រួចក៏គក់ដើមទ្រូងជាទុក្ខ អ្នកឯទៀតជិតផ្ទះនោះក៏នាំគ្នាថយចេញទៅ ឯនាងសាលីក៏ភ័យខ្ទត់ដោះដៃពីចង រត់ទៅរកឪពុកនាំគ្នាវិលទៅផ្ទះវិញដោយសេចក្ដីក្ដៅចិត្ត ។

រីឯសុកិន្ទ្រខំប្រឹងក្រោកឡើង តែស្រពន់អស់កំលាំងខ្លួនប៉ុណ្ណាដើរមិនរួច ឈឺក្បាលឆេងឆោងចាប់ពើតដូចជាគេដំទីងញញួរ ទើបបោលក្រឡេកមើលបរិវេណខ្លួន ក៏ដឹងថាកំពុងដេកលើពូកគង់លើខ្នើយជាច្រើនរបស់ទ្រព្យមានដំឡៃរាយប៉ាយនៅជិតនោះ ទាំងនេះគឺស្នាដៃចោរចង្រៃក៏ឡើងតាមបង្អួចចូលទៅរើអីវ៉ាន់ លុះដល់ព្រួសសុកិន្ទ្រក្រោកទាន់ក៏រត់ត្រង់ជើងទៅ ដល់ព្រួសមនុស្សធ្លាក់ពីលើផ្ទះមកទៀត ក៏ខ្លាចនាំគ្នារត់ទៅតែដៃទទេរៀងខ្លួន ដូចមានដើមផ្កាបាក់ជាឡាក់ហានស្រាប់ដោយហេតុតែមានពូកខ្នល់ខ្នើយគរក្រោមបង្អួចនោះឯង បានជាសុកិន្ទ្ររួចជីវិតមិនស្លាប់ក្នុងគ្រានោះ តែអ្នកផងគ្នាមិនបានមើលថាជាអ្នកចង់សម្លាប់ខ្លួនទេ គេស្មានជាចោរមកដេញចោរលួចនោះឯង ។

បិតាពេញចិត្តណាស់ក៏ចូលទៅត្រកងបី ទើបមុខបបក់ព្រលឹងកូនប្រុសហើយលើកឡើងទៅលើផ្ទះ រកថ្នាំឲ្យកូនផឹករួចដាក់កូនឲ្យដេកស្រួលបួល បានចុះមកនាំប្ដីប្រពន្ធសែងរបស់យកទៅទុកកន្លែងដើមវិញ ដល់កូនយំស្រណោះបាឲ្យកូនផ្ដៅ អស់កំឡាំងមួយមៅស្រែកហៅប្ដីឲ្យដាស់

កូនដើមឡើង ទើបប្រើវាឲ្យជួយជញ្ជូនអីវ៉ាន់ដាក់លើផ្ទះ តែស្វាមីពុំព្រម ដោយយល់ឃើញថា កូនច្បងរបស់ខ្លួនវាមិនសូវស្រួល សុវណ្ណបុប្ផាខឹងញ័រសាច់ឆ្លើយមកវិញថា "ល្អហើយបង-យ៉ាងហ្នឹង ផ្ដេកផ្ដិតឯណាផងបាន បើបងមិនមូលចិត្តគំនិតខ្ញុំផងនោះ ខ្ញុំចុះចេញពីផ្ទះនេះមួយរំពេច នៅជាមួយគ្នាធ្វើម្ដេចបាន បើគេមិនស្ដាប់ពាក្យបន្តិចបន្តួចសោះ" ។

សោភិតកើតទោសៈពេញខ្លួនក៏បញ្ជូនពាក្យឲ្យ "អើបើឯងចង់ទៅណាទៅចុះ បងមិនយល់ពាស់ទេ ស្រេចនឹងចិត្តឯង" ។

សុវណ្ណបុប្ផាឮដូច្នោះ ក៏ស្ទុះចូលទៅក្នុងបន្ទប់ភ្លាមទាញដង្កាប់មក បើកគ្រែបយកក្រមួនលាបបបូរមាត់ រួចចាក់ប្រេងលាបសក់ ក្រោយបន្លំញញឹកញញាក់ធ្វើជាពកូន ទើបចុះពីផ្ទះចេញទៅ ។ សោភិតឃើញដូច្នោះក៏វិលមុខលែងដឹងអ្វី ស្ទុះទៅរាំងមុខប្រពន្ធមិនឲ្យចេញទៅ តែសុវណ្ណ-បុប្ផាប្រានចេញធ្វើមុខមាំ ស្វាមីក៏អង្គុយឱបក្បាលជង្គង់អង្វរកុំឲ្យនាងទៅ ទើបនាងបាត់ធ្វើមុខក្រញូវបែរជាញញឹមមករក ។

សោភិតលែងនឹកអាណិតកូន ចូលទៅក្នុងបន្ទប់ស្រែកហៅឲ្យចេញមក "នែ! ឯងឃើញថាម៉ែឯងគេរវល់ទេ បានជាមិនចេញមកជួយធ្វើការនៅសម្ងំដេកដល់ណាទៀត" ។

សុភក្ត្រឮដូច្នោះមិននិយាយស្ដីថាអ្វី បកជួយចេញពីខ្លួនហើយខំងើបឡើងអង្គុយដោយខំប្រឹងយ៉ាងខ្លាំង ណាអស់កំឡាំងណាឈឺក្បាល

ផង ប្រឹងដើរញញីញញ័រ ហាក់តែគេមកក្រៅ យកដៃកាន់ទ្វារទៅបិទជាប់ផ្នែក បង្កាន់មិនឲ្យជួល ដល់ត្រូវម្តាយចុងកៀនឲ្យចាប់ៗ ក៏ប្រញិបប្រញាប់ ឈានជើងឲ្យវែងៗ តែអនិច្ចាអើយ ជើងទាំងពីរញ័រទទ្រេតទប់ខ្លួនពុំរួច ក៏ស្រុតជ្រុលចុះស្រើបកណ្តាលផ្ទះ សុវណ្ណបុប្ផាឃើញដូច្នោះក៏ស្តីឲ្យថា “ដើរឲ្យលឿនឡើង កុំពុតត្បុតច្រើនពេក ចង់ត្រូវព្រនង់បានដើរឬអ្វី ? ដូចជាគោត្រូវតែគេចាក់ទឹងជន្ទុញបានសមមុខ” ។

សុភិន្ទ្រក៏លើកដៃសំពះម្តាយចុងអង្វរថា “ឱអ្នកម៉ែខ្ញុំអើយ ! ខ្លួនខ្ញុំនេះពុំមែនខ្ជិលច្រអូសមិនចង់ជួយធ្វើការទេ បើខ្លួនខ្ញុំអាចធ្វើការជូនបានត្រឹមណា ខ្ញុំប៉ុនទាំងធ្វើជូនមិនរួញរាត្រឹមណោះ តែពេលនេះសូមអ្នកសន្តោសខ្ញុំម្តងចុះ ព្រោះខ្ញុំអស់កំឡាំងណាស់ មុខជានឹងធ្លាក់ពីលើផ្ទះនេះជាមិនខាន ដោយឡើងចុះជណ្តើរមិនកើត កាលបើធ្លាក់ហើយមុខជានឹងស្លាប់មិនលែង កាលបើខ្ញុំបានស្លាប់ទៅហើយ មុខជានឹងលំបាកដល់អ្នកម៉ែមិនខានទេ បើដូច្នោះសូមអ្នកម៉ែមេត្តាទុកជីវិតឲ្យខ្ញុំបំរើតទៅទៀតចុះ” ។

“អើ ! អញអនុញ្ញាតឲ្យម្តង តែជួយមើលប្អូនផងកុំឲ្យវាយំ” ។

សុភិន្ទ្រក៏យកប្អូនមកតែ រួចទំតកិលចូលទៅកន្លែងខ្លួនវិញ វារឡើងលើគ្រែដេក តែប្អូនតូចវាយំកិចកុចពេកណាស់ ក៏ខំលួងលោមវាឲ្យបាត់យំ “ប្អូនអើយ ! ប្អូនផាទៅកុំយំពេក អាណិតតែបងដែលទំរៃថាប្អូន

ពីរើបនឹងកើតមក ឥឡូវបងអស់កំឡាំងណាស់ នាង់នៅឲ្យស្ងៀមណា ប្អូនណា !!!

ពាក្យនោះហាក់ដូចជាបេះស្ដាប់កំនៅស្ងៀម យកដៃញាត់មាត់ ក្អកក្អមួយសន្ទុះ រួចដេកលក់ដកបង្ហក់ទៅ ៗ

នៅពេលនោះ អ្នកស្រុកផ្អើលឆោឡោឡើង ព្រោះឃើញខ្មោចតាព្រំនៅច្រាំងកណ្ដាលផ្លូវ ពួកគេនាំគ្នាមកត្រួតត្រាមើល តែគេរកមុខអ្នកសម្លាប់មិនឃើញក៏លែងគិតទៅ ចំណែកសំឡាញ់តាព្រំ ក៏មកកៀកសំឡាញ់យំសោកជាច្រើន រួចអ្នកស្រុកក៏នាំយកខ្មោចតាព្រំទៅដុតជាតាមទំនៀមស្រុក ៗ

លុះដល់ពេលល្ងាច សុភ័ទ្រចេញពាក់ទិព្វបានស្មានមុខមាត់ប្អូនក្នុងខ្លួន ដើរដើរឡើងសំអាងកាយស្រលប្លូស ចូលទៅផ្ទះបាយរកអ្វីទីងបរិភោគក៏គ្មាន ទ្រាំឃ្លានណាស់ក៏ចុះពីលើផ្ទះទៅ ក្នុងចិត្តគិតថា នឹងទៅបេះត្រប់កងវត្ត ដល់កណ្ដាលផ្លូវក៏បានប្រទះនឹងប្អូនចំពាម នាងក៏បបួលទៅផ្ទះនាងឯណោះ សុភ័ទ្រក៏ព្រមទៅដល់ហើយក៏កក់ពាក់សំពះសួរទុក្ខនាងសាលី ដែលមានពាក្យមកកាន់ថា

" កូនអើយ ! បើឯងអត់ណាស់ ព្រឹក ៗ ចូរមកស្រស់ស្រូបឯណោះមករួចសឹមទៅសាលា " ថែរទៅពួកតាសីបង្គាប់ឲ្យរៀបបាយទឹកមក សាលីអង្គុយចាំបំរើបង រួចសាកសួរអំពីហេតុដែលបងធ្លាក់ពីលើផ្ទះ

មកដេកលើពូក ដល់ជំងឺរឿងកាសព្វគ្រប់ហើយ នាងក៏ស្រែកឡើងថា ពុទ្ធោអើយ! នេះបំជាមិនអាណិតដល់ចិត្តសាលីសោះតែម្ដង បើគ្មានពួកជំងឺមុខជាស្លាប់បានឃើញមុខគ្នាមិនលែង តែហេតុផលបុណ្យសាលីបានជាមិនអី! បងសុភ័ទ្រអើយ ពីថ្ងៃនេះទៅ ចូរបងសន្យាឲ្យប្អូនថា ទុកជាបងពិបាកយ៉ាងណា ក៏មិនសម្លាប់ខ្លួនដែរ ណា ភ័ទ្រណា!!! ។

"មិនអីទេប្អូន បងសន្យា" ។

"ឲ្យតែដូចពាក្យសន្យាណ៎ា!! ។

នៅវេលានោះ បិតានាងសាលីបានប្រើឲ្យមនុស្សក្នុងផ្ទះដាំថ្នាំរួច ឲ្យសិតមកឲ្យសុភ័ទ្រ ផឹករួចហើយ ក៏មានកំលាំងពលំដូចដើមវិញ លើកដៃសំពះ អរគុណ ទើបលាវិលមកសំណាក់អាត្មាវិញចាប់ធ្វើការ ដណ្ដាំស៊ូដូចមុនៗ ។

## បទទី ១២

# ភ្នំពេញ

ពន្លឺភ្លើងអគ្គិសនីចុះព្រោងព្រាតចិញ្ចែងដូចវេលាថ្ងៃ បំភ្លឺផ្លូវដែលអ៊ូអរទៅដោយរថយន្តគ្រប់បែប ៗ ទោចក្រយាន ទីងត្រីចក្រយាន ទៀលផ្ទាត់ចុះឡើងមិនចេះអស់ លើចិញ្ចើមថ្នល់ធំ មានមនុស្សកុះករដើរហែតាមគ្នាមិនចេះអាក់ មើលពីចម្ងាយឃើញតែលកក្បាលខ្មៅគ្រាំ

គេក្រែង ហាក់ដូចជាមានបុណ្យទានអ្វីអឹកធឹក តាមដោយពិតនោះ ក្រែងក៏ពេញដូចជាមានបុណ្យមួយដ៏ចំឡែកដល់ភ្នែកអ្នកនៅស្រុកក្រៅ ។

មានកុមារម្នាក់ស្លៀកពាក់បែបជាអ្នកខេត្រក្រៅ ដើរជិតឪពុករបស់ខ្លួនទឹកស្ងើចក្នុងចិត្តណាស់មាត់ថា “ស្រុកអ៊ីរុងរឿងម៉្លេះមនុស្សអ៊ីមនុស្ស” ដល់ដើរមួយស្របក់ទៅចង់វិលមុខ ទើបគេចូលក្នុងហាងចិនគន់មើលទំនិញគ្រប់មុខដែលរៀបជាលំដាប់លំដោយក្នុងទូកញ្ចក់ មានរបស់ចំឡែកៗ ប្លែកភ្នែកគួរឲ្យគន់មើលគួរឲ្យទស្សនា បិតាកុមារនោះឃើញក្រប៉ូបស្បែកដាក់លុយទឹកចង់បាន ទើបសួរដំឡៃដល់ចិនអ្នកលក់ក្លួនទៅចៀងកាយចៀកមើលមុខឃើញថា អ្នកស្រុកនិយាយបែបមើលងាយ “ថ្លៃណាស់កុំពាល់” ។

“ថ្លៃណា ស់តើប៉ុន្មានទៅ ?

“តាហ្នឹងថ្លៃ ៥ រៀល ស្បែកល្អផ្ញើពីស្រុកបារាំងមក” ។

ចួនជាទៅជិតនោះមានខ្មែរគ្នាឯង គេជួយនិយាយឡើងថា “នេះឃើញតែគ្នាមកពីស្រុកក្រៅហ្នឹះ ចេះតែដំឡើងថ្លៃទៅតាមចិត្ត ក្រប៉ូបបែបនេះ គេទិញតែ ១ រៀលទេតើ” ។

អាចិនខាតណាត់និយាយអ៊ូជាភាសាវា ហើយយកក្រប៉ូបស្បែកដាក់កន្លែងដដែលវិញ ។

ឪពុកនិងកូនពីរនាក់ ក៏ចេញពីកន្លែងនោះដើរតទៅទៀត លុះ

បត់ចុះបត់ឡើងក៏បានដល់ភាពយន្ត "ផិចសែលស៊ុយ៉ុរ" ដែលមានកណ្ដឹងរោទ៍លាន់ឆ្ងាយ ជាសញ្ញាថាជិតដល់ម៉ោងហើយ នៅមាត់បន្ទប់កន្លែងលក់សំបុត្រ មនុស្សកកដណ្ដើមគ្នាទិញកន្លែងអង្គុយមើល ខាងក្រោយអ្នកតាំងទុះ ពួកនារីឈររៀបថ្នក ពាក់អាវតាន់សម័យផ្សាយទឹកអប់ក្រអូបសាយ អ្នកចម្ងាយតាំងពីទេវកនាំគ្នាឈរមើលកាំងស្នា រគីដល់គេចូលទៅគងអស់ទៅ ក៏ទឹកព្រួចចង់មើលទំងគេ ទើបទិញសំ-បុត្រហើយដើរចូលទៅ ។

វេលាកុនរៀបលេង ចូនជាកុមារនោះងាកមុខទៅក្រោយមើលគេឯង ស្រាប់តែឃើញស្ត្រីកណ្ដាលអាយុម្នាក់ ស្លៀកពាក់ហ៊ឺហាសុទ្ធតែព្រែមានមុខស្រពោនចង្អិត នាំឲ្យនឹកដល់កាពទាតារបស់ខ្លួន ក៏ទឹកអរព្រួចចំរើបឈរឡើងទឹងបក់ដៃហៅ បើជាម្ដាយរបស់ខ្លួនមែន នោះមុខជានឹងស្គាល់កូនមិនលែងទេ នៅវេលានោះស្រាប់តែភ្លើងរលត់ក្លុប នាំឲ្យកុមារសោប់សេល់កងចិត្តពន់ប្រមាណ ព្រោះខានបានពិនិត្យមើលឲ្យច្បាស់លាស់, តើជាម្ដាយរបស់ខ្លួនឬមិនមែន ។

ដល់កុនចេញមក អ្នកស្រុកក្រៅតាំងពីនាក់ ក៏ពុំជាចំមាត់សរ-សើរឆ្ងល់នឹងស្រមោលចេះនិយាយស្ដី ដូចជាមនុស្សមែនទែន ឆ្ងល់នឹងអម្ពាត់យ៉ាងណា ក៏ឃើញស.ម៉ា នឹងភ្នែកយ៉ាងនោះ ឮស្ដូរយ៉ាងណាក៏ឮដូច្នោះមិនមានឃ្លៀងខឹងទំនងដើម តែភាសានិយាយនោះជាភាសា

ប៉ាក់ង    កុមារទេពូលការៈទឹងបកប្រែចេញមកជាខេមរភាសាឲ្យឪពុក ស្តាប់ទាំងអ្នកអង្គុយជិតនោះប្លែកគ្រប់គ្នា  ពីព្រោះកុមារនោះ  ដូចអ្នកមើលបានស្គាល់ក្នុងចិត្តថាដូចអ្នកណាហើយ  គឺសុភទ្រនោះឯង  ដែលសោភិតជាឪពុកនាំមកទីក្រុង ដើម្បីនឹងប្រឡងយកបដិញ្ញាណ ៗ

លុះភាពយន្តលេចពីផ្ទាំងសំពត់សហើយ  មានក្មេងក្តិចពិញេះទៀត ចិត្តសុភទ្រក៏អណ្តែតអណ្តូនព្រឺព្រួច  ទំនើបឡើងជាប្រញាប់រៀតមើល មាតារបស់ខ្លួន  តែគួរឲ្យខ្ញាញ់ណាស់ត្រូវគេប្រានចុះឡើង  ដោយតាម គេរេលទៅមុខ ៗ ដល់ចេញមកខាងក្រៅ ស្រាប់តែឃើញស្ត្រីកណ្តាល អាយុនោះជិះឡានចេញផុតទៅហើយ  សុភទ្រខ្ញាញ់ណាស់យកដៃបោច សក់ក្បាលទឹកចង់យំនៅមុខគេពលគ្នា   ស្តាយមិនបានចេញមកឲ្យទាន់ ទឹងគន់មើលតើជាម្តាយរបស់ខ្លួនឬពុំមែន   ៗ

លុះវិលមកទីសំណាក់វិញ   ក៏អង្គុយសំកុកសញ្ជឹងសញ្ជប់តែម្នាក់ឯង  ម្តាយមីងសាកសួរយ៉ាងណាក៏ពុំបានឆ្លើយឲ្យពិស្តារ  ព្រោះត្រូវការ នៅស្ងាត់តែម្នាក់ឯង  ដើម្បីនឹងរំពឹកដល់អនាគតរបស់ខ្លួន   ទីងទឹកដល់ ហេតុការណ៍អម្បាញ់មិញនេះឯង   ៗ   ម្តាយមីង   មានឧត្តមលម្អមុខ ក្រៀមក្រស់តែក្អកទ្រង់ស្រគាប់  មិនជាអ្នកក្រៀវក្លាហាក់ដូចជារូបស័ក្តិបេះ និយាយទឹកស្អានថាក្មួយអស់កំឡាំងមកពីដើរ    ក៏រៀបកន្ទេលខ្នើយបង មុនឲ្យក្មួយដេកទៅ   ៗ

យប់នោះ សុភិទ្រដេកក្រឡាក់ប្រែប្រួលចុះឡើង នឹកដល់សេចក្តីកំសត់របស់ខ្លួន ក៏ជោរជល់ទឹកភ្នែកជោគខ្នើយ នឹកអំពីបែកបាកមាតា អំពីវេទនានៅម៉ែម្នាក់ឯងនឿយនឹងធ្វើការក្នុងផ្ទះ អំពីឃើញមុខម្តាយប្រហាក់ប្រហែល ហើយមិនបានសួរទៅមើលឲ្យជាក់នឹងភ្នែក នឹកអំពីខ្លួនរៀបទៅប្រឡងមិនដឹងជាយ៉ាងណា ឮសូរសត្វជីងចក់យំកណ្តាលយប់ស្ងាត់រងំស្រណោះដល់រូបកាត្ត បែរមើលប៉ារបស់ខ្លួនកំពុងស្រមុកៗ ដល់នាឡិកាវាយម៉ោង ១១ ក៏កាត់ចិត្តលែងនឹកនារឿងអ្វីៗ មិនយូរប៉ុន្មានក៏លក់ស៊ប់ទៅ ។

លុះព្រឹកព្រាងឡើងកាលណា ក៏ក្រោកបោកដំណេកសំអាតតាក់តែងខ្លួនស្រស់ស្រូបហើយក៏ពាក់ក្រដាសមួយរមូរ ក្រដាសផ្តិតមួយសន្លឹកព្រមទាំងបន្ទាត់និងឧបករណ៍ឯទៀតៗ សោភិតក៏ជូនកូនត្រសងតាមផ្លូវទៅៗ តាមកុមារឯទៀតៗដែលប្រជុំគ្នាពីរៃត្រៃ ក្រោមកនៅសាលាហ្វ្រនីស្វាប្លាំង នាំគ្នាឈរពេញតែចិញ្ចើមថ្នល់ ដណ្តើមគ្នាមើលឈ្មោះដែលបិទនៅនឹងកំពែងសាលា ដើម្បីឲ្យដឹងថាតើខ្លួនត្រូវចូលទៅអង្គុយថ្នាក់ណា ។

(មានត)

# ប្រជុំសុភាសិតខ្មែរតាមលំដាប់អក្សរ

ហ្លួងគិតព្ធមន្ត្រី ញ៉ុក-ថែម *រៀបរៀងនិងរួបរួម*

## អក្សរ ម (តមកពីមុន)

◎ មានគំនិតឥតគំណើត ។

◎ មានធនប្រពន្ធមិនក្រ, មានដីសមិនក្រក្តារខៀន មានរបៀនមិនក្ររបស់ ។

◎ មាន់ណាក្តត, មាន់នោះពង ។

◎ មានះបាត់មិត្តឥតអ្នកជាទៅ, ក្រេវក្រោធយោរយៅមែនបាត់អង្គ ។

◎ មានសម្រាមទើបភ្លក់ផុះ ។

◎ មានទុក្ខមហាក្សត្រ, មានទុក្ខទៅវត្ត, មានទុក្ខស្រីមានរូប ។

◎ មានប្រឡាយទើបទឹកហូរ ។

◎ មាន់ពងលើជង្រុកស្រូវ ។

◎ មាន់ព្រៃកំចាយមាន់ស្រុក ។

◎ មិនជឿពាក្យស្រីអស់ស្រូវពូជ ។

◎ មឹះៗ កេះឆ្នាំងបាយផ្ទុះ ។

◎ មុខភ្លៃ ស្រែដំកៅ ។

៙ មេម៉ាយគូទ ១ ដូចព្រហ្មចារី, មេម៉ាយគូទ ៣ ដូចស្រីសាវ៉ែក ។

៙ ម្ដៅៗ ទៅយកឯដ៏ឆ្ងាយមកគៀតគៀក ។

៙ ម្ដៅៗ ទៅយកស្ករផ្ញើនឹងស្រីមោច ។

## អក្សរ យ

៙ យល់ញាតិឃ្លាតច្បាប់ ។

៙ យល់តូច កុំគាលទ្រ, ទោះយល់ធំកុំគាលស្រាយ ។

## អក្សរ រ

៙ រទេះបាក់មិនគិត ទៅគិតឯគោល្បដាំង ។

៙ រទេះបាក់ត្រង់ណា, ល្មិតស្មៅត្រង់ណោះ ។

៙ រើសពោសដូចពស្អុតស្អុច ។

៙ របស់ព្រះ, បូជាព្រះ ។

៙ រនាបបាក់គ្រាន់នឹងដួស, តែមាត់រហូសកំពប់ប្រាក់ ។

៙ រហ័សតែមាត់, ត្រគាកស្ទាប់ស្ទូក ។

៙ រកទុសប្រទះឈើឆាប់ ។

៙ រស់នៅជាអាក្រក់, ស្លាប់បាត់មុខជាល្អ ។

៙ រើសដៃផ្ទៃផ្អែត ។

៙ ឫក្សផ្កា ក្រៃណាទឹងទឡាក់ណើត ។

៙ ឫស្សីព្រៃ ដើម្បីទៅផ្សេងថ្នាំង, ផ្អូនត្រឡាំងទៅផ្សេងចិត្ត ។

៙ រេបតាំងលើតាំងក្រោមដូចក្បាលកិន ។

៙ រាបគល់ រញ្ជួយដល់ចុង ។

## អក្សរ ល

៙ លាក់តែមុខដូចពង្រល ។

៙ លិចសីមលោក, ផល់កំប៉ូតសីមគោង ។

៙ ពូថ្ករឲ្យមើលខ្យល់, ក្ដីពុំយល់កុំអាលក្រោធ ។

៙ លូកប្រហុកឲ្យកប់ដល់ត្រៀក ។

៙ លួចគេកុំធ្លាប់ដៃ, ដេកថ្ងៃកុំធ្លាប់ភ្នែក ។

៙ លើកស្លាបផ្ការក្អែក ។

៙ លេងនឹងក្មេងកុំអប្បយស, លេងនឹងពស់កុំទាំដៃ, លេងនឹងចាស់កុំបង្រ្គៃ ។

## អក្សរ វ

៙ វាក្ដែងប្រហុកអស់ ។

៙ វាយឲ្យយំហើយ, ទើបបញ្ចុកបេកឲ្យ ។

## អក្សរ ស

៙ សត្វក្អែកស្លាប់ដោយសារប្រើស ។

៙ សង់ផ្ទះតាមចិត្តអ្នកនៅ ។

៙ សប្បុរសគេតបញ្ញគុណ, ទុជ្ជនតបញ្ញកម្រើយ ។

៙ សាច់មិនបានស៊ី, យកឆ្អឹងព្យួរក ៗ

៙ សាបមួយដៃ, ប្រៃមួយចប ៗ

៙ ស៊ីច្រើនៗ ផុះ, លេងច្រើនៗ ឈ្លោះ, ដេកច្រើនៗ ខ្ជិល ៗ

៙ ស៊ីទឹកអ្នកណា, យកអាសាអ្នកនោះ ៗ

៙ ស៊ីបាយដេក បាយសរសើរ, ស៊ីបាយដើរបាយប្រទេចផ្តាសា ៗ

៙ ស៊ីបាយនឹងពន្លឺទៀន, និយាយនឹងមនុស្សមានរបៀន សប្បាយស្តាប់, ស៊ីបាយនឹងពន្លឺខ្យល់ និយាយនឹងមនុស្សកំហល់, ប៉ុនគេយកអង្រែបុកដើមទ្រូង ៗ

៙ ស៊ីសាច់ជាប់មេត្តា, សេពសុរាគ្មានពាក្យទៀង ៗ

៙ សឹកដល់កុំអាលថ្វាយ, ពាក្យពិបាយកុំអាលយក ៗ

៙ សូវកាប់កុំឲ្យជន្ទ, សូវដើរមេឃកន្ទជួរ កុំឲ្យជាន់ទីយ ៗ

៙ សូវប៉ូលកុំឲ្យពេញ, សូវទិញកុំឲ្យជួរ ៗ

៙ សូវខ្ចូលគិតបារ, កុំឲ្យខ្ចូលគិតករញ្ញើ ៗ

៙ សូវបង់ប្រាក់មួយចង់ កុំឲ្យបង់ពាក្យសត្យ ៗ

៙ សូវបែកក្បាលកុំឲ្យបែកឆ្នាំង, សូវបែកចង្កាជាំងកុំឲ្យស្រីមើលងាយ ៗ

៙ សូវឲ្យគ្រពើលេច កុំឲ្យបង្ហាប្រប៉ិច ៗ

៙ សូវឲ្យសាច់កុំបង្ហាញព្រៃ ៗ

៙ សូវយកសំណឹងធ្វើប្រពន្ធ, កុំឲ្យតែប្រពន្ធធ្វើសំណឹង ។

៙ សូវស្ដួចកុំឲ្យដាច់, គិតការពុំទាន់ស្រេចកុំអាលរន្ធត់ ។

៙ សូវស្ដាប់បា កុំឲ្យស្ដាប់មេ លង់ទូកកណ្ដាលទន្លេ កុំឲ្យតែកើនកេះផ្ទុះ ។

៙ សំណាបយោងដី, ស្រីយោងប្រុស ។

៙ ស្នាព្រាន ចម្បាំងស្ដោង, ស្បៀងបាក្ដុំ, ក្រមុំស្រុកចម្ការ, ព្រាច័ន្ទពេជតា, ស្រាស្រុកពោធិ៍សាត់ ។

៙ សម្លមិនឆ្ងាញ់ឲ្យតែក្ដៅ, ប្រពន្ធខ្មៅឲ្យតែនៅក្មេង ។

៙ ស្លឲ្យសាប, អង្គុយឲ្យទាប, ប្រាជ្ញឲ្យវៃ, សំដីឲ្យខ្ពស់ ។

៙ សំលេងប្រាប់ភាសា, កិរិយាប្រាប់មារយាទ ។

៙ ស្លសាបកុក, សាចមកជាប្រហុក, ពេមកជាចន្ទៃ ។

៙ ស្លឹកឈើជ្រុះមិនដែលឆ្ងាយពីគល់ ។

៙ ស្លឹកឈើឥតកំរើក, បើកក្រែកផ្សៀតខ្យល់បក់ ។

៙ ស្លូតស្លាប់ វៀចវេរមានភ័ព្វ, អាយុយឺនយូរ ។

៙ ស្លៀកស្បង់មិនកោរសក់ ទុះកញ្ចក់ឆ្លុះនេត្រា ។

៙ ស្វាមិនបង់បៀម, សៀមមិនបង់ក្បួន, យួនមិនបង់ពុត, ខ្មែរស៊ុតត្រគមិនបង់ថែបូរ ។

៙ ស្វែងរៀនគេបង្គាប់, ពុំស្មើចិត្តជា ។

◎ ស្នេហ៍មិនស្មើស្និទ្ធ ។

◎ ស្អប់កុំឲ្យផាញ់, ស្រឡាញ់កុំឲ្យខ្ចី ។

◎ ស្រឡាញ់ខ្លួនឲ្យស្ងួនចំណី, ស្រឡាញ់ប្ដីឲ្យស្ងួនចិត្ត ។

◎ ស្រឡាញ់ពេញប្រាស, ស្អប់ជំពប់ឈើ ។

◎ ស្រម៉មិនដែលធុំ, ក្រមុំមិនដែលស្អុត, បង្កកមិនដែលក្រន់, កំពង់មិនដែលស្ងាត់, មាត់មិនដែលស្ងៀម ។

◎ ស្រឡាញ់ផ្លែឲ្យថែគល់ ។

◎ ស្រឡាញ់ម៉ែ ឲ្យថែកូន ។

◎ ស្រឡាញ់កុំឲ្យហៅញឹកៗ ដល់លើកសំពះទៅម្ដងៗ ។

◎ ស្រីមួយដុំក្របមួយដើម ។

◎ ស្រើបកាមផ្ដេ, អរគាថក្ដៀន ។

## អក្សរ ហ

◎ ហុកសម្ដីសំឡូងកាក, ហូតប្រក់ក្រាកសំឡូនព្រាយ ។

◎ ហុបកំពោះមិនឲ្យស្រណោះដៃ, ។

◎ ហេតុមិនស្រឡាញ់សិងជាថ្លាយ, ខ្លួនថែកសំពៅថ្លាយសោត ដល់លង្កាធាយ, ស្រឡាញ់ហើយទើបទៅបាន ។

## អក្សរ អ

◎ អន្ទក់មួយកាច់, បបរមួយថ្លាន ។

៙ អក្សរជាត្រី, សំដីជាឯក, លេខជាទោ ។

៙ អណ្ដើកនៅផើង, ចាំអីក្ដក់ហៅក្ដៅ ឬអណ្ដើកនៅផើង, ចាំអីរកក្ដៅ ។

៙ អណ្ដាកជាកាតកន្ទង, ចង់ទ្រព្យធនផងពីព្រោះអណ្ដាក ។

៙ អត់មិនអត់យកកោលអន្ទាក់ ។

៙ អន្ទង់ឲ្យទុនផុក, រីឯកុកឲ្យទុនត្រពាំង, ។

៙ អាក្រក់តែរូប, ម្ហូបគេល្អ, ល្អតែរូបម្ហូបមិនកើត ។

៙ អាស្វាមិនទាន់ស្គាល់ព្រនង់ ។

៙ អាវែកគេស៊ីក្រោមក្លក, អាវែកមិនដឹងខ្លួន ។

៙ ឥតដំបៅហៅផ្ញឺ, ដំបៅមិនឈឺយកឈើចាក់ ។

៙ ឥតទ្រព្យអប្បប្រាជ្ញា ។

៙ អឹមជាងអៀម, សៀមជាងស្រដី ។

៙ អូសទូកកុំឲ្យល្អាន, ចាប់ត្រីបានកុំឲ្យល្អក់ទឹក ឬអូសទូកកុំឲ្យល្អាន, ទឹកថ្លាសោតកុំឲ្យល្អក់ ។

៙ អូសសម្រាស់ប្រទះពាក្យ ។

៙ អួតបេះរបេះក្បាប ។

៙ ឲ្យកូនគ្រាប់ពុតកង់, វិលគ្រប់អង្គត្រូវគ្រប់ប្រាណ ។

៙ អំបែងបែករកអំបែងណាដូច ។

ចប់តែប៉ុណ្ណេះ ។

ច្បាប់ក្រមបរិយាយ

# លោកញ៉ុក-ធួ គ្រូបង្រៀនជំនួយ

*នៅវិទ្យាល័យស៊ីសុវត្ថិ*

(តមក)

ពាក្យនេះ ត្រូវញែកជា ៣ វគ្គ តាមលំដាប់ ៗ វគ្គខាងដើមគឺ "មួយចង់ក្តីច្បាប់ ឲ្យបានខ្លួនគាប់ នៅនាលោកិយ" បានសេចក្តីថា មាតាបិតាមានប្រាថ្នា ចង់ឲ្យកូនចេះដឹងច្បាប់សំរាប់ស្រុក និងទំនៀមទម្លាប់ប្រពៃណី ដើម្បីដំកល់ខ្លួនឲ្យនៅក្នុងសេចក្តីសុចរិតនេះ ១, និងបានជាទីពឹងទីបន្ទោរបស់អ្នកទាំងពួង ដែលត្រូវការនេះ ២, និងនាំខ្លួនឲ្យបានគាប់ចិត្តនៃអ្នកដទៃ ជាទីគោរពកោតរាបរបស់ជនានុជន នៅនាលោកិយនេះ ដោយកំឡាំងវិទ្យាសាស្ត្រនេះ ៣, ទាំង ៣ បទនេះគឺក្នុងវគ្គទីបឋម ព្រោះអ្នកទាំងពួងដែលមានកិច្ចការរវល់ផ្សេងៗ រមែងត្រូវការរកអ្នកចេះច្បាប់ទំលាប់ទំនៀមទុកដូចជាក្បួនខ្នាតមួយៗ, យើងរាល់គ្នាបានឃើញមក ហើយក្នុងប្រទេសមួយៗ អ្នកស្រុកដែលដូចមានទុក្ខ ពុំសុខចិត្តអាស់ នឹងខ្វែងគំនិតគ្នា កើតប្តឹងតក់ដល់ក្រសួងតុលាការ សូមឲ្យអស់លោកចៅក្រម ដែលជាអ្នកចេះច្បាប់ជំនុំជំរះរកសេចក្តីខុសត្រូវកាត់សេចក្តីឲ្យ, រមួយដូចមានធ្វើបុណ្យទានផ្សេងៗ មានធ្វើឈាបនកិច្ច, បញ្ចុះធាតុ បញ្ចុះសីមា, ធ្វើមង្គលការអាពាហ៍ពិពាហ៍ជា

ដើម ៗ ល ៗ អ្នកទាំងឡាយតែងតែរកតាំងអ្នកចេះក្បួនខ្នាត ទាំងច្បាប់ ទំនៀម មកជាអធិបតីបាត់ការ ឲ្យត្រឹមត្រូវឲ្យ, បុគ្គលដែលចេះជំពូកនេះ មានឧបាកូចារ្យនឹងអ្នកផ្សំហោមហាជាដើម ៗ

វគ្គទី ២ "មួយចង់ប្រាជ្ញ មិនឲ្យអប្រិយ" បានសេចក្តីថា មនុស្សខ្លះមានចិត្តប្រាថ្នា , ចង់បានចំណេះវិជ្ជាផ្សេងៗ ជាកំឡាំងប្រយោជន៍ដើម្បីនឹងតាំងខ្លួន ជាបណ្ឌិតជាតិជាអ្នកឈ្លាសវាងវៃ មិនឲ្យថយថោកដោយល្ងង់ទៅ ព្រោះយល់បានថា ធម្មតាអ្នកអាប់ឥតប្រាជ្ញ មានអាយុរស់នៅមិនរុងរឿង ម្ល៉ោះហើយគេខំសង្វាតឃ្មាតខ្មីព្យាយាមរៀនសូត្រឥតខ្ជិលច្រអូសឡើយ ខំរៀនលុះត្រាតែសំរេចការដូចបំណង ៗ

តែវិជ្ជាត្រង់ណេះ លោកសំដៅយកវិជ្ជាល្អៗ ដូចយ៉ាងអក្សរសាស្ត្រ ឬបង្កើតប្រដាប់ប្រដាប្រើប្រាស់ ចេះធ្វើគ្រឿងយន្តផ្សេងៗ ៗ ល ៗ នេះទើបរាប់ជាវិជ្ជាល្អ, បើដើរស្វែងរៀនខាងវិជ្ជាមន្តធ្វើបោរល្បួចប្លន់គេ ជាវិជ្ជាមានទោស នោះលោកពុំរាប់ចូលក្នុងវិជ្ជាប្រសើរទេ ៗ

វគ្គទី ៣ គឺ "មួយចង់បារមី នាំញាតិទាំងឡាយ" បានសេចក្តីថា មនុស្សជំពូកនេះ ចង់បាននូវបារមី គឺគុណធម៌ល្អ ដែលខ្លួនបំពេញឲ្យដល់ត្រើយ គឺសេចក្តីសុខ ហៅថាបារមីមានទានសីលជាដើម មានមេត្តានិងឧបេក្ខាជាបរិយោសាន, បុគ្គលទាំងនេះ គឺភិក្ខុសាមណេរនិងឧបាសកឧបាសិកា ជាអ្នករក្សាសីលឲ្យទានជាដើម លោកអាចដឹក

នាំញាតិសាលោហិត មានមាតាបិតាជាដើម ញុំាងចិត្តឲ្យចុះទៅកាន់ធម៌របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលត្រាស់សំដែងនូវព្រះបរមទុក្ខ ដឹកសត្វកាត់ផ្តសង្សារ ឲ្យរួចចាកអបាយភូមិទាំង ៤ ដាក់ដល់ត្រើយគឺព្រះនិព្វាន ។

១៨- ហៃអស់សាមណេរ កុំធ្វើដូចដែរ ត្រង់ក្តី ពាយដ៏ាយ លំទុតបំរើ អ្នកជាចាស្រ្កាយ ជូនបុណ្យ ទៅម្តាយ អាពុកជីដៃ ។

គ្រូដាស់តឿនសិស្សានុសិស្សកាលបួសហើយថា ចូរអ្នកកុំធ្វើដូចកាលដែលអ្នកនៅជាគ្រហស្ថ បួសហើយកុំធ្វើប្រហែសក្រែបខ្លួនឲ្យដឹងថាខ្លួនសព្វថ្ងៃនេះបួសហើយ, ចូរអ្នកចាំថាកាលមិនទាន់បួស អ្នកមានទម្លាប់ទម្លាប់ទំនៀម សំរាប់គ្រហស្ថ ដែលអ្នកត្រូវប្រតិបត្តិជាប្រក្រតី ឥឡូវមាតាបិតាយកអ្នកមកបំបួសជាសាមណេរហើយត្រូវអ្នកប្រព្រឹត្តតាមសិក្ខាវិន័យឲ្យត្រឹមត្រូវវិញ ។

ចូរអ្នក "លំទុតបំរើ អ្នកជាចាស្រ្កាយ ជូនបុណ្យទៅម្តាយ អាពុកជីដៃ" បានសេចក្តីថា ឲ្យសាមណេរនោះ យកចិត្តទុកដាក់ បំរើគ្រូចាស្រ្កាយ អាចារ្យឧបជ្ឈាយ៍ ដ្បិតកិច្ចបំរើ ឧបជ្ឈាយ៍អាចារ្យនេះ ជាបុញ្ញកិរិយាមួយដ៏ឧត្តម ដើម្បីយកបុណ្យនេះ ឧទ្ទិសបញ្ជូនទៅមាតាបិតា រៀតកល់ខ្លួន ។

ឯកិច្ចបំរើគ្រូឧបជ្ឈាយ៍នោះ គឺឲ្យខំផ្គត់ផ្គង់ទឹកស្រង់ទូវទឹកឆាន់ បោសច្រាសទីសេនាសនៈ គោរពប្រណិប័តន៍ក្រាបសំពះជានិច្ច, គ្រាបើលោកមានពេទនាពាធ ត្រូវរកពេទ្យមកជប់ថ្នាំព្យាជម្ងឺ ។ល។ នេះហើយហៅថាជាសិស្សមានកតញ្ញូ ព្យាយាមធ្វើវត្តប្រណិប័តន៍គ្រូបាធ្យាយ ។

តែបើវេលាស្រេចកិច្ចទាំងឡាយនេះហើយ ត្រូវមានកិច្ចតទៅទៀត ។

សង្វាតសូត្ររៀន កុំធ្វើអៀនប្រៀន ក្នុងចិត្តសព្វថ្ងៃ លំឧតិបម្រើ ផ្ចាប់ដោយហឫទ័យ ចារឹក្កមៃៗ ក្តីច្បាប់កុំបីបង់ ។

ជាឲ្យមានវីរិយៈ ខំរៀនសូត្រឲ្យណាស់ផង "កុំធ្វើអៀនប្រៀនក្នុងចិត្តសព្វថ្ងៃ" ពាក្យនេះប្រាប់ថា ធម្មតាអ្នករៀន ត្រូវកុំឲ្យគិតអៀនស្ទើរស្ទីមិនស្តីនោះ កុំឲ្យខ្មាស់អៀនទីងគ្រូបាធ្យាយឡើយ បើសិស្សឯណាខ្មាស់គ្រូហើយ សិស្សនោះក៏មិនបានចេះដឹងណាស់ ។ បច នេះគ្រូទីងការសិតបុពណាមួយថា "ខ្មាស់ករិយាឥតកូន ខ្មាស់គ្រូឥតចំណេះ" ធ្វើជាអ្នករៀនហើយ ត្រូវតែឲ្យឈ្លះឈ្លាយ ។ សួរហ៏សួរដណ្តឹងគ្រូបាធ្យាយ អំពីកិច្ចការដែលខ្លួនពុំយល់ សំពះសូមឲ្យលោកគ្រូ អធិប្បាយស្រាយតែបញ្ហាឯណាដែលខ្លួនពុំគឺនោះ មិនតែប៉ុណ្ណោះឡើយ ត្រូវគោចហានសាកសួរអ្នកដទៃផងទៀត ដែលគេមានចំណេះ

ផាផាំងខ្លួន កុំគប្បីអៀនអន់ យ៉ាងនេះទើបបានចំរើនបានចំណេះច្រើន ស្ទាត់ នេះហៅថាមិនអៀនប្រៀន ក្នុងការរៀនសូត្រ ។

រីឯកិច្ចគឺ "លំ។តបំរើ ផ្គាប់ដោយហឫទ័យ បារម្ភៃមៗ ក្តីច្បាប់កុំបីបង់" ជាពិតមែនជាយើងរវល់ខ្វល់នឹងរៀនសូត្រហើយ តែយើងមិនត្រូវលះបង់ចោលច្បាប់គឺសិក្ខាវិន័យ ដែលជាធម្មក្រឹត្យសំរាប់សមណៈ ត្រូវឲ្យមានចិត្តនោះនឹកមៃម៉ៃពៃប្រុងប្រយ័ត្ន បំពេញកិច្ចទាំងពីរឲ្យបរិបូណ៌ហោង ។

ទី៩ ច្បាប់នេះសោភណា ទូន្មានអាត្មា ដោយ
នូវក្រឹត្យសង្ឃ ត្រង់ណាហៅច្បាប់ កាន់ខ្ជាប់កុំបីបង់
ចំណេះនៅលង់ ខ្លួនបានជាប់ ។

ច្បាប់នេះហើយ សំរាប់ឲ្យអ្នកប្រៀនប្រដៅខ្លួនឲ្យបានល្អ ផ្សំតធម្មតាអ្នកបួសត្រូវកាន់ក្រឹត្យវិន័យសង្ឃ ឲ្យជាវិរៈមាំទាំ តាមលំដាប់នៃកិច្ច ដូចពាក្យថា "ត្រង់ណាហៅច្បាប់ កាន់ខ្ជាប់កុំបីបង់" ឲ្យយកចិត្តទុកដាក់រក្សាសីលឲ្យជាប់ កុំឲ្យពព្រាសពពាលសៅហ្មងទៅបានដោយសេចក្តីប្រមាទ បំពេញកិច្ចដែលគួរធ្វើ នេះជាឧបាយនៃបញ្ញា ។ បើសាមណេរឯណាមានសេចក្តីរឭកកាន់ច្បាប់ខ្ជាប់នូវក្រឹត្យវិន័យ ពុំឲ្យមានហ្មងបានហើយ នោះលោកពោលថា "ចំណេះទៅលង់ ខ្លួនបានជាប់" ថាអំណើះគេទៅ អ្នកនឹងបានជាប់ មិនលែងឡើយ ។

ត្រង់ណោះបើនឹងពោលយកតាមលំអានបុរាណ នៅកម្ពុជរដ្ឋនេះ បណ្ដា
លោកសង្ឃដែលចេះដឹងជ្រៅជ្រះច្បាស់នូវច្បាប់ទម្លាប់ទំនៀមស្រុកព្រម
ទាំងធម៌វិន័យ ក៏ស្ទាត់ស្ទាញគ្មានទើសទាល់ គ្មានធ្វើឲ្យខុសអំពីពុទ្ធោវាទ
លោកអង្គនេះទើងបានធ្វើជាសមណសក្តិ ក្នុងគណសង្ឃ ជាភជាគណៈ
ហានុក្រម មានគ្រូសូត្រជាដើម, បើលោកអង្គនោះទ្រាំទ្រសិក្ខា
វិន័យពុំបាន លាចាកសិក្ខាបទមកជាគ្រហស្ថវិញ អ្នកនោះគេហៅ
ថា "បណ្ឌិត" គឺជាអ្នកប្រាជ្ញ, បើចូលធ្វើជាខ្ញុំរាជការអម្ចាស់ផែនដី
ក៏ប្រើនសត្វព្រះរាជហឫទ័យ ទ្រង់ព្រះមេត្តាឲ្យមាន យសស័ក្តិទីន
ប្រាក់ខែ ។

សព្វថ្ងៃសោភណា ធ្មួនអាត្មា ដោយនូវក្រឹត្យ
ក្រម បម្រើចាញ់ឆ្ងាយ ឲ្យមានចារក្ត ធើបខ្លួនជាធំ ទៅ
ដល់មហាក្សត្រិយ៍ ។

ន័យខាងលើនេះ មានសេចក្ដីថា ឲ្យសិស្សានុសិស្សទំខ្ញូនខានគាត់
រៀនខ្លួនឲ្យបានតាមលំអានច្បាប់ក្រមនេះជាទំចូតទៅ គឺឲ្យសង្កាតរៀន
សូត្រនឹងលំៗ បំរើគ្រូបាធ្យាយ កុំគប្បីធ្វេសប្រហែសគួបខ្លួន បើអ្នក
មានចំណេះប្រើការបានហើយ ព្រមទាំងកិរិយាមារយាទត្រឹមត្រូវល្អ
តាមដំបូន្មាននេះ ទើងមានកិត្តិសព្ទគេកោតឈ្មោះពីរោះខ្ចរខ្ចាយ ទៅដល់
ព្រះរាជាជាម្ចាស់ផែនដីពុំខានឡើយ ។

(ពណ៌នាមកយ៉ាងនេះ ព្រោះពីដើមយើងរៀនវិជ្ជាទាំងឡាយតែអំពីវត្ត ដោយពុំមានសាលាបង្រៀន ដូចកផការគោណាព្យាបាលសព្វថ្ងៃនេះទេ) ។

ទី ១០- ច្បាប់នេះសោតណា ទូន្មានអាត្មា ដើរនៅពុំចាក នោះខ្លួនឥតបុណ្យ បម្រើមហាក្សត្រិយ៍ គោរពប្រតិបត្តិ យសនោះពុំលែង ។ ហេតុទានដឹងច្បាប់ ចាំនដូចបង្គាប់ ចិត្តត្រួយល់ស្តែង នោះនៅបម្រើ ស្តេចជាកំផែង យសនោះពុំលែង ប្រាកដពណ្ណរាយ ។

ន័យពីគៀលនេះ បានសេចក្តីថា បើសិស្សានុសិស្សណា យកចិត្តប្រតិបត្តិ តាមដំបូន្មានលោកជាគ្រូ ដែលបង្ហាត់បង្ហាញមក, នោះខ្លួនឥតយសស័ក្តិអ្វី ហើយចូលទៅនៅគាល់បំរើ "ស្តេចជាកំផែង" គឺព្រះកជា ជាម្ចាស់ផែនដីដ៏ជាធំ ហើយខ្លួនមានឧស្សាហ៍ គោរពប្រតិបត្តិ ដោយសុចរិតស្មោះត្រង់នោះ សេចក្តីគាប់ប្រសើររុងរឿងពណ្ណរាយ គឺយសស័ក្តិទាំងកើតឡើងដល់ខ្លួនពុំលែងឡើយ, ព្រោះដោយអំណាចសេចក្តីប្រតិបត្តិត្រឹមត្រូវតាមច្បាប់គ្រូប្រៀនប្រដៅមកនោះឯង ។

(មានត)

# អំពីតាំងចៅអធិការនិងមន្ត្រីសង្ឃ

ទើបតាំងថ្មីក្នុងខែយូកុំង-ស៊ូយេតឆ្នាំ ១៩៤៤

( តពីខែមុនទៀត )

១៨- សញ្ញាប័ត្រលេខ ៣៨ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ប្រាក់-សយ កើតឆ្នាំរោង អាយុ ៤១ វស្សា ២០ នាមឆាយា ជាតត្ថេរ ជាចៅអធិការ វត្តដំណាក់ទ្រយឹង ឃុំសំរោង ស្រុកបន្ទាយមាស ។

១៩- សញ្ញាប័ត្រលេខ ៣៩ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ម៉ក-ឌួន កើតឆ្នាំខាល អាយុ ៣១ វស្សា ៨ នាមឆាយា សុវណ្ណ-បញ្ញត្ថេរ ជាចៅអធិការ វត្តកោរគំរើកកាយ ឃុំវត្តអង្គ ស្រុកបន្ទាយមាស ។

២០- សញ្ញាប័ត្រលេខ ៤០ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ អ៊ឹម-សខ កើតឆ្នាំមមី អាយុ ២៥ វស្សា ៥ នាមឆាយា សុវណ្ណជោត ជាចៅអធិការ វត្តសំរោង ឃុំសំរោង ស្រុកបន្ទាយមាស ។

២១- សញ្ញាប័ត្រលេខ ៤១ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ប៉ា-ឌី កើតឆ្នាំថោះ អាយុ ៣០ វស្សា ៨ នាមឆាយា សំវរោ ជាចៅអធិការវត្តអម្ពព្រៃក្រាំងដូង ឃុំសំរោង ស្រុកបន្ទាយមាស ។

២២- សញ្ញាប័ត្រលេខ ៤២ ចុះថ្ងៃ ៣០-៦-៤៤ តាំងលោកគ្រូ ព្រះសាក្យវង្ស ហួត-តាត កើតឆ្នាំកេង អាយុ ៥៣ វស្សា ៣២ ជាគ្រូសូត្រស្តាំ នៅវត្តឧណ្ណាលោម ឃុំលេខ ៣ ក្រុងភ្នំពេញ ។

២៣- សញ្ញាប័ត្រលេខ ៤៣ ចុះថ្ងៃ ៣០-៦-៤៤ តាំងលោកគ្រូ ព្រះត្រៃរត្នមុនី ម៉ឹង-សែស កើតឆ្នាំថោះ អាយុ ៥៤ វស្សា ៣៣ ជាគ្រូសូត្រឆ្វេង នៅវត្តឧណ្ណាលោម ឃុំលេខ ៣ ក្រុងភ្នំពេញ ។

២៤- សញ្ញាប័ត្រលេខ ៤៤ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ទុំ-ខាត់ កើតឆ្នាំខាល អាយុ ៣១ វស្សា ១០ នាមតាយា ពុទ្ធរក្ខិត ជាចៅអធិការ វត្តអង្គសួគ៌ ឃុំកន្ទោរ ស្រុកកំពង់ត្រាច (កំពត) ។

២៥- សញ្ញាប័ត្រលេខ ៤៥ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ទៅ-គន កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៨ នាមតាយា មុនីសត្ថា ជាចៅអធិការ វត្តអង្គអណ្តែត ឃុំត្រពាំងកង ស្រុកឈូក (កំពត) ។

២៦- សញ្ញាប័ត្រលេខ ៤៦ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ប្រាក់-ម៉ម កើតឆ្នាំជូត អាយុ ៤៤ វស្សា ២៣ នាមតាយា គន្ធត្ថេរ ជាចៅអធិការ វត្តទេវីរតីរតនាកម ឃុំប៉ឺនស្រែ ស្រុកឈូក (កំពត) ។

២៧- សញ្ញាប័ត្រលេខ ៤៧ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ប៉ិ-គួន កើតឆ្នាំខាល អាយុ ៣១ វស្សា ៩ នាមតាយា ឥន្ទបញ្ញា ជាចៅអធិការ វត្តអង្គឆ្កាវង្ស ឃុំប៉ឺនស្រែ ស្រុកឈូក (កំពត) ។

២៨- សញ្ញាប័ត្រលេខ ៤៨ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ឃឹម-កែម កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៨ នាមឆាយា ធម្មសុវណ្ណ ជាចៅអធិការ វត្តអង្គទៀលពិសី ឃុំបាទៀរ ស្រុកឈូក (កំពត) ។

២៩- សញ្ញាប័ត្រលេខ ៤៩ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ អ៊ុំ-ទោម កើតឆ្នាំរកា អាយុ ៣៦ វស្សា ១៤ នាមឆាយា វិន័យគ្រូ ជាចៅអធិការ វត្តម្រះព្រៅ ឃុំឈូក ស្រុកឈូក (កំពត) ។

៣០- សញ្ញាប័ត្រលេខ ៥០ ចុះថ្ងៃ ២៩-៦-៤៤ តាំងលោកគ្រូ ទឹម-ម៉ម កើតឆ្នាំរកា អាយុ ៤៧ វស្សា ២៦ នាមឆាយា បញ្ញាគិរី ជាចៅអធិការ វត្តអង្គគយ ឃុំល្បើក ស្រុកឈូក (កំពត) ។

## រាយនាមមន្ត្រីសង្ឃ

### ដែលបានឡើងសមណសក្តិថ្មី

កាលពីថ្ងៃ ១៧ ខែស៊ូយេគ ឆ្នាំ ១៩៤៤ មានព្រះរាជក្រឹត្យតាំងមន្ត្រីសង្ឃទុកជាគណៈជាន់ឯក- ទោ- ត្រី- ចត្វា- នៅវត្តនានាក្នុងក្រុងភ្នំពេញ ដូចមានរាយនាមតទៅនេះ :

## ក - ទីរាជាគណៈជាន់ឯក :

ព្រះពុទ្ធឃោសាចារ្យ ជួន-ណាត ជន្មាយុ ៦០ ឆ្នាំ វស្សា ៤០ រាជាគណៈជាន់ទោ វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទី ព្រះពោធិវង្ស (រាជាគណៈជាន់ឯក) ។

## ១ - រាជាគណៈជាន់ទោ :

ព្រះសាក្យវង្ស ហួត-តាត ជន្មាយុ ៥២ ឆ្នាំ វស្សា ៣២ រាជា-គណៈជាន់ត្រី វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះមហា-វិមលធម្ម (រាជាគណៈជាន់ទោ) ។

## គ - ទីរាជាគណៈជាន់ត្រី :

ព្រះអរិយធម្មមុនី វែន-ប៊ុល ជន្មាយុ ៥៧ ឆ្នាំ វស្សា ៣៦ រាជាគណៈជាន់ចត្វា វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះសាក្យវង្ស (រាជាគណៈជាន់ត្រី) ។

ព្រះញាណវីរិយៈ ទេព-លឿន ជន្មាយុ ៦១ ឆ្នាំ វស្សា ៤០ រាជាគណៈជាន់ចត្វា វត្តទួខមណីកម (គណៈធម្មយុត្តិ) ជាទីព្រះធម្មកវីវង្ស (រាជាគណៈជាន់ត្រី) ។

ព្រះវជិរមេធា កែវ-អ៊ុប ជន្មាយុ ៥៥ ឆ្នាំ វស្សា ៣៥ រាជា-គណៈជាន់ចត្វា វត្តបទុមវត្តី (គណៈធម្មយុត្តិ) ជាទីព្រះអរិយកស្សប (រាជាគណៈជាន់ត្រី) ។

ព្រះអមរាភិរក្ខិត គង់-ជុំ ជន្មាយុ ៦២ ឆ្នាំ វស្សា ៤១ រាជា-គណៈជាន់ចត្វា វត្តបទុមវត្តី (គណៈធម្មយុត្តិ) ជាទីព្រះឧបាលិវង្ស (រាជាគណៈជាន់ត្រី) ។

## ឃ - ទីរាជាគណៈថ្នាក់ចត្វា

ព្រះបាឡាត់អរិយវិមល ពៅ-នេត ជន្មាយុ ៦២ ឆ្នាំ វស្សា ៤០ ឋានា នៅវត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះអនុមុនី (រាជាគណៈថ្នាក់ចត្វា) ។

ព្រះគ្រូ ឧត្តមមុនី ម៉ុង-សេស ជន្មាយុ ៥៤ ឆ្នាំ វស្សា ៣៣ ឋានា វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះទេពមុនី (រាជាគណៈថ្នាក់ចត្វា) ។

ព្រះគ្រូ វិមលបញ្ញា យយ-ហ៊ុ ជន្មាយុ ៥៦ ឆ្នាំ វស្សា ៣៤ ឋានា វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះធម្មវិបស្សនា (រាជាគណៈថ្នាក់ចត្វា) ។

ព្រះបាឡាត់គោធិកម នួន-គី ជន្មាយុ ៤៧ ឆ្នាំ វស្សា ២៦ ឋានា វត្តឧណ្ណាលោម (គណៈមហានិកាយ) ជាទីព្រះស៊ីរីសុទ្ធ (រាជាគណៈថ្នាក់ចត្វា) ។

ព្រះបញ្ញាបរិយ៍ប៉ិដក ពៅ-ញាណ ជន្មាយុ ៥៤ ឆ្នាំ វស្សា ៣៣ ឋានា វត្តសារាវ័ន (គណៈមហានិកាយ) ជាទីព្រះធម្មវិសុទ្ធិវង្ស (រាជាគណៈថ្នាក់ចត្វា) ។

ព្រះគ្រូ វិចិត្តសត្ថា ប៉ាង-គយ ជន្មាយុ ៥៥ ឆ្នាំ វស្សា ៣០ ឋានា វត្តសារាវ័ន (គណៈមហានិកាយ) ជាទីព្រះញាណសំវរ (រាជាគណៈថ្នាក់ចត្វា) ។

បរិយាយសិល្បកថា

## ព្រះគ្រូសុវណ្ណញាណ សួរ-ហាយ ក្រុមជំនុំព្រះត្រៃបិដក

នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

( តមកពីលេខមុន )

សេចក្ដីថា "ឲ្យតែឈ្មោះថាសិល្បៈ មើលទៅហាក់ដូចជាផ្ដេសផ្ដាសសោះ តែទៅជាបានការសម្រេចប្រយោជន៍យ៉ាងសន្ធឹក សូម្បីព្រះអង្គពិតារណាមើលចុះ បុរសខ្វិនបានស្រុកសួយ ៤ ទិសក៏ព្រោះតែសិល្បៈផ្ទាត់អាចម៍ពពែ (នោះឯង)" ។

សិល្បៈទាំងអស់ដូចបានពោលមកនេះ ចាត់ជាមង្គលមួយជាហេតុនាំមកនូវសេចក្ដីសុខ - ចំរើនរុងរឿងចំពោះស្រុកទេសត្រកូលរបស់ខ្លួនក្នុងលោកនេះជាប្រាកដ ។ បុរសស្ត្រីអ្នកមានគំនិតថ្លៃថ្នូរយល់ត្រូវមានព្យាយាមខ្ជាប់ខ្ជួន ស្គាល់ប្រយោជន៍ដ៏ធំទូលាយបានសិក្សាចំពោះសិល្បៈណាមួយឲ្យចេះដឹងស្ទាត់ រមែងបានទទួលផលប្រយោជន៍គឺលាភយស សរសើរ សុខក្នុងបច្ចុប្បន្នទាន់ភ្នែកដោយជាក់ស្ដែង ដូចយ៉ាងលោក-អ្នកទាំងឡាយ ដែលបានឋានន្តរស័ក្ដិយសជាមន្ត្រីធំតូច ក្នុងតំណែងណា ៗ ក៏ដោយ ក៏សុទ្ធតែបានមកដោយសារសិល្បៈទាំងអស់, ខុសគ្នាតែត្រង់ការចេះដឹង គឺអ្នកខ្លះចេះដឹងច្រើន ខ្លះចេះដឹងតិច, អ្នកខ្លះចេះសិល្បៈនេះ, អ្នកខ្លះចេះសិល្បៈនោះប៉ុណ្ណោះ, ពិតណាស់បុគ្គលអ្នក

កាន់ការគ្រប់តំណែងនាទីជាមន្ត្រីមួយៗ ត្រូវជាអ្នកចេះដឹងយល់ការកៈផ្ទាំខុសត្រូវឲ្យវែងឆ្ងាយជាងគេអ្នកតូចៗ ទើបបានសេចក្តីចំរើនទូទៅដល់ប្រទេសជាតិរបស់ខ្លួន, ទាំងប្រជាជនក៏គោរពកោតខ្លាចលាន់មាត់សរសើរថាជាមន្ត្រីខ្ពង់ខ្ពស់ចេះដឹងយល់ប្រយោជន៍ល្អមែន, មិនមែនជាអ្នកល្ងង់ខ្លៅយល់ឃ្លាងអំពីសេចក្តីចំរើននោះទេ ។

គ្រប់សម័យពុទ្ធកាល, អ្នកស្រុកមជ្ឈិមប្រទេស ទោះក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី សេដ្ឋីក្តី មន្ត្រីក្តី រាស្ត្រអ្នកមានទ្រព្យក្តី ច្រើនតែបញ្ជូនកូនចៅឲ្យទៅរៀនសិល្បៈឯនគរតក្កសិលា ព្រោះនគរនោះមានសាលាទិសា-បាមោក្ខធំៗ ជាច្រើនសម្បូណ៌ដោយអ្នកប្រាជ្ញចេះដឹងវិជ្ជាគ្រប់យ៉ាង ។ កូនក្សត្រិយ៍, ព្រាហ្មណ៍, សេដ្ឋី, មន្ត្រីនិងកូនរាស្ត្រ ដែលបានទៅរៀនចេះដឹងសម្រេចវិជ្ជាណាមួយហើយ លុះត្រឡប់មកស្រុកវិញទើបបានទទួលឋានន្តរស័ក្តិធំៗ ជាមន្ត្រីកាន់កាប់ផែនដី, ខ្លះបានជាស្តេច, ខ្លះបានជាសេនាបតី, ខ្លះបានជាមហាមាត្យរាជបណ្ឌិត ។ មន្ត្រីទាំងនោះក្នុងគម្ពីរបាលីច្រើនតែឃើញថា "ឧគ្គហិតសិប្បោ" ប្រែថា "អ្នកមានសិល្បៈរៀនស្រេចហើយ" ដូច្នេះ ។ អ្នកដែលបានចុះស្វាមក្នុងផ្លូវសិក្សាសិល្បវិជ្ជា ចេះស្ទាត់ប្រាកដណាស់ ទើបគួរនឹងឲ្យឋានន្តរជាមន្ត្រីធំៗបាន, ព្រោះថា មន្ត្រីទាំងនោះជាអ្នកកាន់បន្ទុកផែនដី បើកកាត់តម្រង់ទៅរកសេចក្តីចំរើន ។

កងគម្ពីរធម្មបទ ត្រង់រឿងវិឌូឌភៈ មានរឿងថា "ព្រះរាជកុមារ ៣ អង្គគឺមួយអង្គព្រះនាមបសេនទិ ជាបុត្ររបស់ស្តេចមហាកោសលក្រុងសាវត្ថី, មួយអង្គព្រះនាមមហាលិ ជាបុត្ររបស់ស្តេចលិច្ឆវីក្រុងវេសាលី, មួយអង្គទៀតព្រះនាមពន្ធុល ជាបុត្ររបស់ស្តេចមល្លៈក្រុងកុសិនារា" ។

ព្រះរាជកុមារទាំង ៣ អង្គនេះបានទៅរៀនសិល្បៈក្នុងសាលាទិសាបាមោក្ខក្រុងតក្កសិលា បានជួបគ្នាសាកសួរត្រកូលនាមគ្នាទៅវិញទៅមក ស្គាល់គ្នាជាកំលាក់ហើយក៏កើតមានស្រឡាញ់ធ្វើជាមិត្តមេត្រីនឹងគ្នា. លុះនៅរៀនសូត្រក្នុងទីនោះបានចេះដឹងសិល្បវិទ្យាចប់ស្រេចហើយ ក៏នាំគ្នាលាគ្រូអាចារ្យត្រឡប់មកនគររបស់ខ្លួនវិញ, បណ្តារាជកុមារទាំងនោះដែលត្រឡប់មកដល់នគររៀងៗខ្លួនហើយ, បសេនទិកុមារ ក៏បានសំដែងឫទ្ធិសិល្បៈថ្វាយសម្តេចព្រះវរបិតា ល្បងមើល ព្រះវរបិតាទ្រង់ពេញព្រះរាជហឫទ័យក្នុងសិល្បវិទ្យារបស់រាជកុមារ ដោយទ្រង់យល់ច្បាស់ថា "បុត្ររបស់អញនេះចេះដឹងប្រសើរមែន ក៏លើករាជកុមារអភិសេកឲ្យសោយរាជ្យ" ។ មហាលិកុមារក៏សំដែងសិល្បៈចំពោះពួកក្សត្រិយ៍លិច្ឆវីដោយសេចក្តីប្រឹងប្រែងខ្លាំងពេកក៏បែកភ្នែកទាំងពីរ ។ មហាលិកុមារទោះបែកព្រះនេត្រនោះហើយក៏គង់ក្សត្រិយ៍លិច្ឆវីលើកឲ្យធ្វើជាអាចារ្យបង្រៀនពួកលិច្ឆវីកុមារតទៅ ។ ចំណែកខាងពន្ធុលកុមារ, ដែលពួកមល្លក្សត្រិយ៍យកឫស្សី ៦០ ដើមហើយយកដែកបុករត្តីស្នូលក្នុង

ដើមឬស្សីទាំង៦០ដើម មិនឲ្យពន្ធលកុមារដឹងថា ឬស្សីមានស្នូលដែក ហើយក៏ចាប់ដាវលោតឡើងកំពស់ ៨១ ហត្ថ រួចកាប់បាច់ឬស្សី ៦០ ដើម នោះឲ្យដាច់ព្រមគ្នាតែចំឡែកត្រង់ដែលឮសំឡេងស្នូលដែកក្រេះៗ ដឹងថាឬស្សីទាំងនោះមានស្នូលដែក ក៏ទឹកតូចចិត្តយំហើយគ្រវែងដាវចោល ពោលថា "ពួកញាតិទាំងនេះគ្មានអ្នកណា ស្រឡាញ់អញប្រាប់ហេតុនេះដល់អញផងសោះ បើដាអញដឹងថាមានដាក់ស្នូលដែកនឹងកាប់ឲ្យដាច់កុំឲ្យឮស្នូរឲ្យសោះ" លំដាប់នោះ ពន្ធលកុមារពោលចំពោះព្រះវរមាតាបិតាថា "ខ្ញុំនឹងសំឡាប់ពួកមល្លក្សត្រិយ៍ទាំងអស់នេះហើយនឹងសោយរាជ្យ", តែព្រះវរមាតាបិតាឃាត់ខ្លាំងពេកក៏អាក់ខានទៅ ។ ពន្ធលកុមារគិតឃើញថាអញនឹងទៅរកសំឡាញ់ឯក្រុងសាវត្ថី រួចក៏លាព្រះវរមាតាបិតាទៅរកបសេនទិកុមារជាសំឡាញ់ក្រុងសាវត្ថី លុះទៅដល់ហើយព្រះបាទបសេនទិ ក៏ទទួលត្រេកអរសោទរយ៉ាងមហិមាដោយគិតថា "សំឡាញ់របស់អញជាអ្នកប្រាជ្ញ ឥឡូវនេះមកដល់ហើយ" ។ ព្រះបាទបសេនទិក៏តាំងពន្ធលកុមារ ក្នុងតំណែងជាសេនាបតីទៅ ។

រឿងរាជកុមារទាំង ៣ អង្គដែលបាននាំមកដោយសង្ខេបប៉ុណ្ណេះ ដើម្បីឲ្យឃើញថាមនុស្សសម័យនោះ ស្រឡាញ់ពេញចិត្តនឹងអ្នកប្រាជ្ញដែលចេះសិល្បវិទ្យា ជ្រើសរើសលើកដំកើងឲ្យធ្វើជាមន្ត្រីក្នុងតំណែងណាមួយដោយស្មោះស្ម័គ្រ, មន្ត្រីនោះគេហៅថា "មន្ត្រីសមសក្តិ" ព្រោះ

ប្រែកបដោយលក្ខណៈនៃការចេះដឹង ធ្វើការប្រែកបដោយព្រហ្មវិហារធម៌ ឲ្យចំរើនប្រយោជន៍ទូទៅដល់ប្រជារាស្ត្រទាំងអស់ ។

ព្រះសម្មាសម្ពុទ្ធរបស់យើងទាំងឡាយ កាលព្រះអង្គនៅជាព្រះពោធិសត្វមិនទាន់បានត្រាស់នៅឡើយ ព្រះអង្គមានព្រះនាមខ្ពរខ្ពាយល្បីល្បាញថា ជាអ្នកចេះដឹងពូកែក្នុងសិល្បវិទ្យាគ្រប់យ៉ាងស្ទើរតែរាល់ជាតិដែលព្រះអង្គកើត ដូចមាននិទានមកក្នុងគម្ពីរបាលី-អដ្ឋកថា ឬជាតកជាច្រើនរឿងណាស់ ។

សិល្បៈទាំងឡាយដែលកើតមានឡើងដោយអំណាចបុព្វបុរសអ្នកឈ្លាសវៃផ្ចិតសិក្សារៀនសូត្រនាំតៗមក នោះមានច្រើនយ៉ាង គឺសិល្បៈខ្លះជាចំណែកជាន់ខ្ពស់, សិល្បៈខ្លះជាចំណែកជាន់ទាបសម្រាប់រាស្ត្រប្រជាទូទៅ; សិល្បៈដែលពោលមកខាងលើមកនោះមិនបានអស់សព្វគ្រប់ទេ ដូចយ៉ាងសិល្បថ្មីៗដែលកើតមានឡើងតាមជំនាន់កាលសម័យក៏នៅមានច្រើនបែបទៀតណាស់ ។ បុគ្គលជាគ្រហស្ថគួរពិនិត្យជ្រើសរើសមើលសិល្បៈណាដែលត្រូវរៀននោះហើយនាំឲ្យកើតប្រយោជន៍, ត្រូវសិក្សាចំពោះសិល្បៈនោះចុះ ។ ដូចយ៉ាងការរកទទួលទានខាងរបរស្រែ, ចំការ, លក់ដូរ របស់គ្រហស្ថដែលថ្នឹកស្ទាត់ប៉ិនប្រសប់ក្នុងការនោះៗ ក៏ហៅថា សិល្បៈដែរ ។ ការងារខាងស្រែចំការ ហៅថាកសិកម្មសិប្បៈ គឺសិល្បៈក្នុងការភ្ជួររាស់ សាបព្រោះ-ដកស្ទូង, ការងារខាងជួញប្រែលក់

ផ្លូវហៅថា វណិជ្ជសិល្បៈ ។ សិល្បៈទាំងអស់មិនចំពោះសិល្បៈណាឡើយ សុទ្ធតែនាំឲ្យបានទ្រព្យសម្បត្តិ តែបើមនុស្សខ្ជិលច្រអូស មិនមានព្យាយាមខ្ជាប់ខ្ជួន មិនមានឧបាយប្រាជ្ញាអមជាមួយផងទេ ក៏បានប្រយោជន៍តិច, លុះតែមានព្យាយាមមានឧបាយយល់ត្រូវល្អ ទើបបានផលប្រយោជន៍ច្រើន ៗ អ្នកដែលគ្មានដីស្រែ, ចំការ ច្រើនតែចេះស្គាល់ខាងវណិជ្ជសិល្បៈគឺរបរខាងការលក់ដូរ, សិល្បៈនេះគេរាប់ថាជាងបំផុត នាំបានទ្រព្យសម្បត្តិឡើងទៅជាអ្នកមានទ្រព្យទៅជាសេដ្ឋី ជាងសិល្បៈឯទៀត ៗ ។

គន្លងផ្លូវនៃវណិជ្ជសិល្បៈនេះជាផ្លូវធំវែងឆ្ងាយ មិនចាប់ចំលងផ្លូវដូចកសិកម្មសិល្បៈទេ, ព្រោះការលក់ដូរនេះ មិនមានកំណត់ផ្លូវ មិនមានកំណត់ទីកន្លែងមួយ ៗ នោះឡើយ ។

ផ្លូវរបស់វណិជ្ជសិល្បៈការជួញប្រែនេះមាន ៤ យ៉ាង:

១- ឃរវណិជ្ជា ការលក់ដូរទំនិញផ្សេង ៗ ដែលទុកដាក់នៅក្នុងផ្ទះក្នុងផ្សារ,

២- ជាករវណិជ្ជា ការលក់ដូរទំនិញផ្សេង ៗ ដែលនៅក្នុងនាវា ទូក ឬកប៉ាល់,

៣- សកដវណិជ្ជា ការលក់ដូរទំនិញផ្សេង ៗ នៅក្នុងរទេះ ឬដឹកនាំដោយរទេះទៅលក់ដូរ,

៤ – ជង្ឃុរណក្ខា   ការលើកម្រាមទំនិញប្រេង ១ គួរតែមែក ឬសម្ភារដែលទៅដោយកំឡាំងស្មាន ។

ពួកជនអ្នកប្រាថ្នាទ្រព្យសម្បត្តិឲ្យឆាប់ចំរើន ដើម្បីឲ្យបានជួបប្រទះនឹងភោគសុខឬហៅថាលាភសុខ ក្នុងលោកនេះ គួរប្រើកំឡាំងព្យាយាមនឹងការត្រិះរិះក្នុងសិល្បៈណាមួយឲ្យរឿយ ៗ ។ គុណជាតិដែលមនុស្សបុថុជ្ជនតែងប្រាថ្នានោះមាន ៤ យ៉ាងគឺ លាភោ បានទ្រព្យឬគុណមួយជាទីពេញចិត្ត ១, យសោ ខ្ពង់ខ្ពស់ដោយបរិវារ ១, បសំសា អ្នកផងសរសើរ ១, សុខំ សប្បាយកាយ-ចិត្ត ១ ។ គុណធម៌ទាំង ៤ នេះហៅថាឥដ្ឋារម្មណ៍គឺជាទីប្រាថ្នាជាទីត្រេកអរ របស់បុថុជ្ជនផងអស់ ។ បុគ្គលអ្នកប្រាថ្នាចំពោះឥដ្ឋារម្មណ៍នេះ; បើគ្រាន់តែប្រាថ្នាចង់បាន តែបើខ្ជិលរួយៈ សេចក្ដីព្យាយាមនាំមុខជាកំឡាំងជួយផង គឺមិនងាយនឹងបានសម្រេចដូចប្រាថ្នាឡើយ, ដូចអ្នកចង់បានប្រេងដូង ឬអ្នកចង់ទៅទន្លេទៅត្រើយម្ខាង, បើមិនមានព្យាយាមពុះបំបែកដូងចុះឆ្កៀលយកខ្ទិះទេ តើដូងចុះនឹងបញ្ចេញប្រេងមកឲ្យដែរឬ? បើមិនមានព្យាយាមណានាំដើរចុះទៅពីម្ខាងត្រើយទៅកន្លែងបុកបាល់ទេ ។ ។ គេបាល់មកចូលនេះគេមនុស្សនៅលើម្ខាងត្រើយបានដែរឬ? ដូងចុះក៏មិនចេញប្រេងឲ្យបាន, ខ្លួនមួកបាល់ក៏ខ្លួនមនុស្សនៅលើម្ខាងត្រើយមិនកើត;

សេចក្ដីនេះយ៉ាងណាមិញ មនុស្សអ្នកចង់បានឥដ្ឋារម្មណ៍ តែបើខ្វះវិរិយៈនិងបញ្ញាក៏មិនងាយនឹងបានចួបប្រទះយ៉ាងនោះដែរ ។

មនុស្សគ្រប់ត្រកូលនីមួយៗ គ្រប់ផ្ទះមួយៗ ដែលមានបងប្អូនកូនចៅច្រើន តែមានដីស្រែចំការតិច ធ្វើមិនបានផលបរិបូណ៌ មិនគ្រប់គ្រាន់ដល់ការចាយវាយគ្នាច្រើន គួរតែរំលែកបំបែកគ្នាចេញខ្លះ ដើម្បីនឹងបែកមុខគ្នា សិក្សារៀនសូត្រវិជ្ជាសិល្បៈផ្សេងៗ ឬគួរបែកមុខរបររកទទួលទានដោយសេចក្ដីព្យាយាមប្រឹងប្រែងដោយខ្លួនៗ ពីគ្នាគឺអ្នកខ្លះរកទទួលទានរបរនេះ អ្នកខ្លះរកទទួលទានរបរនោះ, អ្នកខ្លះស្វះស្វែងទៅស្រុកឆ្ងាយ, អ្នកខ្លះនៅជិតៗ, អ្នកខ្លះទៅខាងជើងគោក, អ្នកខ្លះទៅខាងជើងទឹក អ្នកខ្លះចេញទៅទិសឯណេះ, អ្នកខ្លះចេញទៅទិសឯណោះ ។

កាលសម័យរបស់ស្រុកទេសនីមួយ ៗ ក្នុងលោកឥឡូវនេះចង្អៀត មិនមែនធូរទូលាយដូចកាលសម័យពីដើមទេ ដូចជាយើងបានប្រទះមកហើយ, បើកាលសម័យចេះតែវិលអណ្ដែតដើរលឿនចង្អៀតញឹកញាប់យ៉ាងនេះ, យើងជាអ្នកកើតមកជួតគោនក្រោមម្លប់ របស់កាលវេលាក្រដើរ ឈរ អង្គុយ ដេក លើផែនដី; យើងត្រូវតែប្រើកំឡាំងកាយចាយកំឡាំងនៃសេចក្ដីព្យាយាម, សេចក្ដីត្រិះរិះគិតគូរឲ្យទៀងទៀងញឹកញាប់ជឿនលឿនតាមចង្វាក់នៃកាលសម័យរបស់ស្រុកទេស ទើបឈ្មោះថាជាអ្នកស្គាល់សេចក្ដីចំរើនមែន ។ កាលវេលាស្រុកទេសពីដើមបាក់

ដូចជាដើរយឺតៗ រង្គើលៗ ព្រោះមនុស្សតិច, បុព្វបុរសគឺជីដូនជីតាក្នុងកាលមុនរបស់យើងក៏ប្រកបការងារព្យាយាមយឺតៗ រង្គើលៗ ដូច្នោះដែរ រូបយើងឥឡូវនេះ នឹងខ្ចីយកកាលសម័យជាន់នោះមកប្រើជាគំរូដូច្នោះ ពុំសមតាមកាលវេលាឡើយ, ប្រៀបដូចជាតូរ្យតន្ត្រីដែលពួកអ្នកលេងដេញជុំផ្គុំគ្នា ឲ្យមានបទភ្លេងញឹកញាប់ បំណែកខាងអ្នកច្រៀងក៏ត្រូវតែច្រៀងលោតសំរឡូងបទនោះឲ្យញឹកញាប់ គឺដូរតាមចង្វាក់ភ្លេងដូច្នោះដែរ ទាំងអ្នករាំអ្នកឡេក ក៏ត្រូវតែរាំត្រូវតែឡេកឲ្យញាប់តាមភ្លេងនោះទៀតដែរ ទើបហៅថា អ្នកលេងមានវិធីបទប្រាកដណាស់ វៃក្នុងការច្រៀងរាំ, បើច្រៀងរាំ ឬ ខុសពីចង្វាក់ភ្លេងឈ្មោះថាអ្នកលេងមិនប្រសប់ក្នុងការលេង ។

កាលសម័យស្រុកទេសឥឡូវនេះចម្រើនញឹកញាប់ រយើងក៏ត្រូវប្រកបកិច្ចការឲ្យញឹកញាប់ លឿនរហ័សតាមរយៈចង្វាក់នៃកាលសម័យ ដូចអធិប្បាយមកនេះឯង ។

ចប់បរិយាយសិប្បកថាតែប៉ុណ្ណេះ ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាសិរីក្ខិត កៅ-ស៊ឹម អ្នកគ្រូគ្រាសិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង


*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

ឃុនឧត្ដមប្រីជា បាប-ពិន ... បណ្ដាំ ................. ៤៥១
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម .... ពិធីបូជាសពអ្នកឧកញ៉ា ជុំ-មៅ...... ៤៥៩
លោក ហាន់-យេង ...... រឿងកំពូលកំសត់ (តមក)........ ៤៦៤
លោក ញ៉ុក-នូ ...... ច្បាប់ក្រមបរិយាយ (តមក)....... ៤៧៧
ព្រះសមុហ៍ឃោសាចារ្យ យូរ-ប៊ុណ្ណ សុវណ្ណសាមជាតក ពាក្យកាព្យ (តមកនិងចប់) ៤៨៣

*ផ្នែកសាសនា*

ពុទ្ធសាសនបណ្ឌិត្យ .... អំពីព្រះរាជទានតាំងសមណស័ក្តិ នៅវត្តឧណ្ណាលោម ........... ៤៩១
អ្នកអាចារ្យ គី-តិមស៊ុរ .... មត្តាតុភាជជាតក .......... ៤៩៥



ឆ្នាំទី ១៦ — លេខ ៩ ខែសេបតេម្ប៊ើ ឆ្នាំ ១៩៤៤ — ថ្លៃជាវៈ ១ ឆ្នាំ ១៥ រៀល ។



№ 9

M·8° 1+61
12-X-4

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire: Luong Nibandhamantri Nhok-Thêm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse: Preah kru Paññalikhito Kao-Sim, Surveillant général de l'École Supérieure de Pāli.

## *TABLE DES MATIÈRES*

### Partie littéraire:


| | | Pages |
|---|---|---|
| K'ŭn Ŏtdăm Preichea Chap-Pinn . . . . . . | Băndau (devinettes cambodgiennes) | 451 |
| Luong Nipoumontrei Nhok-Thêm. . . . . . | Compte-rendu de l'incinération de l'Oknha Choum-Mau . . . . | 459 |
| Monsieur Han-Yéng. . . . | Kămpul kămsăt, roman (suite) . . | 464 |
| Monsieur Nheuk-Nou. . . | Chbáp krĭm bárĭyay (suite) . . . | 477 |
| Prĕah sămtĕk 'ósachar You-Ponn . . . . . . | Suvannasāmajātaka, poème (suite et fin) . . . . . . . . . . . . | 483 |


### Partie religieuse:


| | | |
|---|---|---|
| Institut Bouddhique . . . | Compte-rendu de la remise solennelle des titres aux nouvaux Reachea kĕană, à Vĕat Unnalom . . . . . . . . . . | 491 |
| Achar Ky-Kimsiv . . . . | Mandhāturājajātaka. . . . . . . . | 495 |


16e année — N° 9. Septembre 1944 — Abonnement: un an 15$00.

# បណ្ដាំ

## ពាក្យផ្ដើម

កម្ពុជរដ្ឋយើង មានកវីខ្មែរជាតិប្រឌិតពាក្យបណ្ដាំច្រើនបែប មានប្រការផ្សេងៗ ជាចំណោទបញ្ឆិតបញ្ឆៀង ប្រៀបប្រដូចអំពីភាពលំ-នាំ ទាំងកិរិយានៃវត្ថុ-រុក្ខា-លតា-សត្វ ទាំងមនុស្ស ទុកសម្រាប់ជនានុជន បណ្ដាំគ្នាទៅវិញទៅមក តាមសប្បាយ ឲ្យស្រាយ ឲ្យរក, ជនានុជន ក៏និយមយកជាគតិ បានបណ្ដាំគ្នាតៗមក ជាយូរអង្វែងហើយ ៗ ពួកអ្នកដែលចេះពាក្យបណ្ដាំ កាលនឹងបណ្ដាំគេ តែងដាក់កម្រិតគេជាមុនយ៉ាងម៉ឺងម៉ាត់ ថា "បើរកឃើញរួចខ្លួន, បើរកមិនឃើញទេ នឹងលក់" កាលបើអ្នករក, រកមិនឃើញ អ្នកបណ្ដាំគេក៏លក់តាមត្រូវការ ៗ ពាក្យលក់មានប្រការផ្សេងៗ តាមយោបល់អ្នកបណ្ដាំ ប្រឌិតឡើងខ្លះ តាមចាំតៗគ្នាមកខ្លះ, ស្រេចនឹងអ្នកបណ្ដាំគេចង់លក់បែបណា ក៏លក់បែបនោះ, បណ្ដាពាក្យលក់ទាំងអស់ សុទ្ធតែជាពាក្យបន្តុះបង្អាប់បន្ទាបបន្ថោក ហើយសុទ្ធតែចេញចំណោះអ្នករក ដើម្បីឲ្យឈឺចិត្តខំគិតរក. ដូចជា "លក់ឈ្មោះ ក ទៅដល់ស្រុកដីក្រហម ឲ្យយកដង្កូវ ៥ ក្អម មកកាយលិទ្ធៗ; លក់ឈ្មោះ ខ ទៅដល់ស្រុកបាសាក់ឲ្យគេរំយោគដាក់ ចាក់ដៃបាក់ជើង; លក់ឈ្មោះ គ ទៅដល់ស្រុកស្រែអំបិល ម្ដាយត្រនិលអាពុកត្រ-ឡោល ម្ដាយចុងត្រដោកអាពុកចុងណែនណាន់" ជាដើម; លក់ហើយ ទើបស្រាយបណ្ដាំនោះប្រាប់ៗ បើអ្នករកខ្លាចគេថាកតាបខ្លួន មិនចង់ឲ្យ

ទេលក់ ត្រូវជូនបណ្ណាការដល់គេ, កាលបើជូនហើយ គេក៏ឈប់លក់ គេស្រាយប្រាប់មក ។ ឯពាក្យជូនបណ្ណាការនោះសោត ក៏មានច្រើនបែប តាមអ្នករកគេចេះគេត្រូវការ ដូចជា "ជូនប្រាក់១ទូក ជូនឈូក ១ ត្រពាំង ជូនមាស ៥ ឃ្លាំង ៥០១ រទេះ លោះខ្ញុំចិនទៅកាប់ចម្ការ លោះខ្ញុំផ្កាទៅជួញសំពៅ មានទាំងមេនាំងមកទៅ បែរមុខបែរក្រោយ ដៃ ១ ស្ទួយទឹក ដៃ ១ ស្ទួយប្រេង ប្រាក់ ៥ ជញ្ជីង ជូនដល់ព្រះចក ប្រាក់ ៥ ជង្រឹក ជូនអ្នកបណ្ដៅ តើអ្នកយកឬទេ?" ជាដើម; អ្នកបណ្ដៅទទួលព្រមថា "យកហើយ" ក៏បណ្ដៅផ្សេងតទៅទៀត ។

បើនឹងស្រាវជ្រាវរកដើមកំណើតថា ក្នុងសម័យណា គេណា ជាអ្នកផ្ដើមបង្កើតពាក្យបណ្ដៅបែបណាឡើងមុនគេនោះ ពុំអាចដឹងបាន; ដឹងបានខ្លះតែត្រឹមថា ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះហរិរក្សរាមា-ឥស្សរាធិបតី ព្រះអង្គដួង (ក្នុងព្រះបរមៈកោដ្ឋ) នោះប្រជាជនច្រើនចូលចិត្តបណ្ដៅ, ព្រះករុណាជាម្ចាស់ជីវិតលើត្បូងក៏ទ្រង់សព្វព្រះរាជហឫទ័យដែរ ទ្រង់បានតាំងផ្ដើមបង្កើតពាក្យបណ្ដៅដោយព្រះរាជយោបល់របស់ព្រះអង្គជាច្រើនបែប មានបណ្ដៅដើមទ្រមូងសក ថា "គល់ជាភ្លើងអ្នកផង, កណ្ដាលជាគង, ចុងជាបក្សី" ជាដើម ដែលមានក្នុងទីនេះ ត្រង់លេខ ៦៦ ។

បណ្ដៅដែលមានចំនួនច្រើនជាអនេកប្បការ មិនមែនកើតឡើងដោយស្នាដៃនៃកវីតែម្នាក់ ក្នុងសម័យតែមួយទេ គឺកើតឡើងដោយ

ករច្រើននាក់ ច្រើនសម័យ ៗ បណ្ដាពាក្យបណ្ដាំទាំងអស់នោះ មានបណ្ដាំជាច្រើន ត្រឹមត្រូវល្អណាស់ គួរឲ្យទុកស៊ប់អ្នកដែលផ្ដើមប្រឌិតឡើងជាដំបូងបំផុតនោះក្រៃពេក ដូចបណ្ដាំដំបូកត្រី ថា "រុក្ខាលតាព័ទ្ធបុង មច្ឆាពួនកង ពួះប្របអគ្គី" បណ្ដាំល្មើមាស ថា "លតានាមជាសុវណ្ណ តែងដុះព័ទ្ធព័ន្ធ នាដើមព្រឹក្សា" ជាដើម; បណ្ដាំអស់នេះ អ្នកល្ងង់ ៗ មិនអាចប្រឌិតឡើងបានទេ, លុះតែអ្នកចេះភាសាបាលី ភាសាសំស្ក្រឹត ទាំងចេះពាក្យឃ្លោងហត់ចត់ ទើបប្រឌិតឡើងបាន ។

ខ្ញុំ ពេញចិត្តខាងបណ្ដាំជាបុរាណគតិនេះ បានជាខំស្វះស្វែងសួរ ចាស់ ៗ ក្នុងស្រុកនិគមផ្សេង ៗ បានចំនួន ២១៣ បែបយកមកប្រមូលរបៀបរៀងទុកក្នុងទីនេះ ដើម្បីរក្សាគ្រឿងដំណែលរបស់ខ្មែរតាំងពីបុរាណ ឲ្យបានឋិតថេរទៅកាលតទៅមុខ ទុកជាប្រយោជន៍ដល់ខ្មែរជំនាន់ក្រោយ ដោយយល់ថាជាកិច្ចដ៏ឥតទោស ជាគ្រឿងឲ្យកើតសតិបញ្ញាដល់អ្នកដែលត្រូវការ ។

ខ្ញុំសូមទទួលអំណរគុណយ៉ាងច្រើនចំពោះលោក-អ្នកដែលបានឲ្យពាក្យបណ្ដាំនោះ ៗ ជាអំណោយដល់ខ្ញុំ, សូមឲ្យលោកអ្នកបានសេចក្ដីសុខ សេចក្ដីចម្រើន ដោយផលនៃអំណោយនេះ ។

ថ្ងៃ ១០ ខែមេ ឆ្នាំ ១៩៤៤

ឃុន ឧត្តមប្រីជា ហាប-ពិន និពន្ធករ

នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ដៅ　　　　　　　　　　　　ដោះស្រាយ

១- ឯកអង្គទ្រង់នាមបរ ក្នុងស្របញ៉ែរ ភ្លុកហើយ
ក្រហែមផង? . . . . . . . . . . . . . . . . ក្ដុកកៃ

២- ឯកអង្គទ្រង់នាមបត្តិ ពាញយ៉ះជើងពីរ បញ្ចូល
គ្រាប់មួយ? . . . . . . . . . . . . . . . . ប្រណាក

៣- ឯកអង្គទ្រង់នាមប្រត្យ៉ែក ក្នុងដុំប្រាក់ ដុំមាស
សង់ខាង? . . . . . . . . . . . . . . . . ក្ងោក

៤- ឯកអង្គទ្រង់នាមឯក ធំខ្ពស់អនេក តែពាំបជាង
ស្មៅ? . . . . . . . . . . . . . . . . ភ្នំ

៥- ឯកអង្គទ្រង់នាមព្រឹក្សា ពុកមាត់ដូចផ្កា ក្រយៅដុំ
ខ្វិន មានកូនជាសង្ក្រស្ងួន កូនបាត់ពាំខ្ងួន មិន
ដឹងខ្លួនឡើយ? . . . . . . . . . . . . . . ផញ្ញើង

៦- ឯកអង្គទ្រង់នាមបក្សា មានចិត្តហានក្លា លើស
លុបអស់សត្វនានា ឃើញមនុស្សស្ទុះទៅចំពា
ហៅហានមហិមារកសត្វនានាស្មើគ្មាន? . . . . មូស

៧- ឯកអង្គទ្រង់នាមបក្សា កងធំជម្ពូរ ចង្កេះវៀវ៉ៃ
មានជើងតែមួយទល់ដី ប្រែងប្រាណឃ្លាតខ្ចី
គ្រឺវ៉ែតស្អួង ហោះឯអាកាសទទ្ទេង ក្នុងនោះ

| បណ្តៅ | ដោះស្រាយ |
| --- | --- |
| ឯង ដូចគល់រថាំ ហិចហោះផ្ទុកផ្ទះទន្ទាំ ដូច ដៃគេកាំ តាមភ្នែកមហោស្រព? . . . . . | ខ្លែងក្ពង |
| ៨– ឯកអង្គទ្រង់នាមបក្សី កន្ទុយអូសដី ពាំឈើហោះ ទៀន? . . . . . . . . . . . . . . . . | ខ្លែងក្ពង |
| ៩– ឯកអង្គទ្រង់នាមកាត់ មេទៅផុតមិនយំរក កាលណា មេដល់មក លើកបំពៅទើបស្រែកយំ? . . | ស្គរដៃ |
| ១០– ឯកអង្គទ្រង់នាមមច្ឆា ក្រកលៀនណា សំណា ដៃវែងជាងខ្លួន? . . . . . . . . . . . . | បង្កង |
| ១១ – ឯកអង្គ ខាំមិនទំពា ទុកមួយអន្ទើ, ឯកអង្គ លេបពន្ធំ លេបពុំទូបុង? . . . . . . . . . | អង្គប់កណ្តារ, ដំបុកត្រី |
| ១២ – ព្រឹក្សាដុះនាខាងផ្ទូរ អ្នកផងដើរទៅ ហៅឯង ឡើយឯង? . . . . . . . . . . . . . . | ដើមភ្លូបាត, កណ្តាលបាត ។ល។ |
| ១៣ – ព្រឹក្សានាមជាបក្សី មិនដុះនៅដី ដុះតែលើគេ? | បញ្ញើក្អែក |
| ១៤ – ព្រឹក្សាផ្កាឯបុង ផ្លែឯគល់? . . . . . . . . | ពោត |
| ១៥ – ព្រឹក្សាដុះនាខាងផ្ទូរ អ្នកផងគេហៅ ថាក់ផ្លាស ណាស់? . . . . . . . . . . . . . . . | ម្ទេសផ្លាស (ម្ទេសខ្លាំង) |

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ១៦ - ព្រឹក្សាគេកាត់ជាបំណាក់ មានគសំពេនព័ន្ធ លើ-ដើមព្រឹក្សា មានតាំងដូង មានតាំងស្វា មានតាំងថន់គណាបា មានតាំងកដកស្សុគរ? . . . | ទ្រ |
| ១៧ - ព្រឹក្សាដុះនាមាត់ស្ទឹង អ្នកផងទន្ទឹង ទន់ហើយណាទៅ? . . . . . . . . . . . . . . . . | ដើមរគ្នា |
| ១៨ - ព្រឹក្សាដុះនាខាងផ្លូវ អ្នកផងគេហៅ ថាកផ្លូវណាស់? . . . . . . . . . . . . . . . . | ម្លូរព្រីក |
| ១៩ - ព្រឹក្សាដុះនៅព្រៃព្រៅ អ្នកផងគេហៅ ថាកមកថ្មី? . . . . . . . . . . . . . . . . . . | ដើមភ្ញៀវ |
| ២០ - សត្វមួយមកពីស្រុកឯជើង ក្បាលទើងម៉េង ជើងប៉ុនស្នប់? . . . . . . . . . . . . . . . | ដំរី |
| ២១ - សត្វមួយមកពីស្រុកចិន កន្ទុយសិខរិន ស៊ីក្បាលមនុស្ស? . . . . . . . . . . . . . . . . | កន្ត្រៃ |
| ២២ - សត្វមួយមកពីស្រុកលើ បេះធ្មេញអំពើ ឲ្យមនុស្សឆ្កួតអស់ទាំងស្រុក? . . . . . . . . . . . | ចាបស៊ីស្រូវស្រែ |
| ២៣ - សត្វបួនចួនឈ្មោះតែមួយ សត្វបីពាក់ស្រួយ សត្វមួយពាក់ទន់? . . . . . . . . . . . | ក្អែកគោក, ក្អែកទឹក, អណ្ដើកក្អែក, ត្រីក្អែក, |

បណ្ដៅ　　　　　　　　　　　　ដោះស្រាយ

២៤ - សត្វបួនបួនឈ្មោះដូចគ្នា: មួយនៅគង្គា, មួយនៅអាកាស, មួយនៅព្រៃផ្គសផ្កាស, មួយនៅខ្ញុំគេ? . . . . . . . . . . . . . . . . . . ក្រពើ, ផ្កាយក្រពើ, វល្លិ៍ក្រពើ, ក្បាលក្រពើរទេះ

២៥ - សត្វបួនបួនឈ្មោះតែមួយ: សត្វមួយតែងព្រួយ បារម្ភទ្រព្យគេ, សត្វមួយបិតនៅ នាអាកាសេ អាចារ្យលោកប្រែ ឃើញយប់បាត់ថ្ងៃ, សត្វមួយនៅនា ទីជលាស័យ ចិត្តកាចក្រៃ សាហាវយង់ឃ្នង, សត្វមួយបិតនៅ នាព្រឹក្សាផង អាចារ្យលោកចង ជាពាក្យបណ្ដៅ? . . . . ក្បាលក្រពើរទេះ, ផ្កាយក្រពើ, សត្វក្រពើ, វល្លិ៍ក្រពើ

២៦ - សត្វមានឈ្មោះតែមួយ មានស្លាបប្រាំមួយ មានជើងដប់ពីរ? . . . . . . . . . . . . សេះ, ក្រសេះ, កណ្ដូបសេះ

២៧ - សត្វមួយមកពីស្រុកឯណេង ក្បាលទូលភ្លើង ជើងមានស្នែង? . . . . . . . . . . . . មាន់

២៨ - សត្វមួយឥតឆ្អឹង កើយតែខ្នង ដល់មាន់រងាវយូរ ចេញដួងពីគូត? . . . . . . . . . . . . ក

បញ្ហា ដោះស្រាយ

២៩- សត្វមួយមកពីស្រុកឯលិច កន្ទុយវែងៗ ច្រមុះមានចែង? ជ្រូក

៣០ – សត្វមួយមកពីដើមមេឃ ឃ្លានអាហារខ្លាំងពេក
ចាប់បានទន្សាយវែងក្បាល ទំពាមិនឲ្យឮ
ស្រោក ខ្លាចឮដល់មនុស្សលោក គេក្រែកទៀត
ញ៉ែ? . . . . . . . . . . . . . . . . . . រាហូចាប់ច័ន្ទ

៣១ – សត្វមួយមកពីស្រុកឯលិច កក់តិចៗ ដើរកកប់
វយ? . . . . . . . . . . . . . . . . . . ក្អែប, ម្រឹមព្រះ

៣២ – សត្វមួយទំលើខ្សែដែក ក្អកប៉ុនពន់មាន់? . . . ភ្លើងអគ្គិសនី

៣៣ – សត្វមួយនៅក្នុងរណ្ដៅ ឥតមានគេហៅ
ឆ្លើយទៀតខ្លួនឯង(*)? . . . . . . . . . . . ឆោម

៣៤ – សត្វមួយអង្គុយខ្ពស់ដាំឈើ ឃើញគ្នាកាមក
ព្រើនឆ្លើយតាមស៊ីញ? . . . . . . . . . . . . ឆ្កែ

៣៥ – សត្វមួយដើរទ្រក់ៗ លើទំពក់ចូលព្រៃ? . . . . ឆ្កែ

៣៦ – សត្វមួយនៅក្នុងទឹកកក់ៗ ខ្លួនទន់ទៀតឡោក
ឥតឆ្អឹងឥតឆ្អែង? . . . . . . . . . . . . . ឈើង

៣៧– ដើមប៉ុនអង្រែ ផ្លែប៉ុនអង្រែក? . . . . . . . . . ទន្សែ

---

* ចំលើយជា ផញ់ទាប មុតច្រមុះ ។ ។ (មានត)

# អ្នកឧកញ៉ា ជុំ-ម៉ៅ អនុមន្ត្រីលេខ ៣ នៅក្រសួងសេដ្ឋកិច្ច

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

រៀបរៀង

អ្នកឧកញ៉ា ជុំ-ម៉ៅ ទទួលអនិច្ចកម្មនៅមន្ទីរពេទ្យធំក្រុងភ្នំពេញ ដោយរោគប៉ុកនឹងធ្លាក់ឈាម ក្នុងថ្ងៃអាទិត្យ ២០ អ៊ូត ១៩៤៤ ក្នុងកំណត់អាយុ ៤៤ ឆ្នាំ ។ ពួកក្រុមគ្រួសារនិងក្រុមញាតិបាននាំសពអ្នកឧកញ៉ាយកមកដំកល់ទុកនៅគេហស្ថាន ផ្លូវបេលក្រិ ក្រុងភ្នំពេញ ដើម្បីធ្វើបុណ្យបញ្ជូនផលទៅដល់វិញ្ញាណក្ខន្ធរបស់សពតាមទំនៀមស្រុក ។

ថ្ងៃ ២១ អ៊ូត ឆ្នាំ ១៩៤៤ វេលាម៉ោង ១៦ គេបានរំកិលសពចុះពីគេហស្ថានយកទៅដំកល់លើរទេះសេះ ដើម្បីនាំដង្ហែទៅបូជានៅទីប៉ាឆា មុខវត្តបទុមវតី ក្រុងភ្នំពេញ ។ នៅឱកាសនោះ មានក្រុមគ្រួសារនិងញាតិមិត្តទាំងឡាយជាចំនួនច្រើន ព្រមដោយពួកអ្នករាជការតូច-ធំជាច្រើនក្រុមច្រើនក្រសួង ក្នុងក្រុងភ្នំពេញ ស័ងបាននាំគ្នាទៅជួយហែហមគមសពអ្នកឧកញ៉ាជាអឹកធឹក ។ នៅតាមរយៈផ្លូវដែលដង្ហែសពទៅនោះ គេបាននិមន្តព្រះសង្ឃនៅវត្តនានាឲ្យមករង់ចាំបង្សុកូលសពជាច្រើនរយៈវៀង ៗ ទៅ ទម្រាំតែទៅដល់ទីប៉ាឆា មុខវត្តបទុមវតី ។

លុះគេកែលសពដាក់ដំកល់ក្នុងបាកុំយ៉ិតហើយ ទើបមានក្រុមទាហានកងកិត្តិយស ១ ក្រុមមកឈរតំពាប់ជាកិត្តិយសដល់សពអ្នកឧកញ៉ាជាបដល់វេលាបូជាភ្លើងសព ។ មុនពេលបូជាសព គេបាននិមន្តព្រះសង្ឃវត្តបទុមវតីមកធាតទីងបង្សុកូលតាមទំនៀម ។ នៅឱកាសនោះនៅមានមន្ត្រីធំ-តូច និងញាតិមិត្តជាច្រើនតាមទៅជួយក្នុងពិធីបូជាសពទាំងសំដែងសេចក្ដីគោរពអាល័យដល់សពអ្នកឧកញ៉ា ។ ក្នុងចំណោមពួកមន្ត្រីទាំងនោះ ខាងមន្ត្រីបារាំង មានលោកនីកូឡាស់ ជានាយកក្រសួងប្រៃសាសនោបាយ តំណាងលោកឡឺរេស៊ីដង់ស៊ុបេរីយើរជាដើម ។ ខាងមន្ត្រីខ្មែរ មានលោកអ្នកឧកញ៉ាអគ្គមហាសេនា អ៊ុង-អ៊ុ រដ្ឋមន្ត្រីក្រសួងកំង. ព្រះឃ្លាំងទំនិញកម្មការជាដើម ។ ចំណែកខាងបព្វជិត មានព្រះតេជព្រះគុណព្រះពោធិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ជាដើម ។

កាលពួកភ្ញៀវបានមកសន្និបាតជួបជុំព្រមព្រៀងគ្នាហើយ ទើបគេចែកផ្កាច័ន្ទន៍សម្រាប់ដាក់បូជាសពដល់ពួកភ្ញៀវទាំងអស់ រួចហើយទើបគេអញ្ជើញលោកនីកូឡាស់ តំណាងលោកឡឺរេស៊ីដង់ស៊ុបេរីយើរ ឲ្យដុតឆ្នួនភ្លើងជាដំបូង ហើយពួកមន្ត្រីតូច-ធំព្រមដោយពួកញាតិមិត្តក៏នាំគ្នាតសងទៅដើម្បីដាក់ផ្កាច័ន្ទន៍បូជាសពតាមទំនៀម ។

* *
*

## អំពីគុណសម្បត្តិអ្នកឧកញ៉ា ជុំ-ម៉ៅ

### កាលនៅធ្វើការក្នុងពុទ្ធសាសនបណ្ឌិត្យ

អ្នកឧកញ៉ា ជុំ-ម៉ៅ បានចូលទៅធ្វើការក្នុងព្រះរាជបណ្ណាល័យកម្ពុជា គឺមន្ទីរពុទ្ធសាសនបណ្ឌិត្យសព្វថ្ងៃនេះ ក្នុងឆ្នាំ ១៩២៦ ក្នុងសម័យដែលលោកស្រី ស៊ុយសាន កាប៉ឺឡែស ជាចាងហ្វាងព្រះរាជបណ្ណាល័យ ។ វេលានោះ អ្នកឧកញ៉ាទើបនឹងមានស័ក្តិយសជាទីក្រមការបំរើរាជការនៅឡើយ ។ នៅវេលាដែលក្រមការ ជុំ-ម៉ៅ នៅធ្វើការក្នុងព្រះរាជបណ្ណាល័យនោះ លោកបានខំយកចិត្តទុកដាក់ពិនិត្យសិក្សាអក្សរសាស្ត្រខ្មែរ ត្រាតែបានចេះដឹងស្ទាត់ជំនាញបានជារាជការតាំងឲ្យធ្វើជាក្រមជំនុំ ១ ក្នុងពួកក្រមជំនុំវចនានុក្រមខ្មែរ ដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយសព្វថ្ងៃនេះ ។ កិច្ចការស្នាដៃធំៗ ដែលលោកបានធ្វើទុកក្នុងពុទ្ធសាសនបណ្ឌិត្យ ដែលរាជការបានបោះពុម្ពផ្សាយរួចមកហើយ ច្រើនតែជារឿងដែលលោកបានប្រែពីភាសាបារាំងសែសមកជាខេមរភាសា គឺ សៀវភៅ អំពីព្រះពុទ្ធសាសនា ១, ព្រះរាជប្រវត្តិព្រះបាទជ័យវរ្ម័នទីប្រាំពីរ ១, រឿងឯកសហស្សរាត្រី ឬ មួយពាន់មួយយប់ ១, (តែរឿងខាងក្រោយនេះ ប្រែមិនទាន់ចប់ ដោយហេតុត្រូវផ្លាស់ទៅធ្វើការនៅទីដទៃទៀត) ។

ក្រៅអំពីកិច្ចការស្នាដៃខាងលើនេះ លោកត្រូវទទួលមុខការរៀបចំផ្សំរឿងសម្រាប់ចុះផ្សាយ ក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ដែលត្រូវបោះពុម្ពផ្សាយរាល់ៗខែ ចាប់តាំងពីទស្សនាវដ្ដីនេះកកើតឡើងក្នុងឆ្នាំដំបូង (១៩២៦) ។ ហេតុនេះហើយ បានជាគេឃើញមានឈ្មោះលោកគ្រូមករ ជុំ-មៅ ជាប់នៅនឹងរឿងទាំងឡាយ ដែលមានចុះផ្សាយក្នុងកម្ពុជសុរិយា នៅវេលាដែលលោកធ្វើការក្នុងមន្ទីរនេះ អស់រយៈវេលា ៨ ឆ្នាំ គឺ តាំងពីឆ្នាំ ១៩២៦ រហូតដល់ឆ្នាំ ១៩៣៤ ។

មួយវិញទៀត កិច្ចការដែលត្រូវបកប្រែភាសាក្ដី ការប្រែរឿងឬសេចក្ដីផ្សេងៗ ពីបារាំងមកជាខ្មែរ ដូចជាសុន្ទរកថានិងបាឋកថាជាដើមក្ដី ទាំងនេះជាមុខក្រសួងរបស់អ្នកឧកញ៉ា ជុំ-មៅ ទាំងអស់ ត្រាតែលោកមានកេរ្តិ៍ឈ្មោះយ៉ាងល្បីល្បាញ ក្នុងវិជ្ជាមុខនេះ ។ ក្រៅអំពីនេះ លោកត្រូវទទួលបង្គាប់ផ្ទាល់អំពីចាងហ្វាងក្រសួង ដើម្បីបង្គាប់បញ្ជាកិច្ចការសព្វសព៌ ដល់ពួកភ្នាក់ងារក្នុងក្រសួង ។ កិច្ចការទាំងពួងក៏ប្រព្រឹត្តទៅបានដោយរៀបរយស្រួល មិនដែលមានរឿងនាំឲ្យកើតថ្នាំងថ្នាក់អាក់អន់ចិត្តដល់អ្នកធ្វើការក្រោមបង្គាប់ដល់ម្ដងឡើយ ។ ពួកភ្នាក់ងារក្នុងមន្ទីរពុម្ពសាសនបណ្ឌិត្យ តែងមានចិត្តស្រឡាញ់រាប់អានលោក ដរាបដល់លោកចេញចាកចោលមន្ទីរនេះទៅ ។ សឹងមានសេចក្ដីអាឡោះអាល័យស្ដាយរាល់ៗគ្នា ។

អ្នកទេកញ្ញា ជុំ-មៅ ក្នុងរយៈវេលាដែលលោកនៅធ្វើការក្នុងព្រះរាជបណ្ណាល័យនោះ សឲ្យគេឃើញសមត្ថភាពរបស់លោកយ៉ាងជាក់ច្បាស់ គឺជាអ្នកមានសតិបញ្ញា និងបដិភាណភាពវៃជាចំណាប់. អាចពេលកិច្ចការពាក់ព្រៀវខុសត្រូវបានដោយស្រួលពន់, ជាអ្នកស្ទាត់ជំនាញក្នុងកិច្ចការជាមុខក្រសួងរបស់ខ្លួន, ចំពោះវិជ្ជាប្រែភាសា ពីបារាំងមកជាខ្មែរនោះ ទុកជាគ្រូកែឯក ៗ បាន, ព្រោះលោកនេះជាអ្នកមានចំណេះចេះដឹងល្អ ទាំងខាងភាសាខ្មែរ ទាំងខាងភាសាបារាំង ។

ពុទ្ធសាសនបណ្ឌិត្យមានសេចក្ដីស្ដាយ និងអាឡោះអាល័យជាពន្ទឹកចំពោះមរណភាពនៃមិត្តមួយនេះ ដែលធ្លាប់ធ្វើការមានថ្វីដៃមកហើយ ៗ មិនគួរគប្បីសោះឡើយ ដែលមច្ចុរាជមកបង្ផាច់ផ្ដិលជីវិតមនុស្ស មានអាយុមិនទាន់ដល់កំណត់អាយុក្ខ័យត្រឹម ៤៤ ឆ្នាំប៉ុណ្ណោះ, នៅក្នុងវ័យកំពុងពេញកំឡាំងកាយ-កំឡាំងសតិបញ្ញាស្មារតី.. ..ឱអនិច្ចា! គួរឲ្យស្រណោះ គួរឲ្យអាឡោះអាល័យ. គួរឲ្យសោកស្ដាយណាស់ ។

ឱ! មច្ចុរាជអ្នកឥតមេត្តាប្រណី ឱ! សង្សារវដ្ដសត្វទាំងឡាយមិនទៀងសោះឡើយ ។

# កំពូលកំសត់

## លោកហាន់-យ៉េង រៀបរៀង

(តមក)

លុះមេប្រយោគហៅឈ្មោះឲ្យចូលប្រឡងហើយ កុមារទាំងឡាយក៏ស្រូចូលទៅ មានចិត្តថប់បារម្ភតែរៀងខ្លួន ក៏តក់ភ័យញ័រជើងដូចជាស្រាលខ្លួនដើរស្ទើរមិនជាប់ដី នាំគ្នាអង្គុយតាមលេខរបស់ខ្លួនរួចប្រុងប្រៀបជក់បន្ទាត់ ចាំមេប្រយោគហៅមេសូត្រ ខ្លះចាប់ដងប៉ាកកាញ័រដៃសរសេរពុំចង់កើត ។ ចេញប្រយោគមួយមុខរួចហើយ ក៏ឈប់សម្រាក ៥ នាទី នាំគ្នាសាកសួរពីពាក្យសរសេរចង់ដឹងខុសត្រូវ ឈ្មោះណាធ្វើខុសតិចក៏ត្រេកអរសាទរឡើង អ្នកណាធ្វើខុសច្រើនក៏មុខខ្មៅប៉ែចង់យំ ។

លុះប្រឡងគ្រប់មុខហើយក៏រង់ចាំដល់សំរេច ថ្ងៃនោះឯងអ្នកប្រឡងទាំងប៉ុន្មាន អរផងភ័យផងមិនច្បាស់ក្នុងចិត្តតើខ្លួនជាប់ឬធ្លាក់ ដល់គេហៅថាឈ្មោះខ្លួនជាប់ហើយក៏លោតកញ្ឆេង សប្បាយចិត្តបួលទៅឲ្យគេសួរមាត់ទទេទៀត ឈ្មោះណាធ្លាក់ក៏ស្រពោនមុខ ខ្លះយំផងទៀតក៏នៃគ្នាវិលទៅផ្ទះវិញដើរមួយៗ ជាទុក្ខ ព្រោះត្រូវចាំមួយឆ្នាំទៀតបានមកប្រឡងសាជាថ្មី ថ្ងៃនិទ្ទេសប្រាប់គ្នាត្រូវឲ្យការស្គាល់កុមារទាំងនោះគេកោតណាស់ ទាំងការណែនាំដល់មាតាបិតាដែលជូនបុត្រមក ទឹកសង្ឃឹមថានឹងបានឃើញត្រឡប់មកដល់ផ្ទះ ។

កាលបើសួរមាត់ទទេចរិបូណ៌ហើយ កម្មការខាងប្រឡងក៏ប្រកាសឈ្មោះអ្នកជាប់ឡើង ដែលនាំគ្នាហោះខៀវខ្ញុំទៀតផង ដោយសេចក្តីសប្បាយ ចំណែកសុគន្ធក៏ជាប់បានលេខ ១ ជាប់គេជាប់ឯង ត្រូវមេប្រយោគសរសើរគ្រប់គ្នា កុមារសប្បាយចិត្តណាស់ស្ទុះចេញមកឱបឪពុក នៅពេលនោះស្រាប់តែសួរសំឡេងដែលខ្លួនធ្លាប់ឮស្រែកហៅឈ្មោះខ្លួនយ៉ាងពីរោះ សុគន្ធក្រឡេកមើលទៅក៏ឃើញម្តាយបក់ដៃហៅពីឡានមក នឹកស្មានជាយល់សប្តិ ដល់ម្តាយបើកទ្វាររថយន្តចុះមកក៏រត់ទៅឱបម្តាយយំរកគ្នាទាំងពីរនាក់ ។

គង់វេលាកំពុងប្រឱបគ្នានោះ អ្នកទាំងពីរមានសេចក្តីសោមនស្សលើសលុប មិនបាននិយាយស្តីរកគ្នាទេតែជាវែងមួយមួយ ពីព្រោះជវន-ធាតុដែលអន្តរធានបាត់ទៅជាយូរមកហើយ បានត្រឡប់ចូលមកក្នុងខ្លួនវិញគ្រាន់នឹងកក់ក្តៅ រសាយទុក្ខទាំងប៉ុន្មានបាត់មួយរំពេច ភ្លេចនឹកថាមានគេឈរមើលជុំវិញខ្លួន ចំនួនជា១០នាទីក្រោយមក បានសាសងរគ្នា គិតយកដៃជូតទឹកភ្នែក រួចមាតាសួរបុត្រថា "កូន! ម្តាយដឹងថាថ្ងៃនេះគេប្រឡង បានជាម្តាយមកក្រែងជួបនឹងកូន ចុះកូនសំឡាញ់មាសម្តាយអើយ ឯងសុខសប្បាយទេឬតាំងពីម្តាយបែកមក ម្តាយចុងឯងគេមិនសូវធ្វើបាបទេឬអ្វី? ចំណែកម្តាយគេងតែទុក្ខរងរលើកដល់

កូនពល់ពេល ។ មួយវិញទៀត ឯងបានឃើញតាព្រៃវេជ្ជ ។ អើឥឡូវកូនប្រឡងជាប់ហើយ ល្មមកូនមកនៅនឹងម្តាយមក" ។

សុភក្រ្ទនិយាយរឿងរបស់ខ្លួនជូនម្តាយស្តាប់សព្វគ្រប់ហើយ ក៏បញ្ចប់សេចក្តីថា "អ្នកអើយ ! ខ្ញុំមកកំពេញណាក៏បាន តែក្រែងបាមិនអនុញ្ញាតឲ្យមកតែទុកជាយ៉ាងណាក៏កូនមករកអ្នកមិនទាន ចំណែកតាព្រៃនោះ ចោរចាក់ស្លាប់ទៅហើយ" ។

សោភិតចាំកូនយូរពេក ក៏ស្រែកកៀនឲ្យចាប់ពីចម្ងាយមក សុភក្រ្ទអួលដើមកលាម្តាយរបស់ខ្លួន រួចដើរតាមផុតកទៅ ។

លុះដល់ទីសំណាក់ ត្រូវសោភិតប្រេះប្រាប់ប្អូនស្រីថានឹងត្រឡប់ទៅស្រុកវេលាព្រឹកឡើង សុភក្រ្ទក៏ស្លុតចិត្តបរិភោគអាហារមិនឆ្ងាញ់ ក្រៀមមុខពុំកកាយស្រពោនស្រពាន់ស្អប់ស្អុល ឧបមាដូចជាកូនទាន់ដែលគេនឹងលេងប្រើន ទើបឃើញផល់សំដីរបស់ម្តាយខ្លួន សម័យយល់រូបរបស់អ្នកជាប់និងភ្នែក ចិត្តមិនចង់វិលទៅស្រុកវិញសោះ តែគាត់ចេញពីក្រុងពេញនៅវេលាព្រឹកស្អែកនេះ ដោយមិនដឹងជាដល់ពេលណានឹងបានវិលត្រឡប់មកវិញ ទុអនិច្ចាអើយ ។

ម្តាយមីងនឹកអាណិតក្មួយណាស់ ទើបអង្វរសោភិតឲ្យទុកក្មួយនឹងគាត់ហើយ គាត់នឹងចិញ្ចឹមឲ្យរៀនសូត្រទៅទៀត តែសោភិតមិនព្រម លុះដល់ស្អែកគាត់លបនិយាយជាមួយនឹងក្មួយគាត់ថា "ហ៊ែងមក

ឯងចាំផ្ទះមិនបានទេ ឯងទំមកនៅនឹងមីងចុះ ចាំមីងជួយរកម្ដាយឲ្យឯង ឯងកុំព្រួយពីអ្វីទាំងអស់ ស្រែចម្ការមីងរកចិញ្ចឹមឯងឲ្យឯងរៀនសូត្រ" ៗ

លុះព្រឹកឡើង សុភិទ្រ្ធក៏លាម្ដាយមីងឡើងឡានវិលទៅស្រុកវិញ លាស្រុកភ្នំពេញ លាម្ដាយសំឡាញ់របស់ខ្លួន ដែលពុំបានឃើញមុខនិយាយផ្ទាល់មាត់សោះ ៗ

បឆទី ១៣

## ធម្មជាតិ! ធម្មជាតិ!

សត្វកាយំក្រុំៗទៀបព្រឹក រំលឹកកសិករឲ្យចេញទៅកាន់វាលស្រែ ឯសត្វមាន់ទទះស្លាបពីលើដងនាំរោង ដាស់សញ្ញាជាតិរបស់វាឲ្យក្រោកឡើង ភូមិទាំងមូលក៏ចេញចាកទ្រាំអួរបន្តិចម្ដង ៗ នៅពេលនោះសុភិទ្រ្ធរៀបចំបោសព្រាសផ្ទះសម្អែងស្អាតបាត រួចដាំបាយទុកជូនឪពុកម្ដាយរបស់ខ្លួន ៗ ដល់បែកបច្ចុសសម័យ ទើបចុះដំណើរដើរតាមផ្លូវទៅកាន់ស្រែ ព្រោះគេគិតការនាំតែចាស់ហើយធ្វើការពុំសូវមាំ ទើបឲ្យក្មេងអាយុ ១៣ ឆ្នាំ ទៅមើលកម្មករជំនួស ៗ

ដើរដល់ផ្ទះប្អូនចិញ្ចឹម សុភិទ្រ្ធក៏ឈប់ស្រស់ស្រូបជាមួយនឹងសាលី រួចនាំជូនដំណើរបងវេចកញ្ចប់បាយនឹងម្ហូបឲ្យ ៗ សុភិទ្រ្ធក៏ត្រូវទៅតែម្នាក់ឯងតាមផ្លូវតូច មានស្មៅខៀវស្រងាត់សងខាងប្រកបដោយស្លឹកស្រស់ញញឹមជាប់ទឹកសន្សើម ដែលត្រូវពន្លឺព្រះអាទិត្យទើប

ទឹងរះក៏ភ្លឺផ្លេក ៗ ដូចត្បូងទទឹម ។ មានផ្កាឈើរីកយ៉ាងដេរដាសក្រអូប ឈ្ងុយឈ្ងប់ សមអាកាសត្រជាក់ល្អផង គួរឲ្យនឹកចង់ស្រែកច្រៀងឲ្យពេញសំឡេង ។

មានពួកក្មេងគង្វាលគោស្ងាបរយូមពត់ខ្លួនពត់ប្រាណតាមផ្លូវដើម្បី នឹកពាក់ចង់ខ្លួនងងុយងោកងក់ ដើរមួយ ៗ តាមក្រោយគោរបស់ក សត្វសំឡូតទាំងនោះ ព្រោះដើរតាមបង្អាក់ស្លូតបន្ទន់ទន់តែងដោកព្យួរ នៅករបស់វា កាត់មួយក្តិកាលផ្អាក់ប្រឯទីឆ្ងាយឯណោះ លុះដល់វាល ស្រែធំហើយ ក្មេងទាំងនោះលែងគោឲ្យស៊ីស្មៅតាមចិត្ត រួចនាំគ្នាប្រឡែងលេងជាសប្បាយអឺងកងទាំងព្រឹកព្រហាម ។

ចំណែកឯសុកិន្ទ្រកុមារ ចាត់ការឲ្យពួកកម្មករគោមមុខក្រសួងហើយ ក៏គេចមករត់លេងជាមួយនឹងក្មេងឃ្វាលគោ តែលុះឃើញក្មេងទាំងនោះ កខ្វក់ពេក ក៏ញញើតលែងហ៊ានទៅជិត នឹកគិតក្នុងចិត្តថា ម្តេចក៏គេ បេះតែឲ្យដីជាប់ប្រឡាក់នឹងខ្លួនខ្ញុំគ្មានអាក្រក់ដូច្នេះ ចំណែកស៊ីងថាល្អពេកដូច ម្តេចក៏មិនដំរះក្អែលចេញ ត្បិតម្តេចនឹងបានរូបកាយល្អទៅកេះ រួចនឹក ចង់ណែនាំក្មេងទាំងនោះឲ្យស្គាល់អាត្មខ្លួន ។ ម្យ៉ាងវិញទៀតការសារបស់គេ ក៏ថ្ងៃកដល់ត្រចៀកអ្នកកាន់ពេក ស្តាប់តែពាក្យសុភាពពីរោះចាប់ចិត្ត មកព្រួសផឹមិនល្អដូច្នោះ មានគេគ្នាជាដើមទឹកត្រាំមិនចង់ឲ្យពួកសោះ ។

តែដោយចង់ឲ្យជាតិរបស់ខ្លួនថ្លៃថ្លា ទើបអត់សង្កត់ចិត្តចូលទៅជិតក្មេងទាំងនោះ និយាយពន្យល់ពីឡាក់ហានុសំខាន់នៃអនាម័យ រួចបានវិលទៅត្រួតត្រាមើលក្រោលគោរបស់ខ្លួន ឃើញទីនោះជាទីបជិ-កូលក្រៃលែង ទើបបង្គាប់ឲ្យមនុស្សម្នាផ្លាស់ចំបើងដាក់ឲ្យគោដេករាល់ៗថ្ងៃ ប្រើឲ្យផ្លាស់ខ្សែចងជាថ្មីទាំងអស់ ហើយថែសំអាតបសុសត្វទាំងនោះឲ្យល្អ ហាមមិនឲ្យប្រើកហូសកំណាត់ មិនឲ្យវាយដោយឥតត្រាប្រណី ឯសំដីរបស់សុកិត្រូសោត ក៏ផ្អែមល្ហែមគួរឲ្យស្តាប់ អ្នកទាំងអស់គ្នាក៏ពេញចិត្តធ្វើតាមទាំងអស់ ។

ចាប់តាំងពីកុមារចូលត្រួតត្រាមក ស្រែចំរើនផលជាច្រើនជាងរាល់ឆ្នាំ ព្រោះអ្នកបានពន្យល់អ្នកធ្វើឲ្យប្រតិបត្តិតាមវិធីដែលអ្នកបានរៀនពីសាលាមក ហើយឲ្យដាក់ជីដីឲ្យមានជីជាតិល្អ ពួកកម្មករទាំងប៉ុន្មានក៏សប្បាយចិត្តគ្រប់ ៗ គ្នា រហូតដល់សត្វគោមានសាច់ធាត់ល្អហើយស្អាតផង ពួកក្មេងគោបាលក៏ផ្លាស់កែខុសពីដើម អ្នកណាហើយនឹងនឹកស្មានថា អ្នកទាំងនោះជាអ្នករកស៊ីកកាយព្រះធរណី !

ឯសោភិតនឹងសុវណ្ណបុប្ផា បានប្រាក់កាសច្រើនចូលទូដែក ក៏មានចិត្តសាទរពេញចិត្តនឹងកូនពន់ពេក តែមិនបានសំពលការដោះឲ្យខ្លះផងទេ សុកិត្រូក៏គ្មានពេលទំនេរឈប់សម្រាកខ្លួន នៅពេលដែលកំពុងពេញកំលាំង អត្តភាពកំពុងរីកកំពុងឡើងសម្រស់ ដល់គ្រូ

បំពេញនាទីផ្ទន់ហួសកំរិត ក៏ទ្រុឌទ្រោមទៅមិនពេញបរិបូណ៌ កុមាររស់នៅក្នុងពិភពលោកទោលតែម្នាក់ឯង គ្មានអ្នកឯណាចូលសមាគមផង ក្រៅអំពីនាងសាលីប្អូនចិញ្ចឹម ទំពាក់ត្រកូលផុតទៅតែដដែល ៗ ប្រាសចាកអលង្ការទាំងសេចក្ដីត្រេកត្រអាល តែកុមារមិនបានតក់ស្លុតដល់ការហត់នឿយទាំងនោះឡើយ ។

ទុកជាមនុស្សជាតិទាំងមូលតបដំសេច ក្រៅពីសមាគមរបស់គេក្ដី ទុកជាគ្មានសេចក្ដីរាប់អានអំពីសំណាក់វិញ្ញាតិក្ដី ធម្មជាតិតែងតែទទួលរាក់ទាក់ពេញជាដរាប មិនចេះធុញទ្រាន់ មិនចេះពេបជ្រាយ មិនចេះឡេកឡើយ ជាមិត្រមានអារម្មណ៍ត្រជាក់ មានអធ្យាស្រ័យទន់លំទោនដល់អ្នកពាល់គ្នា ជាមិត្រមិនចេះលេងកលមិនចេះយន់យ៉ន ប្រកបដោយបដិ-ភាណយ៉ាងវិសេស រមែងប្រស្រ័យរកដោយមធុរពចា ពោលគឺសត្វចម្រៀងបក្សីបក្សាទាំងស្លឹកឈើ ត្រខ្យល់បក់ព្រមទាំងសូរសត្វល្អិតយំល្វើងល្វើយ អាចឲ្យសុខដល់អ្នកតក់ក្រកមិនមានថ្ងៃណាឲ្យសៅហ្មងចុះ ។

ចួនណាធម្មជាតិនេះមានសភាពពុំស្លូតបូត តែកាលបើដៃមនុស្សចេញនោះហើយក៏ស្ដាប់បង្គាប់ ពុំបណ្ដោយឲ្យបរិបូណ៌ស្អុកស្អកទីនេះរកស៊ីឲ្យប្រសើរជាងការកកាយព្រៃឈើដែលគ្មានផល ជាការពិបាកនាំឲ្យហត់នឿយក៏ពិតមែនហើយ តែជាជាការបំពេញសាធារណៈប្រយោជន៍ គឺជាដំដីតាមត្រពាំង តែគោងតែទំព្រឹងប្រែងផង ៗ មួយវិញទៀត ជាហេតុ

នាំឲ្យមនុស្សមានកំឡាំងកំហែង ទឹងបរិភោគអាហារក៏មានខុជារស ហើយទឹងនាំចិត្តឲ្យបរិសុទ្ធល្អ ព្រោះវាល់ល្ងាចតែងធ្វើការងារ មិនបានរែកជល់គំនិតអាក្រក់ផ្សេងៗ ។

ចំពោះអ្នកដែលមានភ្នែកមេះមើល មានត្រចៀកមេះស្តាប់ មានច្រមុះមេះស្រង់ក្លិន ពេលស្រែពុំមែនជាទេសរដ្ឋខ្លាំងគួរឲ្យនឿយណាយធុញទ្រាន់នោះទេ សឹងថ្ងៃកៗ ពីរដូវមួយទៅរដូវមួយ ពីពេលមួយទៅពេលមួយ រដូវក្តៅ ទាំងចាស់ទាំងក្មេង នាំគោនឹងនង្គ័លរបស់ខ្លួនទៅជ្រួយដី តាំងពីព្រលឹមរហូតដល់ថ្ងៃអស្តង្គត បន្តគ្នាគួរឲ្យរមិលមើល ចាស់ៗ ហៅគោល្ងង់ណាមឲ្យដើរដោយស្រួល ផាលច្ចូកព្រះធរណីឲ្យត្រឡប់លើជាក្រោម បែកខ្ចាយទៅជាអាចម៍បំណះធំ-តូច ដឹកគន្លងជាជួរពេញស្រែ ក្មេងៗ ក៏ប្រណាំងគ្នាលេងសំដីចុះឡើងរង្វើយទន្ទងគ្នា ឮសូរតែបន្ទ្រឹងទឹងសព្វត្រែដោកគ្រប់កន្លែង ។ ឯអាកាសបក្សីបក្សា ប្រឡែងភ្លៀលឆ្ងាត់ចន្ទីបំរៀងពិរោះលាន់ឮទៅឆ្ងាយ នាំឲ្យអ្នកធ្វើការសប្បាយព្រោះចិត្តមានកំឡាំង ។

រដូវស្ទូង ទាំងប្រុសទាំងស្រីដើរចុះដើរឡើងក្នុងស្រែរើសៗ ពីនេះទៅនោះរញៀវដូចស្រមោច លុយទឹកប្រផេះ ប្អូនក៏សាចទឹកលើគ្នាលេង ឯពួកនារីសោត កាលបើវិលមកផ្ទះវិញមានមុខស្រម៉ក់ដោយភក់

ជាហេតុនាំឲ្យសុភិន្ទ្រនឹកដល់កាព្យ "និរាសនគរវត្ត" របស់អ្នកឧកញ៉ា សុត្តន្តប្រីជា ឥន្ទ្រ តែងទុកថា :

" ស្តាយតែរូបនារីរាងស្រឡៅ ចុះស្ទូងស្រែ ត្រូវកំដៅព្រះសូរ្យា
និងទាំងដីភក់ហ្មងកក្រ អនិច្ចាជាតិអ្នកក្រីក្រជីវា ។
ចាស់ហើយតើនឹងតែងខ្លួនម្តេចល្អ ប្រុសនឹងគតថ្លៃទិញយល់តិចណាស់
ឃើញជាចុះថ្លៃថោកល្មមប្រើប្រាស់ ការសង្វាសនឹងសង្វាតជាប់សង្វៀង ។

ធ្វើម្តេចនឹងបានពួកអ្នកស្រែចម្ការជាតិយើង បានថ្កុំថ្កើងស្តុកស្តម្ភឡើង នឹងបានដំកើងជីតាឲ្យនៅផ្ទះកុំឲ្យត្រូវកំដៅព្រះអាទិត្យ នឹងបញ្ចូញឲ្យទៅស្រែតែដល់ផ្លូវប្រែក ពីព្រោះនៅខណៈនោះ ផ្ទៃដីក៏លុបបាត់ទៅនៅសល់តែគួរស្រូវលឿងឆ្អិនឆ្អៅដូចមាស នាំគ្នាកាន់កណ្តៀវទៅលំដើមស្រូវ ស្រែកច្រៀងយ៉ាងពីរោះពេញវាលស្រែ ទឹកសំឡេងមិនឡើងពេក មិនចុះហួសប្រមាណ សមនឹងភាពអ្នកស្រែនៅពេលនោះ ៗ

សុភិន្ទ្រចំរើនវ័យបានអាយុ ១៥ ឆ្នាំហើយ បានរៀនធ្វើការខាងកសិកម្មគ្រប់មុខ ពេលថ្ងៃរះក៏ចេញពីផ្ទះទៅ ពេលថ្ងៃលិចក៏វិលមកផ្ទះវិញ ៗ ល្ងាចមួយ ដើរមកដល់ផ្ទះនាងសារ៉ាលី ក៏ស្ងាត់ស្ងៀមពុំឃើញនាងឈរចាំផ្លូវដូចមុន ៗ ទៀត សុភិន្ទ្រឆ្ងល់ណាស់ក៏ចូលទៅសាកសួរបានដំណឹងថា នាងទៅឯស្រុកភ្នំពេញបាត់ទៅហើយក៏នឹកមិនអស់ចិត្ត

ដោយនាងមិនបាននិយាយលាខ្ញុំមួយម៉ាត់សោះ ស្រាប់តែទៅឥតស្រណោះតែម្តង បើបានដឹងផង គ្រាន់នឹងផ្តាំឲ្យសួររកម្តាយឲ្យផង ហើយនឹងបានផ្ញើជូនផ្លែត្នោតទៅម្តាយមីងខ្លះ ទើបសុភ័ក្ត្រដំរង់ទៅផ្ទះដោយទឹកមុខពុំសប្បាយ ។

បួនថ្ងៃក្រោយមក សុភ័ក្ត្រកំពុងអង្គុយកាត់សក់ លេចមុខពុកនាងសាលីទៅដល់ហុចសំបុត្រមួយច្បាប់ទៅឲ្យ អ្នកទទួលយកមកហើយកើតរំភើបក្នុងចិត្តញ័រដៃកាន់សំបុត្រពុំចង់កើត បកស្រាយឡើងមើលសេចក្តីថា :

## មកដល់សុភ័ក្ត្រជាបង!

"ពាក្យដំបូងរបស់ប្អូន គឺសូមបួងសួងទេវតាឲ្យជួយថែរក្សាបងឲ្យបានសេចក្តីសុខ បានជាខ្ញុំមិនបានប្រាប់បងឲ្យដឹងនោះ ព្រោះខ្ញុំរវល់ណាស់ ត្រូវបន្ទំឲ្យទៅឯភ្នំពេញ យ៉ាងប្រញាប់ ម្តាយមីងមានជម្ងឺឈឺធ្ងន់ ឥឡូវគាត់បានគ្រាន់បើហើយ ខ្ញុំធ្លាក់នៅក្នុងទីនេះ ដូចជានៅឯណោះដែរ តែមានសេចក្តីព្រួយជាខ្លាំង ដោយពុំបានឃើញមុខនិងប្រស្រ័យជាមួយនឹងបង សេចក្តីផ្តាំផ្ញើយ៉ាងម្តេចម្តា បងមេត្តាអត់ទោសដល់ខ្ញុំផង ព្រោះជាគ្រាដំបូងដែលខ្ញុំសរសេរសំបុត្រ" ។

ជាប្អូនដែលនឹករលឹកមកបងជានិច្ច

សាលី

សេចក្ដីសំបុត្រនេះ ដូចជាបោះអង្គើយពន់ពេកណាស់ មិនសមដល់អត្ថាស្រីយប្អូនចិញ្ចឹមបេះដូង គឺទឹកអន់ចិត្តផង យំតែម្នាក់ឯង ថាប្រហែលជាខាងម៉ែនប៉ុនខាងវិធីសរសេរសំបុត្រទេដឹង ទើបបានធូរទ្រូងបន្តិច ។

យប់នោះឯង ដោយអំណាចនឹកប្អូនខ្លាំង សុភិន្ទ្រសោកសល់ ក្នុងចិត្តប្រែប្រួលចុះឡើងដេកពុំលក់ បើទោះតែឃើញរូបប្អូនជាប់ទីងក្នុងគំនិតច្រើនពេកទៅនាំឲ្យក្ដៅក្បាល រហូតដល់ហូរឈាមពីច្រមុះទទឹក ទើបដេក អស់កំឡាំងណាស់ទំប្រឹងក្រោកឡើង រកក្រមាជ្រលក់ទឹក យកមកត្រដបលើថ្ងាស លុះត្រជាក់ក្បាលបានស្រួលដេកលក់ទៅ ដល់ពេលព្រឹកឡើង ទើបចាប់ផ្ដើមកាសរសេរសំបុត្រតបទៅប្អូនវិញ មានសេចក្ដីថា:

កំពង់ធំថ្ងៃ ១៩ ខែណូវែម្ប្រឆ្នាំ ១៩៣៦

## សាលីសំឡាញ់បង!

“បងមានសេចក្ដីត្រេកអរណាស់ និងបានទទួលសំបុត្ររបស់ប្អូនមួយច្បាប់ ពីថ្ងៃម្សិលមិញ ព្រឹកនេះបងប្រញាប់ប្រញាប់តបទៅវិញឆ្លើយប្អូន ជាបន្ទាន់ហើយរយៈឆ្ងាយណាស់ដែលយើងឃ្លាតពីគ្នា ការដែលបានសាសងជាមួយនឹងប្អូនតាមសំបុត្រនេះ ជាសេចក្ដីសប្បាយដល់បងពន្លឹក ហើយក្រាន់នឹងបានធូរទ្រូងខ្លះ ពេលថ្នារណោះបងស្មានមើលទៅប្រហែលជាប្អូនកំពុងអង្គុយមាលខ្យល់ ប្រងត្រចៀកចាំស្ដាប់វាចារបស់បង ចុះបងច្រឡំទេ! ប្រហែលជាប្អូនកំពុងប្រញាប់គក់ឲ្យម្ដាយមីង

របស់ប្អូនទេនឹង? ឬមួយនាង... យ៉ាងណាបងក៏មិនប្រាកដ ព្រោះបងមើលទៅឃើញតែដោយខនោតតិចប៉ុណ្ណោះ ម្ដេចក៏ប្អូនឃ្លាតឆ្ងាយពីបងម្ល៉េះ ឱសាលីអើយ! ហើយបងប្រាថ្នាតែនឹងនិយាយជាមួយនឹងប្អូនមាត់នឹងមាត់ប៉ុណ្ណោះ" ។

"ត្រង់ពាក្យប្អូនថា ប្អូននៅឯណោះដូចនៅឯណេះដែរ, បងមិនអស់ចិត្តសោះ ហាក់ដូចជាប្អូនគ្មានសេចក្ដីស្រណោះដល់ស្រុកកំណើតផងសោះ ដូចជាគ្មានរលឹកមកដល់បងបន្តិចបន្តួច ទេឬសាលីអើយ! ឬមួយប្អូនចង់ថាដូចម្ដេច?... ប្អូនអើយបើប្អូនសម្រេចកិច្ចរួចហើយ ចូរប្អូនវិលមកវិញឲ្យឆាប់ណា កុំនៅយូរពេក អាណិតមកបងដែលសង្រេងសង្រៃចាំទាំងយប់ទាំងថ្ងៃមករកប្អូន ដែលបរិភោគបាយមិនឆ្ងាញ់ ដែលនិទ្រាពេលយប់បានតិចម៉ោងពេក ដែលមានចិត្តស្រពោនស្រពន់ពុំសប្បាយ មួយវិញទៀតបើប្អូនមានពេលទំនេរ ឲ្យប្អូនអាណិតសើបសួរដំណឹងម្ដាយរបស់បងផង បងនឹងដឹងគុណប្អូនអស់មួយជីវិត" ។

"មុននឹងបញ្ចប់សំបុត្រនេះ បងសូមបញ្ជាក់សេចក្ដីថា រូបបងសព្វថ្ងៃនេះដូចជាទូកប្រាសចាកចង្កូត ពុំនោះសោត ដូចជាពិភពលោកប្រាសចាកពន្លឺព្រះអាទិត្យ ហេតុនេះសូមប្អូនអាណិតវិលមកឲ្យឆាប់ៗ ដើម្បីនឹងណែនាំនាវានោះឲ្យត្រង់តាមផ្លូវ ដើម្បីនឹងបំភ្លឺពិភពលោកឲ្យមានពន្លឺភ្លឺព្រោងព្រាយសប្បាយឡើង ។

មកដល់ប្អូនដោយមេត្រីចិត្ត!

សុភិន្ទ្រ

លុះដល់ប្រាំថ្ងៃក្រោយមក សុភិន្ទ្របានដំណឹងថា នាងសាលីនឹងវិលមកផ្ទះវិញ ទើបបោះបង់ការងាររត់ទៅរង់ចាំឯស្ថានីយ៍រថយន្តឯណោះ មិនទាន់ដល់ម៉ោងក៏ស្ត្រេតស្ត្រាល់នៅមិនទើង ចង់បង្ខំព្រះអាទិត្យឲ្យនោចរទៅឆាប់ៗ សាកសួរដំណឹងដល់អ្នកប្រចាំការដោយច្រើនដង ទាល់តែគេធុញទ្រាន់មិនចង់និយាយរក ចុងបំផុតនាងក៏មកដល់ ។

ដើរតាមផ្លូវមក  នាងក៏ហុចសំបុត្រមួយច្បាប់ប្រគល់ឲ្យទៅបង សុកិន្ទ្របើកមើលដឹងសេចក្ដីគ្រប់សព្វហើយ  ធ្វើមុខជូរហួញញគួរឲ្យអា-ណិតដាក់គូថចុះអង្គុយលើចំណោមថ្មចូលចង្កេះខ្សែកខ្សែលជាច្រើន  សន្សឹមៗ ងើបមុខមើលប្អូនហើយនិយាយបញ្ចេញមកថា 'អូនអើយ! បើបងគ្មានមួយ សេនជូនចេះ  គេនឹងទៅសួរអ្នកម្ដាយបងដូចម្ដេចបាន  ម្យ៉ាងទៀតឲ្យបង ទៅតាមផ្លូវណា  មុខជាអ្នកឈឺធ្ងន់ណាស់ហើយមើលទៅ  ពុទ្ធោ! ពុទ្ធោ អើយ!.... រួចក៏យំដូចជាកូនក្មេង ។

នាងសាលីទើបជួយគិតបងថា "ណ្ហើយបង  ប្អូនមាន៥០,០០ដែរ បងយកជាសោហ៊ុយទៅក្រុងភ្នំពេញចុះ  បងដើរកាត់ព្រៃទៅ  រួចសឹមឡើង រថយន្តឯមុខឯណោះ  កុំឲ្យលោកពូលោកម៉ែនដាប់ឲ្យសោះ" ។

សុកិន្ទ្រអរព្រួចឃ្នាតឡើងទៅលើផ្ទះ ស្លៀកពាក់ស្រួលបួល យក ក្រមារវែងដោតព្រមទាំងបញ្ជូលដាក់គំណែតសញ្ញាប័ត្រ  នឹងសំបុត្រ ស្នាមឯទៀត ៗ  ទម្លាក់តាមបង្អួចទៅលើដើមផ្កា  រួចបានសរសេរសំបុត្រ សូមទោសទុកដាក់លើតុលក្ខណ៍បន្ទប់របស់ខ្លួន  រួចក៏ចុះជណ្ដើរមួយ ៗ ធ្វើ យ៉ាងកំហ៊ី  សៀរៗ យកបង្អួចដើរបណ្ដើរក្រឡេកមើលក្រោយបណ្ដើរ ដល់ផុតផ្ទះហើយក៏តំរង់ទៅផ្ទះនាងសាលី  ទទួលយកប្រាក់ ៥០,០០ ហើយលានាងចេញទៅ  សាកសួរផ្លូវផល់ចាស់ៗ ។

នាងសាលីឈរតាមមើលបងទាល់តែផុតកន្ទុយភ្នែក បានបែរជាក ត្រឡប់ចូលទៅក្នុងផ្ទះវិញ មានទឹកភ្នែកស្រប់មុខ ។ (មានត)

# ច្បាប់ក្រមបរិយាយ

## លោកញ៉ុក ធូ គ្រូបង្រៀនជំនួយ

*នៅវិទ្យាល័យស៊ីសុវត្ថិ*

រៀបរៀង (តទៅ)

ទី ១. — ក្ដីនេះជាច្បាប់ ឲ្យសាមណេរត្រាប់ សព្វសារពាំងឡាយ កុំសើចតិះដៀល អ្នកជាអាចារ្យ អ្នកហោងស្មើម្ដាយ បង្កើតក្ដីច្បាប់ ។

*បទវគ្គនេះជាច្បាប់ សំរាប់ដាស់តឿនសតិជនានុជនទាំងឡាយ ឲ្យបានសេចក្ដីល្អ, បានជាលោកហាមឃាត់សាមណេរគ្រប់រូបថា "កុំសើចតិះដៀល អ្នកជាអាចារ្យ អ្នកហោងស្មើម្ដាយ បង្កើតក្ដីច្បាប់" បានសេចក្ដីថា គ្រូអាចារ្យនេះ លោកជាអ្នកប្រដៅទូន្មាន ឲ្យរៀនច្បាប់ទម្លាប់ទំនឹមទំនៀម និងសេចក្ដីខុសត្រូវគុណនិងទោស ព្រមទាំងសិល្បសាស្ត្រ ចំណេះវិជ្ជាផ្សេងៗ ដោយហេតុនេះ ឃើញថាគ្រូអាចារ្យ លោកមានគុណជាទម្ងន់ធ្ងន់ពន់ប្រមាណ ទុកស្មើដូចមាតា បានហាមឃាត់សិស្សានុសិស្ស ថាកុំឲ្យមើលងាយប្រមាថ តិះដៀល ឬនិយាយស្ដីនូវពាក្យអសុរោះ ទ្រគោះបោកបោះ ឥតគួរសមទៅកាន់គ្រូអាចារ្យឡើយ ។*

( ន័យគាថា )

សាមណេរណា ៗ នោះមានប្រាជ្ញា ដឹងចង់រៀន
ត្រាប់ ឲ្យយកត្រចៀក នោះនឹងចូលស្តាប់ ធ្វើដោយ
ក្រមច្បាប់ នៃគ្រូបាធ្យាយ ។

បទនេះបានសេចក្តីថា បើសិស្សឯណាមានប្រាជ្ញាឈ្លាសវៃ ហើយប្រាថ្នាចង់រៀនទូរច្បាប់ទម្លាប់ដ៏ប្រសើរជាគ្រឿងប្រដាប់ ទុកសម្រាប់ខ្លួនប្រព្រឹត្តទៅ, នោះគប្បីប្រុងស្មារតីប្រញាប់យកត្រចៀកប្រុងចាំស្តាប់លោកអគ្គាធិប្បាយ ដែលត្រូវសំដែងប្រាប់ពន្យល់ដោយស្មោះ ពេលដែលកំពុងស្តាប់នោះ ត្រូវតាំងចិត្តបង្សតិប្រុងចាំស្តាប់ចាប់យកអត្ថរសបទបាទមាត្រាច្បាប់ទំនឹមទំនៀមតាំងអម្បាលម៉ាន កុំឲ្យមានចិត្តអណ្តែតអណ្តូងកាយមាយាទៅកាន់អារម្មណ៍ដទៃ. ប្រយោជន៍កុំឲ្យខ្លួនបង់វេលាទៅទទេ ៗ តែឲ្យជ្រាបហើយ នោះពាក្យត្រូវពន្យល់តាំងប៉ុន្មានទីនឹងក្តុចបាត់ខ្លះមិនខាន អ្នកនឹងខ្វះចំណេះដែលជាប្រដាប់សំរាប់ប្រើញាំងចរិយាខ្លួនជាគុណសម្បត្តិឲ្យល្អតទៅ ៗ

ទី ១២ – សាមណេរណាសោត ចិត្តនោះត្រូវត្រាង
ឲ្យចៀសចេញឆ្ងាយ ច្បាប់នេះមិនចាំ សាមណេរទាំង-
ឡាយ តាមចិត្តសប្បាយ អាត្មាទីទៃ ។

អធិប្បាយថា ធម្មតាគ្រូអាចារ្យលោករមែងមានធម៌សង្គ្រោះដល់សិស្សគ្រប់រូប លោកតែងប្រដៅទូន្មាន តាមគន្លងធម្មបរិយាយនិងច្បាប់សំរាប់ប្រពៃណី, តែពាក្យដែលពោលចេញមក ជួនកាលក៏ពីរោះ ជួនកាលក៏គំរោះគំហែងឲ្យខ្លាច, ទោះបីដូច្នោះគួរតែសិស្ស ទទួលទានត្រងត្រង យកទុកដាក់ក្នុងចិត្តជាឡាក់ហាន តាមពាក្យលោកប្រដៅនោះ កុំឲ្យមានចិត្តក្រេវក្រោធប្រឡាកតបតទៅវិញ ឬមានចិត្តមនោមានះមិនប្រតិបត្តិតាម, នេះបើសិស្សណាជាមនុស្សប្រដៅក្រ នោះលោកពោលថា "ឲ្យចៀសចេញឆ្ងាយ" ទៅតាមអធ្យាស្រ័យរបស់ខ្លួនដទៃៗតាមចិត្តសប្បាយចុះ លោកមិនបង្ខំទេ, ព្រោះលោកយល់ដូចនេះគេទៅនេះ ។

នរអ្នកណា ដឹងស្វែងប្រាជ្ញា ឲ្យបានខ្ពង់ថ្លៃ ថ្នូរ
ដឹងខុសត្រូវ ដោយអធ្យាស្រ័យ ផ្ចាប់ដោយហឫទ័យ
អ្នកជាបាញ្ញាយ ។

បទនេះបានសេចក្ដីថា វិស័យអ្នកចង់ឲ្យបានខ្ពស់មានដំឡើងថ្កើងរុងរឿងមានគ្រូឈ្មោះ គួរតែរករៀនវិជ្ជាសាស្ត្រទាំងឡាយផ្សេងៗ ឲ្យស្ទាញស្ទាត់ហ្មត់ហ្មង បានជាលោកពោលថា "ចូរដឹងខុសត្រូវ" គឺឲ្យដឹងខុសទំនងត្រូវ ល្អទំនងអាក្រក់, ថ្លៃទំនងថោក ទាបទំនងខ្ពស់ ធំទំនងតូច ។ល។ ហើយឲ្យប្រព្រឹត្តប្រតិបត្តិតាមបែបក្បួនដែលគ្រូបិតាប្រៀនប្រដៅមក នេះទើបហៅថា "ផ្ចាប់ដោយហឫទ័យ អ្នកជាបាញ្ញាយ" ។

បើបានដូចពោលយ៉ាងនេះហើយ អ្នកនោះនឹងបានជាមនុស្ស មានជំនឿមួយនឹងគេពុំលែងឡើយ ។

ទី ១៣.- ទោះដឹងស្វែងធម៌ ឲ្យមានសំគាល់ កុំធ្វើ
កយមាយ ទោះដឹងស្វែងច្បាប់ កាន់ខ្ជាប់កុំបីណាយ
កុំឲ្យអន្តរាយ ចូរច្បាប់ក្រាមដង ។

ទក់ទបទនេះ ត្រូវញែកជា ២ បទតាមទំនង -

បទទី ១ - "ទោះទឹងស្វែងធម៌ ឲ្យមានសំគាល់ កុំធ្វើកយមាយ" បានសេចក្តីថា បើនរណាមានប្រាថ្នារកធម៌ ចង់រៀនធម៌ ត្រូវឲ្យមានសតិជំកល់មាំ សំគាល់ចាំនូវកងធម៌ទាំងនោះ ឲ្យជាក់ច្បាស់ ថានេះជាកងសុចរិត នេះជាកងទុច្ចរិត កុំធ្វើកយមាយផ្តេសផ្តាស កុំបណ្តែតបណ្តោយចិត្តឲ្យលឿនលយប្រែប្រួល ឲ្យខុសហួសធម្មក្រិត្យ នឹងខូចប្រយោជន៍ដែលឲ្យកើតផល ។

ខនេះត្រូវឲ្យសិក្សា ឲ្យស្គាល់ធម៌ ១ ម៉ាត់នេះជាមុន តើអ្វីដែលហៅជាធម៌? "ធម៌" ប្រែថា សភាវៈដែលទ្រទ្រង់សត្វលោក គឺបានដល់បុណ្យកុសលសុចរិត ។ បើជា "អធម៌" វិញរមែងនាំសត្វឲ្យទៅកាន់ទុគ្គតិដោយចំណែកផ្សេងៗ ។

លោកពោលថា ចំណែកបព្វជិតគឺភិក្ខុសាមណេរត្រូវប្រព្រឹត្ត

ប្រតិបត្តិធម៌ គឺសិក្ខាវិន័យឲ្យខ្ជាប់ខ្ជួនធ្វើខ្លួនឲ្យស្អាត ដោយសីល សមាធិបញ្ញាឲ្យផូរផង់ កុំឲ្យរំលងលើសល្មើសលើពុទ្ធឱវាទឡើយ ។

ចំណែកគ្រហស្ថប្រុសស្រី ដែលបានប្រកាសថ្វាយខ្លួនជាឧបាសក ឧបាសិកា ជាអ្នករក្សាសីល៥សីល៨ ក៏ត្រូវដំកល់សីលនោះ ឲ្យបរិសុទ្ធ ផូរផង់ល្អ កុំឲ្យមានសៅហ្មង, គប្បីធ្វើឲ្យត្រឹមត្រូវតាមរបៀបពុទ្ធបញ្ញត្តិ ។

បទទី២– "គោរពនិងស្វែងច្បាប់ កាន់ខ្ជាប់កុំបំណាយ កុំឲ្យអន្តរាយ ទូរច្បាប់ក្រមផង" បានសេចក្តីថា បើនរជាតិជនឯណា មានសេចក្តីសង្វាតរករៀនច្បាប់ម្ចាប់តាំងតួនឲ្យបានចេះដឹង, លុះរៀនចេះដឹងហើយ ត្រូវប្រព្រឹត្តខ្លួនឲ្យត្រឹមត្រូវតាមវិធីច្បាប់ កាន់ខ្ជាប់ឲ្យមាំមាំ កុំឲ្យធ្វើឲ្យហួសច្បាប់ ដើម្បីរក្សាសេចក្តីសុចរិត គឺមិនលុះដោយអគតិទាំង៤ មានឆន្ទាគតិជាដើម ។

ឯច្បាប់នោះលោកចែកជា២ពួកផ្សេងគ្នាទៀត ពួកទី១គឺច្បាប់ ដែលម្ចាស់ផែនដី លោកបញ្ញត្តតែងតាំងទុកមក សំរាប់ផ្តន្ទាទោស ទណ្ឌកម្មមនុស្ស ដែលប្រព្រឹត្តល្មើសកន្លងរំលងព្រះរាជបញ្ញត្តិច្បាប់ ត្រូវដាក់គុកឬពិន័យ តាមទោសានុទោស គឺមានច្បាប់ព្រហ្មទណ្ឌ និងច្បាប់រដ្ឋប្បវេណីជាដើម ។ ពួកទី២–គឺជាពាក្យបុរាណភាសិត ឬពាក្យគ្រូអាចារ្យ មាតាបិតាជាដើម ដែលលោកទូន្មានប្រដៅ មនុស្សប្រុសស្រី ឲ្យប្រព្រឹត្តប្រតិបត្តិដោយសុចរិតធម៌ ដើម្បីញ៉ាំងខ្លួនឲ្យល្អ

សុភាពរៀបរយ-សមរម្យតាមច្បាប់សំរាប់ប្រពៃណី នោះគឺច្បាប់ក្រម,-កូនចៅ,-កេរ្តិ៍កាល,-ច្បាប់ស្រី,-ច្បាប់ប្រុស,-ច្បាប់ត្រីនេត្រ,-ច្បាប់ពាក្យចាស់, ។ល។ ជាប្រធាន ។ ច្បាប់ពួកនេះ បើនរជាតិជនណាមិនប្រព្រឹត្តតាមនឹងមានទណ្ឌកម្មផ្ដន្ទាទោសក៏ទេ គ្រាន់តែអំណោយផលឲ្យអ្នកនោះទៅជាមនុស្សថោកទាបគាប់ឥតប្រាជ្ញា មិនជាទីគាប់គាប់ជនា-នុជន, ព្រោះខ្លួនជាមនុស្សអន្ធពាលទៅហើយ ។

ន័យ ១ទៀត អ្នកឯណាពុំអាចប្រព្រឹត្តកាន់តាមច្បាប់ទាំងពីរជំពូកទុកបាន គឺព្រោះមកពីសេចក្ដីប្រមាទនេះ ១, មកពីមិនក្រែងខ្លាចហើយល្មើសលើនេះ ២, មកពីមិនមានហិរិ គឺខ្មាសអៀនទំនងអំពើអាក្រក់និងឧត្តប្បៈ ខ្លាចក្រែងអំពើអាក្រក់នេះ ៣ ។

សេចក្ដី ៣ ជំពូកនេះ នាំឲ្យមនុស្សឃ្លាតឃ្លៀងល្អៀងចេញមិនកាន់ច្បាប់ បើឃ្លាតពីច្បាប់ហើយ អ្នកនោះឯងពុំអាចនឹងធ្វើខ្លួនឲ្យបរិសុទ្ធតាមធម៌តាមច្បាប់បានឡើយ ។ នឹងមិនជាទីគោរពគាប់អានរបស់ជនានុជនបានឡើយ ព្រោះខ្លួនមិនប្រកាន់គោរពច្បាប់ឲ្យខ្ជាប់មាំមួនទៅហើយ, ធ្វើម្ដេចឡើយនឹងនាំប្រដៅអ្នកឯទៀតបាន ។

ទី ១៤ -រីគ្រូចារព្យាយ ប្រដូចនូវម្ដាយ អាពុកគាឃង
ហោង ហ្វឹកហ្វឺនប្រដៅ មិនឲ្យមានចន្លោះ តាមដោយ
កង្វល់ ព្រេងព្រឹទ្ធបុរាណ ។ (មានត)

# ព្រះសមុហ៍ឃោសាចារ្យ យូរ-ប៊ុណ្ណ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

(តមកនឹងចប់)

ជនតាំងពីរនាក់នោះ ទូលចំពោះព្រះកដា ថាទ្រង់កុំឆាឆា ព្រះអង្គជា
អ្នកក្រោ ៗ សូមឲ្យតែព្រះអង្គ ជូនទៅត្រង់សាមបុត្រា អ្នកស្លាប់នៅ
ទីណា យើងយាត្រាទៅទីនោះ ៗ ស្ដេចមានបន្ទូលថា កុំយាត្រាទៅឲ្យ
សោះ ទីនោះក្រែងមានគ្រោះ ត្រង់បន្ទោះព្រៃស្រោងស្រោង ៗ មាន
តែហ្វូងសត្វម្រឹគ ដោតតកំបាំងប្រែប្រាង ស្លាក់ជូរឲ្យតេងតាង ទីងទៀស
រាងទៅពុំរួច ៗ មានតាំងពួកស្មានស្មា ដំរីខ្លារ៉ែបែកត្រលួច ក្របីខ្ទីង
ស្នែងស្រួច ខ្លួនព្រើព្រួចសព្វអង្គា ៗ ពន្លឺព្រះសាវិត្យ អ័ព្ទងងឹតពេញ
មេឃា មិនគួរជនទេហា ចរយាត្រាទៅបានឡើយ ៗ ឯជនតាំងពីរនាក់
ស្ដាប់ព្ធដាក់ទុក្ខឥតស្បើយ អង្វរថាក្រៃអើយ កុំគោះតើយសៀមស្ងាក់
ទៅ ៗ ទោះទុកជាយ៉ាងណា សូមក្រោជូនខ្ញុំទៅ ឲ្យបានដល់កូនពៅ
ទោះយប់ជ្រៅក៏មិនខាន ៗ បើមិនឃើញមុខកូន យើងស្លាប់សូន្យទាំង
ពីរប្រាណ ទីងរស់នៅពុំបាន ទុក្ខក្ដាមានខ្លាំងនៃក្រៃលែង ៗ គ្រានោះ
ស្ដេចបរិលយក្ស នាំជនខ្វាក់ប្រាប់កន្ថែង ដល់ហើយទើបទ្រង់ថ្លែង ថា
នេះឯងសាមបុត្រា ៗ ឯជនតាំងពីរនាក់ បានស្គាល់ដាក់កូនពុំផា

ដេកផ្ទាល់លើពសុធា ឥតមានគ្នានៅម្នាក់ឯង ៗ យកដៃស្ទាបបាតា ដល់
សិរសាតែងថ្លែង ខ្សោចផ្សាផ្ទួនទៅក្រលែង ហើយទើបថ្លែងរៀបរាប់ថា ៗ

## ពិលាបទុក្ខលបណ្ឌិត និងនាងបារិកា

ពាក្យ ៧

ឱសាមកុមារម្ទុះស្រស់ឆោម រូបល្អឥតខ្ចោះគួរគយគន់ សំដី
និយាយក៏ស្រទន់ ពីរោះពេកពន់ឥតឧបមា ៗ ឥឡូវមាតាបិតាមក
ឃើញកូនពន្ធកដល់មរណា កូនក្រិនស្ងួតប្រែះចេញពីគ្នា កើតទុក្ខ
វេទនាព្រោះអាល័យ ៗ កូនអើយអ្នកដូចជាស្រវឹង ឬមួយកូនខឹងឥតប្រា-
ស្រ័យ មាតាបិតាហើយលាក្ស័យ តាំងនៅមានវ័យពេញសម្លាញ់ ៗ
ឬមួយកូនព្រួយនឿយលំបាក បំពេកសោកហើយគ្មានខ្លាញ់ ទូលព្រះ
ករជាវិស្រលាកបាញ់ ឬកូនខាលពាញ់ព្រះបេស្កា ៗ ឱសាមកូនអើយ
អ្នកអង្គ យើងតាំងពីឆ្លាប់ទំពីងបា ចំណីគោជននឹងផលា បានរស់
ដក់ព្រោះព្រលឹង ៗ ម្តេចឡើយកូនស្លាប់ចោលយើងទៅ ឲ្យយើង
រស់នៅឥតពំនឹង ពីថ្ងៃនេះហើយគ្មានទំពឹង ស្ងប់ស្ងាត់ស្ងួនឲ្យឈឹងដូច
សុសាន ៗ បើម្តាយឪពុកជាទៅក៏ គ្រាន់នឹងរក្សាគ្នាទៅបាន ឥឡូវ
នឹងកាន់តាំងពីប្រាណ ម្តេចនឹងពឹងបានគ្នា ៗ ស្តាយអើយស្តាយ
ភពកូនព្រលឹង មករដេកស្ដូកស្ដឹងក្នុងព្រៃក្រា ធូលីដីខ្លាចជាប់កាយា

មិនមានចរចាតបមកសោះ ៗ ឱលោកណាអើយនៅទីនេះ ដែលមាន
ចំណោះជួយសង្គ្រោះ មេត្តាដល់ខ្ញុំដោយចិត្តស្មោះ ឲ្យកូនកំព្រាមាន
ស្មារតី ៗ កាលកូនរស់នៅទីស្ងាត់ ចរត្រាច់យាត្រារកចំណី ផ្លែ
ឈើមើមឈើបេះថ្មីៗ ទាំងទុំចាស់ខ្ចីមិនខ្វះខាត ៗ ទឹកងូតទឹកផឹកមាន
គ្រប់គ្រាន់ មិនឲ្យអស់ទាន់ខ្ញុំសង្វាត ឯលះពេលទៅដងត្រពាំងខ្លាក
សុទ្ធតែថ្លាស្អាតពេញៗ ពាង ៗ ពេលព្រឹកអ្នកបោសទីកស្រម ពេល
ថ្ងៃរៀបចំភោជន៍ស្អិតស្អាង ទាំងទឹកថ្លៃងយើងសង់ខាង ជាទាអះអាង
ធ្វើសព្វគ្រប់ ៗ បើឥតពីកូនសូន្យទៅហើយ គ្មានអ្នកណាឡើយគេ
គោរព ធ្វើការទីនេះរាល់ថ្ងៃយប់ លុមនឹងសេពគប់ធ្វើជាគ្នា ៗ

## ពាក្យសច្ចៈ បទព្រហ្មគីតិ

គ្រានោះជនពីរនាក់ ប៉ាត់អួលអាក់សោកស្រណោះ ផ្គងដៃ
ឡើងចំពោះ ក្នុងទីនោះសច្ចាថា ៗ បើជាសាមបណ្ឌិត បានប្រព្រឹត្ត
នូវធម៌ណា ដោយសច្ចវាចា ពិសក្តៀវក្លាសាបសូន្យទៅ ៗ គឺមានចិត្ត
ត្រេកអរ ប្រព្រឹត្តធម៌ដ៏ជ្រាលជ្រៅ ជាផ្លូវដែលកូនទៅ ដកល់នៅក្នុង
ចិន្តា ៗ ឬពោលនូវពាក្យពិត ពួកបណ្ឌិតហៅសច្ចា ទើបបានថែ
រក្សា នូវមាតាបិតាផង ៗ ប្រព្រឹត្តធម៌គោរពក្រែង ខ្លាចស្រប់ស្រួន
ចាស់រៀមច្បង មិនហ៊ានពោលកន្ទ្រើង ឲ្យសៅហ្មងដោយសំដី ៗ

ទ្រង់មានចិត្តស្នេហា ករុណាកូនពិស៊ី ដោយគុណបុណ្យបារមី តិច
ប្រែនក្តីជួយសង្គ្រោះ ។ អ្នកប្រាជ្ញពីបុរាណ លោកតែងបានពោល
ពីកេះ ថាសាមបណ្ឌិតនេះ កាន់ចំពោះធម៌ណាៗ ។ សូមឲ្យបុណ្យ
កុសល ជួយផ្តាច់ផល់ពិសគ្រៀវក្លា ចេញចាកពីកាយា ដោយសច្ច
ធម៌នោះឯង ។

## ពាក្យនាងទេពធីតា

រីទេវតាអង្គនោះ មកសង្គ្រោះហើយទើបថ្លែង សច្ចធម៌ជាក់ស្តែង
ទ្រង់កខ្មែរនោះទៀតថា ។ ខ្ញុំបិតនៅទីនេះ យូរដល់ម៉្ញះឥតនរណា
ស្រឡាញ់ពេញចិន្តា ដូចជាបាសាមបណ្ឌិត ។ ទ្រង់ក្តីគន្ធមានទ៍ បុរេ
ជាតិជាស័ក្តិសិទ្ធ មានក្លិនក្រអូបពិត គួរពិចិត្យថង់ចេតនា ។ ខ្ញុំពោល
ពាក្យទាំងអស់ ជាសច្ចស្រេចស្រដ៏សច្ចា សូមឲ្យពិសឈឺផ្សា គង់សើព
សាមបាត់ទៅ ។ កាលបើជនទាំងនោះ ផ្តងចំពោះទឹកសំដៅ រកធម៌
ដែលមាននៅ គឺកូនកោះម្លាប់រក្សា ។ រីឯសាមបណ្ឌិត បានប្រព្រឹត្ត
ធម៌មេត្តា ដោយគុណបុណ្យសច្ចា មានសញ្ញាក្រោកឡើងហើយ ។
ទើបក្រាបទៀបបាទា ពោលពាក្យថាម្ចាស់អើយ កូនបានរស់វិញ
ហើយ កុំសោកឡើយចូរចរចា ។ ទើបដាក់មកបន្តំ ស្តេចជាធំហើយ
ទូលថា សូមយានទៅសាលា ទាំងមាតាបិតាខ្ញុំ ។ ត្រាមោះពោធិសត្វ

បុរសគ្គបិត្តសុខុម មិនមានធម៌តំនុំ ប្រឹងបន្ទំបុណ្យកុសល ៗ ទើបនាំយកមាតា នឹងបិតាបានទៅដល់ ព្រមទាំងក្សត្រសោតសល់ ទីមណ្ឌលនៃសាលា ៗ រៀបចំទីបន្ទំ គួរនិយមដល់ក្សត្រា បំពេញធម៌មេត្តាដោយជ្រះថ្លាឥតសៅហ្មង ៗ ហើយទូលថាព្រះអង្គ ស្តេចយាងត្រង់ទីនេះមុន សូមទ្រង់មានបំណង ដោយប៉ុនប៉ងចង់សោយអ្វី ៗ ផលាផងទាំងឡាយ ខ្ញុំលើកថ្វាយមានទុំខ្ចី ទ្រង់សោយដោយមេត្រី ទ្រង់កុំបីព្រួយព្រះទ័យ ៗ ព្រះបាទបិលយក្ស ព្រះទ័យស្ញុំត្រអាក្សាប្រើយ ទតឃើញហេតុបច្ច័យ ក្នុងសម័យគួរគោរព ៗ ទើបមានបន្ទូលថា ខ្ញុំនេះណាវង្វេងសិប់ មិនដឹងហេតុសព្វគ្រប់ ព្រោះដែលផ្ទប់ដោយមោ-ហា ៗ បានឃើញអ្នកប្រាកដ ដល់កំណត់នឹងមរណា ឥឡូវមានជីវ៉ដូចបន្ទោរះពេញវង់ ៗ ទើបពោធិសត្វទូលថា បើអ្នកណាបានផ្គត់ផ្គង់បំរើដោយផ្ចិតផ្ចង់ ចំពោះត្រង់ឪពុកម្តាយ ៗ អ្នកនោះរួចពោសទុក្ខគទៅមុខបានរីងធ្ងាយ ទេវតាផងទាំងឡាយ ទំនួលខ្វាយជួយរក្សា ៗ ទាំងពួកបណ្ឌិតផង តែងចាំចងសរសើរថា ស្លាប់ទៅកើតសួគ៌ា ដោយផលាការបំរើ ៗ ស្តេចទ្រង់ព្រះសណ្តាប់ តបប្រញាប់ឆ្លើយថាអើ កិច្ចនេះល្អណាស់ហើ គួរអញធ្វើកុំបង្អង់ ៗ ទើបផ្ទឹងព្រះហត្ថា ត្រឹមសិរសាបង្គំផ្គង់ ចិត្តស្មោះចំពោះត្រង់ ដល់ពួកអង្គពោធិសត្វ ៗ ថាខ្ញាលសាមបណ្ឌិត ខ្ញុំនេះពិតជាវិបត្តិ មិនដែលទឹកប្រយ័ត្ន កិច្ចប្រតិបត្តិដូចទីពីង ៗ

សូមអ្នកពន្យល់ប្រាប់ ខ្ញុំចាំស្តាប់មិនខានទេ លោកអ្នកជាទីពឹង គ្រាន់ពំនឹងដល់គាថា ។

## ពោធិសត្វសំដែងធម៌ ១០ ចំពោះស្តេចបិលយក្ស

គ្រានោះពោធិសត្វ បុរសកតន៍ទ្រង់មេត្តា សំដែងធម៌ទេសនា ធម្មបរិយាយតាំង ១០ យ៉ាង ។ ចំពោះស្តេចបិលយក្ស ព្រះទ័យស្លុតគ្រប់កសាង ទុកជាត្រៃសំណាង គ្រាន់នឹងការទៅខាងមុខ ។ បពិត្រព្រះក្សត្រា ទីមួយណាទ្រង់ចាំទុក ចិញ្ចឹមម្តាយឪពុក ឲ្យបានសុខគ្រប់វេលា ។ ទីពីរទ្រង់សន្តោស ប្រណីក្មេកសបុត្រភរិយា សង្គ្រោះដោយទ្រព្យា ញាំងពាទយាឲ្យបានស្អាត ។ ទីបីទ្រង់ប្រព្រឹត្ត ចំពោះមិត្រនឹងអមាត្យ ពលលកគ្រួរតាមខ្នាត ឲ្យនៅទេបព្រាប់ផែនដី ។ ទីបួនទ្រង់ទឹកដល់ អស់ពួកពលនឹងពាជី សូមទ្រង់កុំញាំញី ផ្តាច់ជីវិតអស់សង្ខារ ។ ទីប្រាំស្រុកនិគម ទ្រង់និយមច្បាប់ពុទ្ធការ បើទ្រង់មានត្រូវការ យកពន្ធដារត្រាប្រណី ។ ទីប្រាំមួយគីរដ្ឋ នឹងជនបទធំឥតបី ការពារដោយប្រសើរ ក្នុងផែនដីឲ្យបានសុខ ។ ទីប្រាំពីររក្សា ធម៌សមណនឹងព្រាហ្មណ៍ទុក ក្នុងអង្គជាប្រមុខ ទើបបានសុខស្រីសួស្តី ។ ទីប្រាំបីមេត្តា ដោះបាណាម្រឹគបក្សី ទ្រង់កុំធ្វើបាបអ្វី ភ្ជាត់ឈ្មោះតែដល់មរណា ។ ទីប្រាំបួនទ្រង់ធម៌ ដោយស្មោះសរ ប្រពន្ធសក្យា រៀនសូត្រផ្សាយសាស្នា ទំការនាយកកុសល ។ ទីដប់ទ្រង់

ប្រព្រឹត្ត ធម៌សុចរិតឥតកន្លល់ ជាផ្លូវនាំទៅដល់ ទីសុគតឋានសួគ៌ា ។ ពួកទេវតាឥន្ទព្រហ្ម តែងនិយមយកផលា សន្សំគ្រប់ៗគ្នា ដោយផ្ទះថ្លា ឥតសៅហ្មង ។ បពិត្រព្រះមហាក្សត្រ ទ្រង់កំណត់ចិត្តចាំបង ធម៌ ១០ នេះឥតហ្មង កុំកន្លងហួសមាត្រា ។ បើទ្រង់បានប្រព្រឹត្ត ឲ្យសុចរិតសព្វវេលា នឹងទៅកើតសួគ៌ា ឆកាមានោះពុំខាន ។ ព្រះអង្គកុំប្រហែស ធម៌វិសេសដែលទ្រង់បាន ស្តាប់ចាំទាំងប៉ុន្មាន ឲ្យអាក់ខានខូចអសារ ។ មហាបុរសរ័តន៍ ញុំាងមហាក្សត្រឲ្យរក្សា សីលប្រាំពីបាណា ដល់សុរាទីបំផុត ។ សូមទ្រង់តាំងសតិ ទីងហរិឲ្យបរិសុទ្ធ ដោយប្រាជ្ញមោះមុត កុំកក់ស្អុតនឹងលោកធម៌ ។ គ្រានោះស្តេចបិលយក្ស ព្រះទ័យស្ម័គ្រធម៌បវរ ទទួលដោយស្មោះសរ ទ្រង់ត្រេកអរឥតឧបមា ។ ទ្រង់មានព្រះត្រាស់ថាល្អណាស់អ្នកថ្លៃថ្លា ខ្ញុំដាក់លើសិរសា ជាសរណាមួយជីវិត ។ ឥឡូវខ្ញុំសូមលា ទៅភពន៍ប្រព្រឹត្ត ធម៌នេះឲ្យសុចរិត តាមភាសិតដូចប្រាថ្នា ។ បំណែកខាងឥសី នេះតាំងចំភាវនា សម្រេចអភិញ្ញា ទៅកើតនាឋានព្រហ្មលោក ។ សត្វព្រះជាត្រៃ សព្វញ្ញូដ៏មានជោគ លះបោលគ្រឿងសោកគ្រោក បានវិមោក្ខគតិនិព្វាន ។ សំដែងចប់ផ្តួលប្រាប់ តាមលំដាប់ជនដែលមាន កុសលពីបុរាណ ឲ្យឃើញបានយ៉ាងនេះថា ។ ព្រះឥន្ទ្រាធិរាជ មានអំណាចកាលនោះណា ឥឡូវបានមកជា អនុរុទ្ធជាអរហន្ត ។ ព្រះបាទបិលយក្ស មានយសស័ក្តិធំលើសលុះ បានជាព្រះ

អានន្ទ អនុជតន់ព្រះជិនស្រី ។ ឯនាងបារិកា បានមកជានាងថេរី ភទ្ទកា-បិលានី ជាពួកស្រីមានសទ្ធា ។ នាងទេពធីតានោះ មានចិត្តស្មោះបានមកជា នាងឧប្បលវណ្ណា សាវិកាព្រះសម្ពុទ្ធ ។ ឯទុកូលបណ្ឌិត ឥសីសិទ្ធចិត្តបរិសុទ្ធ បានជាសិស្សព្រះពុទ្ធ ខ្ពស់បំផុតឈ្មោះកស្សប ។ សុវណ្ណ-សាមកុមារ បុណ្យអស្ចារ្យមិនគេឡប់ មកកាន់ធម៌ផ្សាយផ្សព្វ តែងតែអប់រំចិត្តសត្វ ។ អន្លោលជាតិមកត្រង់ ជាតួអង្គតថាគត បានត្រាស់ដឹងប្រាកដ គេកំណត់ថាព្រះពុទ្ធ ។ ទ្រង់ញុំាងពួកសព្វសត្វ ដែលវិបត្តិឲ្យរួចផុត ទៅកាន់ទីបរិសុទ្ធ លែងច្យុតគតិទិញ្ញាន ។ រឿងនេះសូមសង្ខេប ធ្វើតាមបែបព្រះទ្រង់ញាណ ដែលបានទេសន៍ទូន្មាន ប្រោសប្រទានទុកជាច្បាប់ ។ ឲ្យយើងទាំងប្រុសស្រី ក្មេងចាស់ក្តីយកគម្រាប់ តាមផ្លូវលោកធ្វើស្រាប់ ត្រូវតែគ្រាប់កុំបះបង់ ។ ទីបំផុតនេះខ្ញុំ សូមបង្គំចំពោះត្រង់ ព្រះពុទ្ធទ្រង់ប្រោសស្រង់ សត្វលិចលង់ក្នុងសង្សារ ។ ទាំងធម៌បរិសុទ្ធ ខ្ពស់បំផុតពីរប្រការ ព្រះសង្ឃផ្ចាច់សង្ការ ខ្ញុំត្រូវការដោយគោរព ។ សូមឲ្យកំចាត់បង់ អពមង្គលសព្វគ្រប់ បានសុខទាំងថ្ងៃយប់ ដោយគោរពគុណារតនា ។ សូមឲ្យមានកំឡាំង ចិត្តខ្ញុំតាំងផ្សងសច្ចា បើបានកើតជាតិណា មានប្រាជ្ញាដ៏មោះមុត ។ បានកើតទាន់សាសនា ខ្ញុំប្រាថ្នាជួបព្រះពុទ្ធ ស្តាប់ធម៌វិសេសសុទ្ធ ទីបំផុតនិព្វានហោង ។

ចប់សុវណ្ណសាមជាតក ទី ៣

# ពិធីព្រះរាជទានតាំងសមណស័ក្តិ

## ទីរាជាគណៈ – ចៅអធិការ – គ្រូសូត្រ

### នៅវត្តឧណ្ណាលោម

កាលពីថ្ងៃព្រហស្បតិ៍ ១៧ ធ្នូ ១៩៦៤ វេលាម៉ោង ១៧ និង ៣០ នាទី (ម៉ោង ៥ កន្លះល្ងាច) មានរៀបពិធីតាំងសមណស័ក្តិទីរាជាគណៈនិង ចៅអធិការ គ្រូសូត្រ ស្តាំ-ឆ្វេង ក្នុងវិហារវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងលោកឡើរសេស៊ុជង់ស៊ីប៉េរីយេរខៃ កម្ពុជរដ្ឋ ទ្រង់ស្តេចយាងទៅ-អញ្ជើញទៅ ជាអធិបតីក្នុងពិធីនេះ ជាផ្លូវរាជការព្រះករុណា និងរាជការអាណាព្យាបាល ។

លុះព្រះករុណាជាម្ចាស់ជីវិត និងលោកឡើរសេស៊ុជង់ស៊ីប៉េរីយេរ ទ្រង់ស្តេចយាង-អញ្ជើញ ចូលក្នុងវិហារវត្តឧណ្ណាលោមហើយ ទ្រង់ប្រោសព្រះរាជទានប្រគេនសញ្ញាប័ត្រនិងផ្តិតសមណស័ក្តិទីរាជាគណៈ ដល់ព្រះមហាថេរានុត្ថេរៈ ៩ រូប តាមលំដាប់ថ្នាក់មុនក្រោយ ។

១ – ព្រះពុទ្ធឃោសាចារ្យ (ជួន-ណាត) ចាងហ្វាងសាលាបាលីជាន់ខ្ពស់, រាជាគណៈសម្រាប់ទោ, បានឡើងសមណស័ក្តិជាព្រះពោធិវង្សរាជាគណៈ សម្រាប់ឯក ព្រមទាំងបានឡើងជាចៅអធិការវត្តឧណ្ណាលោមផង ៕

២ – ព្រះសាក្យវង្ស (ហួត-តាត) អាចារ្យបង្រៀនសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់, អធិបតីក្រុមជំនុំប្រែព្រះត្រៃបិដកនៅពុទ្ធសាសន-

បណ្ឌិត្យ, ពជាគណៈសម្រាប់ត្រី, បានឡើងសមណស័ក្តិជា ព្រះមហាវិមលធម្ម (ថៀនហួន) ពជាគណៈសម្រាប់ទោ ព្រមទាំងបានឡើងជាគ្រូសូត្រស្តាំវត្តឧណ្ណាលោមផង ។

៣- ព្រះអរិយធម្មមុនី (ថែន-ប៉ុល) ពជាគណៈសម្រាប់ចត្វា, បានឡើងសមណស័ក្តិជា ព្រះសាក្យវង្ស ពជាគណៈសម្រាប់ត្រី ។

៤- ព្រះគ្រូឧត្តមមុនី (ម៉ឹង-សែស) គ្រូជំនុំប្រែព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ បានឡើងសមណស័ក្តិជា ព្រះទេពមុនី ពជា-គណៈសម្រាប់ចត្វា ព្រមទាំងបានឡើងជាគ្រូសូត្រឆ្វេងវត្តឧណ្ណាលោមផង ។

៥- ព្រះបាឡាត់អរិយវិមល (ពៅ-នេត្រ) បានឡើងសមណ-ស័ក្តិជា ព្រះឥន្ទមុនី ពជាគណៈសម្រាប់ចត្វា ។

៦- ព្រះគ្រូវិមលបញ្ញា (ឃយ - ហ៊ូ) បានឡើងសមណស័ក្តិជា ព្រះធម្មវិបស្សនា ពជាគណៈសម្រាប់ចត្វា ។

៧- ព្រះបាឡាត់គោធិកម (ឌួន-គិ) បានឡើងសមណស័ក្តិជា ព្រះសិរីវិសុទ្ធញ្ញាណ ពជាគណៈសម្រាប់ចត្វា ។

ព្រះពជាគណៈទាំង ៧ រូបនេះ គង់នៅវត្តឧណ្ណាលោម ។

៨- ព្រះគ្រូបរិយបិដក (ពៅ-ញាណ) បានឡើងសមណស័ក្តិជា ព្រះធម្មវិសុទ្ធិវង្ស ពជាគណៈសម្រាប់ចត្វា ។

៩ – ព្រះត្រៃពិតសត្ថា (ផង់-កុយ) បានឡើងសមណសក្តិជា ព្រះញាណសំវរ រាជាគណៈសម្រាប់ចត្តា ។

ព្រះរាជាគណៈទាំង ២ រូបនេះ គង់នៅវត្តសារាវ័ន ។

លុះរួចកិច្ចព្រះរាជទានសញ្ញាប័ត្រតែងផ្ចិតសមណសក្តិស្រេចហើយ ទើបព្រះមហាវិមលធម្ម (ហួត-តាត) សូត្រសុន្ទរកថា ជាតំណាងតាងនាម នៃព្រះមហាថេរានុត្ថេរៈ ដែលបានទទួលសមណសក្តិថ្មី ព្រមទាំងសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ និងព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិកនិកាយ នូវអស់ព្រះសង្ឃថេរានុត្ថេរៈ ទាំងឡាយជាង ១០០ រូប ដែលបាននិមន្តមកកាន់ទីសន្និបាតនោះ ។

លុះចប់សុន្ទរកថាហើយ ព្រះសង្ឃទាំងអស់ក្នុងទីសន្និបាតនោះ បានសូត្រធម៌ "ជយន្តោ" ចំរើនសិរីសួស្តីជយមង្គល ថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូង, ជូនលោកឡេស៊ីដង់ស៊ុបេរីយើរ និងអស់លោករដ្ឋមន្ត្រីសេនាបតី ។

លុះចប់ធម៌ជយន្តោហើយ ព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់កាន់ផ្ទួងផ្កា ១ កម្រង លោកឡេស៊ីដង់ស៊ុបេរីយើរកាន់ផ្ទួងផ្កា ១ កម្រង ស្តេចអញ្ជើញយកទៅដាក់ថ្វាយក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូប ។ ព្រះពោធិវង្ស (ជួន-ណាត) បានថ្វាយទៀនធំ ១ ចំពោះព្រះករុណាជាម្ចាស់ជីវិត, ទៀនធំ ១ ទៀតជូនទៅលោកឡេស៊ីដង់ស៊ុបេរីយើរ ហើយ

បានគុជបូជាព្រះរតនត្រ័យ ៗ ព្រះពោធិ៍វង្ស បានធ្វើសច្ចាធិដ្ឋានចំពោះព្រះភ័ក្ត្រព្រះករុណាជាម្ចាស់ជីវិត មានលោកឡឺរេស៊ីដង់ស៊ុបេរីយ៉េរ បិតនៅក្នុងទីនោះផងថា សូមឲ្យកម្ពុជរដ្ឋរួចផុតចាកគ្រោះថ្នាក់គ្រប់យ៉ាង! សូមឲ្យជួបប្រទះតែសេចក្តីសុខសេចក្តីចំរើនតទៀតទៅ!

ព្រះករុណាជាម្ចាស់ជីវិតនិងលោកឡឺរេស៊ីដង់ស៊ុបេរីយ៉េរ ក៏សំដែងសេចក្តីរីករាយទទួលពាក្យសច្ចាធិដ្ឋានរបស់ព្រះពោធិ៍វង្ស ៗ

ពួកឧបាសកជើងវត្តឧណ្ណាលោម បានលៀងភេសជ្ជៈចំពោះអស់លោកឥស្សរជនក្នុងទីសាលនោះ ដោយសោមនស្សរីករាយនិងគារវភាព ៗ

មួយទៀត ក្នុងពិធីនោះ មានពុទ្ធសាសនិកបព្វជិតគ្រហស្ថ ដែលនិមន្តមក-អញ្ជើញមកជួបជុំជាច្រើន ៗ ខាងបព្វជិត មានសម្តេចព្រះមហាសុមេធាធិបតីជាប្រធាន ៗ ខាងគ្រហស្ថ (ក្រៅពីព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងលោកឡឺរេស៊ីដង់ស៊ុបេរីយ៉េរ) មានលោកអ្នកឧកញ៉ាអគ្គមហាសេនាជាដើម ៗ ខាងស្ត្រីពុទ្ធសាសនុបណ្ឌិត្យ មានលោកអគ្គលេខាធិការ ឌុយប៉ុង ជាដើម ៗ ចំណែកខាងពួកឧបាសកជើងវត្តឧណ្ណាលោម មានអ្នកឧក្រស៊ីញ៉ែកជាដើម បានមកជួបជុំប្រគេនភេសជ្ជៈ ដល់ព្រះសង្ឃជាសាធារណទានមិនចំពោះបុគ្គល, ភេសជ្ជទាននោះច្រើនបរិបូណ៌ ឥតមានខ្វះខាតឡើយ ៗ

# មន្ធាតុរាជជាតក

## អាចារ្យ គី-គឹមស៊ីវ ប្រែនិងរៀបរៀង

យាវតា ចន្ទិមសុរិយាតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ ឧក្កណ្ឋិតភិក្ខុំ អារព្ភ កថេសិ ។

សត្ថា រីអង្គសម្តេចព្រះបរមសាស្តាចារ្យ កាលស្តេចទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថ គង់នៅក្នុងព្រះវិហារជេតពនសុគន្ធ-កុដិស្រីមហាវិហារ អារព្ភ ទ្រង់ព្រះប្រារព្ធភិក្ខុអ្នកអផ្សុកមួយរូបឲ្យជាហេតុ កថេសិ ទើបទ្រង់សំដែងជាតកនេះដោយគាថាថា យាវតា ចន្ទិមសុរិយា ដូច្នេះជាដើម ។

កិរ ដូចបានឮមកថា មានភិក្ខុ ១ រូប ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី បានឃើញស្ត្រីមានកាយប្រដាប់ដោយគ្រឿងអលង្ការ ក៏កើតសេចក្តីបដិពទ្ធក្នុងស្ត្រីនោះ ហើយមានសេចក្តីអផ្សុកប្រាថ្នានឹងសឹកចេញជាឃរាវាស ភិក្ខុទាំងឡាយដឹងរឿងនោះ ទើបនាំភិក្ខុនោះទៅគាល់សម្តេចព្រះលោកនាថហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុនេះជាអ្នកមានសេចក្តីអផ្សុក ។

សម្តេចព្រះបរមសាស្តាមានព្រះពុទ្ធត្រាស់សួរថា ម្នាលភិក្ខុ បានឮថា អ្នកមានសេចក្តីអផ្សុកពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គអផ្សុកពិតមែន ទើបមានព្រះពុទ្ធត្រាស់ថា

ម្នាលភិក្ខុ បើអ្នកសឹកចេញទៅជាឃរាវាស អ្នកនឹងអាចញ៉ាំងសេចក្តីប្រាថ្នាឲ្យពេញបានដែរឬ? ធម្មតាតណ្ហា គឺសេចក្តីប្រាថ្នាក្នុងកាមគុណទាំង ៥ នេះជារបស់ដែលបុគ្គលណាមួយមិនគប្បីឲ្យពេញបាន ប្រៀបដូចមហាសមុទ្រដ៏ធំទូលាយមិនអាចនឹងឲ្យពេញដោយទឹកដែលហូរមកអំពីមហានទីទាំង ៥ ដូច្នោះ សូម្បីពុកណបណ្ឌិតទាំងឡាយ ដែលបានសោយសិរីរាជសម្បត្តិជាបរមចក្រពត្រាធិរាជ មានអំណាចផ្សាយទៅក្នុងទ្វីបធំទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ ទីងបានសោយទិព្វស្រីផ្ការក្នុងជាន់ចាតុម្មហារាជិកា ទាំងបានសោយទិព្វសម្បត្តិក្នុងតាវត្តិង្សទេវលោកឋិតនៅក្នុងវិមានសម្តេចសក្កទេវរាជអស់កាលយូរ រហូតសម្តេចមឃកន្លងទៅដល់ ៣៦ ព្រះអង្គ ក៏នៅតែមិនអាចញ៉ាំងកាមតណ្ហាគឺសេចក្តីប្រាថ្នាក្នុងកាមគុណទាំង ៥ ឲ្យបរិបូណ៌ពេញទីបាន ម្នាលភិក្ខុ អ្នកអាចនឹងធ្វើកាមតណ្ហា ឲ្យបរិបូណ៌ពេញទីបានដែរឬ? កាលមានព្រះពុទ្ធត្រាស់ដូច្នេះហើយ ទើបទ្រង់នាំរឿងក្នុងអតីតកាលមកត្រាស់ទេសនាដូចតទៅនេះ ។

អតីតេ បឋមកប្បេ មហាសម្មតោ នាម រាជា អហោសិ ។

ក្នុងកាលបឋមកប្បកន្លងទៅហើយ មានព្រះរាជាមហាសម្មតិវង្ស ១ ព្រះអង្គ ព្រះរាជឱរសរបស់ព្រះរាជាអង្គនោះ បានជាក្សត្រទ្រង់

ព្រះនាមថា ព្រះចៅរោជរាជ ព្រះរាជឱរសរបស់ព្រះចៅរោជរាជនោះ បានជាក្សត្រទ្រង់ព្រះនាមថា ព្រះចៅវររោជរាជ ព្រះរាជឱរសរបស់ព្រះចៅវររោជរាជនោះបានជាក្សត្រទ្រង់ព្រះនាមថា ព្រះចៅកល្យាណបតី ព្រះរាជឱរសរបស់ព្រះចៅកល្យាណបតីនោះ បានជាក្សត្រទ្រង់ព្រះនាមថា ព្រះចៅឧបោសថរាជ ព្រះរាជឱរសរបស់ព្រះចៅឧបោសថរាជនោះ បានជាក្សត្រទ្រង់ព្រះនាមថា ព្រះចៅវរឧបោសថ ព្រះរាជឱរសរបស់ព្រះចៅវរឧបោសថរាជនោះ បានជាក្សត្រិយ៍ទ្រង់ព្រះនាមថា ព្រះចៅមន្ធាតុរាជ ព្រះចៅមន្ធាតុរាជនោះប្រកបដោយរាជរិទ្ធិសក្តាតេជះបរិបូណ៌ ដោយរ័តន៍ពិសេស ៧ ប្រការ ជាបរមចក្រពត្រាធិរាជ មានបុញ្ញានុភាពអស្ចារ្យក្នុងកាលដែលព្រះអង្គទ្រង់បត់ព្រះហស្តខាងឆ្វេង សណ្ដូកព្រះហស្តខាងស្តាំ ភ្លៀងកែវ ៧ ប្រការ ក៏បង្អុរចុះមកប្រមាណត្រឹមជានុមណ្ឌល ដូចជាភ្លៀងបង្អុរធ្លាក់ចុះមកអំពីអាកាស ព្រះចៅមន្ធាតុរាជជាមនុស្សអស្ចារ្យយ៉ាងនេះ កាលព្រះអង្គទ្រង់វ័យនៅជាកុមារប្រកបដោយការលេង កំណត់កាលដ៏យូរបាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ កាលបានសោយសិរីរាជសម្បត្តិជាបរមចក្រពត្រាធិរាជ កំណត់កាលបាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ ព្រះជន្មាយុរបស់ព្រះចៅមន្ធាតុរាជនោះមានកំណត់បាន ១ អសង្ខេយ្យ ។

លុះតមកមានមួយថ្ងៃ ព្រះចៅមន្ធាតុបរមចក្រពត្រាធិរាជនោះ មិនអាចនឹងញ៉ាំងកាមតណ្ហាឲ្យលុះព្រះទ័យបាន ទើបទ្រង់សំដែងអាការដែលព្រះអង្គទ្រង់អផ្សុក គឺមិនត្រេកអរក្នុងរាជសម្បត្តិ ។ ពួកអាមាត្យរាជបរិស័ទក្រាបបង្គំទូលសួរថា: បពិត្រព្រះអង្គជាសម្មតិទេវរាជ អាការដែលព្រះអង្គទ្រង់អផ្សុកនោះ បណ្តាលមកអំពីហេតុអ្វី? នែ! អាមាត្យទាំងឡាយ យើងឃើញកំឡាំងបុណ្យរបស់យើងមានច្រើន សិរីរាជ-សម្បត្តិប៉ុណ្ណេះមិនល្មមដល់សេចក្តីត្រេកអររបស់យើងទេ សិរីរាជ-សម្បត្តិក្នុងឋានណា ហ្ន៎ ទើបជាទីរីករាយជាងនេះ? បពិត្រព្រះអង្គជាសម្មតិទេវរាជ ទេវលោក ទើបជាទីរម្មណីយដ្ឋាន សម្រាន្តព្រះទ័យជាងមនុស្សលោកនេះ ។ ព្រះចៅមន្ធាតុបរមចក្រពត្តិ បានទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ក៏ទ្រង់ធ្វើចក្រកែវឲ្យនាំទៅក្នុងខាងមុខ ហើយស្តេចយាត្រាព្រមដោយរាជបរិស័ទតាមចក្រកែវនោះឡើងទៅកាន់អា-កាសវិថី ។

ចំណែកស្តេចចតុម្មហារាជិកាទាំង ៤ ឃើញព្រះចៅមន្ធាតុបរម-ចក្រពត្តិ ស្តេចមកក៏កាន់ទិព្វមាលា មានក្លិនក្រអូបឈ្ងុយឈ្ងប់ នាំពួកទេពធិតាទាំងឡាយជាបរិវារមកធ្វើបច្ចុគ្គមនាការនៅពាក់កណ្តាលមាគ៌ា អញ្ជើញស្តេចឡើងទៅប្រថាប់ក្នុងឋានចាតុម្មហារាជិកា ហើយក៏បង្វែរសិរីសម្បត្តិក្នុងឋានចាតុម្មហារាជិកាថ្វាយព្រះចៅមន្ធាតុបរមចក្រពត្តិ សូម្បី

បានដោយទិព្វសម្បត្តិក្នុងជាន់ចាតុម្មហារាជិកា ព្រមដោយពលបរិវារនឹងទេវបរិវារអស់កាលយូរ ក៏នៅមិនអាចនឹងធ្វើសេចក្តីប្រាថ្នាឲ្យពេញបាន ទើបសំដែងអាការដែលព្រះអង្គទ្រង់អផ្សុកទ្រង់មិនបានត្រេកអរក្នុងទេវសម្បត្តិក្នុងជាន់ចាតុម្មហារាជិកានោះទៀត ។ សម្តេចចាតុម្មហារាជិកាទាំង ៤ ក៏ក្រាបបង្គំទូលសួរថា បពិត្រមហារាជព្រះអង្គទ្រង់អផ្សុកដោយហេតុអ្វី? ព្រះបាទមន្ធាតុបរមចក្រពត្តិត្រាស់ថា សិរីសម្បត្តិត្រឹមប៉ុណ្ណេះនៅមិនជាទីត្រេកអរល្មមដល់សេចក្តីប្រាថ្នារបស់យើងទេ ហើយត្រាស់សួរថា សិរីសម្បត្តិក្នុងទីណាហ្ន៎ ទើបជាទីត្រេកអរវិសេសជាងនេះទៀត? សម្តេចចាតុម្មហារាជិកាទាំង ៤ ក្រាបបង្គំទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គទាំងឡាយនេះជាអ្នកទទួលធ្វើការក្រោមបង្គាប់ស្តេចនៃទេវតាទេ ទីដែលរម្មណីយដ្ឋានជាងគេនោះមានតែតាវត្តិង្សទេវលោកឯណោះ ទើបជាទីរីករាយទៅដោយកាមារម្មណ៍ដ៏ឧត្តមជាងជាន់ចាតុម្មហារាជិកានេះ ។ កាលព្រះបាទមន្ធាតុបរមចក្រពត្តិ បានទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ទើបទ្រង់ធ្វើចក្រកែវឲ្យនាំទៅក្នុងខាងមុខ ព្រះអង្គព្រមដោយពលបរិវារ ក៏ស្តេចបែរព្រះភក្ត្រចំពោះទៅតាវត្តិង្សទេវលោក ។

លំដាប់នោះសម្តេចសក្កទេវរាជ ទតព្រះនេត្រឃើញព្រះបាទមន្ធាតុបរមចក្រពត្តិស្តេចមក ទើបទ្រង់កាន់ទិព្វមាលាសុគន្ធជាតិ មានអមរ

ទេវតាចោមរោមជាបរិវារ ស្តេចចេញទៅធ្វើបច្ចុគ្គមនាការទទួលចាប់ព្រះហស្តព្រះចៅមន្ធាតុបរមចក្រពត្តិហើយត្រាស់ថា សូមអញ្ជើញស្តេចយាងមកខាងណេះ លុះព្រះចៅមន្ធាតុបានស្តេចទៅដល់សំណាក់សម្តេចមឃវ៉ាហើយ ពួករតនបរិនាយកពលនៃរក៏នាំចក្កកែវព្រមទាំងពលបរិស័ទត្រឡប់ចុះមកកាន់មនុស្សលោកវិញ ចំណែកសម្តេចមឃវ៉ាទេវរាជនោះ លុះនាំព្រះចៅមន្ធាតុបរមចក្រពត្តិមកដល់តាវត្តិង្សទេវលោកហើយ ក៏ចែកទិព្វសម្បត្តិថ្វាយព្រះចៅមន្ធាតុ បរមចក្រពត្តិនោះពាក់កណ្តាលហើយឲ្យប្រថាប់នៅក្នុងតាវត្តិង្សទេវនគរ ។

តាំងដើមអំពីនោះមក ព្រះរាជាទាំងពីរព្រះអង្គគឺព្រះចៅមន្ធាតុបរមចក្រពត្តិនិងសម្តេចកោសិយសក្កទេវរាជក៏សោយទិព្វសម្បត្តិជួសុខស្មើគ្នាក្នុងតាវត្តិង្សទេវលោកនោះកំណត់កាលបាន ៣ កោដិ ៦០ សែនឆ្នាំ លុះសម្តេចព្រះកោសិយសក្កទេវរាជអង្គនោះអស់ព្រះជន្មាយុចុតិទៅ សម្តេចសក្កទេវរាជអង្គថ្មីមកឧប្បត្តិជំនួសឡើងទៀត ហើយសោយរាជសុខពាក់កណ្តាលដូចអង្គមុន កាលបើដល់អាយុក្ស័យហើយក៏ចុតិទៅ សក្កទេវរាជដែលឧប្បត្តិឡើងនិងចុតិទៅវិញដោយទំនងនេះ រាប់បាន ៣៦ ព្រះអង្គ ចំណែកព្រះចៅមន្ធាតុបរមចក្រពត្តិនោះ មានព្រះសរីរកាយជាមនុស្ស បានសោយទិព្វសុខាភោគដ៏បរិសុទ្ធទើបមិនចុតិចាកទេវស្ថាន ។

បានសោយទិព្វសម្បត្តិក្នុងឋានចាតុម្មហារាជិកា ព្រមដោយកងបរិវារ នឹងទេវបរិវារអស់កាលយូរ ក៏នៅមិនអាចនឹងធ្វើសេចក្តីប្រាថ្នាឲ្យពេញបាន ទើបសំដែងអាការដែលព្រះអង្គទ្រង់អផ្សុកទ្រង់មិនបានត្រេកអរ ក្នុងទេវសម្បត្តិក្នុងឋានចាតុម្មហារាជិកានោះទៀត ។ សម្តេចចាតុម្មហារាជិកាទាំង ៤ ក៏ក្រាបបង្គំទូលសួរថា បពិត្រមហារាជ ព្រះអង្គទ្រង់អផ្សុកដោយហេតុអ្វី? ព្រះចៅមន្ធាតុបរមចក្រពត្តិត្រាស់ថា សិរីសម្បត្តិត្រឹមប៉ុណ្ណេះនៅមិនជាទីត្រេកអរល្មមដល់សេចក្តីប្រាថ្នារបស់យើងទេ ហើយត្រាស់សួរថា សិរីសម្បត្តិក្នុងទីណាហ្ន៎ ទើបជាទីត្រេកអរវិសេសជាងនេះទៀត? សម្តេចចាតុម្មហារាជិកាទាំង ៤ ក្រាបបង្គំទូលថា បពិត្រមហារាជ ខ្ញុំព្រះអង្គទាំងឡាយនេះជាអ្នកទទួលធ្វើការក្រោមបង្គាប់ស្តេចនៃទេវតាទេ ទីដែលរម្មណីយដ្ឋានជាងគេនោះមានតែតាវត្តិង្សទេវលោកឯណោះ ទើបជាទីរីករាយទៅដោយកាមារម្មណ៍ដ៏ឧត្តមជាងឋានចាតុម្មហារាជិកានេះ ។ កាលព្រះចៅមន្ធាតុបរមចក្រពត្តិ បានទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ទើបទ្រង់ធ្វើចក្កកែវឲ្យនាំទៅក្នុងខាងមុខ ព្រះអង្គព្រមដោយកងបរិវារ ក៏ស្តេចហែរព្រះកក្រ្តចំពោះទៅតាវត្តិង្សទេវលោក ។

លំដាប់នោះសម្តេចសក្កទេវរាជ ទតព្រះនេត្រឃើញព្រះចៅមន្ធាតុបរមចក្រពត្តិស្តេចមក ទើបទ្រង់កាន់ទិព្វមាលាសុគន្ធជាតិ មានអមរ

ទេវតាចោមរោមជាបរិវារ ស្តេចចេញទៅធ្វើបច្ចុគ្គមនាការទទួលរាប់ព្រះហស្តព្រះចៅមន្ធាតុបរមចក្រពត្តិហើយត្រាស់ថា សូមអញ្ជើញស្តេចយាងមកខាងណេះ លុះព្រះចៅមន្ធាតុរាជស្តេចទៅដល់សំណាក់សម្តេចមឃវាហើយ ពួករតនបរិនាយកពលកែវក៏នាំចក្រកែវព្រមទាំងពលបរិវារត្រឡប់ចុះមកកាន់មនុស្សលោកវិញ ចំណែកសម្តេចមឃវាទេវរាជនោះ លុះនាំព្រះចៅមន្ធាតុបរមចក្រពត្តិមកដល់តាវត្តិង្សទេវលោកហើយ ក៏ចែកទិព្វសម្បត្តិថ្វាយព្រះចៅមន្ធាតុ បរមចក្រពត្តិនោះពាក់កណ្តាលហើយឲ្យប្រថាប់នៅក្នុងតាវត្តិង្សទេវនគរ ។

តាំងដើមអំពីនោះមក ព្រះកដាតាំងពីព្រះអង្គព្រះចៅមន្ធាតុបរម-ចក្រពត្តិនិងសម្តេចកោសិយសក្កទេវរាជក៏សោយទិព្វសម្បត្តិរួមសុខស្មើគ្នាក្នុងតាវត្តិង្សទេវលោកនោះអស់កាលបាន ៣ កោដិ ៦០ សែនឆ្នាំ លុះសម្តេចព្រះកោសិយសក្កទេវរាជអង្គនោះអស់ព្រះជន្មាយុចុតិទៅ សម្តេចសក្កទេវរាជអង្គថ្មីមកចាប់បដិសន្ធិឡើងទៀត ហើយសោយរាជ្យសុខពាក់កណ្តាលដូចអង្គមុន កាលបើដល់អាយុខ័យហើយក៏ចុតិទៅ សក្កទេវរាជដែលចាប់បដិសន្ធិឡើងនិងចុតិទៅវិញដោយទំនងនេះ រាប់បាន ៣៦ ព្រះអង្គ ចំណែកព្រះចៅមន្ធាតុបរមចក្រពត្តិនោះ មានព្រះសរីរកាយជាមនុស្សបានសោយទិព្វសុខាភោជន៍ដ៏បរិសុទ្ធដោយមិនចុតិចាកទេវស្ថាន ។

លុះដល់សម្តេចសក្កទេវរាជអង្គទី ៣៧ ច្យុតិទៀតក្នុងតាវត្តិង្ស-ទេវកតទៀត ក៏បានសោយទិព្វសម្បត្តិវដ្ឋសុខពាក់កណ្តាលជួបអង្គមុខ ឯព្រះចៅមន្ធាតុបរមចក្រពត្តិមានសេចក្តីប្រាថ្នាក្នុងបញ្ចពិធកាមគុណ មិនមានទីបំផុត ក៏កើតសេចក្តីខ្វល់ខ្វាយចិត្តមិនគាប់ព្រះទ័យក្នុងវដ្ឋសុខ ត្រឹមប៉ុណ្ណោះ ទើបទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដែលយើងមកសោយ ទិព្វសម្បត្តិតែត្រឹមពាក់កណ្តាលប៉ុណ្ណោះ យើងនឹងផ្តាច់ព្រះជន្មជីព សម្តេចមឃវាអង្គនេះចេញ ហើយនឹងសោយទិព្វសម្បត្តិក្នុងឋានតាវ-ត្តិង្សនេះឲ្យដាច់ខាតសុខតែម្នាក់ឯង, តែទ្រង់មិនអាចនឹងផ្តាច់ព្រះជន្មជីព សម្តេចមឃវានោះបានឡើយ កាលបើមិនសម្រេចព្រះរាជបំណងដូច ទ្រង់ព្រះតម្រិះទុក ក៏កើតទុក្ខទោមនស្សតូចព្រះទ័យគ្រប់ទិវារាត្រី ។

ធម្មតាកាមតណ្ហា គឺសេចក្តីប្រាថ្នាក្នុងកាមគុណនេះ ជាមូលនៃ សេចក្តីវិបត្តិ ព្រោះហេតុនោះ អាយុសង្ខាររបស់ព្រះចៅមន្ធាតុបរមចក្រ-ពត្តិក៏ត្រូវវិនាសទៅ ខណៈនោះជរាក៏ចូលមកបៀតបៀនព្រះសរីរកាយ ឲ្យគ្រាំគ្រាទ្រុឌទ្រោមទៅ តែធម្មតាសរីរយន្តៈមនុស្សជាតិទាំងឡាយ មិនដែលបែកធ្លាយក្នុងទេវលោកនោះឡើយ ព្រោះហេតុដូច្នោះ ព្រះចៅមន្ធាតុបរមចក្រពត្តិ ក៏ត្រូវចុតិឃ្លាតចាកទេវលោកចុះមកនៅក្នុងព្រះរាជឧទ្យាន ។

ចំណែកឧយ្យានបាល (អ្នករក្សាសួន) បានឃើញស្តេចមន្ធាតុរាជ-ស្តេចមកនៅក្នុងឧទ្យានដូច្នោះ នាំសេចក្តីនោះទៅក្រាបបង្គំទូលដល់រាជ-ត្រកូល ។ ក៏នាំគ្នាមកគាល់តែងទីព្រះក្រឡាបន្ទំក្នុងព្រះរាជឧទ្យាន ថ្វាយព្រះចៅមន្ធាតុបរមចក្រពត្តិផ្ទំជាអនុដ្ឋានសេយ្យាសន៍ ។

ក្នុងខណៈនោះ ពួកសេវកាមាត្យទាំងឡាយនាំគ្នាក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គជាសម្មតិទេវរាជ ឥឡូវនេះព្រះអង្គខឹងឲ្យខ្ញុំទូលបង្គំទាំងឡាយធ្វើដូចម្តេចក្នុងទីចំពោះព្រះកត្រព្រះអង្គ ? ព្រះចៅមន្ធាតុបរមចក្រពត្តិត្រាស់ថា អ្នកទាំងឡាយចូរឲ្យដំណឹងទៅដល់មហាជនឲ្យបានដឹងគ្រប់គ្នាថា ព្រះចៅមន្ធាតុបរមចក្រពត្តិបានសោយរាជសម្បត្តិជាបរមចក្រពត្រាធិរាជមានឥស្សរភាពផ្សាយទៅក្នុងទ្វីបធំទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារនិងបានទៅសោយទិព្វសម្បត្តិក្នុងជាន់ចាតុម្មហា-រាជិកាក៏យូរអង្វែង ទាំងបានទៀតទៅសោយទិព្វសម្បត្តិក្នុងតាវត្តិង្សទេវ-លោក រហូតដល់អស់អាយុរបស់ព្រះឥន្ទ្រ ៣៦ ព្រះអង្គ ក៏នៅមិនអាចនឹងញ៉ាំងសេចក្តីត្រេកអរ សេចក្តីប្រាថ្នាក្នុងកាមារម្មណ៍ឲ្យពេញព្រះទ័យបាន ដល់ទីបំផុតក៏ត្រូវចុតិឃ្លាតចាកទេវលោកចុះមកផ្ទំក្នុងព្រះរាជឧទ្យាន ឥឡូវនេះស្តេចទិវង្គតហើយ ។ ព្រះចៅមន្ធាតុបរមចក្រពត្តិមានព្រះរាជតម្រាស់ផ្តាំដូច្នេះហើយក៏ស្តេចទិវង្គតទៅតាមយថាកម្មរបស់ព្រះអង្គ ។

សត្ថា ឥមំ ធម្មទេសនំ អាហរិត្វា សម្តេចព្រះបរម-សាស្តាចារ្យទ្រង់នាំព្រះធម្មទេសនាគឺជាតកនេះមកសំដែងហើយ ទើបត្រាស់នូវបទព្រះគាថាទាំងឡាយដូចតទៅនេះ

យាវតា ចន្ទិមសុរិយា បរិហរន្តិ ទិសា ភន្តិ វិរោចមានា
សព្វេវ ទាសា មន្ធាតុ យេ បាណា បឋវិស្សិតា
ន កហាបណវស្សេន តិត្តិ កាមេ ន វិជ្ជតិ
អប្បស្សាទា ទុក្ខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ
អបិ ទិព្វេសុ កាមេសុ រតិំ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ៗ

សេចក្តីថា ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយកាលរះឡើងដើរវិលវង់ក្បែរភ្នំសិនេរុរាជ មានរស្មីដ៏ភ្លឺស្វាងរុងរឿងផ្សាយទៅក្នុងទិស ទាំង ១០ ដោយទីមានកំណត់ត្រឹមណា សត្វគឺមនុស្សទាំងឡាយដែលអាស្រ័យនៅលើផែនដីក្នុងទីមានកំណត់ត្រឹមណោះ ជាខ្ញុំព្រះចៅមន្ធាតុរាជទាំងអស់ ព្រះចៅមន្ធាតុរាជកាលទ្រង់មានព្រះរាជបំណងនឹងសង្គ្រោះដល់មនុស្សដែលជាខ្ញុំទាំងប៉ុណ្ណោះ ទ្រង់ទះព្រះហស្តក្នុងកាលណា ក្នុងកាលណោះ ភ្លៀងកែវទាំង ៧ ប្រការក៏បវត្តនាការធ្លាក់ចុះមក សូម្បីយ៉ាងនោះ សេចក្តីឆ្អែតក្នុងវត្ថុកាមនិងកិលេសកាម ក៏នៅមិនល្មមដល់ព្រះចៅមន្ធាតុរាជនោះ ក៏បណ្ឌិតកាលដឹងច្បាស់ថា កាមទាំងឡាយមានសេចក្តី

ត្រេកអរតិច ក៏មានសេចក្តីសុខតិច ប្រកបទៅដោយសេចក្តីទុក្ខច្រើន ដូច្នេះ ក៏មិនមានសេចក្តីត្រេកអរក្នុងកាមទាំងឡាយ ១ ទៀត សាវ័ករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ សូម្បីមានគេដកអរពេញចិត្តដោយកាមដ៏ជាទិព្វទាំងឡាយ លោកក៏មិនមានសេចក្តីប្រាថ្នានឹងត្រេកអរក្នុងកាមដ៏ជាទិព្វនោះឡើយ លោកប្រាថ្នាត្រេកអរតែក្នុងព្រះនិព្វានធម៌ដែលជាទីអស់ទៅនៃតណ្ហា ដោយចំណែកមួយប៉ុណ្ណោះ ។

កាលសម្តេចព្រះបរមសាស្តាចារ្យ ទ្រង់នាំអតីតនិទានមកត្រាស់ទេសនាយ៉ាងនេះហើយ ទើបទ្រង់ប្រកាសនូវអរិយសច្ចទាំងឡាយ លុះចប់អរិយសច្ចហើយ ភិក្ខុដែលអផ្សុកនោះក៏បានសម្រេចសោតាបត្តិផល ព្រមទាំងភិក្ខុទាំងឡាយដទៃក៏បានសម្រេចផលមានសោតាបត្តិផលជាដើម ទើបសម្តេចព្រះលោកុត្តមាចារ្យទ្រង់ប្រជុំជាតកថា ព្រះចៅមន្ធាតុបរមចក្រពត្តិក្នុងគ្រានោះ គឺអង្គតថាគតហ្នឹងឯង ។

ចប់មន្ធាតុរាជជាតក ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុំម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — *ទំព័រ*

ស្មៀន គង់-សន . . . . . . . ពាក្យសុភាសិតបុរាណ . . . . . . . . . ៥០៥

ឃុំឧត្តមប្រីជា ចាប-ពិន . . . ចណ្ដៅ (តមក) . . . . . . . . . . . . ៥០៧

លោក ហាន់-យេង . . . . . . . រឿងកំពូលកំសត់ (តមក) . . . . . . . . ៥១៦

លោក ញ៉ុក-នូ . . . . . . . ច្បាប់ក្រមបរិយាយ (តមកនិងចប់) . . . . ៥៣០

*ផ្នែកសាសនា*

ដំណឹងអំពីក្រសួងធម្មការ . . . អំពីចៅអធិការនិងមន្ត្រីសង្ឃ ដែលទើបតាំងថ្មី ៥៤៨

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . ឯកភាគនៃទំលិនូបញ្ហា (តមក) . . . . . ៥៥៣

ឆ្នាំទី ១៦ — លេខ ១០ ខែអុកតូប្រ៍ ឆ្នាំ ១៩៤៤ — ដំឡៃជាវៈ ១ ឆ្នាំ ១៥ រៀល ។

N° 10

M. 8° 1461
27-XI-44

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire: Luong Nibandhamantri NHOK-THÊM, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Preah kru Paññalikhito KAO-SIM, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

**Partie littéraire:**



| | | Pages |
|---|---|---|
| Smien Kong-Sân . . . . | Peak sŏp'easĕt bŏran. . . . . . . | 505 |
| K'ŭn Ŏtdăm Preichea Chap-Pinn . . . . . . | Băndau (devinettes cambodgiennes) | 508 |
| Monsieur Han-Yêng. . . . | Kămpul kămsăt, roman (suite) . . | 516 |
| Monsieur Nheuk-Nou. . . | Chbáp krăm bărĭyay (suite et fin) | 530 |



**Partie religieuse:**



| | | |
|---|---|---|
| Communiqué du Département des Cultes . . . | Nominations de Chau At'ikar et Montrei săng . . . . . . . . | 548 |
| Luong Nĭponmontrei Nhok-Thêm . . . . . . . | Ekabhāga-Milindapañhā (suite). . . | 557 |



16e année — No 10. Octobre 1944 — Abonnement: un an 15$00.

BIBLIOTHÈQUE D'EXTRÊME-ORIENT

# ពាក្យសុភាសិតបុរាណ

ខ្ញុំបាទស្បៀនគង់-សន ផ្ទះនៅផ្លូវជេសបុស លេខ ៤៦ ឃុំលេខ ៤ ក្រុងភ្នំពេញ ។ កាលខ្ញុំបាទនៅពីក្មេង (ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម ព្រះករុណាសុវណ្ណកោដ្ឋ) នោះខ្ញុំបាទបានធ្វើដំណើរចេញពីស្រុកខ្មែរទៅស្រុកកូសាំងស៊ីន បានចូលទៅសំណាក់នៅវត្តមួយហៅថា វត្តបង់បត់ នៅក្នុងខែត្រព្រែកឫស្សី បានប្រទះឃើញសាស្ត្រាស្លឹករឹត ១ ខ្សែ រេចដាច់ដាចអស់ហើយនៅសល់តែបីសន្លឹក សេចក្តីក្នុងសាស្ត្រានោះជាពាក្យកាព្យហើយជាពាក្យសុភាសិត ខ្ញុំបាទចាប់យកមកមើលឃើញមានសេចក្តីពិរោះស្តាប់ ជាប់ដល់ត្រចៀកខ្ញុំបាទពន់ពេក ទើបខំទន្ទេញទាល់តែចាំមាត់ ។ ឯពាក្យដំបូន្មានទាំងនេះ មាននៅក្នុងច្បាប់អ្វី ឬសាស្ត្រាអ្វី ខ្ញុំមិនដែលប្រទះឃើញសោះ បើដោយស្មានទៅមិនលែងមានទេ ក្នុងក្បួនច្បាប់ចាស់ៗ ដែលចារនឹងស្លឹករឹត នៅស្រុកខ្មែរយើងនេះ ។ ឯពាក្យដំបូន្មានដែលខ្ញុំបាទនៅចាំបាន រហូតមកដល់សព្វថ្ងៃនេះដូច្នេះ :

(បទព្រហ្មគីតិ)

. . . . . . . . . . . . . . . . . . . . . . . . . . . . .

ក្សត្រាពឹងទសពិធ   រាជបណ្ឌិតពឹងធម៌ស   យោធាពឹងអស្សតរ
អ្នកគោចរពឹងសាលា ។ សំពៅពឹងព្រះពាយ   អ្នកអក្រាយពឹងរាបា

កជសីហ៍ពីងគូហា សត្វមហិង្សាសោតពីងស្ទែង ៗ ក្សត្រិស្រែវលីគួណ៌
គតាវកេក្រួយសសក្តិសែង ពីងវក្តប្រតិបត្តិស្ទែង ជាលំនៅទីប្រសើរ ៗ

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

(បទកាកគតិ)

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ធ្វើអ្វីឲ្យស្រាន់ ធ្វើអ្វីឲ្យបាន ធ្វើអ្វីឲ្យផ្ចង់ ធ្វើអ្វីឲ្យត្រូវ ធ្វើអ្វីឲ្យត្រង់
ធ្វើអ្វីឲ្យគង់ ធ្វើអ្វីឲ្យគាប់ ៗ រីធ្វើឲ្យស្រាន់ ប្រើអត់ក្រោធថ្កាន
រំលាយទោសធាប់ រីធ្វើឲ្យបាន ប្រើឲ្យមានទៀង ប្រើផ្ចង់ចិត្តស្តាប់
ច្បាប់ច្បាស់មាត្រា ៗ រីធ្វើឲ្យត្រូវ ប្រើគិតដោយនូវ ច្បាប់ក្បួន
សាស្ត្រា រីធ្វើឲ្យត្រង់ ប្រើផ្ចង់ចិត្តជា កុំបីឆន្ទា មោហាគតិផង ៗ
រីធ្វើឲ្យគាប់ ឲ្យគង់សណ្តាប់ រៀនច្បាប់ក្រមផង ចំណោរលង់ទៅ
ឃ្មានបុណ្យពេកហោង ឲ្យអស់អ្នកផង រិះរករៀនគ្រាប់ ៗ អ្វីគួរឲ្យផ្ចង់
អ្វីគួរឲ្យផ្គង អ្វីគួរឲ្យផ្គាប់ អ្វីគួរឲ្យត្រង់ អ្វីគួរឲ្យគ្រាប់ អ្វីគួរឲ្យស្តាប់
អ្វីគួរឲ្យស្តាយ ៗ គួរផ្ចង់សីលា គួរផ្គងទានា គួរផ្គាប់ចិត្តទាយ គួរ
គ្រេកគ្រង់ច្បាប់ គួរគ្រាប់ប្រាជ្ញប្រាយ គួរស្តាប់បរិយាយ គួរស្តាយ
អាត្មា ៗ

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ខ្ញុំបាទសូមជំរាបជូនដំណឹងដល់អស់លោក-អ្នកមើលទស្សនាវដ្ដីនេះ ប្រសិនបើលោកអ្នកឯណាមួយបានបេះចាំពាក្យកាព្យជាសុភាសិតបុរាណនេះចប់ចុងចប់ដើមក្ដី ឬមួយបានប្រទះឃើញនៅក្នុងច្បាប់សាស្ត្រអ្វីក្ដី សូមមេត្តាកត់ត្រាចម្លង ឬជូនដំណឹងទៅពុទ្ធសាសនបណ្ឌិត្យក៏បាន ដើម្បីឲ្យលោកចាត់ចែងបោះពុម្ពច្បាប់សុភាសិតដ៏ពីរោះនេះ ចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយាជាប្រយោជន៍ដល់អ្នកមើលទាំងអស់គ្នា ។

នៅទីបំផុត ខ្ញុំបាទមានសង្ឃឹមថា ពាក្យដំបូន្មានបុរាណទាំងប៉ុន្មានបន្ទាត់ដែលបានពោលមកនេះ ល្មមជាគ្រឿងប្រដាប់សតិបញ្ញារបស់អស់លោក-អ្នកមើលបានខ្លះពុំខាន ទើបខ្ញុំបាទសរសេរសុភាសិតដែលខ្ញុំបាទចាំមាត់តាំងពីក្មេងមកនោះ យកមកជូនពុទ្ធសាសនបណ្ឌិត្យ ដើម្បីឲ្យលោកចុះផ្សាយក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ជាប្រយោជន៍ដល់សាធារណជនទាំងឡាយតទៅ ។

# បណ្ដាំ

## យុវឧត្តមប្រិយា ចាប-ពិន

### រួបរួមនិងរៀបរៀង

( តមក )

*បណ្ដាំ* — *ដោះស្រាយ*

៣៨- ដើមកាត់ទឹក ស្លឹកកាត់ខ្យល់ ផ្កាជនស្លុយធ្លល់
ដើមផុះឯណា ? . . . . . . . . . . . . . . . ចក

៣៩- ដើមប៉ុនដងជញ្ជីង ស្លឹកលើងផ្កាស ម្ដង:អើយដូនបង
ទៅរកផ្សិតដើមនោះក្រ ផុះតែដោយមាត់អ្នក ?. ទ្រង

៤០- ដើមកាហូរ ស្លឹកកាកញ្ចាញ់ចូវ ផ្លែកាមូលប៉ែន ?. ត្នោត

៤១- ដើមកាប៉ុនស្នូវទំព ក្រាប់កាប៉ុនក្រាប់ស្ព ? . . . ផ្ទូរ

៤២- ដើមកាក់ទ្វរ ផ្កាទីងផ្លែនៅឆ្ងាយពីគ្នា ? . . . . . ពោត

៤៣- ដើមកាប៉ុនខ្សែពាន ស្លឹកកាយោនយាន ផ្លែក
ញ៉ែកញ៉ប ? . . . . . . . . . . . . . . . . ម្រះ

៤៤- ដើមកាប៉ុនកន្ទាស ស្លឹកកាវេះវេះ ផ្លែកាវិញវុញ ?. ម្រះ

៤៥- ដើមកាប៉ុនទៀន ល្មៀនឡើងប៉ុនស្នូក ផើកផោក
កណ្ដុកលបង ? . . . . . . . . . . . . . . . ឈូក

៤៦- ដើមកាប៉ុនទៀន ល្មៀនឡើងប៉ុនចាស ? . . . . . ត្រលិត

បណ្ដៅ ដោះស្រាយ

៤៧ – ដើមកន្ទ្រៃ ផ្លែកន្ទាន់កន់ យកដៃទៅកាន់

កន្ទិតម៉ម ? . . . . . . . . . . . . . . . . . . ម្ទេស

៤៨ – ដើមជាអន្ទង មែកជាអន្ទើ ដីគោះដីគើ

ដីអឹអឹកអាំ ? . . . . . . . . . . . . . . . . . ខ្សៀ

៤៩ – ដើមកន្ទ្រៃ ផ្លែចែកស្រាម ? . . . . . . . . ប៉េងប៉ោះស្រាម

៥០ – ដើមក្រឡាក្រឡាញ់ ស្លឹកកញ្ឆាញ់ ផ្លែផ្សចក់? ទិក

៥១ – ដើមប៉ុនសរសៃអម្បោះ ស្លឹកមូលកំប៉ោះ ផ្កាស? ស្ពង់

៥២ – ដើមពិសី នៅទូពិសា ដល់ទុំកាលណា គេ

បោលបង្វៀត ? . . . . . . . . . . . . . . . . . ធនោង

៥៣ – ដើមជាគ្រឿនទេស ផ្លែពិសេសពិសោល្មប់ អ្នក

ផងស្រឡាញ់គ្រប់ ពុំដែលស្អប់ទេអ្នកអើយ ? . . ប៉ូតុំក្រស្នា

៥៤ – របស់មួយមកពីស្រុកយួន គ្រាប់គ្រួនមាត់ប្រហា ? . ពាង

៥៥ – របស់មួយតូចតល់ធំចុង រុញចូលទៅក្នុង ធ្វើ

ឲ្យគមមី ? . . . . . . . . . . . . . . . . . . . ជន្លួរត្រចៀក

៥៦ – របស់មួយមានស្លាបមិនចេះហើរ មានជើងមិនចេះដើរ

មានមាត់មិនចេះស្ដី ? . . . . . . . . . . . . . . . ផ្ទះ

| បណ្តៅ | ដោះស្រាយ |
| --- | --- |
| ៥៧ – របស់មួយមាននៅស្រុកខ្មែរ – យួន មានបន្លា ផ្លែក ស៊ីផ្អែម? . . . . . . . . . . . . . . . . . | ខ្នុរឬធូរេន |
| ៥៨ – របស់មួយមាននៅស្រុកខ្មែរ – យួន មានភ្នែកជុំខ្លួន ដើមដុះលើផ្លែ? . . . . . . . . . . . . . . . . . | ម្នាស់ |
| ៥៩ – របស់មួយនៅជិតបង្កើយ តែមើលឃើញឆ្ងាយ លន្លឹម? . . . . . . . . . . . . . . . . . | ចុងច្រមុះ |
| ៦០ – របស់មួយមានតែក ឥតក្បាល មានតែខ្លួន ឥតជើង? . . . . . . . . . . . . . . . . . | អាវ |
| ៦១ – របស់មួយមានតែបង្កេះ និងជើង ឥតខ្លួន ឥតក្បាល? . . . . . . . . . . . . . . . . . | ខោ |
| ៦២ – របស់មួយមកពីស្រុកសៀម អង្គុយសៀមៗ គេចាប់ដាក់ខ្នោះ? . . . . . . . . . . . . . . . . . | ជើងក្រានសៀម |
| ៦៣ – របស់មួយវែងមិនវែង ខ្លីមិនខ្លី ដាក់ជើងដល់ដី ធ្វើភ្ជួរស្រែ? . . . . . . . . . . . . . . . . . | គ្រឿងស្ទង់ |

៦៤ – របស់មួយមកពីស្រុកជន យកដៃទពងៗពុំដែល ញាស់ ច្រមុះនោះសិនស្របណាស់ ក៏តែងបន្លស់ ជីវិតសត្វជន មានគូរដូចជាផ្លែង គូរនោះសោត

បណ្តៅ　　　　　　　　　　ដោះស្រាយ

ហោង ឥតមានគង្គា ត្បូងថ្ងៃទិត្យនៅហត្ថា មាន

ទងលតា វល្លិ៍ត្នោដើមចុង ខ្ពង់នោះណា សឹងជ្រុង

កន្ទុយសោតត្រង់ ឥតមានក្បាច់ក្បូរ មានឃ្មុំទំនៅ

ក្បាលគ្បូរ ចំកុកគត់គ្បូរ ចង់ខាំបក្សី ហើចហោះ

ផ្ទុកផ្ទោះឥតបី ស្បូរសត្វអសនី បីដូចខ្ទះដើមឆ្នាំ ?.. ស្លា

៦៥ — មេព្រស កូនដេញ ? . . . . . . . . . . . . . . ស្លា ម្លូ

៦៦ — គល់ជាក្ងោកអ្នកជង, កណ្តាលជាគង, ចុងជាបក្សី? ដើមព្រមូងសោក

៦៧ — ណែលណោលកណ្តាលបាត　　ត្រែបនទាទ

កណ្តាលបង់ ស្ងួនប្រឡងដែលមិនមុត ? . . . ឡាក

៦៨ — អ្នកឡើងមិនបានបេះ, អ្នកប្រឡេះមិនបានស៊ី, អ្នក

នៅទទេស៊ីផ្អែក ? . . . . . . . . . . . . . ជើង ដៃ មាត់

៦៩ — មានភ្លើងមិនឆេះ មានផ្ទះមិនហុយ ស្អុយមិនធុំ

ហើរមិនទំ យំមិនឃើញរូប ? . . . . . . . . ｝ ផ្កាភ្លើង / ផ្កាផ្ទះ / ជើងអាចម៍កុក / ពពក ផ្គរ

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ៧០ — មួយលោទ មួយដេញ មួយស៊ើបស៊ៀញ មួយលាក់ | ដើមលោទ<br>ដើមរំដេញ<br>ដើមក្រូច<br>ស៊ើបឬមុគ្រើ<br>ដើមល្ហុ |
| ៧១ — បង់ចំឲ្យចាក់ បង់កក់ឲ្យដក បង់រែកឲ្យចាំង ? . . . | ស៊ីបាយ<br>ផ្ទីយបាយ<br>ដម្រុះស្មៅ |
| ៧២ — ឈើឆាប់មានដង្ហើម សត្វឥតឆ្អឹងនៅក្នុងទឹក ស្ងួន ហើយមានសត្វទ្រូក បណ្ដូលមានទឹក ដើមដុះលើគោក? . . . . . . . . . . . . . . . . . | ស្នប់<br>ឈ្នើង<br>បង្កង<br>អំពៅ |
| ៧៣ — ឈើមួយកំណាត់មានដង្ហើម សត្វឥតឆ្អឹងនៅកណ្ដាលទន្លេ ទំងើងគេទះទួងឯង ?. . . . . . . | ស្នប់ បង្កង<br>ទះមូស |
| ៧៤ — មានខ្សែមិនចង, មានដំបងមិនកាន់ មានបន្ទំមិនពិដោរ, មានត្រាវមិនស្ងោរ, មានវែកមិនដួស ? . . . . . . . . . . . . . . . | ពស់ខ្សែគោ,<br>ពស់ដំបងត្រញ៉ង,<br>ពស់បន្ទំមេ, ពស់ឆាងត្រាវ, ពស់វែក |

| បណ្ដៅ | ដោះស្រាយ |
| --- | --- |
| ៧៥- គេះឆ្អឹងជំនីរ, ស៊ីប្រហុស, អោបដើមពោះ, ដឹក សេះកាត់ត្រឡោក? . . . . . . . . . . . . | តាប៉ុ<br>ប៉ុគ<br>ស្គរ<br>ទ្រ |
| ៧៦-ដើមមួយទល់ដីស្នែងបែងក្បាល ពោះពរប៉ោលប៉ាល ដុះដោះខាងឆ្វេង មានផ្គាមួយ ពរតែងបាញ់ លេងបាញ់ត្រូវខ្លួនឯង ស្រែកយំរាល់ព្រឹក?.. | ទ្រ |
| ៧៧- កូនក្មេងតូចមួយ លីស្មាឡើងក្តំ ត្រដៀវរុំបយំ កែវអើយស្រងាត់? . . . . . . . . . . . . | ទ្រ |
| ៧៨- កូនស្ងួនពិសេស ខាមជាអ្នកទេស តម្រង់ហាន ឆ្ងាយ គេរឹតគេរួត គេដំគេវាយ ទាំងកូន ទាំង ម្ដាយ ហាក់ដូចមានទោស? . . . . . . | ស្គរដៃ |
| ៧៩- ត្រឡាចមិនត្រឡាច ល្ពៅមិនល្ពៅ លើកដាក់ លើភ្លៅ កន្ទ្រឹមពាក់ស្ពត្រ? . . . . . . . . | ស្គរដៃ |
| ៨០- ជើងរស្ទុក មាត់រស្អូញ អាហោរខ្ទូចលាញ ទាប់ហើយបណ្ដៅទៅ? . . . . . . . . | ដើមទាល់ |
| ៨១- ទឹកមួយថុក ផ្ទកផ្ទកវៃណល? . . . . . . . | ថ្លាងស្ពោរ<br>អន្សមផ្អិក |

| ចំណោទ | ដោះស្រាយ |
|---|---|
| ៨២- ផ្កាគោក, ដំបូកទឹក? . . . . . . . . . . . . . | ផ្គួង.ដោះស្រៃ |
| ៨៣- កាប់មួយចសដល់ថ្ន កាប់មួយចសដល់ដីស កាប់មួយចសដល់ទឹកសមុទ្រ? . . . . . . . . | ផ្គួង |
| ៨៤- ទឹកមួយថូក ខ្យល់បក់មិនគ្រើប? . . . . . . . . | ផ្គួង |
| ៨៥- ទឹកមួយថូក កុកកមិនឃើញ? . . . . . . . . | ផ្គួង |
| ៨៦- គិតគូកត្រពាំងដូនតា ទឹកមិនដែលថ្លា ស្មៅមិនដែលដុះ កុកមិនដែលចុះ ត្រីមិនដែលមាន? . . | ជ្រាំ |
| ៨៧- អង្គុយមួយសន្ទុះ អាចម៍មួយប្រក្លាយ? . . . . . | អាចម៍បន្ទោះ |
| ៨៨- ក្រោកកៀន? . . . . . . . . . . . . . . . . | អាចម៍បន្ទោះ |
| ៨៩- គុកគុលមមុលក្ដងដី សត្វជើងប្រាំបី នាំមុខគុកគុល?. | ខ្ដុល |
| ៩០- ស៊ីទីងចំពុះ ជុះទីងស្នាប? . . . . . . . . . . . . | ខ្ដុល |
| ៩១- ឈើកោងវែងឈើកាង ការក្យជាន់ផាង ត្រីខ្លាតខ្លាយ? . . . . . . . . . . . . . . | ត្បាល់កិនស្រូវ |
| ៩២- ជាន់កន្ទុយស្រែកដើក? . . . . . . . . . . . . | ត្បាល់ជាន់អង្ករ |
| ៩៣- អ្នកដេកពីក្រោមនៅស្រណុក អ្នកជាន់ពីលើអន្ទកៗ ស្ទើរបាក់ខ្នងចង្កេះ? . . . . . . . . . . . | ត្បាល់ជាន់អង្ករ |

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ៩៤- ឈើពុកក្រកឈើខ្ទឹម ឈើពារទទ្រឹមប៉ាំងចំពេត ? . . | ត្បាល់ជាន់អង្ករ |
| ៩៥- កាលអារស់ អាងាប់ស្រែកឆោង ? . . . . . . | រទេះគោ-ក្របី |
| ៩៦- កំប្រុកកំព្រំ អង្គុយលើក្ដួយផ្អែបៗ ? . . . . . . | ជាយពុះ |
| ៩៧- បើកបង្អួចបង្ហើរមាន់ស ? . . . . . . . . . . | ស្ដោះទឹកមាត់ |
| ៩៨- អង្គុយមាត់ជណ្ដើរបង្ហើរមាន់ស ? . . . . . . . . | ស្ដោះទឹកមាត់ |
| ៩៩- យប់ឡើងឈ្មោះតាអែ ព្រឹកឡើងរកកាវ៉ៃ គកធ្មឹង ដំនើរ ? . . . . . . . . . . . . . . . . . . | លោកសង្ឃ |
| ១០០ គេស្អប់ធាត់ គេអាណិតស្គម ? . . . . . . . . . | ការុង |
| ១០១- ឲ្យស៊ីឆ្អែតចងក ? . . . . . . . . . . . . . . | ការុង |
| ១០២- សអើយសសាញ់ សអត់ពីអញ ត្រពោកស្វិតជីវ ? | ការុង |
| ១០៣- ក្របីខ្មៅស៊ីតែចុងៗ គោសត្រឡុំស៊ីតែគល់ៗ ? . | កន្ត្រៃ,កាំបិតកោរ |
| ១០៤- ឈើគោងប្រហោងកណ្ដាល ស្ដេចមានការ ត្រូវការឈើគោង ? . . . . . . . . . . . . . | កាំភ្លើង |
| ១០៥- អាធំជេងត្រែង លេងទឹកមិនល្អក់ អាតូចបកម៉ក់ លេងទឹកល្អក់វរ ? . . . . . . . . . . . . . . | ឈ្នក់,អង្រុត |
| ១០៦- ឫស្សីមួយគុម្ព ជញ្ជាំងក្ដុនបឹន ? . . . . . . . | អង្រុត |
| ១០៧- ទៅពីកាយដូចគេចឹង ដាក់គូទកឹង ដូចគេទំ ? . . . . | ផុះ |

(មានត)

កាំពូលកាំសត់

លោកហាន់-យេង រៀបរៀង

(តទៅ)

បទទី ១៤

# កណ្ដាលព្រៃស្ងាត់

ព្រះអាទិត្យរៀបនឹងលិចទៅហើយ ខ្យល់រំភើយៗមកគួរឲ្យត្រ-ជាក់ចិត្តនាកណ្ដាលព្រៃស្ងាត់ មានសត្វស្វាលោតពីមែកមួយទៅមែកមួយ ចួនព្រើដៃ ចួនព្រើជើង ចួនព្រើកន្ទុយយោលទោងលេងតាមទំនើងចិត្ត ខ្លះបេះបោចផលាកកេស៊ីធ្វើក្រមេចក្រមើមគួរឲ្យចង់សើច ស៊ីអស់ហើយនៅសល់គ្រាប់ក៏ចោលទៅលើសុក្រិទ្ធ (ដែលកំពុងដេកលក់ឲ្យគ្នាក្លាក់ឡើង) មុខស្រមេងស្រម៉ងគន់មើលបងតានរ ដែលនាំគ្នាឈរឡែកមុខដើរឲ្យ មានកូនតូចៗ តោងពោះមេជាប់ សុក្រិទ្ធក៏នឹកទោបកូនចិត្ត ដោយខ្លួនកំព្រាម៉ែឪម្នាក់ឯង កណ្ដាលនឹកណ្ដោចកណ្ដាលព្រៃពុំដឹងទិសតំបន់ឯណា ធ្វើម្ដេចនឹងបានជួបមាតាអេះ សមជាអ្នកទន្ទឹងមើលផ្លូវកូនយ៉ាងណាទៅ តើដម្នាក់អ្នកជាឆ្ងល់ប្ដីស្រាល ឪបងតានរ! អ្នកនៅជួបជុំគ្នាគួរឲ្យសប្បាយចិត្តអីម៉្លេះ . . . "

«ជួយផង! ជួយផង! ព្ទសូរសំឡេងមនុស្សរំពងឡើងកណ្ដាលព្រៃស្នួសាន សុក្រិទ្ធក៏ងើបឡើងផ្ទៀងត្រចៀកស្ដាប់ តើសំឡេងមក

ពិចារណា ដល់សំឡេងដដែលលាន់សាជាថ្មីទៀត ក៏ស្ទុះរត់ទៅលុះ-ដល់មាត់ទន្លេ ទើបឃើញក្រមុំចាមម្នាក់ ត្រូវពស់ថ្លាន់រឹតជាប់នឹងដើមឈើ កំពុងតែរើបម្រះឲ្យឃ្លាតឆ្ងាយពីអាសិរពិស សុក្រិន្ទឃើញដូច្នោះ ក៏កាន់ដំបងមួយស្ទុះទៅ ចំណែកពស់ឃើញមនុស្សមកជិតក៏រេក្បាលចុះឡើងរកចឹកនារីបវរនោះ សុក្រិន្ទក៏វាយឲ្យត្រូវក្បាលពស់អស់ទំហឹងដៃ ពស់គេចទាន់ អ្នកក៏ភ្ញាក់ស្មៀតដួលប្រដាង សត្វសាហាវខ្លាំងណាស់ មានភ្នែកតាំងគ្នាដាលក្រហមរុងរោចន៍ដូចភ្លើងប្រល័យកល្បលាភ្ញន់លែងតែអាហារវ៉ា ស្ទុះមកប្រយុទ្ធនឹងប្រុសកំឡោះ យកកន្ទុយវណ្ឌជើងសុក្រិន្ទជាប់លើកខ្ពស់ពីដីចំនួនមួយម៉ែត្រ ប្រាថ្នានឹងបោកទៅលើប្រថពី ឲ្យខ្ទេចខ្ទីខ្ទាំងល្អិតទៅជាផេះ សុក្រិន្ទក៏ការទាជាប់ យារដំបងទាន់សំពងត្រូវក្បាលពស់យ៉ាងដំណំ ផ្ទប់ទៅនឹងដើមឈើ ពស់ក៏នឹងនឹងណាកន្ទុយក្បាកក្ដាក់តាំងពីនោក់ដល់ដី មនុស្សឥតប្រណីសំពងផ្ទួនថែមទៀត ត្រាតែដាច់ខ្យល់ដល់មរណភាពនាគ្រានោះឯង ។

ចំណែកនាងចាម មានសេចក្ដីត្រេកអរក្រៃក្រៀបផងពុំបាន រៀបហោសសំអាតខ្លួនប្រាណដៃជើងស្អាតបាត យកក្រមារុំមុខដូចដើមវិញ ទទួលយកកន្ត្រងពោរពាសទៅដោយផ្លែឈើដ៏មានឱជារស រួចឈរអើមអៀមមើលមុខសុក្រិន្ទ សុក្រិន្ទក៏សាកសួរដំណឹងថា “ ចុះអ្នកអញ្ជើញទៅណាមកណា បានជាមកត្រូវពស់វណ្ឌកណ្ដាលព្រៃដូច្នេះ ? ”

“ចាះ! ខ្ញុំមករកគេបេះផ្លែឈើយកទៅឲ្យបងប្អូនតាស្រ័យ ព្រោះនាំគ្នាធ្វើជំនួញដល់លក់ដូរអស់គិតវិលទៅស្រុកវិញ មកដល់ទីនេះជួនជាល្ងាច ទើបនាំគ្នាឈប់ស្នាក់ទទួលទានបាយ ហើយខ្ញុំត្រូវប្រើឲ្យមករកបេះផ្លែឈើ ក្រៅអំពីនោះមកដូច . . . ដូច . . . បងជ្រាបស្រាប់សព្វគ្រប់ហើយ ការដែលបងបានជួយសង្គ្រោះជីវិតខ្ញុំនោះ ជាព្រះគុណធ្ងន់ណាស់ ខ្ញុំនឹងមិនភ្លេចទេដល់អស់មួយជីវិតរបស់ខ្ញុំ បងអាណិតអញ្ជើញទៅជាមួយនឹងខ្ញុំ ទៅឯទូកឯណោះ នឹងបានអាពុកម្ដាយខ្ញុំសងគុណអ្នកបងឲ្យគាប់ចិត្ត” ។

ថាហើយនាងក៏នាំមុខដើរទៅ សុគ្រិនក៏ដើរតាមក្រោយ គន់មើលនាងបង់ប៉ាយល្អសល្មមនឹងទំនាំងខ្លួន មួយស្របក់ក៏បានដល់ទៅទូក នារីមានរូបចុះទៅទូកទុកសុគ្រិនឲ្យនៅរងលើច្រាំង មួយសន្ទុះមានតាចាមដូតកក្បាលក្រមាស ពុកមាត់ស្កូវមុខញញឹមចេញមកហៅកំឡោះនោះ “នែអ្នកកំឡោះ អញ្ជើញមកណេះនឹងបានប្រស្រ័យគ្នា ដល់សុគ្រិនអង្គុយសំប់ស្រួលបួលហើយ គាត់ក៏និយាយពាក្យអរគុណជាច្រើន រួចបានសួរអំពីដំណើរដើមទងកុមារវិញ កាលបើសុគ្រិននិយាយប្រវត្តិរូបរបស់ខ្លួនចប់បរិបូណ៌ហើយ អ្នកស្ដាប់ទាំងប៉ុន្មានក៏ស្រក់ទឹកភ្នែកទឹកអាណិតគ្រប់គ្នា នៅស្ងៀមស្ងាត់អស់មួយស្របក់ធំ តាចាមនិយាយឡើងថា “ណ្ហើយកូន! អ្នកកុំកើតទុក្ខអី មកៈនៅនឹងយើងមក

យើងនឹងចិញ្ចឹមអ្នក ព្រោះឪពុកក៏គ្មានកូនប្រុសដែរ ឪពុកសូមឯងជាកូន តើឯងសុខចិត្តទេ ?

" បាទ ! ខ្ញុំបាទមានកិច្ចទៅរកមាតាផង នឹងនៅជាមួយលោកតា ដូចម្ដេចបាន " ។

" មិនអីទេ ចាំតាជូនឯងទៅរក កុំបារម្ភអ្វី ឲ្យតែសុខចិត្តព្រមធ្វើកូនតាចុះ" ។

សុភ័ទ្រនឹកអស់តែកន្លែកចិត្ត មិនដឹងជានឹងឆ្លើយបែបណា បោល ភ្នែកមើលទៅឃើញនារីចាស់ កំពុងមូរក្រមានឹងម្រាមដៃ មានទឹកមុខ មិនស្រស់បស់ មានភ្នែកចាំងគួរឲ្យអ្នកឲ្យនៅ ទើបសុភ័ទ្រព្រម ព្រៀងនៅជាមួយនឹងត្រកូលតានោះ ។

លុះបរិភោគអាហារល្ងាចរួចហើយ សុភ័ទ្រក៏ឡើងទៅលើប៉ាំង ដើរលេងក្រោមពន្លឺព្រះចន្ទ្រ ដើម្បីនឹងរំភើយខ្លួន មុននឹងចូលដំណេក ដល់កន្លែងមួយមានគល់ឈើស្អាត ក៏អង្គុយលេងនៅទីនោះ ងើយមុខ មៀងមើលតារាករ ដែលរីកពាយភ្លឺលន្លំមឯនភាល័យ ទើបនឹកសម័យ ដល់មាតារបស់ខ្លួន បង្កើតជារូបនិម្មិតច្បាស់នឹងមំសចក្ខុ ឃើញរូបអ្នក ស្គមរីងរៃកំរើកដៃជើងគ្រូវ ញញឹមព្រៀមស្រស់មករក ហើយមានវា- ចាថា " ឱកូនកែវម្ដាយអើយ ! ម្ដាយនឹងជាប់ខ្យល់ស្លាប់ក្នុងវេលានេះ មិនខានទេ ម្ដេចឡើយមាសមេនាងមិនមករកម្ដាយ ឲ្យម្ដាយចាំជួបផង

ឱកូនអើយ ! បើប្រសិនណាជាបានកូនមកជិត មុខជាម្តាយនឹងជាវិញជាពុំខាន បើទុកជាស្លាប់សោតក៏បិទភ្នែកជិតដែរ មករកម្តាយណា ណាកូនណា ” ។

សុភទ្រក៏ហុចដៃទាំងពីរទៅ រូបនិម្មិតក៏ចាក់សូន្យមួយរំពេចនាំឲ្យកុមារគេចគេមើលពុំឃើញ ទឹកចុកណែនទ្រូងកាន់តែតឹងស្ទើរនឹងក្ខាយ ទឹកភ្នែកហូរខ្វាយមកពេញមុខ រួចក៏ដួលផ្ងប់ទៅលើព្រះធរណីដីនឹងខ្លួន ថាហាក់ដូចជាគេលើកទៅឆ្ងាយទៅ រួចក៏ផ្អែកទៅនឹងដើមឈើយកគុម្ពមកពីទួតទួនខ្លួនជុំវិញ ដល់បើកភ្នែកឡើងកំរើកដៃ ស្រាប់តែឈឺឆ្អៀបអស់សរសៃផ្សាពេញខ្លួន សំឡឹងមើលឲ្យជាក់ ក៏ឃើញចំណងយ៉ាងមាំទឹកធ្លាក់ណាស់ បែរមើលទូទាំងបរិវេណ ក៏ឃើញមនុស្សជាច្រើនអង្គុយនិយាយគ្នា សុទ្ធតែមានអាវុធគ្រប់ដៃ ទើបកុមារក្រោកសួរគេថា “លោកពូអើយ ! ហេតុដូចម្តេចបានជាខ្លួនខ្ញុំត្រូវគេចងដូច្នេះ ? លោកពូជួយស្រោចស្រង់ខ្ញុំបានផង ” ។

ឈប់ប៉ុណ្ណឹងហើយ កុំនិយាយអ្វីតទៅទៀត តែខំមុខជាមានគ្រោះដល់ខ្លួនមិនខាន ។

រួចពួកអស់នោះនិយាយគ្នាតទៅទៀត អ្នកមួយនិយាយឡើងថា “តាមខ្ញុំ កុំឲ្យពួកវាមកតាមអីនាំឲ្យពិបាកកយុទ្ធទេ យើងនាំគ្នាពួនឲ្យរាទៅផុតទៅ ទើបអាលវិលត្រឡប់ទៅប្លន់ឆក់យកសម្បត្តិតែម្តង ” ។

អ្នកមួយឆ្លើយថា "ទេ ! យើងត្រូវទៅជូនកូម៉ិងឯលិចឯណោះ ហើយលែងគ្នាទៅ កុំធ្វើបាបវាអី ព្រោះទុះ ជាសម្លាប់វាទៅក៏ពុំបាន ជាអ្វី" ។

អ្នកមួយទៀតបែកគំនិតថ្មីថា "បើដូច្នោះ យើងទុកម្នាក់ឲ្យយកសំបុត្រទៅកំហែងទារប្រាក់ចំនួន ២០០រ,០០ សឹមបើកលែងក្មេងនេះឲ្យ ហើយពួកយើងនាំគ្នាទៅជូនកូម៉ិងលិច" ។

គិតព្រមព្រៀងដូច្នោះហើយ ក៏នាំគ្នាទៅបាត់អស់ទៅ នៅសល់តែម្នាក់កាន់សំបុត្រយកទៅបង្កប់ក្នុងទូក រួចវិលមកវិញយាមល្បាកមនុស្សពោស ។

ដល់ពួកចោរនោះឡើងមើលសំបុត្រហើយមិនដឹងជាថាអ្វី ព្រោះអ្នកអស់នោះមិនចេះអក្សរខ្មែរ ទើបសួរគ្នាទៅវិញទៅមក ចួននៅនោះមានខេមរជាតិម្នាក់ ជួយមើលសំបុត្រឲ្យស្តាប់ លុះដឹងរឿងហេតុហើយ ក៏តក់ស្លុតរៀងខ្លួន គិតនាំគ្នាតាមទៅ តែមកគិតគ្នាថាចាំព្រឹកចាំយើងនាំគ្នាទៅដណ្តើមយក រួចក៏នាំគ្នាចូលដេកទៅ ទុកម្នាក់ឲ្យនៅមើលគយឃ្លាំ ។

ចំណែកនារីតាមឮដូច្នោះ នាងក៏ព្រួយចិត្តឡើងមកលើគោកដើរតាមស្នាមជើងមនុស្ស ស្វែងរកអ្នកមានឧបការគុណលើរូបនាងប្តេជ្ញាក្នុងចិត្តថា កាលបើខ្លួនអញរកអ្នកនោះមិនឃើញដរាបណាអញក៏មិន

វិលមកវិញ ដកបនោះ ទំរើមួយសន្ទុះទៅក៏បានឮសូរសំឡេងក្រុំក្រួល មកប៉ះដល់ត្រចៀកនាង នាងក៏ភ្ញាក់ព្រើត ងើបតិចៗ សន្សឹមៗ ចូលទៅ ឃើញចោរដេកលក់ស្រមុកខ្ញុរៗ ឆ្ងាយពីនោះបន្តិចឃើញសុក្រ ទ្រូកំពុង ម្លូបខ្ទុម ទើបនាងនឹកករុណាតោបចិត្តក៏ស្ទុះចូលទៅស្រាយចំណង នៅសល់តែមួយក្រុងទៀតគង់ផុតស្រឡះ ស្រាប់តែឃើញមនុស្សទុច្ចរិត ភ្ញាក់ឡើងភ្លាម នាងក៏ធ្វើជាដើរចេញមករក ប្រិចកមុះញញឹមញញែម ចោរក៏និយាយដោយពាក្យទន់ថា “ ឱនាងទេព្ធអើ! ខ្ញុំស្មានថាជាអ្នកណា នាងទៅណាមកណាកើត ចាំខ្លួនខ្ញុំបានទេ ?

“ចាះ! ខ្ញុំស្គាល់អ្នកបងច្បាស់ ខ្លួនខ្ញុំនេះអស់ស្រុកដើររកហើយ ខ្លួនឃើញ អ្នកបងបានជាដើរចូលមកជិត តែឃើញដេកលក់ពុំហ៊ានហៅ ” ។

នាយចោរនោះ ធ្លាប់ជាប់ចិត្តស្នេហានឹងនាងនោះ ក៏និយាយ បញ្ចុះបញ្ចូលទៅមកជាច្រើន នៅពេលនោះ ស្រាប់តែឮសូរជើងដើរពី ក្រោយខ្នង នាងធ្វើជាភ័យ ហើយខ្សឹបនិយាយចោរនោះថា “ អ្នកបងអើយ ឪពុកខ្ញុំមកតាមខ្ញុំហើយ តែគាត់ឃើញខ្ញុំអង្គុយលេងជាមួយនឹងអ្នកបង មុខជាគាត់កាប់ខ្លួនខ្ញុំជាមិនខាន អ្នកបងករុណាពួនទៅសិនទៅ ។ នាងក៏ក្រឡេកឃើញពួកគេនៅទៀបនោះ ក៏បង្ខំឲ្យនាយចោរស្ទុះចូល ក្នុងពួកគេនោះ លុះដោយៈសេចក្តីស្រឡាញ់ត្រេកសន្តក់ ចោរនោះក៏ព្រម

ចូល ផុតដើរហើយនាងក៏រកខ្សែបង់មាត់យ៉ាងខ្ជាប់ រួចគេចចេញមក នាំសុគន្ធីត្រឡប់ទៅទូកវិញ ។

កំឡោះទីងក្រមុំទាំងពីរនាក់នោះ នាំគ្នាត្រសងមកវិញយ៉ាងលឿន មានចិត្តរីករាយសប្បាយចិត្ត ដើរមើលមគ្គុទ្ទេសក្សហើយដកដង្ហើមយ៉ាងវែងដោយសេចក្តីរំដោះទុក្ខ នារីបាមបើកមុខឡើងឲ្យច្បាស់ គន់មើលឃើញត្រចះត្រចង់មូលក្រឡង់ដូចគេគូរ ភ្នែកទាំងពីរព្រាយពន្លឺបីដូចផ្កាយលើមេឃ មណ្ឌលមុខពេញចរផូរផង់ប្រមុះស្រួចត្រង់សណ្ឋានប្រមុះបាក់ង នាងមានរូបឆោមលោមព័ណ៌គួរឲ្យត្រេកត្រអាលឲ្យក័ន្តកាំងស្មារតី វិស័យដូចទង់កាមទេពប្រាកដ ដំណើរនាងទ្រង់ស្រគត់ស្រគំ រៀបរយល្អណាស់ បង់ហោយសានយាសសមសួនទឹកដីកៅតួបទ្រនាប់ សុគន្ធីគន់មើលសព្វហើយក៏បានដល់ទូក ។

ពួកបាមផ្អើលឡើងសាកសួរដំណើរ រួចគិតជំនុំគ្នាទីងថ្លៃម្តេចឲ្យផុតពីហេតុក្តាយនោះ ទើបព្រមព្រៀងគ្នាថាទីងចេញទៅទាំងយប់ទើបបាន ដាច់ស្រេចហើយក៏ទាញយុថ្កាស្រាវព្រួរចេញទូកចាកទីនោះទៅ ទំប្រញាប់ដៃចែវមិនហ៊ានឈប់បង្អង់ ទំផង់ស្មារតីមិនឲ្យង៉ុយងោកងក់ លុះទៀបភ្លឺពួមានទំរាំសាទិនតាមខ្យល់មកក៏បានដល់ភូមិគេ ជួបចិត្តនាំគ្នាសម្រាកខ្លួននៅទីនោះ នារីបាមក៏លើកបបរត្រីងៀតយកមកលៀងអ្នកហាត់នឿយ ។

# បទទី ១៥

# ម៉ាសអើយនាងម៉ាស

ព្រះសុរិយទេវបុត្រស្ដេចចេញចាកនិទ្រា ទ្រង់ឡើងប្រថាប់លើព្រះរាជរថ គោចរតាមវិថីសក្កាកាសត្រា បើកទ្វានទ្វារប្រាសាទ ស្ដេចចេញមកញញឹមព្រាយ មានព្រះភក្ត្រគគាយ ស្រស់បស់មានអត្យាស្រីយ៉ាងទន់ភ្លន់ ពេលនេះត្រាយ៉ាងស្រទន់មកលើភូមិប្រាំងចំពោះចំភ្ញីរព្រះយ័ញសំណាញ់លាតណាផែដាំងនៅមុខផ្ទះ ជាឧបករណ៍សំ-គាល់នៃភូមិអ្នករកស៊ីនេសាទត្រី មានពន្លឺថ្ងៃចាំងចូលទៅក្នុងបង្អួចនៃផ្ទះក្ដារដម្បូលក្បឿងមួយ ញាំងបន្ទប់គេងនោះឲ្យភ្លឺឡើង ។

ក្នុងបន្ទប់នោះ នាងម៉ាសកូនតាឡាយម៉ាណ កំពុងឆ្លុះកញ្ចក់គន់មើលរូបរាងរបស់នាង នាងបានរើក្រមាពណ៌គ្រប់បែបពីទូចេញមកហើយយកមកទប់ម្ដងមួយលមើលតើពណ៌បែបណាសមនឹងរូបនាង រើសចុះរើសឡើងក៏នៅតែទាស់ចិត្ត ព្រោះដ្បិតផ្កាមិនស្លូវ ស្រស់ប្ដូផ្កាមិនសូវល្អ ធ្វើរបៀបជាច្រើនលើកច្រើនសារ ប្ដូរទាញមកលើស្មា ប្ដូរឲ្យខ្លីឡើង ប្ដូរឲ្យវែងចុះ ពុំនោះសោតខ្ទាស់ពីសក់ចេញក្រៅសំពត់ គឺខ្ទាត់ចុះពត់ឡើងដោយយកចិត្តទុកដាក់មិនមែនត្រឹមមួយឬពីរនាទីប៉ុណ្ណោះទេ ដែលនាងតាក់តែងកាយ គឺនាងនេះក្រោកឡើងតាំងពីព្រលឹមឯណោះ ឈរនៅសំឡឹងកញ្ចក់ផ្ទុះមុខយូរៗ ញញឹមកែរូបរបស់នាងម្ដងៗ ធ្វើឲ្យកផ្ទៀងផ្ទួនផ្អូបនាងកិន្នរី គួរឲ្យមានចិត្តមេត្រីនឹងរូបនោះមកពន់ពេកក្រៃលែង ។

តែដោយហេតុអ្វីហ្នឹង! បានជានាងយកចិត្តទុកដាក់ទីងសំអាងខ្លួនខុសពីថ្ងៃមុនៗ ? ជាបញ្ហាដែលនាងបានសាកសួរដល់ខ្លួននាងរាប់រយដងមកហើយ តែនាងរកសេចក្ដីដោះសាពុំឃើញ ពុំដឹងជាដោយអានុភាពកំបាំងអ្វីនាំឲ្យនាងអណ្ដែតអណ្ដូងរាយមាយដូច្នេះ ហេតុការណ៍ដែលមានមកដល់ជីវិតរបស់នាងថ្មីៗ នោះ គឺសុភិន្ទបានចូលមកជ្រែកក្នុងត្រកូលរបស់នាងនោះឯង ហើយមានឋានៈជាបងចិញ្ចឹមរបស់នាងផង ក្នុងចំនួន ២ ខែទៀតនឹងឡើងជាបងរបស់នាងបង្កើតតាមច្បាប់ កាលបើកុមារនេះ ចូលជាតិតាមចុះឈ្មោះជាបុត្រឡាយម៉ាណៃពេលណា ៗ តែអ្នកស្រុកគេហៅថាខត ៗ គ្រប់គ្នា កាលបើនាងម៉ាសរំពឹងគិតដល់រឿងនេះ ក៏ទឹកសើចតែម្នាក់ឯងដែលនឹងគេញាក់ ចេញទៅឈរនៅមាត់បង្អួចរំពៃមើលធម្មជាតិនានា នាពេលនោះធម្មជាតិព្រឹក្សលតាវល្លិ៍ក៏ថ្លែកដល់ភ្នែករបស់នាង ហាក់ដូចជាមានវិញ្ញាណចេះនិយាយសាសងមករក ចេះផ្សំហេតុឲ្យសមតាមរឿងតាមទឹកចិត្តរបស់នាង បក្សាបក្សីព្រៀងត្រលប់មកបោះត្រចៀកនាងហើយ សម្រស់រ៉ើង ៗ មកទៀត ធ្វើឲ្យនាងក្រួចក្រញាប់ញ័រដល់ខ្សែរវ៉ា ដែលកន្ត្រាញរងើងក្នុងខ្លួនរបស់នាងហាក់ដូចជាមានខ្សែអសុទ្ធអ៊ីមួយ រួបចិត្តរបស់នាងទៅទីធម្មជាតិ ៗ ដើមអំពិលផែកសាខាមានផ្លែរយោងរយាងដើមម្រះក្បៀរខៀវស្រងាត់ស្រួចត្រដឹមទៅលើ សំណាញ់ទៅដែលចំរេក

លើបន្ទប់ឬស្សី ស្ពានឈើដុះស្លែចុះទៅកងទឹក តាំងនេះជាទីលើករបស់នាងដល់ទៅអនាគតជាប្រារម្មណ៍មិនខ្ចេះព្រមដល់សតិរបស់នាង គឺគឿនសមាគមរបស់នាងរៀងទៅ ជាសការទិត្យនៅតែមួយកន្លងមិនទិកសះទៅទីណា ដែលញ៉ាំងទឹកក្នុងឲ្យហូរប្រោកមកបាន ឬមួយធ្វើបបូរមាត់ឲ្យញញឹមផ្អែមល្ហែមតាមពេលតាមកាលដែលចិត្តនឹងត្រេកអរសោទរ ឬស្រពោនស្រពន់សោះសូន្យ ។

"ម៉ាសអើយ ! សំឡេងយាយណ្ណារស្រែកហៅពីផ្ទះធំមក ។

នាងម៉ាសក៏ភ្ញាក់ព្រើតចេញចាកការសម័យ ស្ទុះចេញទៅជាយ៉ាងប្រញាប់ប្រញាល់ ដើម្បីនឹងទទួលពាក្យបង្គាប់របស់មាតា ។

"ម៉ាក់ ! ត្រូវការប្រើកូនឲ្យធ្វើអ្វី?

"ឯងយកទឹកតែទៅជូនឪពុកឯង នឹងបងឯងផង" ។

នាងទទួលពាក្យហើយ យកដៃទទួលប៉ាន់តែយ៉ាងយាសដើរដំរង់ទៅកន្លែងធ្វើការ លុះដល់កាលណានាងក៏ទុនចុះយកពែងមកសិតទឹកតែដាក់លើថាសរួចទើបនាងលើកយកទៅជូនឪពុករបស់នាង តពីនោះមក បានទៀងយកទៅហុចឲ្យសុកិទ្ធបុះទៅខត កាលបើនាងមើលមុខគេចំហើយ មុខនាងក៏ឡើងក្រហមព្រឿងៗ ដៃរបស់នាងក៏ញ័របន្តិចធ្វើឲ្យខ្ទាតទឹកក្ដៅទៅលើដៃកុមារ ដែលទទួលពែងពីដៃនាង ហើយនិយាយដោយស្មោះថា "អរគុណហើយអូន បានអូនសិតទឹកតែឲ្យមុខជានឹង

មានកំឡាំងពីសមិនខាន អូនបងថ្ងៃនេះល្អចំណាប់ណាស់ សមខ្លួនស្រស់ ផាត់ក្រមាទៅខាងក្រោយផង បងនឹកស្មានថាជានាងទេពអប្សរចុះមក លេងផែនដីទេតើ បងមិនបញ្ញាអូនទេ កុំឲ្យអៀនអន់ចិត្តអី ព្រោះថ្ងៃនេះ អូនប្លែកជាងសព្វកាលច្រើនណាស់" ។

នាងម៉ាសក៏ញញឹមយ៉ាងស្រស់ ទទួលពាក្យសរសើរដល់លំអ របស់នាង ពេញចិត្តនឹងសំដីដ៏ពីរោះពាក្យនោះពន់ប្រមាណ ទឹកអរ ព្រួចគួរពោះស្រាលអស់ខ្លួនប្រាណអណ្តែតអណ្តូងជាសុខ មានទឹកមុខ រីករាយសប្បាយឥតគណនា កើតបីតិព្រោងព្រោយថ្លាស្រឡះបញ្ចាស់ ដល់ចិត្តរបស់នាង ទឹកចង់អង្គុយនៅទីនោះឲ្យយូរបន្តិចទៅទៀត ដើម្បី នឹងគន់មើលឧតដួសសំណាញ់ឆ្ងាយ តែជាយថាភាពនោះកាលស្រឡះពេក នឹងត្រូវអ្នកផងគេឡើកមើលត្រប់គ្នា ទើបនាងម្ចាវិលចូលទៅក្នុងផ្ទះ វិញ ដើរទៅហាក់ដូចជាមានអ្វីសក្តិសិទ្ធិទ្រទ្រង់ ស្រាលដូចសំឡី ឈានដើរដើរស្ទើរមិនជាប់ទឹងផែនដី ព្រោះតែប្រឹមប្រិយរបស់ស្និទ្ធ ស្នាលនៅជិតភ្នែក មុននឹងឡើងទៅលើ នាងក៏ពោលភ្នែកក្រឡេកមើល ទៅទៅឧត ក្នុងពេលនោះហាក់ដូចជាត្រឡាក់ដោយឫទ្ធិមេផែក ក្រឡេត មករក ក៏ប្រទះភ្នែកនឹងភ្នែក នាំឲ្យនាងមានសេចក្តីត្រេកអរជាច្រើន ។

យប់នោះ នាងអង្គុយលើងជិតបង្អួចមៀងមើលមេឃ នៅកណ្តាល ពពួកផ្កាយជាបរិវារ ព្រះចន្ទ្រាមូលក្រឡង់ស្រស់បំព្រងផ្សព្វផ្សាយពន្លឺ

ពាសពេញ  ញុំាងផ្កាំងព្រឹក្សាឲ្យស្រស់ញញឹមព្រោងព្រាយ  នាំឲ្យ
មនុស្សរីករាយសោយទុក្ខពីថ្ងៃ  ឯសត្វវែយ៉ៃវែ ៗ ផកអាក់ក្រោមស្លឹក
ឈើ សត្វប្រផៀវរពោះច្រៀលថ្វាត់ឯរបោស់  ខ្យល់រំភើយ ៗមកត្រូវ
នាង  ធ្វើឲ្យនាងព្រឺព្រួចទូទាំងសព៌ាង្គកាយ  មានចិត្តសប្បាយទៅគន់
មើលនក្ខត្តឫក្សតទៅទៀតតែឯកឯង  ដល់យប់ជ្រៅបានដាច់ចិត្តក្រោក
ពាក់ទឹកនោះចូលកាន់ដំណេក  តែនាងមិនបានធ្មេចភ្នែកតែម្តងទេ  នៅ
សញ្ជឹងហេតុការណ៍ផ្សេង ៗ  ចុងបំផុតក៏លើកដៃធ្វើសញ្ញាលាយ៉ាង
ទន់ភ្លន់ញញឹមព្រាយហើយបានបិទភ្នែកជាសុខទៅ  តើនាងលាអ្នកណា
ហ្ន៎មុននឹងនិទ្រា? ប្រហែលជាលាព្រះចន្ទហើយមើលទៅ ។

ចំណែកខាងនាយឧត  ក៏អង្គុយគន់ធម្មជាតិស្រស់ប្រពៃដែរ  គន់
មើលខែមើលផ្កាយលើមេឃ  តាមមើលដំណើរពពកដែលសាត់មកពី
ទិសទក្សិណសន្សឹម ៗ  មកបន្តិចម្តង ៗ  ពាល់តែដល់ព្រះចន្ទហើយ
បាំងមិនឲ្យពណ្ណរាយ  ភូមិបានងងឹតចុះក្រា នាយឧតក៏ស្រងូតស្រងាត់
សៅហ្មង  កុមារហាក់ដូចជាសោបសូន្យក្នុងចិត្តស្រងេះស្រងោចកណ្តោង
ក្រណ្តោចពន់ពេកណាស់  ដល់ព្រះចន្ទភ្លឺច្បាស់ឡើងវិញ  ក៏បានឮសូរ
តាមខ្យល់បក់មក  កាត់សេចក្តីស្ងាត់នៃរត្តិកាល  ជាសំឡេងមាតា
បំពេបុត្រយ៉ាងលន្ទង់លន្ទោចគួរចង់យំ  នាយឧតកើតទុក្ខប៉ុនភ្នំដកដង្ហើម
ធំជាច្រើនដង  នឹកដល់មាតារបស់ខ្លួនដែលមានជម្ងឺឈឺជាទម្ងន់ សមភ្នែក

*អ្នកខន់ផង ទឹកភ្នែកស្រក់ចុះមកជោកថ្ពាល់ទាំងគូខ្សឹកខ្សួលជាច្រើន ហើយមើលពពកសដូចស្បៃដណ្ដប់មេឃ សាត់វិលទៅទិសទក្សិណវិញ អ្នកក៏ស្រែកផ្ដែផ្ដាំថា :*

"ឱពពកអើយ ! អ្នកអាណិតឈប់បង្អង់មួយស្របក់សិន ចាំស្ដាប់ពាក្យបណ្ដាំរបស់ខ្ញុំ អ្នកតែងសាត់វិលវល់ឯអាកាស គង់ស្គាល់ទីលំនៅនៃមាតារបស់មាតាខ្ញុំជាមិនខាន បើអ្នកទៅដល់ទីក្រុងភ្នំពេញហើយ អ្នកមេត្តារកមាតាឲ្យខ្ញុំផង ហើយជំរាបថា ខ្ញនខ្ញុំនេះមានសេចក្ដីនឹករលឹកមកដល់អ្នករាល់ទិវារាត្រី មានចិត្តស្រពោនស្រពន់ស្ញប់ស្ញាត់ពុំរករាយ តែហេតុដែលឃើញយូរពុំបានទៅជួបនោះ ព្រោះជាប់នៅតបស្នងសងគុណត្រកូលឡាយម៉ាននេះ ដែលបានជួយជីវិតរបស់ខ្ញុំ នឹងបានជួយឧបត្ថម្ភឲ្យបានសុខមានជីវិតរស់នៅតាមធម្មតា តែថាក្នុងមិនយូរប៉ុន្មានទេ ខ្ញគុខ្ញុំនឹងទៅជួបមុខអ្នកមាតាជាមិនខាន ពាក្យបណ្ដាំរបស់ខ្ញុំអស់ប៉ុណ្ណេះហើយ ពពកអើយ ! អ្នកកុំភ្លេចឲ្យសោះណាពពកណា !!! (៣៩៣)

## ច្បាប់ក្រមបរិយាយ

## លោកញឹក-នូ គ្រូបង្រៀនជំនួយ

នៅវិទ្យាល័យស៊ីសុវត្ថិ រៀបរៀង

(តមកនិងចប់)

គ្រូបាធ្យាយ បានជាលោកប្រៀបដូចមាតាបិតានោះ ព្រោះលោកមានសេចក្ដីសន្ដោសប្រណីសិស្សានុសិស្ស ដោយប្រការផ្សេងៗ ជាច្រើនមហិមា ពិតមែនកាលដើមមាតាបិតា បង្កើតរូបកាយមក ហើយបីបាច់បំញុំបុត្រនោះមក លុះត្រាតែចំរើនវ័យវឌ្ឍនាធំឡើង ល្មមនឹងរៀនសូត្រចំណេះវិជ្ជា ក៏នាំយកទៅឲ្យនៅវត្ត ប្រគេនលោកគ្រូអង្គណាមួយ ដែលលោកចេះដឹងជ្រៅជ្រះ ទូរអត្ថធម៌អក្សរក្បួនច្បាប់ សុំឲ្យលោកបង្ហាត់បង្រៀនកូនឲ្យ លោកនោះក៏ទទួលភារៈយកព្រះទ័យទុកដាក់ "ហ្វឹកហ្វឺនប្រដៅ" ឲ្យចេះដឹង តាំងពីអក្សរសាស្ត្រ សាស្ត្រាបាលីព្រមទាំងពាក្យសំដី និងកិរិយា សណ្ដាប់ធ្នាប់ឲ្យត្រឹមត្រូវ ឲ្យស្គាល់ខ្ពស់ទាបសុភាពរៀបរយ "តាមដោយគន្លងព្រេងព្រឹទ្ធបុរាណ" គឺច្បាប់ទម្លាប់ទំនឹមទំនៀម តាមបុរាណតៗ មក, លោកនេះហើយ បានឈ្មោះសន្មតហៅថាគ្រូបាធ្យាយ គឺញ៉ាំងយើងឲ្យចេះដឹងសិល្បវិជ្ជា តាំងពីតូចបានជាលោកប្រៀបទុកដូចជាមាតាបិតា ។

តែក្នុងបច្ចុប្បន្នសម័យនេះ ពួកអ្នករៀនខ្លះក៏បានទៅនៅវត្តពីក្មេងក៏មាន ខ្លះអាពុកម្ដាយនាំយកទៅឲ្យរៀននៅសាលាភាសាបារាំងសែស

តែម្តងក៏មាន តែទោះដូចម្តេចក៏គង់មានគ្រូបាធ្យាយបង្ហាត់បង្រៀន ប្រដៅច្បាប់ទម្លាប់ ចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗ ដែលជាសេចក្តីល្អសុចរិត, ហេតុដូច្នេះគួរសិស្សានុសិស្សគ្រប់រូប គប្បីគោរពកោតខ្លាចប្រណិប័តន៍គ្រូបាធ្យាយ តាមដំបូន្មាននៃច្បាប់ក្រមនេះកុំឲ្យឃ្លាត, ដូចមានន័យលោកពោលទុកតទៅនេះ ។

ចរអ្នកណា ចិត្តស្មោះត្រាជ្ញា ជាស្មើត្រាណា ឲ្យគិត
ដញ្ញឹង រំពឹងលែងចាង កុំធ្វើចំពាង ប្រទូស្តរឹងស្អង ។

ឃ្លានេះលោកពន្យល់ថា បើនរណាចិត្តស្មោះរកចំណេះវិជ្ជាជាពន្ធុ ធ្លុះឲ្យយល់ការធំ គុណដំណែងរបស់ខ្លួនឲ្យបានខ្ពង់ខ្ពស់ប្រសើរនោះ លោកពោលថា "ឲ្យគិតដញ្ញឹង" បានសេចក្តីថា បើខ្លួនធ្វើកិច្ចការអ្វី ត្រូវឲ្យគិតឲ្យហ្មត់ចត់ឲ្យល្អិតល្អតាមលំដាប់ច្បាប់ ដែលគ្រូប្រដៅទុកមក ត្រូវតែធ្វើកិច្ចការទាំងឡាយដោយពិនិត្យពិច័យ កុំបំពាបំពានល្មើសលើដំបូន្មានគ្រូ ទើបការនោះនឹងបានល្អ, ហើយលោកហាមថាកុំឲ្យ "ប្រទូស្តរឹងស្អូន" គឺកុំតាប់ហេតុកេរៀនគ្រូវិញ នោះបើគ្រូស្តីប្រដៅយើងជាសិស្ស មិនត្រូវជាគ្រូស្តីបន្ទោសដោយសំអប់ទេ ត្រូវឲ្យគិតដល់បុពណរកាសិតមួយមាត់ទៀតថា "ពាក្យពិតវៃធរស្អុន" ពាក្យនេះត្រូវយល់ថា ប្រៀបដូចជាអ្នកឯណាមួយប្រព្រឹត្តអំពើទុច្ចរិតមិនគប្បីនឹងគន្ធងធមិតខ្លួនច្បាប់ ហើយមានអ្នកឯណាជាមិត្តក្តីដោយស្មោះត្រង់

គេមកស្ដីរំឭកដាស់តឿនដោយសេចក្ដីត្រឹមត្រូវ នោះអ្នកដែលជាមនុស្សអន្ធពាល ត្រឡប់ជាក្ដៅក្រហាយនឹងពាក្យដែលគេស្ដីរំឭកឲ្យល្អនោះវិញ ឬដូចជាមាតាបិតានិងគ្រូបាធ្យាយ ឃើញកូន-ឃើញសិស្សធ្វើខុសមិនគប្បី លោកក៏ដេរស្ដីប្រដៅចង់ឲ្យល្អ ឯកូននឹងសិស្សនោះត្រឡប់ជាក្ដៅក្រហាយទៅវិញ ត្រង់ណោះហើយគឺ "ពាក្យពិតតែងល្វីង" ។

ហេតុនេះគួរយើងដែលជាកូនជាសិស្ស ឲ្យមានសេចក្ដីពិចារណាឲ្យថែខ្លួនល្អ កុំប្រទូស្ដទៅរកគ្រូដែលប្រដៅនោះឡើយ ។

ទី ១៥– នាគីបោរគ្រូ ដូចអ្នកនាំផ្លូវ ដើរដោយកន្លង ពោះគឺជីវិតទៅ ស្រុកតាក្លូចដំដង ស៊ីវផ្លូចបំណង នៃចិត្តចិន្ដា ។

អធិប្បាយថា ធម្មតាគ្រូបាធ្យាយនេះ លោករមែងអនុគ្រោះសិស្សានុសិស្ស ព្រមទាំងជនានុជន, លោកមានមេត្តាបង្ហាត់បង្រៀនសិល្បសាស្ត្រទាំងពួង ដល់ជនានុជនទាំងពួង ប្រុសស្ត្រីគ្រប់ភាសាមិនរើសមុខ, បានជាបុរាណបណ្ឌិត លោកលើកគ្រូអាចារ្យនេះទុកជាមគ្គនាយក សំរាប់ដឹកនាំផ្លូវ ចំណែកខាងចំណេះវិជ្ជា ឲ្យស្ទាញស្ទាត់ទៅតាមគន្លងផ្លូវ គឺច្បាប់ក្បួនដំរាប់ដំរា, ព្រោះបុរជនទាំងឡាយកាលនៅជាកុមារតូច ៗ នៅឡើយ ពុំទាន់ចេះវិជ្ជាអ្វី, លុះចូល

ទៅកាន់សំណាក់គ្រូអាចារ្យហើយ សុំឲ្យលោកប្រៀនប្រដៅ លោកក៏មេត្តាបង្ហាត់បង្ហាញ ឲ្យរៀនសរសេរស្រៈព្យញ្ជនៈ មើលសាស្ត្រាបាលីច្បាប់ក្បួន រៀនគិតលេខបូកសងគុណ ហាត់ឲ្យស្គាល់គ្រប់បែប បែបខាងអក្សរសាស្ត្រ ព្រមទាំងគំនូរគូរលេងជារូបភាពផ្សេងៗ បានការហើយ លោកប្រៀនប្រដៅ ឲ្យប្រព្រឹត្តកិរិយាមារយាទឲ្យត្រឹមត្រូវតាមគន្លងធម៌ ទំនៀមទម្លាប់ច្បាប់សណ្ដាប់ប្រវេណី គឺឲ្យដឹងខុសត្រូវបុណ្យបាបគុណទោសជាដើម ។ល។ ហើយលោកអធិប្បាយពន្យល់ អំពីអំពើពាលទុច្ចរិត ហាមឃាត់មិនឲ្យធ្វើបញ្ចវេរទាំង ៥ មានសម្លាប់សត្វជាដើម មានផឹកសុរាមេរ័យជាបរិយោសាន , ដាស់តឿនឲ្យធ្វើតែអំពើសុចរិតល្អ មានឲ្យរក្សាសីលជាដើម, ហេតុនេះហើយទើបលោកពោលថា គ្រូអាចារ្យជាអ្នកនាំផ្លូវសិស្សានុសិស្ស ។

ចំណែកឯសិស្សបានយកចិត្តទុកដាក់ ខំហាត់សង្វាតរៀនអង់ត្រាប់តាមច្បាប់ទំនៀមរបស់គ្រូអាចារ្យបរិបូណ៌ហើយនោះ លោកទុកសិស្សនោះជាអ្នកដើរតាមដំណើរផ្លូវត្រូវប្រៀនប្រដៅ ក៏សឹងបានសំរេចប្រយោជន៍ដូចបំណង ដោយអំណាចចំណេះវិជ្ជាដែលចេះដឹងនោះ បានជាលោកប្រៀបទុកជាដូចជាអ្នកត្រាច់ចរទៅស្រុកធំតូច ស្គាល់ផ្លូវប្រាកដរមែងនឹងដល់ផ្លូវប្រាថ្នា ។

បើសិស្សណា មិនកាន់ច្បាប់ដំកប់គ្រូអាចារ្យប្រៀនប្រដៅមកទេ ធ្វើតាមតែអំពើចិត្តឯង លោករមែងរិះរៀលដូចន័យតទៅនេះ ។

រីដឹងចេះឯង ដូចអ្នកវង្វេង កណ្ដាលអន្ធាធ៍ ពុំនោះដូចខ្វាក់ តែម្នាក់អាត្មា បរចេញយាត្រា ឥតអ្នកដឹកដៃ ។ ស្ទាបម្បីរកផ្លូវ ពុំដែលដឹងត្រូវ ដើរពាលឯព្រៃ ហេតុដឹងចេះឯង ឥតអ្នកដឹកដៃ ចិត្តនោះសង្ស័យ ដូចដល់ពុំដល់ ។

បានសេចក្ដីថា វិស័យធម្មតាមនុស្ស បើចេះដឹងឯងនូវកិច្ចការអ្វី ឥតមានគ្រូអាចារ្យបង្ហាត់បង្រៀនណែនាំពន្យល់ ឲ្យភ្លឺយល់ជាក់ច្បាស់ទេ រមែងធ្វើការអ្វីមិនល្អបាន មិនបានសំរេច ។

ប្រៀបដូចជាមនុស្សវង្វេងផ្លូវ ហើយដើរត្រាច់កាត់ព្រៃព្រឹក្សតែម្នាក់ឯង, ឬដូចមនុស្សខ្វាក់ទាំងពីរ ចរចេញទៅកាន់ទីបច់ឋានណាឥតអ្នកដឹកដៃ មនុស្ស ២ ពួកនេះទោះបីចំប្រឹងការស្ទាបរកផ្លូវក៏ពុំត្រូវតាមផ្លូវដែលស្រួលដែលល្អ សម្បីបើដល់ទីបំណងខ្លួនហើយ ក៏នៅតែសង្ស័យក្រែងពុំទាន់ដល់, ទោសទាំងនេះ ម្នាក់មកពីខ្វាក់ភ្នែក ឥតអ្នកដឹកដៃ, ម្នាក់ភ្នែកភ្លឺក៏មែន តែមកពីខ្សត់ចំណេះល្ងង់ខ្លៅ ឥតគ្រូបាធ្យាយប្រៀនប្រដៅ នូវវិជ្ជាផ្សេង ៗ. បានជាពុំអាចយល់កិច្ចការទាំងពួងបាន បើទាំងចំណេះបន្តិចបន្តួចក៏ពុំបានជាតួតែ យកជាការពុំបានពិតប្រាកដ,

ដូចជាវិទ្យាអក្សរសាស្ត្រ, បើពុំបានពិចារណា តាមក្បួនខ្នាតឲ្យមួនមាំ គ្មានគ្រូពន្យល់វិធីអក្ខរៈ ឬប្រែសព្ទផ្សេងៗ ឲ្យយល់ក្លីច្បាស់ នោះរមែងសរសេរច្រឡំសរខុសទៅជាធម្មតា ហើយខ្លួនអ្នកសរសេរពុំអាចដឹងបានជាខុសសរ សរខុសផង, ព្រោះមកពីមិនទាន់ចំណេះវិជ្ជាតាំងពូនឲ្យស្លូត មួនមាំឥតគ្រូបាធ្យាយណែនាំពន្យល់ឲ្យក្លីច្បាស់ ទោះបីខុសក៏ពុំដឹងជាខុសចេះតែស្មានថាត្រូវហើយ បានជាលោកប្រៀបទុកដូចមនុស្សស្រវឹងស្រា មនុស្សខ្វាក់ភ្នែកតាំងសង់ទាំងនោះឯង ។

ទោសតាំងនេះ អ្នកតាំងឡាយកុំគប្បីធ្វេសប្រហែស បើចង់ចេះចំណេះវិជ្ជាសិល្បសាស្ត្រតាំងពូន ត្រូវតែរៀនពីគ្រូអាចារ្យ យកបែបផែនគ្រូអាចារ្យ សំគាល់ទុកក្នុងចិត្តឲ្យមួនមាំ ទើបលោករាប់ថាជាពហុស្សូតអ្នកចេះចាំច្រើន ។

ទី ១៦– ធនះដូចអ្នកជង ពុំដោយកន្ទង់ នៃលោក
ណាយល់ សឹងធ្វើមោហោ ធោរសោកតាំហល់. ពុំអាច
ធបធល់ ធាធ្វង់ធាស្រាល ។

ពួកមនុស្សដែលមានកិរិយាប្រព្រឹត្ត មិនប្រសើរ គឺមានខាងយោគអាក្រក់សណ្ដាប់ធ្នាប់អាក្រក់ ប្រព្រឹត្តអាក្រក់ ចិត្តអាក្រក់ ទាំងនេះមកពីសន្តានចិត្តអន្ធពាល ព្រោះពាលមានលក្ខណៈ ៣ យ៉ាង គឺគិតអ្វីគិតតែពីសេចក្ដីអាក្រក់នេះ១, ធ្វើកិច្ចអ្វី ធ្វើតែកិច្ចអាក្រក់នេះ២, បើពោល

កថាអ្នកក៏ពោលតែកថាគគ្រក់នេះ ៗ, ហេតុនេះហើយ បានជាលោកពោលថាមនុស្សពាលនោះ “ ពុំដោយគន្ធ នៃលោកណាយល់” គឺថាសុភាសិត ឯណាជាពុទ្ធភាសិតឬបុរាណភាសិត ដែលល្អប្រពៃ ហើយមាតាបិតាគ្រូអាចារ្យ លោកនាំយកមកទូន្មានប្រៀនប្រដៅកូនទឹងសិស្សឯណា ដែលប្រព្រឹត្តគគ្រក់ កូនទឹងសិស្សនោះជាមនុស្សពាលមិនស្តាប់ត្រាប់តែងយក ថែមទាំងសំដែងអាការក្រេវក្រោធចេញមកឲ្យឃើញដល់ក្ដុមហាជនពល់គ្នាទៀត, ដូចន័យលោកពោលថា “ សិងឆ្មើមោហោ ទោសោគំហល់ ពុំអាចទប់ទល់ នាធ្ងន់នាស្រាល” បានសេចក្តីថាបុត្រទឹងសិស្សនោះជាមនុស្សពាល លុះឮមាតាបិតាគ្រូអាចារ្យស្តីប្រដៅឲ្យល្អ ក៏កើតបដិឃៈ ក្តៅខ្ទាញ់ ក្នុងហទយវត្ថុក្រេវក្រោធខឹងពុំអាចអត់សង្កត់ចិត្ត ឲ្យស្ងប់រំងាប់បានឡើយ ម៉្លោះហើយក៏ធ្វើយកតបទៅកាន់លោកអ្នកដ៏មានគុណនោះវិញ , ទោសនេះមកពីសិស្សនោះកូននោះ ជាមនុស្សពាលល្ងីល្ងង់ ផ្ទួងញាំងសន្តានចិត្ត ឲ្យមានទោសមកដាល់ដាច់ ហើយបញ្ឆេះកំហឹងឲ្យពោលពាក្យមិនគប្បីមានប្រការផ្សេងៗ នេះមកពីមិនស្គាល់ធ្ងន់ស្រាល ។

ហេតុនេះយើងទាំងឡាយ កុំគប្បីយកដំពប់ចរិតសិស្សឬកូនកំហាក់ទាំងនោះជាតួយ៉ាងឡើយ ត្រូវចាំពាក្យចាស់ ១ មាត់ទៀតថា “ សិស្សប្រាជ្ញដ្បិតគ្រូ ដេរពោលដំកយ ” នេះជាឧសថដ៏ប្រសើរ សំរាប់

តែទឹកចិត្តសិស្សខ្លួនដែលមោហោនោះ ឲ្យស្គាល់គុណ គ្រូអាចារ្យ មាតាបិតាដែលមានលើខ្លួន ។

ទី ១៧- ប្រដៅក្តីច្បាប់ សឹងជាពុំគាប់ មោហពុំពន្ល
អន្ធពាល ក្តីច្បាប់ធម្មង សឹងជាផាស្រាល មោហពុំ
ចិត្តអន្ធពាល ចង់តែសប្បាយ ។

ពាក្យមួយបទនេះ មានទំនងជាធម្មតា គ្រូអាចារ្យរមែងតែងតែបង្រៀនខ្លួនក្សួនច្បាប់ដែលមានខ្លឹមសារគម្ពីរក្សត្រផ្ទាល់ជ្រៅ សព្វគ្រប់ ដើម្បីឲ្យសិស្សចេះដឹងនឹងប្រព្រឹត្តប្រតិបត្តិតាម, តែសិស្សខ្លះជាមនុស្សមានសន្តានចិត្តជាអន្ធពាលទុកចារ, ប្រៀបដូចមនុស្សម្នាក់ឬចូងគឬគាប់ឥតប្រាជ្ញាពុំឈ្លាសវៃ ពុំយល់ន័យអត្ថរសប្រស្នា រាល់ដែលគ្រូពោលប្រដៅពន្យល់នោះ គ្រឡប់ជាពុំគាប់ចិត្តខ្លួនវិញ ហើយលបគិតជៀលតាប់ទោសគ្រូថាគ្រូស្អប់ខ្លួន គ្រូកាចឥតមេត្តាករុណា ។ល។ ព្រោះដោយហេតុពាក្យប្រដៅនោះ ពុំត្រូវចំណុចចិត្តខ្លួន ដែលជាមនុស្សពាលចង់តែសប្បាយ មានបំណងចង់សេពសេពលេងល្បែងតាំងពីក្មេងជាដើម, ទំនងបានគេគ្រាន់ថាខុសគាប់យ៉ាងណាក៏ទេ ទំនងបានដឹងថាបទនេះល្មើសខុស ទំនងផ្លូវសុចរិតក៏ទេ ឬដឹងខ្លះដែរ តែចិត្តមានះ ចាកការបត្តិបន្ទូច ជាគិតគំនិតសាន្តសប្បាយប៉ុណ្ណោះទំនងទៅជាអ្វី បើខុសទំនងច្បាប់ ក៏ពុំខ្វល់ប៉ុន្មានទេ ក៏ធ្វើលោកបំពានទៅ, មនុស្សប្រមាទបែបនេះ ច្រើនតែ

ភ្លាត់ចំណាប់ពុំស្ងប់ទាន ,  ព្រោះដោយចិត្តអន្ធពាល  ពុំប្រព្រឹត្តតាមដំបូន្មានគ្រូអាចារ្យប្រៀនប្រដៅ  ប្រយោជន៍ឲ្យខ្លួនបានសេចក្ដីល្អសុចរិតនោះឡើយ ។

សិស្សដែលបើនឹងរឹងរូសយ៉ាងនេះ កើតមកពីហេតុអ្វី? លោកប្រាប់ពោលថា  ព្រោះ

ពុំដឹងដើមគ្រូ  បង្កើតអក្សរ  ប្រដូចឪម្ដាយ  ក៏ពី
មនុស្សលោកគេ  រួចដល់ស្លាប់ឆាយ  ចៀសចតុរាបាយ
នរកានាំដំបូង ។

បានសេចក្ដីថា  សិស្សដែលជាពាលនោះ  មកពីពុំដឹងហេតុបំណាច់របស់គ្រូអាចារ្យ  ដែលលោកមានប្រាថ្នា  ចង់ឲ្យសិស្សានុសិស្សបាននូវប្រយោជន៍  យ៉ាងខ្ពស់ក្រៃលែងដល់ខ្លួន,  គឺលោកបំភ្លឺពីផ្លូវច្បាប់ទាំងអាណាចក្រ  ដើម្បីឲ្យសិស្សនោះបានសេចក្ដីចំរុងរឿងឧត្តុង្គឧត្ដមក្នុងលោកិយនេះ ១ ឲ្យភ្លឺក្នុងផ្លូវពុទ្ធសាសនា  ដើម្បីយកមគ្គផលឲ្យរួចចាកចតុរាបាយ  នរកទាំងបួន  ព្រមបរលោកនាយនេះ ២, ហេតុនេះបានជាលោកទុកគ្រូអាចារ្យ "ប្រដូចនឹងម្ដាយ" ព្រោះម្ដាយបង្កើតរូបកាយ ឧបត្ថម្ភចិញ្ចឹមបីបាច់ថែរក្សា  ឯចំណែកគ្រូអាចារ្យ  ជួយឧបត្ថម្ភទំនុកបំរុង  ក្នុងកិច្ចបង្ហាត់បង្រៀន  ឲ្យកើតចំណេះវិជ្ជាផ្សេងៗ បានជាលោកប្រៀបដូចមាតា  ។

មួយវិញទៀត បើសិស្សឯណា មានប្រាជ្ញាអាចយល់នូវគុណជាតិនៃការសិក្សាទាំងនេះបានប្រាកដហើយ នោះគប្បីកាន់ដោយមាំមួននូវការសិក្សាដែលជាមធុរស ដូចមានតទៅនេះ ៗ

ឆាប់ហៅគ្រូ កុំធ្វើម្ខះ ចិត្តឆោះឲ្យស្លូន កុំធ្វើធំពេក
ចង់ធំនែខ្លួន ក្រែងបាបមកជួន នៅនាលោកិយ ៗ

លោកថា បើសិស្សណា បានយល់ក្តីនូវគុណូបការៈរបស់គ្រូ ហើយគួរគោរពប្រណិប័តន៍ មិនត្រូវដំកើងឫកពា ក្រអឺតឆ្មើងឆ្មៃឃើញគ្រូ ហើយធ្វើឫកកញ្ចប់កញ្ចូរដាក់គ្រូឡើយ ៗ

ទុកណាជាខ្លួន មានយសស័ក្តិធំជាងក្តី មានសម្បត្តិទ្រព្យច្រើនជាងក្តី ត្រូវតែធ្វើចិត្តឲ្យស្លូន ដាក់ខ្លួនឲ្យទាបជាងគ្រូ គោរពខ្លាចដោយគោរពស្មោះត្រង់កុំគប្បីភ្លេច, បើសិស្សណាមិនគោរពគ្រូ លោកពោលថា "ក្រែងបាបមកជួន នៅនាលោកិយ" បានសេចក្តីថា បណ្តាសិស្សណា ពុំដឹងគុណគ្រូ ពុំគោរពគ្រូ អ្នកនោះនឹងបានបាបគឺសេចក្តីអាក្រក់ ដល់ខ្លួនថាជាមនុស្សអកតញ្ញូ ក្នុងនាលោកិយនេះពុំខាន ៗ

ទី ១៨ រីគ្រូមានព្យាយ អាចឲ្យពណ្ណាកាយ មានរូបរស្មី
ហើយឲ្យរុងរឿង អស់បញ្ចិន្ទ្រិយ ស្មើព្រះផនធី ជនកា
ស្រោតហោង ៗ

សេចក្តីនេះ ប្រៀបបីដូចពេទ្យ ដែលពូកែចំណានខាងរក្សាភ្នែក នោះបើភ្នែកនោះឈឺចាក់ដោត រងទុក្ខវេទនា អាប់ស្រអាប់ មើលអ្វីពុំច្បាស់ លុះពេទ្យប្រកបថ្នាំដាក់ភ្នែកឲ្យ ភ្នែកនោះក៏ជាស្រឡះភ្លឺច្បាស់ឡើងល្អ ជាធម្មតាវិញ នេះមានឧបមាយ៉ាងណា ?

សមគ្នានឹងអ្នករៀនវិជ្ជា កាលដើមហាក់ដូចជាមនុស្សខ្វាក់ គ្រូអាចារ្យ ដូចពេទ្យហ្ន៎, គ្រូបង្ហាត់បង្ហាញសិស្ស នូវសិល្បសាស្ត្រផ្សេងៗ សិស្សដែលខំសង្កាត់រៀនសូត្រ ចាំកំប៉ុងធ្លើលួចយកចំណេះពីគ្រូនោះយូរទៅសឹងមានប្រាជ្ញាឈ្លាសវៃ ក៏សេចក្តីស្រប់ពីពួក, ស្រេចបរិបូណ៌ហើយ លោកជូនឲ្យចេញប្រឡង, បើជាប់លេខមានសញ្ញាប័ត្រ ទើបសង្គមហៅថាជាអ្នកមានវិជ្ជាដ៏ប្រសើរ ពលការផ្ទាល់ ក៏យកទៅប្រើការឲ្យរុងរឿង មានយសស័ក្តិប្រាក់ខែជាច្រើន, ហេតុនេះហើយដែលគ្រូអាចារ្យ ធ្វើឲ្យសិស្សបានចំរើន បានជាពោលទុកថា "ស្រីគ្រូដូចទី ដូចគោមភ្លោះ" ។

ឯឧបការគុណរបស់មាតាបិតានោះ លោកសំដែងថា

ព្រះជនកាសោភណា បង្កើតអាត្មា ឲ្យមានសរីរ
ជង់ រក្សាពីតូច មិនឲ្យមានបាង អស់សុខទុក្ខជង់
ពុំដែលរួចផ្អឹង ។

សេចក្ដីថា អាពុកម្ដាយបង្កើតយើងមក ហេតុចិញ្ចឹមយើង បីបាច់រក្សាល្អណាស់ មានបំបៅដោះផ្ដល់ទឹកបញ្ចុកបាយជាដើម លុះដល់ធំឡើង លោកនៅតែត្រិះត្រងរក្សា តែងតែទទួលទុក្ខសុខ របស់បុត្រធីតាពុំដែលធុញទ្រាន់ឡើយ, ជាបើកូនឈឺចាប់ ឬមានទុក្ខដូចម្ដេចៗក្ដី ឬមួយទៅប្រព្រឹត្តទុច្ចរិតលើសពីនិក្ខប់ ត្រូវមានទុក្ខទោសដូចម្ដេចៗក្ដី នោះចិត្តមាតាបិតា ក៏រមែងព្រួយផងពុំមានគេដូច, មានខំសង្គ្រោះរកជួយសងបំណុលជួស ខំទៀតសម្បត្តិទ្រព្យទៅកូនដែលក្រលំបាក យកទៅលក់បាយចិញ្ចឹមជីវិតក៏មាន ។ល។ ទាំងនេះក៏មកតែមាតាបិតាលោកមានសេចក្ដីមេត្តាករុណា ដល់បុត្រធីតានោះ ។

រួមសេចក្ដីទៅឃើញថា មាតាបិតានឹងត្រូវការពារនេះជាគុណល្អគង របស់បុត្រនិងសិស្ស ដូចន័យអធិប្បាយមកនេះ ។

ទី ១៩ - ព្រះជនក ព្រះជននី បើនឹងស្រដី ប្រសើរពេកកពន់ ជាភ្នំព្រះសុមេរុ នោះហោចមហាធ្ងន់ ជាបើនឹងថ្លឹងណាន់ ពុំអាចគាប់ស ។

បើនឹងពណ៌នា សរសើរពីគុណមាតាបិតា ដែលមានលើកូនប្រុសកូនស្រីទាំងឡាយ សំងឃើញថាជាច្រើនក្រៃពេកឥតកំរិតនឹងលើកយកមកប្រៀបធៀបឲ្យស្មើនោះពុំបានឡើយ ប្រសើរក្រៃពេកណាស់, ទើបលោកប្រៀបថា ភ្នំព្រះសុមេរុ ជាបព្វតដ៏ឥតឧបមា

ខ្ពស់ហួសប្រមាណ លើសលែងឧបត្ថាចាំងពួង គុណឪពុកទាំងបួននេះ ថាបើនឹងគួរទៅឯទម្ងន់ទៀតៈលោកថា "នោះហោងមហាធ្ងន់" ធ្ងន់ពន់ពេកហួសប្រមាណ "ថាបើនឹងគណនា ពុំអាចគន្ធង" លោកថាបើនឹងថ្លឹងយកទម្ងន់វិញ ក៏ពុំអាចនឹងកប់ដោយផែសំខ្យាថាប៉ុណ្ណោះៗ ពុំបាន ។ បើនឹងលើកយកទំហំ, កំពស់នឹងទម្ងន់ភ្នំព្រះសុមេរុរាជ មកផ្ទឹមនឹងទំហំ កំពស់ទម្ងន់គុណមាតាបិតា ដែលមានគុណលើបុត្រធីតា នោះឃើញថាពុំអាចនឹងវែងគន្ធងកើនហួសឬពុំស្មើបានឡើយ, ដូច្នេះហើយយើងជាបុត្រធីតាកុំគប្បីភ្លេចគុណមាតាបិតារបស់យើងគ្រប់រូប ដែលមានព្រះគុណធ្ងន់ជាងភ្នំព្រះសុមេរុនោះឡើយ ។

មិនតែគុណមាតាបិតាប៉ុណ្ណោះទេ លោកប្រាប់តទៅទៀតថា,

ត្រីទាញាយ ប្រដូចផ្លូវម្ដាយ អាពុកឃាងហោង
អាចឲ្យត្រឹមព្យាប់ ប្រះដាវធម៌ដង់ ដោយផ្លូវគង្គង់ ព្រះពុទ្ធឆ្ងាញ់ឆ្ងាយ ។

បានសេចក្ដីថា បណ្ដាបុព្វការីរបស់យើង មិនតែអំពុកម្ដាយប៉ុណ្ណោះទេ លោកកប់យកគ្រូបាធ្យាយបញ្ចូលមកទៀត ជាបុគ្គលដែលមានគុណលើយើង ដែលស័ក្យានុសិស្សគ្រុកស្មើនឹងអំពុក-ម្ដាយយើង ដូចបានអធិប្បាយមកខ្លះហើយខាងដើម, តែគង់ទីនេះ លោកលើកយកខ្លួនឯកថា នៃគ្រូបាធ្យាយយើងទៀតថា "អាចឲ្យ

ក៏ច្បាប់ប្រដៅធម៌ផង ដោយនូវគន្លង ព្រះពុទ្ធទាំងឡាយ" ថាគ្រូបា-ធ្យាយប្រដៅយើងជាសិស្សឲ្យដឹងច្បាប់ទម្លាប់ជាគតិលោក ហើយប្រដៅនូវធម៌ តាមដោយគន្លង ដែលព្រះបរមគ្រូសព្វញ្ញូពុទ្ធ ព្រះអង្គទ្រង់ត្រាស់សំដែងទុកមកជាច្បាប់សំរាប់ឲ្យពួកពុទ្ធបរិសទ្យប្រតិបត្តិតាម ដើម្បីជាប្រយោជន៍ ដឹកនាំសិស្សឲ្យបានជាមនុស្សល្អក្នុងលោកនេះប្រការ១ ឲ្យរួចចាកទុក្ខ ក្នុងជាតិនេះនឹងជាតិក្រោយនេះប្រការ១ ។

គ្រូបាធ្យាយមានគុណវិសេសយ៉ាងនេះ បានជាលោកលើកយកមកតាំងទុកដូចមាតាបិតារបស់យើង ។

ទី ២០- នរអ្នកណា ដោះមានប្រាជ្ញា ឲ្យគិតវែងឆ្ងាយ កុំណានោះនាំងបី ហៅឧបាទ្វលាយ កុំឲ្យអន្តរាយ ក្តីពីព្យាយាម ។

អ្នកទាំងឡាយ កាលណាបើមានវិជ្ជា រៀនច្បាប់សំរាប់ក្បួនខ្លួនបានហើយ ទាំងខាងអាណាចក្រនិងពុទ្ធចក្រ សតិបញ្ញាក៏ល្អមានគ្រាន់ប្រើប្រាស់បានតាមសតិកំឡាំង នោះត្រូវឲ្យមានយោបល់ យល់គិតអំពីគុណលោកអ្នកមានគុណ ឲ្យមាំមួនកុំភ្លេចប្រហែស. បានជាលោកប្រដៅថារិកទុកថា "នរអ្នកណា ពោះមានប្រាជ្ញា ឲ្យគិតវែងឆ្ងាយ" បានសេចក្តីថា ធម្មតាបណ្ឌិតជាតិ លោករមែងគិតពីអ្នកមានឧបការ-

គុណកុំភ្លេច ព្រោះលោកប្រកបដោយសេចក្តីជាអ្នកមានកតញ្ញូ ។ ចុះចំណែកយើងជាកូនចៅនៃមាតាបិតា ជាសិស្សនៃគ្រូអាចារ្យ តើត្រូវធ្វើដូចម្តេច? ទើបហៅថា ជាអ្នកមិនភ្លេចគុណ, ដូច្នេះលោកវិនិច្ឆ័យប្រាប់ជាបញ្ហាថា "គុណនេះទាំងបី ហៅមហាគុណ" គឺលោកជាមាតាបិតានិងគ្រូអាចារ្យ ទាំងបីនេះ លោកមានឧបការគុណ លើសលន់ពន់ពេកជាងអនេកប្បការ លើកូនចៅសិស្ស, គុណទាំងនោះធ្ងន់ក្រៃលែងលើសទម្ងន់ភ្នំព្រះសុមេរុរាជទៅទៀត, ដូច្នេះឯងហើយ ទើបលោកទូន្មានយើងថា "កុំឲ្យអត្តកាយ ក្តីពិព្យាយាម" ថាកុំឲ្យភ្លេចគុណនោះឲ្យសោះ, ត្រូវឲ្យចាំជាប់ក្នុងចិត្ត ថាមាតាបិតាគ្រូអាចារ្យរបស់យើងនេះ លោកមាននឿយហត់ប៉ុណ្ណា ចិញ្ចឹមរក្សាយើង, បង្ហាត់បង្រៀនចំណេះវិជ្ជាផ្សេងៗ ឲ្យយើងចេះដឹង បើលើកឃើញដូច្នេះហើយត្រូវមានព្យាយាម ធ្វើបដិបត្តិកុំឲ្យដាច់ មានគោរពក្រាបសំពះជាដើម, បើខឹងពោលឲ្យពិស្តាបន្តិច ហាយើងត្រូវធ្វើបដិការៈគត់គុណខ្លួនរកាផងនា-នាក្រោមទាំងសំពត់ការសាវស្សផង, បើលោកមានជម្ងឺពេកាមករៀតរៀន យើងជាកូនត្រូវរកពេទ្យមើលដាក់ថ្នាំព្យាបាល ដូចកាលលោកថែទាំយើងពីតូចមក ។

មួយទៀតព្រះរតនគុណ គឺព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ដែលលោកជាអ្នកបង្ហាត់ឲ្យល់ផ្លូវយើង ទៅកាន់សេចក្តីសុខ ។

ព្រះពុទ្ធលោកជាអគ្គបុគ្គល លោកឆ្ងាយចាកកិលេស ត្រាស់ដឹងឯងប្រពៃ ហើយទ្រង់ផ្សាយធម៌ដែលកំបាំង ដោយអំណាចសីលសមាធិបញ្ញាដ៏បរិសុទ្ធរបស់ព្រះអង្គ, ទើបទ្រង់ព្រះនាមថាព្រះសម្មាសម្ពុទ្ធ ។

ព្រះធម៌ គឺព្រះពុទ្ធវចនៈ ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ទូន្មានសត្វលោកដើម្បីដឹកនាំឲ្យវៀរចាកអកុសលកម្ម, ដោយព្រះមហាករុណាប្រោសបំភ្លឺសត្វឲ្យរួចចាកទុក្ខវេទនា ។

ព្រះសង្ឃជាសាវកព្រះដ៏មានព្រះភាគ លោកបដិបត្តិប្រពៃហើយជាបុញ្ញក្ខេត្តដ៏ឧត្តម របស់សត្វលោក ។

ដូច្នេះយើងត្រូវគោរព គុណទាំងបីនេះទៀត ជាបុព្វការីរបស់យើង, ដូចពោលខាងក្រោយនេះតទៅទៀតថា ។

រីបុណ្យនិងបាប អំពើសុភាព នោះក៏តែងតាម
ប្រដូចស្រមោល អន្ទោលតាមប្រាណ ពុំដែលឃ្លៀសឃ្លាត ត្រង់ក្តីសល់រលំ ។

ជាបើយើងពុំភ្លេចគុណលោកទាំងនេះទេ យើងនឹងបានបុណ្យ គឺសេចក្តីសុខចំរើនយសស័ក្តិ ទ្រព្យភោគសម្បត្តិ ដោយអំណាចផលបុណ្យកតញ្ញូនោះ តែបើយើងប្រមាទធ្វេសប្រហែស បំភ្លេចបំបាត់គុណ

ទាំងនោះចោលអស់ហើយ, យើងនឹងបានបាប គឺសេចក្ដីរងទុក្ខវេទនា ក្រលំបាកគោកយ៉ាកល្ហមល្ហាម ។

ឯផលបុណ្យនឹងបាប - ទាំងពីរនេះ, លោកប្រៀបដូចស្រមោលនៃរូបយើង រមែងតែជាប់ដិតនឹងខ្លួនយើងពុំដែលឃ្លាត ឯយើងសោតក៏ពុំអាចនឹងចៀសឲ្យផុតបាន, បើយើងធ្វើអំពើល្អ បុណ្យគង់កើតមានដល់យើង, បើយើងធ្វើនូវអំពើអាក្រក់ បាបក៏គង់មានដល់យើង, យ៉ាងនេះយើងត្រូវប្រព្រឹត្តតាមច្បាប់ក្រមនេះឲ្យបរិបូណ៌ ។

ទី២១ - ឲ្យគិតជញ្ជឹង ហើយឲ្យរំពឹង ប្រាជ្ញាឲ្យយល់ ឲ្យមានពិរិយ៍ សង្រួមកុសល កុំធ្វើរវល់រវល់ នឹងក្ដីទុក្ខសោក ។

អធិប្បាយថា ធម្មតាជាមនុស្សនេះ ឲ្យយកប្រាជ្ញាត្រិះរិះពិចារណាពិនិត្យ ឲ្យបានជាប់ក្នុងខ្លួនសន្ដាន គឺឲ្យខំប្រឹងព្យាយាមកសាងកុសល កាន់ទៀងត្រង់សុចរិតធម៌ មានរក្សាសីល៥ ពាក់សីល៨ ចំរើនមេត្តាករុណាកុំឲ្យដាច់ "កុំធ្វើរវល់រវល់ នឹងក្ដីទុក្ខសោក" គឺលោកឲ្យលះបង់អំពើទោស ទុក្ខនឹងសោកចោលចេញ កុំឲ្យមាននៅក្នុងសន្ដានចិត្ត ព្រោះសេចក្ដីសោកស្រណោះនេះ ឥតអំពើទេ ហើយជាមន្ទិល នាំឲ្យសត្វវិលវល់ក្នុងវដ្ដសង្សារ ត្រូវឲ្យជឿថាជីវិតមិនទៀង រូបមិនទៀង រូបនេះមិនមែនជារបស់យើង ។ល។ បើអ្នកឯណាប្រដៅចិត្ត ឲ្យចុះកាន់

គន្លងធម៌បានដូច្នេះហើយ, ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់សរសើរដូចមាន ន័យតទៅនេះ ។

នរអ្នកណា ដឹងនាំអាត្មា ឧស្សាហ៍អធ្យាត
ស្វែងធម៌ជាផ្លូវ ទៅកាន់បរលោក ចូលមហាបាដិ-
មោក្ខ គឺនិព្វានហោង ។

អធិប្បាយថា បើបុគ្គលឯណាខំប្រឹងប្រែង ធ្វើចិត្តឲ្យល្អស្អាត សង្អាតកោសរួសកិលេស មានលោភៈ ទោសៈ មោហៈ ជាដើម ដែលជាគ្រឿងសៅហ្មងចិត្ត ឲ្យស្ដើងលើងអស់ទៅនេះហៅ "ស្វែងធម៌ជាផ្លូវទៅកាន់បរលោក" ទើងបាននាំខ្លួន ឲ្យបានសេចក្ដីសុខ ទៅលោកខាងមុខ "ចូលមហាបាដិមោក្ខ គឺនិព្វានហោង" លុះបានឃើញច្បាស់ នូវអរិយសច្ចធម៌ទាំង ៤ តាមពិតហើយក៏កើតសេចក្ដីនឿយណាយក្នុងខន្ធទាំង ៥ ហើយដំណើរទៅតាមផ្លូវធំ គឺព្រះអដ្ឋង្គិកមគ្គជាផ្លូវត្រង់ ចូលទៅកាន់ស្ថានព្រះបរមនិព្វាន ជាឯកន្តសុខនោះឯងហោង ។

ចប់ច្បាប់ក្រមចរិយាយប៉ុណ្ណេះហោង ។

---

# បញ្ជីស្រង់ចំនួនចៅអធិការនិងមន្ត្រីសង្ឃ

ដែលទើបតាំងថ្មីក្នុងរដូវវស្សា ឃត-ស៊ុត ឆ្នាំ ១៩៥៥

១- សញ្ញាប័ត្រលេខ ៥១ ចុះថ្ងៃ ២៨-៧-៥៥ តាំងព្រះគ្រូឧត្តមមុនី ម៉ឹង-សេស កើតឆ្នាំខាល អាយុ ៥៤ វស្សា ៣៤ ជាចៅអធិការ វត្តមហាមន្ត្រី ឃុំលេខ៤ ក្រុងភ្នំពេញ ។

២- សញ្ញាប័ត្រលេខ ៥២ ចុះថ្ងៃ ៦-៨-៥៥ តាំងលោកគ្រូ ណុប-ហុក កើតឆ្នាំឆ្លូវ អាយុ ៥៥ វស្សា ៥ នាមឆាយា ហត្ថត្ថេរ ជាចៅអធិការ វត្តកំស ឃុំសឹងគោល ស្រុក-ខែត្រកំពត ។

៣- សញ្ញាប័ត្រលេខ ៥៣ ចុះថ្ងៃ ៦-៨-៥៥ តាំងលោកគ្រូប៉ុក-ឆន់ កើតឆ្នាំច អាយុ ៣២ វស្សា ១០ នាមឆាយា គម្ពីរត្ថេរ ជាចៅអធិការ វត្តក្រាលមាស ឃុំក្រាលមាស ស្រុក-ខែត្រកំពត ។

៤- សញ្ញាប័ត្រលេខ ៥៤ ចុះថ្ងៃ ៦-៨-៥៥ តាំងលោកគ្រូលៀង-យូត្រ កើតឆ្នាំកៃ អាយុ ២៥ វស្សា ៥ នាមឆាយា សុវណ្ណជោត ជាចៅអធិការ វត្តអង្គរធំ ឃុំសឹងគោល ស្រុក-ខែត្រកំពត ។

៥- សញ្ញាប័ត្រលេខ ៥៥ ចុះថ្ងៃ ៦-៨-៥៥ តាំងព្រះវិន័យធរ យស់-នាង កើតឆ្នាំមមី អាយុ ៦៣ វស្សា ៤២ នាមឆាយា ធម្មត្ថេរ ជាចៅអធិការ វត្តស្នំអំពិល ឃុំសឹងគោល ស្រុក-ខែត្រកំពត ។

៦ - សញ្ញាប័ត្រលេខ ៥៦ ចុះថ្ងៃ ៦-៨-៤៤ តាំងលោកគ្រូកៅ-ស៊ិន កើតឆ្នាំមមែ អាយុ ៦២ វស្សា ៤១ នាមឆាយា ឥន្ទត្ថេរ ជាចៅអធិ-ការ វត្តពិជ័យឧដុង្គ ឃុំកំពត ស្រុក-ខេត្តកំពត ។

៧ - សញ្ញាប័ត្រលេខ ៥៧ ចុះថ្ងៃ ៦-៨-៤៤ តាំងលោកគ្រូអ៊ុង-អិន កើតឆ្នាំមមី អាយុ ២៧ វស្សា ៧ នាមឆាយា ឥន្ទត្ថេរ ជាចៅអធិការ វត្តកុនសត្វ ឃុំកុនសត្វ ស្រុក-ខេត្តកំពត ។

៨ - សញ្ញាប័ត្រលេខ ៥៨ ចុះថ្ងៃ ៦-៨-៤៤ តាំងលោកគ្រូ យួន-សាញ់ កើតឆ្នាំម្សាញ់ អាយុ ២៦ វស្សា ៦ នាមឆាយា មុនិសមុ-ទ្ទត្ថេរ ជាចៅអធិការ វត្តរកា ឃុំកោះតូច ស្រុក-ខេត្តកំពត ។

៩ - សញ្ញាប័ត្រលេខ ៥៩ ចុះថ្ងៃ ៧-៨-៤៤ តាំងលោកគ្រូកែវ-ផន កើតឆ្នាំរោង អាយុ ៤៩ វស្សា ៨ នាមឆាយា សុវណ្ណជោត ជាចៅអ-ធិការ វត្តសុគន្ធសួគ៌ ឃុំធ្លក ស្រុកទ្រាំង (តាកែវ) ។

១០ - សញ្ញាប័ត្រលេខ ៦០ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ញាណ-ទៀម កើតឆ្នាំរោង អាយុ ៥៣ វស្សា ៣៣ នាមឆាយា ធម្មត្ថេរ ជាចៅអធិការ វត្តពោធិ៍ចិន ឃុំពោធិ៍ចិន ស្រុកកំពង់សោម (កំពត) ។

១១ - សញ្ញាប័ត្រលេខ ៦១ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ជ្រុក-សម កើតឆ្នាំមមែ អាយុ ៣៨ វស្សា ១៧ នាមឆាយា ឥន្ទត្ថេរ ជាចៅអធិការ វត្តសុវណ្ណរង្សី ឃុំលាបៀរ ស្រុកលាបៀរ (កំពង់ឆ្នាំង) ។

១២ – សញ្ញាប័ត្រលេខ ៦២ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ មួ-សួស កើតឆ្នាំមមែ អាយុ ២៦ វស្សា ៥ នាមឆាយា ឥន្ទបញ្ញា ជាចៅអធិការ វត្តអន់ឆ្អើត ឃុំដីទរ ស្រុកកំពង់សោម (កំពត) ។

១៣ – សញ្ញាប័ត្រលេខ ៦៣ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ជ័យ-គង់ កើតឆ្នាំមមែ អាយុ ៨២ វស្សា ៦០ នាមឆាយា សុវណ្ណសរ ជាចៅអធិការ វត្តកំលត ឃុំពោធិ៍ចិង ស្រុកកំពង់សោម (កំពត) ។

១៤ – សញ្ញាប័ត្រលេខ ៦៤ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូជ័ម-ម៉ុល កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៧ នាមឆាយា ធម្មបញ្ញា ជាចៅអធិការ វត្តជ្រយត្រាច ឃុំភាគបន្ទាយ ស្រុកកោះឡៀរ (កំពង់ឆ្នាំង) ។

១៥ – សញ្ញាប័ត្រលេខ ៦៥ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូនង-គាត កើតឆ្នាំរកា អាយុ ៣៥ វស្សា ១៤ នាមឆាយា សុវណ្ណតេរ ជាចៅអធិការ វត្តពោធិគិរី ឃុំថ្នស ស្រុកកំពង់សោម (កំពត) ។

១៦ – សញ្ញាប័ត្រលេខ ៦៦ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូអ៊ុង-កាក់ កើតឆ្នាំមមី អាយុ ៥១ វស្សា ២៩ នាមឆាយា សុវណ្ណវិន័យ ជាចៅអធិការ វត្តគិរីសាគរ ឃុំថ្នស ស្រុកកំពង់សោម (កំពត) ។

១៧ – សញ្ញាប័ត្រលេខ ៦៧ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ មាស-ប៊ុទ្ធ កើតឆ្នាំរកា អាយុ ៤៨ ឆ្នាំ វស្សា ២៧ នាមឆាយា គម្ភីរបញ្ញា ជាចៅអធិការ វត្តដីទរ ឃុំដីទរ ស្រុកកំពង់សោម (កំពត) ។

១៨-សញ្ញាប័ត្រលេខ ៦៨ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ចិក-សុក កើតឆ្នាំរកា អាយុ ៣៥ វស្សា ៨ នាមឆាយា បញ្ញាសរ ជាចៅ-អធិការ វត្តវាលគួច ឃុំដីដាត ស្រុកកំពង់សោម (កំពត) ។

១៩– សញ្ញាប័ត្រលេខ ៦៩ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូខន់-ញៀប កើតឆ្នាំជូត អាយុ ៤៤ វស្សា ២១ នាមឆាយា បញ្ញាកេសរ ជាចៅ-អធិការ វត្តអន្តក្នោត ឃុំដនវែន ស្រុកកំពង់សោម (កំពត) ។

២០– សញ្ញាប័ត្រលេខ ៧០ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូឆាន់-ញៀប កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៦ នាមឆាយា ហកសាថេរ ជាចៅអធិការ វត្តកណ្តាល ឃុំដីដាត ស្រុកកំពង់សោម (កំពត) ។

២១– សញ្ញាប័ត្រលេខ ៧១ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូម៉ុ-ជៀប កើតឆ្នាំមមែ អាយុ ៥១ វស្សា ១៨ នាមឆាយា ខេសរគោត្រ ជាចៅអធិការ វត្តតិរីបទុម ឃុំដីដាត ស្រុកកំពង់សោម (កំពត) ។

២២– សញ្ញាប័ត្រលេខ ៧២ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូញ៉ែម-អួន កើតឆ្នាំរកា អាយុ ៣៦ វស្សា ១៦ នាមឆាយា សុវណ្ណបញ្ញោ ជាចៅអធិការ វត្តអូរស្វែង ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច (កំពត) ។

២៣– សញ្ញាប័ត្រលេខ ៧៣ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូមូល-ឈួន កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៧ នាមឆាយា ឆយប្បញ្ញោ ជាចៅអធិការ វត្តស្រែត្រាវ ឃុំថ្នល ស្រុកកំពង់សោម (កំពត) ។

៣៤ — សញ្ញាប័ត្រលេខ ៨៤ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ អ៊ិន-សាំង កើតឆ្នាំរោង អាយុ ៣៧ វស្សា ១៧ នាមឆាយា បទុមសារ ជាចៅអធិការ វត្តដងទង់ ឃុំស្វាយទង ស្រុកកំពង់ត្រាច (កំពត) ។

៣៥- សញ្ញាប័ត្រលេខ ៨៥ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូហួត-ឆាយ កើតឆ្នាំមមី អាយុ ៦៣ វស្សា ៤២ នាមឆាយា បទុមសារ ជាចៅអធិការ វត្តក្រាំងលាវ ឃុំស្រែជា ស្រុកកំពង់ត្រាច (កំពត) ។

៣៦- សញ្ញាប័ត្រលេខ ៨៦ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូម៉ែន-ញ៉ែក កើតឆ្នាំឆ្លូវ អាយុ ៣២ វស្សា ១២ នាមឆាយា ព្រហ្មជោត ជាចៅអធិការ វត្តផ្គុស ឃុំស្រែជា ស្រុកកំពង់ត្រាច (កំពត) ។

៣៧- សញ្ញាប័ត្រលេខ ៨៧ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ កុប យ៉ាត កើតឆ្នាំមមី អាយុ ៣៨ វស្សា ១៣ នាមឆាយា ធម្មសារ ជាចៅអធិការ វត្តអន្លង់ដំបងដែក ឃុំស្វាយទង ស្រុកកំពង់ត្រាច (កំពត) ។

៣៨- សញ្ញាប័ត្រលេខ ៨៨ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ សៅ-សេង កើតឆ្នាំរក អាយុ ៣៧ វស្សា ១៥ នាមឆាយា បទុមស៊ ជាចៅអធិការ វត្តជុំបុណ្យ ឃុំស្វាយទង ស្រុកកំពង់ត្រាច (កំពត) ។

៣៩- សញ្ញាប័ត្រលេខ ៨៩ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ ទូច-ពេង កើតឆ្នាំច អាយុ ២៣ វស្សា ៤ នាមឆាយា មង្គលតេរ ជាចៅអធិការ វត្តដងទង់ ឃុំស្វាយទង ស្រុកកំពង់ត្រាច (កំពត) ។

៤០- សញ្ញាប័ត្រលេខ ៩០ ចុះថ្ងៃ ៩-៨-៤៤ តាំងលោក គ្រូ ត្រី-អន កើតឆ្នាំកុរ អាយុ ៣៤ វស្សា ៤ នាមឆាយា សុវណ្ណ-ត្ថេរ ជាចៅអធិការ វត្តគងជុំវិជ្ជ ឃុំដងពែង ស្រុកកំពង់សោម (កំពត) ។

៤១ - សញ្ញាប័ត្រលេខ ៩១ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូ កែវ-អុំ កើតឆ្នាំរោង អាយុ ៤១ វស្សា ២០ នាមឆាយា សង្ឃរក្ខិត ជាចៅអធិការ វត្តអង្គជ័យ ឃុំបឹងសាលា ស្រុកកំពង់ត្រាច (កំពត) ។

៤២- សញ្ញាប័ត្រលេខ ៩២ ចុះថ្ងៃ ៩-៨-៤៤ តាំងលោក គ្រូ ផែក-សួរ កើតឆ្នាំខាល អាយុ ៦៧ វស្សា ៤៦ នាមឆាយា សុវណ្ណកេសី ជាចៅអធិការ វត្តស្រែជា ឃុំស្រែជា ស្រុកកំពង់ត្រាច (កំពត) ។

៤៣-សញ្ញាប័ត្រលេខ ៩៣ ចុះថ្ងៃ ៩-៨-៤៤ តាំងលោក គ្រូ សៅ-ឡេង កើតឆ្នាំមមែ អាយុ ៣៨ វស្សា ១៨ នាមឆាយា ឥន្ទសរ ជាចៅអធិការ វត្តអញ្ញាគិរី ឃុំឫស្សីស្រុក ស្រុកកំពង់ត្រាច (កំពត) ។

៤៤- សញ្ញាប័ត្រលេខ ៩៤ ចុះថ្ងៃ ៩-៨-៤៤ តាំងលោក គ្រូ ម៉ិច-ប៉ែម កើតឆ្នាំរកា អាយុ ៣៦ វស្សា ១៤ នាមឆាយា ពុទ្ធរក្ខិត ជាចៅអធិការ វត្តព្រះគោ ឃុំ- ស្រុកកំពង់ត្រាច (កំពត) ។

៤៥- សញ្ញាប័ត្រលេខ ៩៥ ចុះថ្ងៃ ៩-៨-៤៤ តាំងលោកគ្រូអ៊ុំស-សាក់ កើតឆ្នាំរកា អាយុ ២៤ វស្សា ៤ នាមឆាយា សង្ឃវុឌ្ឍិ ជាចៅអធិការ វត្តអន្លង់ចម ឃុំដំណាក់កន្ទួត ស្រុកកំពង់ត្រាច (កំពត) ។

៤៦ - សញ្ញាប័ត្រលេខ ៩៦ ចុះថ្ងៃ ២១-៨-៤៤ តាំងលោកគ្រូប្រាក់ជិន កើតឆ្នាំមមែ អាយុ ២៦ វស្សា ៤ នាមឆាយា សោភិតោ ជាចៅអធិការ វត្តត្រពាំងវែង ឃុំបល្ល័ង្គ ស្រុកបារាយណ៍ (កំពង់ធំ) ។

៤៧ - សញ្ញាប័ត្រលេខ ៩៧ ចុះថ្ងៃ ២៣-៨-៤៤ តាំងលោកគ្រូថង-ជិន កើតឆ្នាំម្សាញ់ អាយុ ២៨ វស្សា ៧ នាមឆាយា ឥន្ទបន្ត ជាចៅអធិការ វត្តមរគ្គា ឃុំព្រែកខ្សាច់ ស្រុកកោះកុង (កំពត) ។

៤៨ - សញ្ញាប័ត្រលេខ ២ ចុះថ្ងៃ ២៨-៨-៤៤ តាំងលោកគ្រូពុក-ហោម កើតឆ្នាំរក អាយុ ៣៦ វស្សា ១៦ នាមឆាយា បញ្ញាសីលោ ជាចៅអធិការ វត្តទួនរុង ឃុំស្វាយយាន (គណធម្មយុត្តិ) ស្រុកស្វាយទាប (ស្វាយរៀង) ។

៤៩ - សញ្ញាប័ត្រលេខ ៩៨ ចុះថ្ងៃ ៣១-៨-៤៤ តាំងលោកគ្រូគោគ-ពិន កើតឆ្នាំម្សាញ់ អាយុ ៥២ វស្សា ៣០ នាមឆាយា ធម្មត្តោ ជាចៅអធិការ វត្តទួលសង្ហារ ឃុំញ៉ែ ស្រុកសន្ទុក (កំពង់ធំ) ។

បក្កភាគនៃមិលិន្ទបញ្ហា

ហ្វង់និពន្ធមន្ត្រី រូបរូមប្រែគម្ពីរមិលិន្ទបញ្ហា

(តទេ)

## អង្គ ២ របស់ជាងបាំងៈ

១. តាំងឈើតាមខ្សែបន្ទាត់ ។

២. តាំងយកសាច់សំបកស្រាយចេញទុកតែខ្លឹម ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការគឺៈ

១- ប្រតិបត្តិអនុលោមទៅតាមពាក្យប្រៀនប្រដៅរបស់សម្តេចព្រះជិនស្រីឈរលើផែនដី គឺសីល ចាប់កាន់ពូថៅ គឺបញ្ញា ដោយដៃគឺសទ្ធា ហើយចាំងកិលេសទាំងឡាយឲ្យស្ងួតហួតហែងទៅចាកខន្ធសន្តាន ។

២- លះបង់ចោលមិច្ឆាទិដ្ឋិ ដូចជាសាច់ស្រាយ ដែលមានសស្សតទិដ្ឋិនិង ឧច្ឆេទទិដ្ឋិជាដើមចេញ ហើយយកតែធម៌ដែលមានខ្លឹមសារប៉ុណ្ណោះ ។

## អង្គ ២ របស់ហ៊ឹរម្ងាប់ពិសៈ

១- មិនមានដង្កូវកើតឡើងក្នុងថ្នាំពិស ។

២- រម្ងាប់ពិសបានគ្រប់យ៉ាង ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយគុណសម្បត្តិ ២ ប្រការ គឺៈ

១- មិនបង្កកិលេសដូចជាដង្កូវឲ្យកើតឡើងក្នុងចិត្ត ។

២- កំចាត់រាគៈ ទោសៈ មានៈ ទិដ្ឋិ ដូចជាពិសចោលចេញ ។

## ពួកមានអង្គ ៣

## អង្គ ៣ របស់ផ្កាឈូកៈ

១— ដុះឡើងក្នុងទឹក ធំចំរើនឡើងក្នុងទឹក តែមិនជាប់ទឹកឡើយ ។

២— ដុះផុតអំពីទឹកក៏អណ្តែតនៅលើទឹក ។

៣— ត្រូវខ្យល់បក់តែបន្តិចបន្តួច ក៏រញ្ជួយសន្ធឹកយោកយោកទៅមក ។

ប្រៀបដូចអ្នកប្រតិបត្តិ ប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ

១— មិនជាប់ចិត្តនឹងត្រកូលនឹងពួកគណៈ លាភ យស សរសើរ សុខ ហើយនឹងបច្ច័យជាគ្រឿងបរិភោគទាំងឡាយដកបដល់មិនជាប់ជំពាក់ ដោយកិលេសទាំងអស់ ។

២— គ្របសង្កត់លោកធម៌ទាំងពួងបានហើយ ដុះអណ្តែតនៅក្នុងលោកុត្តរធម៌ ។

៣— តាំងសង្រួមចិត្តមិនឲ្យភ្លាត់ទៅក្នុងកិលេស សូម្បីតែបន្តិចបន្តួចក៏ដោយ មានប្រក្រតីឃើញកិលេសបន្តិចបន្តួចជាសភាពគួរខ្លាចជានិច្ច ។

## អង្គ ៣ របស់សំពៅ :

១— ដឹកជនជាច្រើនឲ្យបានឆ្លងទៅដល់ត្រើយ ។

២— ទម្រាំត្រាំទ្រនឹងកំឡាំងទឹករលកបោកបក់នឹងខ្យល់ទឹកហូរខ្លាំងខ្យល់ទឹកវិលវល់បាន ។

៣— បើកចេញទៅក្នុងមហាសមុទ្រ ដ៏ធំធេងមានជំរៅជ្រៅពន់ទឹក ដ៏ដេរដាសដោយហ្វូងមច្ឆាតូចធំជាច្រើន ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ:

១— បម្រុងជញ្ជូនសត្វក្នុងមនុស្សលោក ព្រមទាំងទេវលោកឲ្យបានឆ្លងដល់ត្រើយ ដោយអំណាចសេចក្ដីព្រមព្រៀងនៃគុណធម៌ទុកដូចជានាវា គឺសីលគុណនិងវត្តប្រតិបត្តិជាដើម ។

២— អត់ទ្រាំតទល់នឹងកំឡាំងកិលេស គឺលោកធម៌ទាំង ៨ ប្រការដែលមានឧបមាដូចរលកទឹក ។

៣— ខ្វល់ខ្វាយកសាងបារមី ដែលជាសេចក្ដីប្រតិបត្តិបង្អោនទៅរកសញ្ញាទាំង ១០ ប្រការ ធ្វើចិត្តឲ្យត្រាច់ទៅក្នុងអរិយសច្ច ៤ មានបរិវដ្ដ ៣ មានអាការ ១២ ។

## អង្គ ៣ របស់នាយសំពៅ:

១— មានស្មារតីល្អមិនភ្លេសប្រហែស ទាំងយប់ទាំងថ្ងៃ ចាំគន់ថែរក្សាត្រួតត្រាសំពៅ ។

២— ផ្លូវដើរទឹកគ្រប់ទិស នាយសំពៅត្រូវតែដឹងសព្វអន្លើក្នុងមហាសមុទ្រនោះ ទុកជាផ្លូវមានគ្រោះថ្នាក់ឬគ្មាន នាយសំពៅក៏ត្រូវដឹងទាំងអស់ ។

៣ — តាំងត្រៃរ័យដោយខ្លួនឯង មិនឲ្យអ្នកដទៃមកប៉ះពាល់ ប្រយ័ត្នសំពៅ មិនឲ្យមានអន្តរាយ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ

១ — ជាអ្នកមិនប្រមាទទាំងយប់ទាំងថ្ងៃជានិច្ច ទប់រក្សាចិត្តដោយយោនិសោមនសិការៈ ។

២ — ចេះដឹងច្បាស់លាស់នូវធម៌ទាំងឡាយ ដែលជាកុសលអកុសល មានទោសឥតទោសដែលគួរសេពមិនគួរសេព អាក្រក់និងល្អ ជាកណ្ហធម៌ និងសុក្កធម៌ ។

៣ — តាំងចិត្តសង្រួមដូចជាត្រៃរ័យទុកក្នុងចិត្ត ហាមចិត្តមិនឲ្យត្រិះរិះទៅក្នុងអកុសលវិតក្ក សូម្បីជាអំពើលាមកបន្តិចបន្តួចក៏ដោយ ។

## អង្គ ៣ របស់ព្រះឥន្ទ្រ:

១ — ពោរពេញទៅដោយសេចក្ដីសុខជាទីបំផុត ។

២ — ជាកំពូលនៃទេវតាទាំងឡាយ ។ តែងលើកសរសើរនាំឲ្យកើតសេចក្ដីសប្បាយរីករាយយ៉ាងក្រៃលែង ។

៣ — មិនដែលកើតចិត្តនឿយណាយក្នុងទិព្វសម្បត្តិ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ:

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ ចេញពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង


*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

| | | |
|---|---|---|
| ឃុនបណ្ណានុរក្ស ប៉ូ-ប៉ូ | ដំរៀបសិល្បសាស្ត្រ | ៥៦១ |
| លោក ហាន់-យេង | រឿងកំពូលកំសត់ (តមក) | ៥៧១ |
| ឃុនខត្តមប្រីជា ឋាប-ពិន | បណ្ដាំ (តមកនិងចប់) | ៥៨២ |

*ផ្នែកសាសនា*

| | | |
|---|---|---|
| លោកគ្រូចៅអធិការ ឯក-ញឹម | ធម្មបទភាសិត | ៥៩៤ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ឯកភាគនៃមិលិន្ទប្បញ្ហា (តមក) | ៦០៦ |
| ពុទ្ធសាសនបណ្ឌិត្យ | អំពីព្រះរាជទានចាំងសមណស័ក្តិ នៅវត្តបទុមវតី | ៦១៣ |

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire: Luong Nibandhamantri NHOK-THÊM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse: Preah kru Paññalikhito KAO-SIM, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

### Partie littéraire:


| | | Pages |
|---|---|---|
| K'ŭn Pannanurak Bou-Po | Dămlăi sălpăsas . . . . . . . . | 561 |
| Monsieur Han-Yêng. . . . | Kămpul kămsăt, roman (suite). . | 570 |
| K'ŭn Ŏtdăm Preichea Chap-Pinn . . . . . . | Băndau (devinettes cambodgiennes) (suite et fin) . . . . . . . . . | 582 |


### Partie religieuse:


| | | |
|---|---|---|
| Vénérable Chau At'ikar Ek-Nhim . . . . . . | T'éammăabăt p'easĕt . . . . . . . | 594 |
| Luong Nîponmontrei Nhok-Thêm . . . . . . . | Ekabhāga-Milindapañhā (suite) . . | 606 |
| Institut Bouddhique . . . | Compte-rendu de la remise solennelle des titres aux nouveaux Reacheakĕană, à Véat Bitămăvĕadei . . . . . . . . | 613 |

## ជំនឿសិល្បសាស្ត្រ

យុទបណ្ណា ទុរក្ស ចូ-ចូ រៀបរៀង

## "ប្រាជ្ញាបុណ្យផង កើតដោយប្រតិបត្តិ"[១]

សេចក្តីចេះដឹងសិល្បសាស្ត្រមន្តវិជ្ជាការគ្រប់យ៉ាង មានចេះអក្សរ និងលេខជាដើម ហៅថាប្រាជ្ញា ។ នេះកើតមានឡើងដោយសារតែបានរៀនសូត្រអំពីសំណាក់គ្រូអាចារ្យ ។

សេចក្តីសុខ, សេចក្តីចំរើន, យសស័ក្តិ, សម្បត្តិទ្រព្យនិងផលប្រយោជន៍ទាំងអស់ក្នុងលោកនេះ ហៅថាបុណ្យ ។ នេះកើតឡើងដោយសារតែមានសេចក្តីព្យាយាមខំរៀនសូត្រ ឬខំធ្វើការរកស៊ី និងបានកាន់ច្បាប់ទម្លាប់ស្តាប់ដំបូន្មានមាតាបិតាគ្រូអាចារ្យ មិនហ៊ានប្រព្រឹត្តកន្លង ។

ការប្រព្រឹត្ត, កាន់, ធ្វើតាម ហៅថាប្រតិបត្តិ ។ មនុស្សដែលបានសម្រេចផលប្រយោជន៍ គឺមានប្រាជ្ញាឬមានបុណ្យស័ក្តិកើតដោយប្រតិបត្តិនោះ ដូចជាមាន :

## រឿងគ្រូពេទ្យជីវកកោមារភច្ច[២]

ក្រុងវេសាលីជាក្រុងស្តុកស្តម្ភធំទូលាយ មានមនុស្សកុះករច្រើនម៉ឺ ដេរដាស មានអាហារចំណីសម្បូណ៌ មានប្រាសាទ ៧.៧០៧ មានផ្ទះកំពូល ៧.៧០៧, មានសួនច្បារ ៧.៧០៧, មានស្រះបោក្ខរណី ៧.៧០៧, មានស្រីផ្កាមាសម្នាក់ឈ្មោះនាងអម្ពបាលី មានរូបល្អគួរ

---

១ ច្បាប់ក្រម ។ ២ វិនយបិដក មហាវគ្គ ចីវរក្ខន្ធក ។

ពិតពិលមើលមើល គួរឲ្យស្រឡាញ់ ត្រូវចិត្តមនុស្សគ្រប់គេ ជាស្រីប្រសប់លេងល្បែងក៏ច្រៀងដេញដំប្រគំ ពួកមនុស្សជាច្រើននាក់តែងនាំគ្នាចូលទៅរកនាងនោះៗ ក្នុង១ យប់យកថ្លៃ ៥០ រៀល ក្រុងវេសាលីក៏បានចំរើនរុងរឿងដោយសារតែនាងអម្ពបាលីនេះឯង ។

គ្រានោះ មានពួកកុដុម្ពីនៅក្រុងរាជគ្រឹះបានទៅឯក្រុងវេសាលីដោយមានកិច្ចណាមួយ បានសង្កេតមើលការរចនាបែបភាពលំអរបស់ក្រុងវេសាលីសព្វគ្រប់ហើយបានទាំងឃើញនាងអម្ពបាលីនោះផង លុះមើលឃើញសព្វគ្រប់ស្រេចហើយក៏ត្រឡប់មកក្រុងរាជគ្រឹះវិញ បានចូលទៅគាល់ព្រះបាទពិម្ពិសារក្រាបបង្គំទូលអំពីការរចនាបែបភាពលំអរបស់ក្រុងវេសាលីទាំងអស់តាមដែលខ្លួនបានឃើញ ហើយក្រាបបង្គំទូលសូមអនុញ្ញាតតាំងស្រីផ្កាមាសម្នាក់ក្នុងក្រុងរាជគ្រឹះផង លុះស្ដេចទ្រង់ត្រាស់អនុញ្ញាតហើយ ពួកកុដុម្ពីក៏បានតាំងនាងកុមារីម្នាក់ឈ្មោះសាលវតី មានរូបល្អគួរឲ្យចង់មើល គួរឲ្យស្រឡាញ់ មានសម្បុរល្អ ត្រូវចិត្តមហាជនគ្រប់គេឲ្យធ្វើជាស្រីផ្កាមាស នាងនេះប្រសប់លេងល្បែងក៏ច្រៀងដេញដំប្រគំ មានប្រុសៗស្រឡាញ់ចូលចិត្តទៅរកនាងជាច្រើន នាងនេះក្នុង ១ យប់យកថ្លៃ ១០០ រៀល ។

នាងសាលវតីធ្វើជាស្រីផ្កាមាសមិនយូរប៉ុន្មានក៏មានគភ៌ ទើបនាងរិះគិតថា ធម្មតាស្រីតែមានគភ៌ហើយ ប្រុសៗមិនសូវពេញចិត្តឡើយ

ប្រសិនបើគេដឹងថាអញមានគតិ មុខជាអញលែងបានប្រាក់មាសហើយ បើដូច្នោះមានតែអញប្រាប់គេថា ខ្លួនអញឈឺ គិតហើយក៏ផ្ដាំនាយទ្វារថា នែនាយទ្វារ អ្នកឯងហាមកុំឲ្យប្រុសណាមួយចូលមករកខ្ញុំឡើយ បើមាននរណាមកសួររកខ្ញុំ ត្រូវអ្នកឯងប្រាប់ថា នាងសាលវតីឈឺទៅហើយ ៗ លុះដល់នាងសាលវតីមានគតិគ្រប់ខែហើយក៏សម្រាលកូនប្រុស ១ មក នាងបង្គាប់ឲ្យខ្ញុំស្រីដាក់ទារកក្នុងចង្អេរចាស់ហើយឲ្យយកទៅដាក់ចោលលើគំនរសម្រាម ជួនជាពេលនោះ ព្រះអភយរាជកុមារចេញទៅគាល់ស្ដេចពីព្រលឹម បានក្រឡេកមើលទៅឃើញទារកនៅលើគំនរសម្រាមមានសត្វក្អែកហោមរោមជុំវិញ ក៏ប្រើមនុស្សឲ្យរើសយកទារកនោះទៅក្នុងវាំងប្រគល់ឲ្យមេដោះចិញ្ចឹមហើយសន្មតឲ្យឈ្មោះថាជីវក ដោយហេតុទារកនោះនៅរស់ ក្រោយមកទៀតឲ្យឈ្មោះថាកោ-មារភត្យ ដោយហេតុទារកនោះអភយរាជកុមាររើសយកមកចិញ្ចឹមរក្សា រួមឈ្មោះទាំងមុខទាំងក្រោយហៅភ្ជាប់គ្នាថាជីវកកោមារភត្យៗ កាលចំរើនធំឡើងបានដឹងក្ដីហើយ ក៏ចូលទៅគាល់អភយរាជកុមារក្រាបទូលសួរថា បពិត្រព្រះសម្មតិទេព ស្រីណាជាមាតារបស់ខ្ញុំប្រុសណាជាបិតារបស់ខ្ញុំ អភយរាជកុមារត្រាស់ប្រាប់ថា ហៃបាជីវកអើយ ទុកជាខ្លួនអញក៏មិនបានស្គាល់ម្ដាយឪពុកបាឯងដែរ ប៉ុន្តែខ្លួនអញទុកដូចជាឪពុកបាឯងចុះ ព្រោះអញរើសយកឯងពីគំនរសម្រាមមកចិញ្ចឹមរក្សា

ជីវកកោមារភច្ចឮដូច្នោះគិតថា ពួករាជត្រកូលនេះតែគ្មានសិល្បសាស្ត្រហើយ មិនងាយនឹងចិញ្ចឹមជីវិតបានស្រួលទេ បើដូច្នោះមានតែអញរៀនសិល្បសាស្ត្រ លុះគិតហើយក៏លបចេញពីសំណាក់អភយរាជកុមារដើរសំដៅទៅឯក្រុងតក្កសិលា បានចូលទៅសុំរៀនក្នុងសំណាក់អាចារ្យទិសាបាមោក្ខ(១) ដ៏ឯកខាងវិជ្ជាពេទ្យ រៀនសិល្បសាស្ត្រនោះបានច្រើនឆាប់រហ័សណាស់ ឥតភ្លេចភ្លាំងទៅវិញឡើយ ។

ជីវកកោមារភច្ចនៅរៀនវិជ្ជាពេទ្យបានចំនួន ៧ ឆ្នាំ ក៏នឹកឆ្ងល់ថា អញរៀនក្បួនពេទ្យនេះចំនួន ៧ ឆ្នាំមកហើយ មិនដឹងជាកាលណានឹងរៀនចប់ឡើយ ទើបចូលទៅដំរាបសួរគ្រូថា បពិត្រលោកអាចារ្យ កាលណាខ្ញុំនឹងរៀនវិជ្ជាពេទ្យនេះចប់ អាចារ្យទិសាបាមោក្ខប្រាប់ថា នែជីវក បើអ្នកឯងសង្ស័យដូច្នោះ ចូរអ្នកកាន់ចបជីកដើរចេញទៅចម្ងាយ ១ យោជន៍ ជុំវិញក្រុងតក្កសិលា ហើយរកមើលស្មៅឬឈើណាដែលធ្វើជាថ្នាំមិនកើត ចូរអ្នកយកស្មៅឬឈើនោះមកបង្ហាញខ្ញុំ ជីវកកោមារភច្ចកាន់ចបជីកដើរទៅតាមបង្គាប់អាចារ្យ ឥតឃើញមានស្មៅឬឈើណាដែលធ្វើជាថ្នាំមិនកើតឡើយ ឃើញសុទ្ធតែធ្វើថ្នាំបានទាំងអស់ឥតសល់ ទើបវិលចូលមកដំរាបអាចារ្យវិញ អាចារ្យប្រាប់ថា នែជីវក វិជ្ជាពេទ្យយើងបានបង្រៀនអ្នកចប់សព្វគ្រប់អស់ហើយ ចំណេះ

---

១ ជាប្រធានក្នុងទិស គឺអាចារ្យដែលចេះដឹងខាងវិជ្ជាពូកែល្បីឈ្មោះទៅគ្រប់ទិស ។

របស់អ្នកឯងប៉ុណ្ណោះព្រមទាំងចិញ្ចឹមជីវិតបានហើយ ចូរអ្នកវិលទៅនៅស្រុកវិញចុះ ថាហើយក៏ឲ្យស្បៀងបន្តិចបន្តួចគ្រាន់នឹងអាស្រ័យតាមផ្លូវ ជីវកកោមារភត្យទទួលយកស្បៀងហើយ សំពះលាអាចារ្យចេញពីនគរតក្កសិលាដើរសំដៅទៅក្រុងរាជគ្រឹះ លុះដើរទៅដល់ពាក់កណ្តាលផ្លូវជិតនឹងដល់ក្រុងសាកេតក៏អស់ស្បៀងរលីង ទើបជីវកកោមារភត្យគិតថា ផ្លូវអស់ទាំងនេះជាផ្លូវដាច់ស្រយាល ក្របាយទឹកចំណីអាហារណាស់ នរណាឥតស្បៀងអាហារដើរទៅផ្លូវនេះមិនរួចទេ បើដូច្នោះមានតែអញស្វែងរកស្បៀងឲ្យបានសិនរួចសឹមទៅ ។

គ្រានោះ ក្នុងក្រុងសាកេត មានភរិយាសេដ្ឋីម្នាក់កើតរោគឈឺក្បាល ៧ ឆ្នាំមកហើយ ពួកគ្រូពេទ្យយ៉ាងធំៗ ច្រើននាក់ នាំគ្នាមកព្យាបាលរោគនោះមិនជា យកតែរង្វាន់អស់ជាច្រើន ជីវកកោមារ-ភត្យបានដឹងដំណឹងនោះហើយក៏ចូលទៅឯលំនៅសេដ្ឋី ប្រើនាយទ្វារឲ្យចូលទៅជំរាបភរិយាសេដ្ឋីៗ សួរថា គ្រូពេទ្យនោះតើក្មេងឬចាស់ នាយទ្វារជំរាបថា បពិត្រអ្នកម្ចាស់ គ្រូពេទ្យនោះនៅក្មេងទេ ភរិយាសេដ្ឋីឆ្លើយថា ហ៊ើយកុំ នាយទ្វារ បើគ្រូពេទ្យនៅក្មេងម៉្លេះធ្វើម្តេចនឹងមើលរោគអញជា ដ្បិតមានគ្រូពេទ្យយ៉ាងធំៗ ច្រើននាក់មកមើលមិនជាទៅហើយ យកតែរង្វាន់អស់ជាច្រើន នាយទ្វារចេញទៅប្រាប់ជីវក-កោមារភត្យវិញតាមពាក្យភរិយាសេដ្ឋីគ្រប់ប្រការ ជីវកកោមារភត្យ

ប្រើនាយទ្វារឲ្យទៅដាក់បម្ពង់ទៀតថា អ្នកម្ចាស់កុំអាលឲ្យវត្ថុអ្វីៗមុនឡើយ ចាំអ្នកម្ចាស់ជារោគពេលណា បើចង់ឲ្យរបស់អ្វី ក៏ឲ្យពេលនោះចុះ នាយទ្វារចូលទៅជំរាបភរិយាសេដ្ឋីៗក៏ព្រមបើកឲ្យចូលទៅ លុះជីវកកោ-មារភច្ច ចូលទៅដល់ហើយក៏សង្កេតមើលអាការរោគបានស្គាល់ច្បាស់ ទើបសុំទឹកដោះគោរអំពីភរិយាសេដ្ឋី ១ ចុកដៃយកមកស្លាយនឹងថ្នាំច្រើនមុខទៀត ឲ្យភរិយាសេដ្ឋីដេកផ្ងារលើគ្រែហើយបញ្ចូលថ្នាំនោះៗ ក៏ខ្ទរចេញពីមាត់មកវិញ ភរិយាសេដ្ឋីខាក់ថ្នាំនោះទៅក្នុងកន្ថោរ ហើយប្រើខ្ញុំស្រីឲ្យយកសំឡីមកផ្តិតយកទឹកដោះគោទុក ជីវកកោមារភច្ចបានឃើញដូច្នោះគិតថា យីអើ អស្ចារ្យអ្វីម្ល៉េះ ស្រីមេផ្ទះនេះកម្រក់ណាស់តើ មិនសមបើហានប្រើខ្ញុំស្រីឲ្យយកសំឡីមកផ្តិតទឹកដោះគោនេះទុកសោះ ឯទឹកដោះនេះសមតែចាក់ចោលទៅវិញទេ ១ ទៀតអញប្រើថ្នាំថ្លៃ ១ អស់ជាច្រើនទៅហើយ ស្រីនេះនឹងឲ្យផ្ទាន់តែបន្តិចបន្តួចដល់អញម្តេចបាន ឯភរិយាសេដ្ឋីស្គាល់អាការទឹកមុខជីវកកោមារភច្ច ប្រែប្លូកដូច្នោះក៏ប្រាប់ថា នែលោកគ្រូពេទ្យ យើងជាស្រីគ្រប់គ្រងផ្ទះ ត្រូវតែចេះសំចៃទឹកដោះគោនេះទុក ដ្បិតទឹកដោះគោនេះនឹងធ្វើជាថ្នាំលាបជើងពួកទាសកម្មករក៏បាន នឹងចាក់ចង្កៀងអុជក៏បាន លោកកុំតូចចិត្តឡើយ ផ្ទាន់របស់លោកមុខជាមិនខូចខាតទេ ជីវកកោមារភច្ចបញ្ចូលថ្នាំភរិយាសេដ្ឋីតែម្តងប៉ុណ្ណោះ ក៏ស្រះជារោគឈឺក្បាលស្រឡះភ្លាម ទើបភរិយាសេដ្ឋីឲ្យផ្ទាន់

៤ ពាន់រៀល កូនប្រុសនឹងកូនប្រសាស្រីបានដឹងថាម្ដាយខ្លួនជាជម្ងឺហើយ ក៏ឲ្យរង្វាន់ ៤ ពាន់រៀលម្នាក់ៗទៀត ឯសេដ្ឋីជាស្វាមីក៏បានឲ្យប្រាក់រង្វាន់ ៤ ពាន់រៀលផងឲ្យខ្ញុំប្រុសខ្ញុំស្រីនឹងរថទឹមសេះថែមទៀតផង រួមទឹប ប្រាក់ទាំងអស់បាន ១៦ ពាន់រៀល ជីវកកោមារភច្ចទទួលយករង្វាន់ទាំងអស់នោះចេញទៅឯក្រុងរាជគ្រឹះ លុះទៅដល់ក្រុងរាជគ្រឹះហើយបានចូលទៅគាល់អភយរាជកុមារក្រាបទូលថា សូមទ្រង់មេត្តាប្រោស រង្វាន់ទាំងអស់នេះហើយដែលជាស្នាដៃដំបូងរបស់ទូលបង្គំជាខ្ញុំ សូមព្រះសម្មតិទេពទ្រង់ទទួលយកថ្លៃសម្រាប់ចិញ្ចឹមទូលបង្គំជាខ្ញុំចុះ អភយរាជកុមារឆ្លើយថា នែនាយជីវក ណ្ហើយកុំ របស់ទាំងនេះស្រេចនឹងអ្នកឯងចុះ ប៉ុន្តែត្រូវអ្នកឯងសង់ផ្ទះនៅក្នុងវាំងយើង ជីវកកោមារភច្ចក៏ព្រមធ្វើតាមព្រះបន្ទូល ។

កាលជាចំណោរមក ព្រះបាទពិម្ពិសារទ្រង់កើតព្រះរោគឫសដូងបាតបានត្រាស់ហៅជីវកកោមារភច្ចឲ្យមកព្យាបាលព្រះរោគនោះ ជីវកកោមារភច្ចបានយកថ្នាំចំនួនមួយក្រចកដាក់លាបផ្សះព្រះរោគឫសដូងបាតនោះតែម្ដងប៉ុណ្ណោះ ព្រះរោគក៏សះជាដាច់ស្រឡះ ទើបព្រះបាទពិម្ពិសារទ្រង់ត្រាស់បង្គាប់ឲ្យស្រីៗ ប្រាំរយនាក់ស្អិតស្អាងគ្រឿងអលង្ការគ្រប់ប្រដាប់ហើយឲ្យដោះចេញគរជាគំនររួចទ្រង់ព្រះរាជទានគ្រឿងអលង្ការ ១ គំនរព្រមទាំងស្រីប្រាំរយនាក់នោះផងឲ្យជីវកកោមារភច្ច ។

ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស កុំព្រួយព្រះរាជហឫទ័យឡើយ សូមព្រះសម្មតិទេព គ្រាន់តែទ្រង់រឭកឧបការរបស់ខ្ញុំព្រះអង្គចុះ ព្រះបាទពិម្ពិសារទ្រង់ត្រាស់ថា បើដូច្នោះ ចូរអ្នកឯងបម្រើយើងផង បម្រើស្រីស្នំផង បម្រើភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានផង ជីវកកោមារភត្យក៏ទទួលបម្រើតាមព្រះរាជឱង្ការ ។

ក្រោយពីនោះមកទៀត មានសេដ្ឋីម្នាក់នៅក្រុងរាជគ្រឹះកើតរោគឈឺក្បាល ៧ ឆ្នាំមកហើយ ពួកគ្រូពេទ្យធំៗមើលពុំជា យកតែរង្វាន់អស់ជាច្រើនហើយរត់បោលលែងមើលទៅ មានពួកគ្រូពេទ្យខ្លះទាយថា នៅតែ ៥ ថ្ងៃទៀតសេដ្ឋីមុខជានឹងស្លាប់ មានពួកគ្រូពេទ្យខ្លះទាយថា នៅតែ ៧ ថ្ងៃទៀតសេដ្ឋីមុខជានឹងស្លាប់ វេលានោះមានពួកកុដុម្ពីបានចូលទៅគាល់ព្រះបាទពិម្ពិសារសូមព្រះរាជានុញ្ញាតឲ្យជីវកកោមារភត្យទៅព្យាបាលរោគសេដ្ឋីនោះ ឯជីវកកោមារភត្យកាលបានទទួលព្រះរាជានុញ្ញាតហើយក៏ចូលទៅឯលំនៅសេដ្ឋី លុះទៅដល់ហើយបានពិនិត្យមើលអាការរោគក្នុងខ្លួនសេដ្ឋីក៏ដឹងជាក់ច្បាស់ ទើបសួរសេដ្ឋីថា នែគហបតី ប្រសិនបើខ្ញុំមើលជម្ងឺលោកជា តើលោកនឹងឲ្យអ្វីខ្ញុំ សេដ្ឋីឆ្លើយថា លោកគ្រូពេទ្យ ខ្ញុំជូនសម្បត្តិទ្រព្យរបស់ខ្ញុំទៅលោកទាំងអស់ ទាំងខ្លួនខ្ញុំសោតក៏ទៅនៅបម្រើធ្វើជាខ្ញុំលោកទៀត ជីវកកោមារភត្យសួរថា បើដូច្នោះលោកសម្រាន្តផ្ទៀងតែម្ខាងចំនួន ៧ ខែបានឬទេ ? បាទលោកខ្ញុំ

ដេកបាន ។ ចុះលោកសម្រាន្តផ្ទៀងម្ខាងទៀតចំនួន ៧ ខែបានឬទេ ? បាទ លោកខ្ញុំដេកបាន ចុះលោកសម្រាន្តផ្កាប់ចំនួន ៧ ខែបានឬទេ ? បាទ លោកខ្ញុំដេកបាន ជីវកកោមារភច្ចឲ្យសេដ្ឋីដេកលើគ្រែចងសេដ្ឋីភ្ជាប់នឹងគ្រែហើយ ក៏វះក្បាលវែកលលាដ៍ចេញឆ្កឹះយកសត្វមេរោគល្អិតៗ បានពីរចាប់បង្ហាញឲ្យគេមើលប្រាប់ថា ហ៏អ្នកកល់គ្នាមើលចុះសត្វទាំងពីរនេះអា ១ តូចអា ១ ធំ ពួកគ្រូពេទ្យដែលហ៊ានទាយថា នៅតែ ៥ ថ្ងៃទៀតសេដ្ឋីមុខជានឹងស្លាប់នោះ ព្រោះគេបានឃើញសត្វមេរោគធំនេះ តែដល់ថ្ងៃគំរប់ ៥ វានឹងជញ្ជក់ស៊ីខួរក្បាលសេដ្ឋីអស់ បានជាសេដ្ឋីស្លាប់ គេទាយដូច្នេះត្រូវហើយមិនខុសទេ ចំណែកពួកគ្រូពេទ្យខ្លះដែលហ៊ានទាយថា នៅតែ ៧ ថ្ងៃទៀតសេដ្ឋីមុខជានឹងស្លាប់នោះ ព្រោះគេបានឃើញសត្វមេរោគតូចនេះ តែដល់ថ្ងៃគំរប់ ៧ វានឹងជញ្ជក់ស៊ីខួរក្បាលសេដ្ឋីអស់ បានជាសេដ្ឋីស្លាប់ គេទាយដូច្នេះត្រូវហើយមិនខុសទេ ប្រាប់ហើយក៏បិទមុខរបួសរួចដេរថ្មេរក្បាលគេទៅវិញលាបថ្នាំឲ្យ លុះសេដ្ឋីដេកផ្ទៀងតែម្ខាងបាន ៧ ថ្ងៃក៏និយាយនឹងជីវកកោមារភច្ចថា លោកគ្រូពេទ្យ ខ្ញុំដេកផ្ទៀងតែម្ខាងចំនួន ៧ ខែមិនបានទេ គ្រូពេទ្យសួរថា ក្រែងលោកបានសន្យានឹងខ្ញុំថា សម្រាន្តបាន ៧ ខែមែនទេ ? បាទខ្ញុំបានសន្យាដូច្នោះមែនហើយ តែថាបើលោកបង្ខំឲ្យខ្ញុំដេកផ្ទៀងតែម្ខាង ៧ ខែ ខ្ញុំមុខជាស្លាប់មិនខានទេ ។

(មានត)

# កំពូលកំសត់

## លោកហាន់-យ៉េង រៀបរៀង

(តទៅ)

ថ្ងៃនិទ្ទុក្ខចរហើយ នាយឧតហាក់ដូចជាបានធូរទ្រូងជាងមុនបន្តិច ហាលភ្នែកតាមមើលពពកទៅ នៅអង្គុយហាលខ្យល់អស់ពេលយូរ បានចូលកាន់ដំណេក ។

មានយប់មួយ ព្រះចន្ទរះត្រចះត្រចង់កណ្ដាលតារាករបំភ្លឺផ្ទៃលោកឲ្យរីករាយសប្បាយ នាងម៉ាសនិងនាយឧតបាននាំគ្នាចុះទៅជិះទូកលេង នាវាតូចលយកាត់ទឹកភ្លឺផ្លេក ៗ រ៉េច ៗ ហាក់ដូចជាមានមច្ឆាពណ៌ប្រាក់ហែលហៃលលេងជាមួយ សត្វលេខគគ្រាំគគ្រេងខ្ទិចព្រោងលាន់ឮ ៗ កុមារកុមារីមានចិត្តត្រេកអរសោទរជនគ្នា ទំនងមួយជាតិស្រឡះយ៉ាងត្រចះនាពេលនោះ នៅស្ងៀមទាំងអស់គ្នាមិនមានសាសន៍ថាអ្វី បន្តិចស្រាប់តែព្យុះខ្យល់យ៉ាងធំលាន់ឮឡើង ពពកលោខ្មៅបក្សូរឲ្យស្រណោះកូនកគ្រែស្ងាត់ អណ្ដែតតាមខ្យល់សោកបាត់ទៅឆ្ងាយទៅ នាំឲ្យនាយឧតកើតសង្ស័យក្នុងចិត្ត ទឹករលកដល់នាងសាលីដល់មាត់កំសត់របស់ខ្លួនម៉ើបុប្ផាព្រាប់ចុះ យកដៃទាំងពីរខ្ទប់មុខខ្សឹកខ្សួលយ៉ាងខ្លាំង នាងម៉ាសកើតស្រឡាំងកាំងក័ន្តភាំងស្មារតី ទឹកកិរិយាចំឡែកនៃបងរបស់នាងទើបនាងស្ទុះមកលួងលោមថា: "បងអើយ! បងយំកើតទុក្ខព្រួយចិត្តព្រោះហេតុអី បងស្រដីឲ្យប្អូនបានដឹងផង ប្អូនមាននរណាធ្វើឲ្យធ្លាំនឹង

ឲ្យតន្ទូលចិត្តបងទេដឹង ឬមួយខ្លួនខ្ញុំនេះ បានប្រព្រឹត្តអំពើអ្វី ឲ្យជ្រុល លើបងឬដូចម្តេច ! សូមបងប្រាប់ឲ្យប្អូនបានដឹងផង" ។

នាយខតឮសូរសំឡេងញ៉ែៗ របស់នាងម៉ាសជាប្អូនហើយ ក៏សន្សឹមងើបមុខឡើង មុខក្រៀមក្រំស្លុតស្រពោនជោកទៅដោយទឹកភ្នែក ដែលស្រក់ចុះទៅជាដំណក់ៗថ្លាដូចត្បូងពេជ្រដោយអំណាចស្នេ ព្រះចន្ទ្រ តែនាយខតនៅស្ងៀម គ្រវីក្បាលជាទំនងថា ទុក្ខរបស់ខ្លួនធ្ងន់ដូចភ្នំនឹងប្រាប់ផងពុំបាន តែនាងចេះតែលួចសួរផ្ទួនៗ យកក្រមាជូតក្បាលជូតទឹកភ្នែកយ៉ាងថ្នមឲ្យបងរបស់នាងពេញចិត្ត ទំនងសេចក្តីយល់ចិត្តយល់ថ្លើមរបស់ប្អូន នាយខតក៏ឆ្លើយថា "ឱប្អូនអើយ! អ្នកធ្ងន់តាំងពីប៉ុន្មានព្រមតាំងរូបប្អូននេះ គ្មានធ្វើអ្វីឲ្យសៅហ្មងដល់ចិត្តផងបងនោះទេ តាំងពីបងបានមកជួតកោនក្នុងត្រកូលប្អូននេះ បងបានសេចក្តីសុខគ្រប់ប្រការ ឥតមានប្រាថ្នាចង់បានអ្វីទៀតទេ តែពេលនេះ ឱប្អូនអើយបងនឹកប្រារព្ធដល់ម្តាយរបស់បង ដែលប្រាសឆ្ងាយពីបងទៅចំនួន ៣ ឆ្នាំមកហើយ ខ្លួនបងតែងតែជាទុក្ខព្រួយមិនដែលខាតខានពេលណាឡើយ ហើយពីយប់មុននោះបងបានដំណឹងមកថាម្តាយរបស់បងមានជម្ងឺឈឺជាទម្ងន់ ហើយអ្នកចង់ឃើញមុខបងពន់ពេកណាស់ ពុំដឹងជាបានសះស្បើយទៅហើយឬយ៉ាងណាទេ ហើយបងនៅសប្បាយក្លើតក្លើនតែ

ម្នាក់ឯងដូច្នេះជាការមិនគួរសោះ បានជាបងយំខ្សឹកខ្សួលដូច្នេះ មើលទៅបងចង់សុំលាប្អូនទៅរកមាតាហើយ ... ។

“ទៅរកមាតា” នាងម៉ាសផ្ទួនពាក្យឡើង ។

នាយឧតក៏ងក់ក្បាលទទួល ។

“បើដូច្នោះ បងមិនបោលប្អូនឲ្យនៅតែឯងហើយ! ។

“ប្អូនកុំកើតទុក្ខព្វើអ្វី ការនិរាសចាកគ្នាជាច្បាប់សម្រាប់ផងទូទៅ មិនស៊ាំគាល់ថា ឈ្មោះណាជាឈ្មោះណាទេ ខ្ញុំបងពុំមានបំណងនឹងឃ្លាតឆ្ងាយពីប្អូនឡើយ តែថាពេលនេះជាកម្មផលបងគង់តែចាកទៅទៅទាំងទុក្ខម្នោម្នេញ ដើម្បីនឹងបានជួបមុខអ្នកមេជាទីស្រឡាញ់ ប្អូន! បងមិនភ្លេចគុណប្អូនទេ ប្អូននៅជាសប្បាយចុះ មើលបំរើមាតាបិតារបស់ប្អូន បើសំណាងយើងមានគត់តែនឹងបានឃើញគ្នាមិនលែងទេ ព្រោះផែនដីនេះនោនសណ្ឋានមូល គង់តែនឹងជួបគ្នា បើមិនត្រង់ណេះក៏ត្រង់ណោះ” ។ នាងម៉ាសកាលបើឮពាក្យសំដីដូច្នោះ ក៏ណែនណាន់តាន់ចង់និយាយពុំកើត ដូចជាមានសភាវៈអ្វីមកបិទបំពង់កជិត មិនដឹងជានឹងគិតយ៉ាងណា ក៏បោកខ្លួនលើស្មានាយឧតយំសោកជាច្រើន កំឡោះឃើញដូច្នោះក៏ភ្ញាក់ខ្លួនព្រឺត ទើបញញឹមដល់ខ្សែដែលបំណងនឹងចងជើងរបស់គេឲ្យជាប់នឹងដីត្រាំងចំពេះ តែមានចិត្តល្អបរិសុទ្ធណាស់ ទើបយកដៃអង្អែលក្បាលប្អូនលួងលោមឲ្យស្ងប់ស្ងាត់អារម្មណ៍ នាងម៉ាស

ក៏សម្លឹមៗបាត់យំដើបមុខឡើងមើលមុខបង ហើយញញឹមយ៉ាងផ្អែមល្ហែមត្រជាក់ចិត្ត រួចប្រាសក្បាលទៅវិញ ដាក់ថ្ពាល់សស្អាតផ្តេកទៅលើទ្រូងនាយឌុត យកដៃស្តាំអង្អែលស្មាហើយមានវាចាថា " បងអើយ! សូមសន្យានឹងប្អូនថា កុំចោលប្អូនណាបងណា !! ។

នាយឌុតអឹមអៀមនៅស្ងៀមមិនឆ្លើយ ព្រោះពុំច្បាស់តើនាងប្រាថ្នាយ៉ាងណាលើរូបខ្លួន នាងម៉ាស ក៏ក្រោកឡើងចាប់ដៃនាយឌុតទាំងពីរជាប់ហើយ ចោលភ្នែកឲ្យចំភ្នែកបងកំឡោះសោកស្ងួរឡើងទៀតថា "ម៉េចបង និយាយឲ្យប្អូនច្បាស់គន់ចិត្តផង?

នាយឌុតពុំដឹងកែប្រែបែបណា ក៏អេះអុះថា "បង....បង ..." ។ ព្រោះល្អណាស់ពេលនោះ មានសំឡេងចាស់ៗ ស្រែកហៅមកថា "អឺយ!ចៅឌុត! នាំគ្នានិយាយលេងដល់ណាទៀត យប់ជ្រៅណាស់ហើយ អ្នកទាំងពីរភ្ញាក់ព្រើតដកដៃពីគ្នាចេញ នាយឌុតអរលើសលប់យកដៃទាញច្រវ៉ាប្រញាប់វិលមកផ្ទះវិញ ឲ្យផុតពីសេចក្តីស្ងួររបស់នាងម៉ាស ។

យប់នោះឯងនាយឌុតដេកមិនលក់សោះ សេចក្តីនឹករត់ទៅរកមាតាក៏ឧប្បត្តិឡើងក្នុងខួរក្បាលរបស់គេ ទើបគិតគ្នាន់គ្នេររៀបសំពត់អាវស្រេចលបស្តាប់មើលក្រែងភាគអ្នកផ្ទះ គេដេកស្ងប់ស្ងាត់ហើយឬនៅក៏ឮស្នូរតែសំឡេងគុកកែងឹងចបកងរំពង នឹងសព្ទស្នូរស្រមុក ទើបនាយឌុត

ទាញយកក្រដាសទៅដៃ សរសេរសុំត្រចុកពោលទឹងដំណេកខ្លួន ដើម្បីទីងឲ្យអ្នកផ្ទះនោះដឹងដើមហេតុ រួចហើយក៏ម្ម៉ាចុះចេញពីផ្ទះទៅ ដើរយ៉ាងថ្នមជើង ចេញផុតភូមិកាលណា ក៏ទំរត់តែម្ដងនាំឲ្យឆ្កែផ្អើល ព្រុសលាន់ ទើបនាយឧតឈប់ងាកមើលក្រោយខ្លាចក្រែងគេតាមទាន់ ដើររត់ទៅទៀតបោះជើងយ៉ាងវែងៗ ។

## បទទី ១២

# វិទ្យាល័យ ស៊ីសុវត្ថិ

លុះដល់ម៉ោង៨គត់ ស្គរសាលាក៏លាន់ឮខ្ទរៗឡើង ក៏ជាហេតុញ៉ាំងចិត្តអ្នករៀនឲ្យរីករាយគ្រប់គ្នា កាលបើពួកសិស្សជាន់មធ្យមចុះមកដល់ថ្នាក់ក្រោម ស្រាប់តែព្រះពិរុណហែកមេឃធ្លាក់ចុះមកលើប្រឹប ពិលាខធំៗ គ្រាប់ភ្លៀងធំៗ ផ្ទះលើស្លឹកឈើទៀតស្រឹត ដែលរលាស់ឲ្យធ្លាក់ចេញជាលំអងទៅក្រោម មានជាទឹកហូរបន្តគ្នាពីជាយដំបូលមកធ្លាក់ដល់ព្រះធរណីរលាយប៉ឺឲ្យរលាយដូចជាស្ករ រួចផ្គុំគ្នាជាខ្សែទឹកហូរទៅឆ្ងាយ កាលបើត្រូវទឹកធ្លាក់ពីលើមក ក៏ឮស្នូរផ្ទុកផ្ទាក់ៗ ដដែលៗ ឲ្យស្រងេះស្រងោច អ្នកទាំងអស់គ្នាក៏លាន់មាត់ឡើងដោយសេចក្ដីធ្លាក់ចិត្ត ព្រោះផ្សិតត្រូវឈរចាំអស់ពេលយូរ ហើយពោះក៏ឃ្លានផង ខ្លះអត់ទ្រាំពុំបានក៏ដោះអាវដាក់ក្នុងក្រប៉ូច ហើយជះគន់ជំរង់ទៅរកអាហារ ដែលត្រៀមចាំឯផ្ទះ ដែលសាយក្លិនមកដល់ទប់ទល់ពុំបាន ។

លើចិញ្ចើមផ្លូវ កុមារីបាក់នំម្នាក់ដើរមួយៗ ត្រង់ភ្លឹង ឡើងមុខព្រងើយមិនរវល់ទីងក្រៀងសាបមកត្រូវ នាងមួយទៀតពាក់អាវក្រៀងពណ៌ខ្មៅរត់គាត់រាលសាលាចុះឡើង រលាស់សក់ក្បាលទៅក្រោយព្រមដោយលំអគ្គូឲ្យគន់ មានដំណក់ទឹកស្រក់តក់ៗ មកពីលើមុខសស្អាត ៗ នៅក្នុងខាងលិចពួកសិស្សនៅក្នុងសាលា នាំគ្នាអួអាលេងបាល់ដាសប្សាយនៅក្រោមកន្ទេងផែក អ្នកឯទៀតៗ នាំគ្នាប្រជុំនិយាយពីនេះពីនោះគ្រាន់កំសាន្តចិត្ត ៗ

នៅមុខថ្នាក់រៀនជាន់ក្រោម រ៉ែកកុខាងត្បូង ពួកកុមារ ៦ នាក់ឈរនិយាយគ្នាលេង នាងមួយខ្ពស់ចង្រ្គាងខ្នងកោងបន្តិច ឈ្មោះនាងសមមណី មានសំលេងស្រួយស្រស់ដូចផ្ការដើមទឹក មួយទៀតគឺនាងវិលឡា កន្ទាបមុខមូលភ្នែកស្អាប់សំលេងញ៉ាវៗសើតមិនត្អ ឯនាងសារុត មុខជ្រងស្គមតូចស្តើងហើសខាងក្នាក់រស័យដូចសត្វក់ប្រកគមកដល់គូរមេខ្ញុំរមេស្រុខពីរនាក់ មួយនោះ មានរូបកងជាត់កន្ត្រៀមុខធំថ្ពាល់ត្រយល់ ម៉ាត់មានរន្ធះវែង ភ្នែកតូចពព្រឹមលើបបាក់ទៅ កាលមើនាងសើច នាងនេះហាក់ដូចជារូបតុក្កតាបេះដើរដូចខ្លោះឯង នាងមានឈ្មោះថាមាក់ខ្សែវ តែអ្នកផងហៅថា "អ្នកស្រីប៉េងហុង" ចំណែកគូរមេត្រីរបស់នាងនោះ កង់តូចទន់ក្លុំដូចដើមត្រែង មុខមាត់ប្រិមប្រិយ៍មូលក្រឡង់ល្អគ្មានខ្ចាស់ត្រង់ណា នាងញញឹមឡើងកាលណាក៏ក្រៀ

ផ្ទៃដ៏បំព្រងឡើងដូចរស្មីនៃវ័យក្មេង នារីនេះឈ្មោះផលា តែគេតែង ហៅថា "ផ្កាយព្រឹក" ដោយនាងជាសេចក្ដីសប្បាយនៃប្ដីរបស់នាង ក្រោយបំផុតបានដល់មកនាងបុប្ផាសួគ៌ ជាកុមារីគប្បីលក្ខណា កិរិយា ស្រគត់ស្រគំ មាត់ក្រហមភ្នែកធំក្រឡេតចិញ្ចើមស្ដើងទាស់ទីងដំណើរ ដើរទ្រន់ដូចហង្សបក្សិន ។

នៅជិតនោះ មានកុមារពីរនាក់កំពុងដៃគ្នាលេង កុមារម្នាក់មុខ ស្រពោនពុំសូវស្ដីនិយាយ យកដៃផ្អកលើភ្នាក់បង្អួចចាំស្ដាប់ នាយលុន-ហាក់អធិប្បាយសេចក្ដី កុមារទីពីរនោះមាឌធ្លាមធំ ថ្ពុះស្រួច ភ្នែកធំ សក់ញ៉េកចំពាក់កណ្ដាលក្បាល កំពុងតែនិយាយបញ្ចប់ផ្ដាត់មេដៃជ្រុំផង រួចសើចកងឡើងបញ្ចេញធ្មេញឈរប្រាង ដែលបបូរមាត់ក្រាស់បិទមិន ជិត ហើយក៏បង្អិលខ្លួនដូចព្រាបលើផ្សូលផ្ទះ តែអ្នកទាំងពីរនោះ ច្រើន អាក់សេចក្ដីសន្ទនាដោយសំណើចយ៉ាងខ្លាំងនៃកុមារទាំង ២ នាក់ លុន-ហាក់ក៏បាត់មាត់ស្ងៀម ត្រចៀករបស់គេក៏មិនភ្នែកឲ្យនិយាយតទៅទៀត រួច ខ្ទងឯងលាន់សំដីឡើងថា "លុន - ហាក់ឯងកុំហាមាត់សើចខ្លាំងពេក លេចកូនធ្មេញហើយ កូនធ្មេញអីល្អម៉្លេះហ្ន៎ ! ។

គ្រាវេលានោះ បុប្ផាសួគ៌ទប់ទឹកភ្នែកសើចផ្អើមុខក្រញូវ ចង ចិញ្ចើមកេគ្នា បាញ់ភ្នែកសំឡក់មកសើរឆេងផ្លាក់សាប ។

"ឥណេះខ្ញុំស្បើយហើយ គុណព្រះជួយ" បុរសដដែលពោលឡើង ដោយយកដៃបាំងមុខ "នេះបានចំជាអគ្គិទេក្រ កុំថាឡើយត្រឹមថ្មដែក សូម្បីតែភ្នំព្រះសុមេរុក៏រលាយដែរ" ។

នៅពេលនោះ បុប្ផាស្មគ្រអត់ពុំបានក៏ប៉ាត់ញាក់ដងរង់មក ព្រម ដោយកុមារីឯទៀត ១ ផង មុខនាងឡើងក្រហមនេះដូចបន្តង់ដុត នាំឲ្យ លុន-ហាក់រត់ឲ្យរួចខ្លួនបាត់ទៅ នៅសល់តែកុមារម្នាក់ស្រពោននោះឯង នៅកណ្ដាលចំណោមកុមារីទាំង ៦ នាក់ បុប្ផាស្មគ្រសួរឡើងថា "បង ទំយាយឲ្យអ្នកណាអម្បាញ់មិញនេះ ជាសេបចេញកូនធ្មេញ?

"បាទ ខ្ញុំថាឲ្យលុន-ហាក់ ដំកបប្រសាសន៍អ្នក តើមានប៉ះពាល់ ដល់រូបអ្នកដែរឬអ្វី?

"ប៉ះប៉ះដែរ ព្រោះខ្ញុំមិនមែនកូនគ្រូចៅដៃគាលណា ចាំបងថា យ៉ាងនេះអី បងដឹងថាខ្ញុំអកុសលមានធ្មេញកូបដុះជើងធ្មេញដែរ មេត្តាក៏ ចិត្តអាក្រក់បន្ទុះបង្អាប់ដូច្នេះ?

"ឱ ! អ្នកមានកូនធ្មេញឬអ្វី? ខ្ញុំមិនដឹងសោះ ។

"ចាំតើអី"

"មិនតើទេ ដំកបប្រសាសន៍ ខ្ញុំបាទមិនដឹងពិតណា តែតាមសំ-ឡេក គេថានាងណាមានកូនធ្មេញនោះប្រសើរណាស់ ទីងបានជា លោកជំទាវមិនខានទេ រូបអ្នកនេះទីងមានសំណាងមិនខាន ។

នារីទាំង ៥ នាក់ក៏សើចគិលឡើង ធ្វើឲ្យទោសៈនាងបុប្ផាសួគ៌ ប្រឡោតខ្លាំងឡើង នាំចប្លូរទាត់ជាលឈាមធ្វើភ្នែកម៉ក់ៗ សមពេលនោះ ខ្ទុះអស្សុទិបាញ់ផាំងមក កុមារបោនមាត់ថា "នេះហ្មានចំផារខ្ទុះទាំង ប៉ោពីរជាន់ ក្អកអស់ហើយប្រែព្រឹក្សា ខ្ញុំស្ទើរតាំងស្មារតីបាត់ព្រលឹង ព្រលះអស់ ចុះឆ្អកខាងណោះមិនភ័យទេឬអ្វី ហើងយ៉ាងនេះ?"

បុប្ផាសួគ៌ឮពាក្យចំអកដល់ខ្លួនដូច្នោះ ក៏ខឹងណាស់ស្រក់ទឹកភ្នែក កន្ត្រំជើង មាត់រអ៊ូរដើរចេញពីនោះទៅ ព្រមទាំងនាង ៣ នាក់ទៀត នៅសល់តែផ្កាយព្រឹកខឹងឆ្អកប៉េង ហុង ផ្កាយព្រឹកលាន់មាត់ថា : "ម្តេចក៏គ្រាប់ភ្លៀងអ៊ីម៉្លេះហ្ន៎! ហៅសែនរំខានអស់យ៉ាងហើយ ចុះ បងគិតដូចខ្ញុំដែរឬអ្វី មិនអាណិតគេឬ មេឃខ្សោយយ៉ាងនេះ? មួយវិញ ទៀតឃ្លានបាយទេ ថ្ងៃល្ងាចណាស់ទៅហើយ?

"ទេ ! ខ្លួនខ្ញុំនេះឃាក់ដូចជាឮគេរត់ដែរ មិនមែនឃ្លានបាយ ឃ្លានទឹកទេ គ្រាន់តែហ៊ាតអាហារមើរព្យុះនោះក៏ធ្លូតទៅហើយ បើបាន តែបួននៅជាមួយផងនោះ ទុកជាភ្លៀងដល់យប់ក៏ពុំឃ្លានដែរ ។

ខ្យល់រំភើយៗ បក់បូលមកប៉ះសក់ផ្កាយព្រឹកដែលលលកទៅ ក្រោយមុខនាងក៏ឡើងពណ៌ស៊ីជម្ពូយ៉ាងស្រស់ ដល់បានឮសំដីប៉ុស្សថា ដូច្នោះនាងនឹកអៀនខ្មាសមុខចុះ ម៉ាក់ឡេក៏យកគួយដៃគោះក្អកបបស់

នាងផ្កាយព្រឹកបែរទៅរក "ម៉ែឪដឹងថាទឹងគោះអ៊ីចឹង ហៅជិនអស់យ៉ាង ហើយ" ។

រួចក៏នាំគ្នាសើចឡើង ផ្កាយព្រឹកនិយាយទៀតថា "ហៅស្កាយអស់យ៉ាងហើយ បុប្ផាសួគ៌ទៅបាត់ បានអ្នកណាគ្រាន់តែអជ្រុតពេះ មើលចុះមុខគាន់តែស្រពោនទៅហើយ ។ ទុក្ខោអើយ! គួរអាណិតណាស់ហ្ន៎!

រួចក៏ហោលកន្ទុយភ្នែកមើលបុរសនោះ កុមារីទាំងពីរនាក់ញញឹមរកគ្នារួច ក៏នាំគ្នាដើរចេញទៅបាត់ទៅ ទុកឲ្យអ្នកនោះនៅតែម្នាក់ឯង ។

ភ្លៀងក៏នៅតែធ្លាក់ខ្លាំង ៗ មកនៅឡើយ អាកាសក៏ងងឹតចុះ ព្រោះចូលសន្ធ្យាកាលទៅហើយ ត្រូវខ្យល់ត្រជាក់បក់មក ត្រូវកុមារៈនោះ នាំឲ្យទឹកឃ្លានបាយគាន់តែខ្លាំង ទើបគាត់ចិត្តចេញពីសាលា ដើរហាលភ្លៀងរងាញាក់ត្រខ ៗ ដល់ផ្លូវហើយក៏ឡើងជិះត្រីចក្រយានដម្រង់ទៅផ្ទះអាត្មា កាលបើដល់កន្លែងហើយ ក៏តាំងចាប់ផ្តើមបរិភោគអាហារ រួចដើរចុះឡើងចំនួនកន្លះម៉ោង ទើបទាញកៅអីអង្គុយនៅមុខតុ ទាញដងប៉ាកកានិងក្រដាសមក អង្គុយផ្ចង់គំនិតមួយស្របក់ ទើបសរសេរសេចក្តីដូចមានខាងក្រោមនេះ

ភ្នំពេញថ្ងៃ ១៥ អុកតូប្រ៍ ១៩៣៧

# មកដល់សាលីប្អូនសំឡាញ់!

ប្អូនអើយភ្លៀងទើបនឹងដាច់គ្រាប់ មេឃក៏ស្រឡះប្រាសចាកមន្ទិល ព្រះចន្ទ្រះចាំងភ្លឺព្រោងព្រាតរស្មីលើផ្ទៃទឹកទន្លេ ធ្វើឲ្យបងស្រណោះនឹកដល់ពេលដែលយើងអង្គុយលេងនៅមាត់ទឹក ទើបបងភ្ញាក់ខ្លួនព្រឺតចាំបាច់ជា ខានផ្ញើសំបុត្រឲ្យដំណឹងមកសាលីប្អូនរបស់បងជាយូរណាស់មកហើយ សមជាប្អូនទន្ទឹងសង្ឃឹមណាស់ ហើយមើលទៅ យប់នេះបងមានពេលទំនេរច្រើន បងបានចាប់ផ្តើមពាក្យ ដោយសេចក្តីត្រេកអរសរសេរក្រោមពន្លឺព្រះចន្ទ្រ ។

កាលបងផុតពីកណ្តាប់ដៃនារីបាម បងបានមកសំណាក់ផ្ទះម្តាយមីង ហើយគាត់បានបញ្ចើមបងឲ្យរៀនសូត្រតទៅទៀតឯសាលាឈ្នួល ថ្ងៃមួយ បង ចាប់លើចំពៀមផ្ទះ “កេតិកេត៌” ស្រាប់តែឃើញស្ត្រីកណ្តាលអាយុចេញពីផ្ទះគាត់ខោអាវខក ព្រួសស្ទុះមកឱបបងតែម្តង បងភ្ញាក់ព្រើតងាកមើលទៅ ស្រាប់តែដឹងថាជាអ្នកម្តាយរបស់បង ឱប្អូនអើយ! រកអ្វីឲ្យសប្បាយយ៉ាងនោះហើយក្តី នឹងជួបមុខម្តាយនឹងកូនក្រោយពេលដែលឃ្លាតឆ្ងាយមកជាយូរនេះគ្មានទេ! សេចក្តីមេត្រីដែលបងបានរៀបទុកក្នុងដើមទ្រូង គល់កំឡុង ៣ ឆ្នាំមកហើយ ក៏ផុះស្រោចស្រប់ទៅលើដើមទ្រូងមាតារបស់បង បងក៏រឹតអ្នកយ៉ាងខ្លាំង ក្រែងអ្នកឃ្លាតចេញពីបងទៅទៀតបាន ។

ចាប់តាំងពីថ្ងៃនោះមក បងលែងនៅផ្ទះម្តាយមីងទៀតហើយ គឺក្លាយទៅជានៅជាមួយនឹងម្តាយរបស់បង ផ្ទះនោះធំស្រឡះល្អណាស់មានសួនច្បារពីមុខមានកាលសម្រាប់លេងកូនគី ដល់ប្អូនមកលេងស្រុកភ្នំពេញជាន់ក្រោយទៀតនោះបងនឹងបានទទួលប្អូនយ៉ាងគួរបំផុត ម្តាយរបស់បងស្រឡាញ់ប្អូនខ្លាំងណាស់ ហើយមានប្រាថ្នាតែនឹងជួបឃើញប្អូនប៉ុណ្ណោះ រាល់តែថ្ងៃយើងជជែកគ្នានិយាយតែអំពីប្អូនប៉ុណ្ណោះ ។

សព្វថ្ងៃនេះ បងបានចូលរៀនក្នុងវិទ្យាល័យស៊ីសុវត្ថិហើយ ថ្ងៃចូលដំបូងកាលបើបងដើរហួសមន្ទីរអាជ្ញាឃុំបន្តិចទៅ ក៏កើតកាន់ភាំងភិតសរង់ នៅមុខគុកពីរជាន់នឹងដើមឈើមកពីប្រទេសក្រៅមានស្លឹកខៀវស្រងាត់ ផុះជាផ្ការនៅផ្កាលេង

ធ្វើឲ្យមានម្នាប់សប្បាយ លុះបងឈានជើងចូលក្នុងកន្លែងរៀនហើយក៏ភ្ញាក់ខ្លួនព្រើត ដោយឃើញកុមារីទាំងយួនទាំងខ្មែរចំនួន ១០ នាក់ ឈាយឡំនឹងអស់ពួកក្រុមកុមារ បងក៏អត់មិនបានឈាន់មាត់ថា "ប៉ៃ! មានពួកស្រីៗជាមួយនឹងយើងផង" បណ្ដាអ្នករៀនដូចគ្នា បងពុំស្គាល់អ្នកណាមួយឡើយ ហើយមានម្នាក់ដូចជារូបរាយគួរសម ។ ចំណែកឯពួកអាចារ្យបង្រៀនទាំងប៉ុន្មាន ក៏មានអធ្យាស្រ័យរីករាយរាក់ទាក់ស្រួលល្អ តែសុទ្ធតែជាជាតិយួនទាំងអស់ ធ្វើឲ្យបងនឹកអន់ចិត្តជាច្រើនដោយគិតថា "ដូចម្ដេចហ្ន៎! បានជាជាតិខ្មែរយើងមិនចូលចិត្តធ្វើគ្រូសោះ បណ្ដោយឲ្យជាតិដទៃគ្រប់គ្រងសាលាឯងទៅវិញ" ។ បងចូលរៀនបានមួយខែមកហើយពុំមានទាស់អធ្យាស្រ័យអ្វីនឹងអ្នករៀនផងគ្នាទេ ចំណែកពួកនារីក៏ស្រួលណាស់ដែរក្រៅអំពីបុប្ផាសួគ៌ ដែលខ្ចិចខ្ចក់ច្រើនបន្តិច ។

បងសូមលាប្អូនត្រឹមណេះ បានលើកក្រោយនឹងសរសេរឲ្យវែងជាងនេះទៅទៀត ព្រោះបងពុំមានពេលទំនេរច្រើនទេ សូមប្អូនអត់ទោសដល់បងចុះ ។

## បាកសុភិទ្រ

ចំណែកខាងសុភិទ្រក៏បានសេចក្ដីសុខដរាបមក រៀនក៏ពូកែបានឡើងថ្នាក់ជាលំដាប់ មានមិត្រគប់រកជាច្រើន អាចារ្យទាំងប៉ុន្មានក៏ពេញចិត្តនឹងកុមារគ្រប់គ្នា ព្រោះតែខ្លួនអ្នកតែងបានកិត្តិយសប័ត្រអំពីសំណាក់អាចារ្យធំផល់ជាប់ឆ្នាំក៏បានរង្វាន់ពុំដែលខានរហូតដល់ថ្នាក់ទី ៤ ក៏ប្រឡងឌីប្លូមជាប់ រួចអ្នករៀនយកចំណេះបាស្សូទៀត តែងខំប្រឹងប្រែងមិនដែលឲ្យខូចពេលវេលា ដោយការដើរលេងឥតប្រយោជន៍សោះឡើយ រហូតដល់បានសម្រេចប្រយោជន៍ យ៉ាងជាន់ខ្ពស់បណ្ដាច់ពីជាន់ទៀតគឺបាស្សូ ។

(មានត)

បណ្ដៅ

# ឃុនទត្តមប្រីជា ពាប - ពិន

ប្រមូលនិងរៀបរៀង (គយកនិងចប់)

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ១០៨ - ដើរទៅបាត់ញាត់ ដល់ទៅព្រៃស្ងាត់ ផ្តើមមុខ ដូវញញ? . . . . . . . . . . . . . . | ផុះ |
| ១០៩ - អង្គុយមួយកំប៉ុក សក់ស្រកពេមអ៊ី? . . . | អាចម៍ |
| ១១០ - ខ្សែមួយបន្លាយកយគ្រប់ស្រុក? . . . . . . | ផ្លូវ |
| ១១១ - ទុកពោលហាស់ ប្រើណាស់ថ្មី? . . . . . | ផ្លូវ |
| ១១២ - ឈាដមួយកញ្ញ្រួង រែងគ្រប់ស្រុក? . . . | ផ្កាយ |
| ១១៣ - ដូនមួយចំណាស់ ចិតលើឈើមេឃ? . . . . . | ខែ (ព្រះចន្ទ) |
| ១១៤ - ចានមួយថ្ងៃពាល់ល្ងាច កេះចាប់គ្នា? . . | ថ្ងៃ |
| ១១៥ - វេញកន្ទុះ ទុកខ្ទុះអាញ់ញ? . . . . . . . | ចេសម្ពុល |
| ១១៦ - គ្របះឲ្យខ្ញាញ់ សំឡីនឲ្យព្រំ ទាន់អើយសម្ងំ បនផ្ញាំងក្នុងឲ្យ? . . . . . . . . . . . | ដោះតម្ពុម្ពុល |
| ១១៧ - វេញព្នួរទៅក្បូបគល់ គិតមិនយល់ដល់ក្បួរផ្សពួរ? | ចេសម្ពុល |
| ១១៨ - លតានាមជាសុវណ្ណ តែងផុះពីទុកទួន លើដើម ព្រៃក្បា? . . . . . . . . . . . . . . | ល្ងៀមាស |

| បណ្ដៅ | ដោះស្រាយ |
| --- | --- |
| ១១៩ – ក្រោលតាព័ទ្ធបុង មច្ឆាពួនកង ពួនប្រែអគ្គី ? | ដំបុកត្រី |
| ១២០ – ទឹកមួយថ្លុក ពាស់ពេញអើតត ? . . . . . . | ចង្កៀងខ្លាញ់ |
| ១២១ – កំប៉េងកំប៉ោះ កំប៉េងឥតដោះ កំប៉ោះកូនច្រើន ចិញ្ចឹមកូនរស់ ? . . . . . . . . . . . . . | មេមាន់ |
| ១២២ – ចបាច់កលៀនអណ្ដាត ? . . . . . . . . . | ក្អមទឹក |
| ១២៣ – ត្រលេងត្រលោងលោត អ្នកណាទោតរកមិន ឃើញ ? . . . . . . . . . . . . . . . . . | សត្វត្រលេង<br>ត្រលោង |
| ១២៤ – គោក្រហមលិទ្ធគូតគោខ្មៅ ? . . . . . . . | ភ្លើងនឹងឆ្នាំង |
| ១២៥ – អស់តាំងគេដើរតាមផ្លូវ អាមួយតូរម៉ូវ ដើរ តែក្នុងព្រៃ ? . . . . . . . . . . . . . . . | ស្រមោល |
| ១២៦ – ដាក់ប្រលើបុងឫស្សី មិនត្រូវត្រី ត្រូវទាំងកំប្លង់ ? | ពោមពោះ |
| ១២៧ – ហាលស្រូវលើបុងរកា អ្នកតានប្រាញ់សាស្រូវ មិនអស់ ? . . . . . . . . . . . . . . | មើលសាស្ត្រ |
| ១២៨ – ខ្ញុំកខ្ញុកដកឡើងក្រហមទុំ ? . . . . . . . | អង្គុលទុំ |
| ១២៩ – កំប៉ុតដូចស្ពឺកម្ទ ប្រហោងគ្រហូ មមិសដុក ? | ស្លឹកត្រចៀកពោ |
| ១៣០ – កំប៉ុតៗ កំពាងៗ ព្រឹកព្រហាមបញ្ចុកស៊ីៗ ? | បង្គរ |

| បណ្ដាំ | ដោះស្រាយ |
|---|---|
| ១៣១ - នាងរូបនាងរៀវ ចង្កេះនាងរៀវ នាងអុំទូកលេង នាងផ្ទាត់តាប៉ុ នាងកាយផាគ្រូង នាងអុំទូកលេង កណ្ដាលអាកាស? . . . . . . . . . . . . | ខ្វងក្ដួង |
| ១៣២ - អស់ទាំងគេដើមចេញពីគល់ ប្លែកតែនាងមួយ នោះ ដើមចេញពីក្បាល? . . . . . . . . . . | ដើមចេក |
| ១៣៣ - ខ្ញុំកើតឡើងឮបងខ្ញុំប្រាប់ ថាម្ដាយខ្ញុំស្លាប់តាំងពីខ្ញុំមិនទាន់កើត[១]? . . . . . . . . . . . | ដើមចេក |
| ១៣៤ - កុកកុរ កុកចុះទៅ កុរឡើងលើ ក្រឡេកមើលទៅ ដូចជើងក្រពើ កុរឡើងលើ កុកចុះក្រោម? | ស្លងចេក |
| ១៣៥ - អស់ទាំងគេរកស៊ីនៅដី អាសង្ខ័ក្នុងរកស៊ីលើផ្ទះ? | សង្កើច |
| ១៣៦ - សេះគេស្អប់ ឆាប់គេថើប? . . . . . . . . . | សង្កើច |
| ១៣៧ - ទឹកមួយថ្នក់ កំពីសពាងពេញ? . . . . . . . . | ផ្លែក្រូច |
| ១៣៨ - ហៅអ្នកបងទ្រូង ឃើញសត្វបួនជើង យើងផងប្តុទេ សត្វលាក់ក្រចក កយកទៅស៊ី ត្រង់ផ្ទៃពោះមេ ក្រោមដើមលាក់ផ្កា? . . . . . . . . | លោកសង្ឃ, ជីរ, មាន់, ទា, ស្រែ, ដើមល្ហា |

---

១ ន័យមួយថា ផឹករលុងផេកពា ។ ៗ

បណ្តៅ | ដោះស្រាយ

១៣៩ – ឈើខ្វៃនៅដីគេកាត់ វែកជាកំណាត់ វែងជា
ជ្រុងបួន ស្រេចហើយគេសាង ជារូបស្រីសួន
ហើយគេបញ្ចាំន ទៅងាហានផ្ទុំ ហោលប្អូនទឹម
នួនរហង់ ត្រចោងឯកអង្គ កណ្តែងកណ្តោច
អាសូរស្រីតូច ៗ ពុំដឹងតំណូច អាណោច
អាធ័ម ហេតុកម្មពីព្រេងនាយនាំ មកឲ្យរងកម្ម
រង្គួយតែស្រី ? . . . . . . . . . . . . . . ដូចពៃសំណែន

១៤០ – អង្កាមស្រមាមអស់អង្គ កំកៀបផ្សូរផង់ កំផែឡើង
ស្រី ប្រមុះទៅញល់ទឹងដី កំផែឡើងស្រី កំ-
កៀប ៗ បង ? . . . . . . . . . . . . . ដំបែបិទស្រា

១៤១ – កកីបីពោះ កកោះពោះផង កញ្ចប់ចាំងណាង
ព្យ៉ាកព្យ៉ាកស្រទៀត ? . . . . . . . . . . . . កី

១៤២ – ប៉ត្ចិកប៉ក្រើក ដៃទែងជើងបើកបាក់បោះរន្ធស្រាប់
ទង្គិចម៉ាប់ ៗ ចេញទឹកសើម ៗ ? . . . . . . ត្បាញសំពត់

១៤៣ – ញ៉ែ ៗ ញ៉ាំច ៗ កាន់រំពាត់មួយជាប់ លេងក្មេង
តាចកែ ចាស់ហើយមិនគិតអៀនគេ លេងក្មេង
តាចកែ ទាំងព្រឹកព្រហាម ? . . . . . . . . ផ្ចិតកប្បាស

| មណ្ដាំ | ដោះស្រាយ |
|---|---|
| ១៤៤ - ព្រហាមស្រាងស្រេច កាន់ពាត់មួយប្លាច់ ទៅរក ក់យគេ តាស់ហើយមិនគិតខ្មាសគេ ទៅរក ក់យគេរោកាំរើន ? . . . . . . . . . . . . | ភ្លើចកប្បាស |
| ១៤៥ - កំងអើយកំងរេ កំងជុះកណ្ដាលទន្លេ គេហៅកំងអី ? | ព្រិល |
| ១៤៦ - ស៊ីសល្អបីជង ដល់ចាស់គោងខ្នង ស៊ីល្អម្ដងទៀត ? | ស្រូវ |
| ១៤៧ - លើកបីត្រកង ព្រលឹងមាសបង បីជងហើយដាក់ ? | ច្រូតស្រូវ, ចងកណ្ដាប់ |
| ១៤៨ - ចងដោមប្រឡោមបោះទៅ កណ្ដាលទឹកជ្រៅ រកបាំរង់ ជងដែនប្រឡែនងែកាន់ ចាប់ជាកំណាន់ ដូចគេសំពះ តាំងព្រាំទៅទាំងព្រាយ សាមសិប នៅអាយ បើកទ្វាររង់ចាំ ? . . . . . . . . | ប៉ែនធ្វើនំ បញ្ចុក |
| ១៤៩ - ប៉ុលប៉ាលហាលស្វាប ដើងតាបលាបម្រ័ក្យ ដើងប្លាក់ចាក់ច្រាស ? . . . . . . . . . . | តាំងយូ |
| ១៥០ - បក្សីបក្សាសក្កុ ខ្លួនហើរទៅបាត់ ទុកតែជើងនៅ ? | ជើមជើងបាប |
| ១៥១ - ទាញល្ពៅមួយភ្លោយកល់មែក ? . . . . . . . . | រហាត់រៃ |
| ១៥២ - អាសដាក់លើអាខែកកែក ទាញហើយរឹតតែ ស្រែក ស្រែកហើយរឹតតែទាញ ? . . . . . . | ក្រុះមះម្យោះ |

បណ្ដៅ ដោះស្រាយ

១៥៣ - ប្រស់អីយប្រស់ប្រួល ប្រស់ផុះកណ្ដាលទួល
គេហៅប្រស់អី? . . . . . . . . . . . . . . ប្រស់ស្លា

១៥៤ - ត្រអីយត្រត្រឹង ត្រផុះកណ្ដាលបឹង គេហៅត្រអី? ត្រលឹក

១៥៥ - ចាប់គន្លុយស្រែកហៅ លេចអាចម៍មួយស្រែ តែ
មិនស្អុយ? . . . . . . . . . . . . . . . . . ហ្វូះផ្ដៅ

១៥៦ - អង្គុយមិះៗ ក្ដិះអាចម៍មាន? . . . . . . . . . . ផ្ទៀសបង្កុះ

១៥៧ - ជើងបី ភ្នែកបួន? . . . . . . . . . . . . . មនុស្សចាស់ ដែលកាន់ ឈើច្រត់ ពាក់វែនតា

១៥៨ - ក្រហមចុង សម្រុញកន្ទុ រលើងក្រៅ? . . . . . បារី

១៥៩ - ស៊ីមិនឆាត់ ឥតមិនស្គម? . . . . . . . . . ដក់ញុំ

១៦០ - ដីមួយដុំ ដំនុំគ្នាស៊ី? . . . . . . . . . . . ហ៊ីបស្លា

១៦១ - មានគិលចង្កិលលើផ្ទះ ក្បៀរច្រើនលើកដៃសំពះ
ទទួលមានគិល? . . . . . . . . . . . ហ៊ីបស្លា

១៦២ - អាក្រឡឹតបុកក្ដិតមេសាមែន ដកឡើងក្រហម
ទែង យកអណ្ដាតលិទ្ធពុង? . . . . . . . ត្បាល់បុកស្លា

បណ្ដៅ ដោះស្រាយ

១៦៣ – កំប៉ុតពីក្រោម មួយពង្រោមពីលើ សង្កត់
ក្បាលផើងផើ តើគេហៅអ្វី? . . . . . . . . . . ឈ្នក់ចាប់ត្រី

១៦៤ – ស្រុកមួយមានតែឈ្មោះ កល់រូបទាំងអស់ ទៅ
ហើយមិនមក? . . . . . . . . . . . . . . ស្រុកខ្មោច / ព្រៃខ្មោច

១៦៥ – ឮតែមាត់យំ មិនដែលឃើញរូប? . . . . . . ផ្គរ

១៦៦ – អ្នកអើយមើលលើ មើលសត្វក្រពើពងលើ
ចុងឈ្នាត? . . . . . . . . . . . . . . . ទៅតំពុងក្រពើ

១៦៧ – ទាញដើមល្មើរលើក រំពើកល្មើរាយ ទាញដើមដក់
ពាយ គញ្ចនារី កំប្រុកក្បាលពារ កន្ទ្រែខក្បាល
ប្រាំ ពុម្ពរដើមឆ្នាំ គន្ធុយព្រើតៗ? . . . . . ស្លាបបាច / ទឹកស្រែ

១៦៨ – អង្គឯកចាំខ្សែតជាងគេ កូនមិនដូចមេ មេមិនដូច
កូនគេចាប់កូនបង គេយកកូនទៅ ទុកមេឲ្យនៅ
ក្រោមទ្រព្យគេ? . . . . . . . . . . . . . . . កូនសោ

១៦៩ – នាងអ៊ីនាងអើត គន្ធុយបន្តោត អើតលិចៗ? . . . ផ្ចិតហាក់ថ្នាំ

១៧០ – ពីតូចស្លៀកសំពត់ ធំឡើងមិនចេះរត់ ស្រាត
សំពត់ដួតក្បាល? . . . . . . . . . . . . . . . ផ្លែត្រប់

បណ្ដាំ ដោះស្រាយ

១៧១- សសួលបណ្ដូលគូទ ក្រហមចុង សំទិកគល់? ទៀន

១៧២- កំប៉ុកកំប៉ូវ អង្គុយកណ្ដាលផ្លូវ ពាក់អាវព្រៃឡា ពីង្គក់

១៧៣- ចាស់ហៅឪ ក្មេងហៅឪ ស្ដេចពីម៉ែពីឪ ក៏ហៅឪទាំងអស់? ............... ឪឡឹក, ឪឡឹ, ឪឡោកៗល។

១៧៤- គោដេក ខ្សែដើរ? ............... ឪឡឹក, ត្រសក់

១៧៥- អាចួរអាជាត់ អាចួរអត់មាត់ អាចួរជាក់ឯង? ... ទើយ

១៧៦- កន្ទបខ្ចាញ់ចុក ដេកលក់មិនក្រោក ? .... ទើយ

១៧៧- ទទឹងមួយបន្ទប់ ទន្ទឹងតែយប់ លេបមនុស្សទាំងមូល? ............... មុង

១៧៨- អស់ទាំងគេពាក់ចិញ្ចៀនពីមុខ ស្រីសទ្រលុកពាក់ចិញ្ចៀនពីខ្នង? ............ មុងក្រវិល

១៧៩- លើកដើងរំលងក្បាល? ......... មុង

១៨០- យប់ប៉ោង ថ្ងៃផត? ......... មុង

១៨១- យប់ផត ថ្ងៃប៉ោង? ......... ដង្ក្រ

១៨២- មួយត្របកពីលើ មួយត្របកពីក្រោម ដំម្រែកគ្នាព្រឹម ស្រណុកកក់ក្ដៅ? ....... ភ្នែក

បណ្ដៅ                ដោះស្រាយ

១៨៣ - មមិសពីលើ   មមិសពីក្រោម   ទន្ទិចគ្នាព្រម

ស្រណុកតាល់ព្រឹក? . . . . . . . . . . . . . ភ្នែក

១៨៤ - ស្បូវមួយកណ្ដាប គ្របមាត់អណ្ដូង? . . . . . . រោមភ្នែក

១៨៥ - ពីតូចទូលដី ធំឡើងមិនបេះស្ដី ស្លៀកពាក់ស្បង់ចីវរ? ទំពាំង

១៨៦ - កំពីងពួយអើយ   ពីរនៅបង   កំពីងពួយបង

បងហើយស្រាយវិញ? . . . . . . . . . . ចងពាក

១៨៧ - សេះបួនបួនទឹងកម្លាំង   ទូកបួនប្រែប្រាំង   អគ្គី

មានទឹក   មច្ឆាហែបហែលអើក   អគ្គីមានទឹក

មានស្ដេចមានរាស្ដ្រ? . . . . . . . . . . បព្រិង្គ

១៨៨ - គតាំងចម្បាំងលើគទីត ពលសេហ៍ខ្លាំងខ្លាំង សង្គ្រាម

ជយា   គតាំងប្រណាំងឫទ្ធា   ដីងពាញឈ្នះគ្នា

ហើយច្បាំងម្ដងទៀត? . . . . . . . . . . បក្រិង្គ

១៨៩ - លលួកលលេប   លលេងបន្ទិប   លលេបស៊ីតា

ចាល១ លេងមេណា   លលេបសីតា   ព្រះរាម

ស្ដេចខ្វល់? . . . . . . . . . . . . . . បព្រិង្គ

១៩០ - កៃងគោងប្រហោងឥលប្បាត ចាក់ទំសង្កាត ពោះ

លើងគេង? . . . . . . . . . . . . . . . . បន្ទាល

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ១៩១ - កុកដូចគ្នាត ទំស៊ុសង្កាត រកពោះដាក់គ្មាន? | កណ្ដៀវ |
| ១៩២ - នាងអើយនាងមា អស់ប្រាំរស្សា មិនទាន់ផ្កាម្ជុល? | ស្លឹកគ្រៃ |
| ១៩៣ - កុកដូចគទុង សំយុងដូចកគ្នាត ទំស៊ុសង្កាត រកពោះដាក់គ្មាន? . . . . . . . . . . . . . | វែក |
| ១៩៤ - ដំបូកមួយ មានរន្ធប្រាំពីរ? . . . . . . . . | ក្បាលមនុស្ស |
| ១៩៥ - ពីតូចសក់ស្កូវ ដល់ធំតូរម៉ូវ សក់ស្កូវបាត់អស់? | ផ្លែថ្កូវ |
| ១៩៦ - ស្រីខ្មៅស្រអែម ក្បាលផ្អែម កន្ទុយសាប? . . | អំពៅ |
| ១៩៧ - ស្រីសជប្បារ មនុស្សគ្រប់គាសា ប្រាថ្នាស្រស់? | ប្រាក់ |
| ១៩៨ - ស្រីលឿងខ្ចៀវខ្ចី មនុស្សលើផែនដី ទាន់មេត្រីគ្រប់គ្នា? . . . . . . . . . . . . . . . . | មាស |
| ១៩៩ - មេស្លូត កូនកាច? . . . . . . . . . . . . . . | ស្បូវ |
| ២០០ - ស្លឹកដូងសំយាក ស្លឹកចាកសំយុង ពពេលចុង ជ្រុង នរណាហ៊ានកាត់? . . . . . . . . | អណ្ដាត |
| ២០១ - ឈើកោងរលីងក្ដី គេដេររុំចយំ តែអើយ ស្រងាត់? . . . . . . . . . . . . . . . . . | ឥន្ទធ្នូ(ឥន្ទធនូ) |
| ២០២ - លតាដើមពាន់ក្រគាត់ ម្ដេចឡើយមានចិត្ត ចង់ផល់ | |

បញ្ហា ដោះស្រាយ

បក្សា លោលាលេងទេណា មុតដៃសីតា
ព្រះរាមស្ដេចខ្លាល់? . . . . . . . . . វល្លិប្រដល់ភ្នំ
លំពែងព្រះរាម

២០៣- កាច់តែកើតជាអ្នក ចាប់ពោលទៅមុខ ពុំខុក
ឡើយណា ចាប់បានទាំងជាយក្រែងរ៉ា ពោល
កុងគន្ធា ប៉ុនស្រែអំពក? . . . . . . . បង់សំណាញ់

២០៤- អន្ទយលើមែក វែកក្ដិត? . . . . . . . ផ្លែសំរោង

២០៥- មួយត្របកបី មួយត្របកបួន មួយត្រកង មួយ
ត្រកួន មួយដន្ទាប់មាសក្នុង? . . . . . ផ្លែភ្លូ ឬផ្កាឈូក

២០៦- ខ្ទន់ប៉ុនកដៃ ក្បាលក្រហមឆៅ ក្រញូវចូល
ទៅ ទៀរទឹកមាត់ទឹកក? . . . . . . . ក្រៀងសេដាចាយ

២០៧- ថៃអើយអ្នកថៃ ខ្ទប់នកូតដៃ លេបនគរមួយ
បាន លេបទាំងសម្បត្តិ លេបទាំងពិមាន លេប
នគរមួយបាន ទើបហៅអ្នកថៃ? . . . . បិតង់ព្រះបត់

២០៨- ប៉ុនកដៃអាល័យគូទ? . . . . . . . . . . កន្ទុយពោ

២០៩- ពីក្មេងតូចលើ ធំឡើងបេះត្រឡប់ធំលើជាងក្រោម ផ្លែស្វាយចន្ទី

| បណ្ដៅ | ដោះស្រាយ |
|---|---|
| ២១០-ជើងបួនទល់មេឃ ជើងបួនទល់ដី ក្បាលបី ភ្នែកប្រាំមួយ? . . . . . . . . . . . . . . | ធនុស្សសែង<br>ផ្ចិត |
| ២១១-ក្ដិតទល់ក្ដិត ក្បាលទល់ក្បាល ភ្នែកនៅកណ្ដាល វែកញ៉ែសជោក? . . . . . . . . . . . . . . | សង្រែក |
| ២១២-មានរូបមើលមិនឃើញ តែចាប់បាន? . . . . . | ចាប់ខ្យល់ |
| ២១៣-ដើមឡេកដុះលើដើមឬស្សី ស៊ីកបី ផ្លែមួយ? . . | ស្លាធំ |
| ២១៤-ទឹកៗ ស្អាបៗ រំលាបៗ ទូកទៀត? . . . . . . | សំលៀកកាំបិត |
| ២១៥-កាសោមហៀរ កាសោធវៃ ចាប់បានដៃកាសោម ហៀរ ស៊ីសាច់ខ្លាក់ត្រាប់ កញ្ឆែត្រាប់ កន្ទ្រើង ត្រង? . . . . . . . . . . . . . . . | ផ្គោះពោះ<br>កញ្ជាស |
| ២១៦-ស្រីសត្រអោក ដុះមាំសត្រពោក អណ្ដូយនៅពទ ផ្សារ? . . . . . . . . . . . . . . . . | មើមទឹម |
| ២១៧-កាបួននាក់សែងគួច កាក្រឡឹតដើរមុខ? . . . . . | អណ្ដើក |

ធម្មបទភាសិត

# លោកគ្រូចៅអធិការ ( ឯក-ញឹម )

វត្តធម្មិស្សរការាម ឃុំ-ស្រុកសូទ្រនិគម ខេត្តសៀមរាប

រៀបរៀង

ពួកគាថា ដែលជាបទផ្កាកែវក្នុងសៀវភៅនេះ ខ្ញុំព្រះករុណា អាត្មាភាព (ឯក-ញឹម) នាម ធម្មិស្សរោ ចៅអធិការវត្តធម្មិស្សរការាម ឃុំសូទ្រនិគម ស្រុកសូទ្រនិគម ខេត្តសៀមរាប ។

បានស្រង់យកគាថានានាក្នុងគម្ពីរផ្សេងៗ មានគម្ពីរធម្មបទ ខុទ្ទកនិកាយជាដើម មកប្រែរៀបរៀងធ្វើជាពាក្យព្រាំបី ឲ្យត្រូវតាមរបៀបបាលីក្នុងគាថាទាំងឡាយនោះៗ ដើម្បីជាប្រយោជន៍ឲ្យស្រួលដល់លោកអ្នកសិក្សាទាំងឡាយផង ដើម្បីជាប្រយោជន៍ដល់ការស្ងូត្រក្នុងទីប្រជុំបុណ្យទាំងឡាយ មានបុណ្យភ្ជុំបិណ្ឌជាដើមផង ដើម្បីនឹងបានបោះពុម្ពផ្សាយចែកជាធម្មទាន ក្នុងឱកាសបុណ្យបញ្ចុះសីមា វត្តធម្មិស្សរការាម នៅថ្ងៃអាទិត្យ ១ កើត ខែមិគសិរ ឆ្នាំរកាសប័ក ព.ស.២៤៨៧ ផង ។

លុះរៀបរៀងរួចហើយ បានបញ្ជូនដល់ពុទ្ធបរិស័ទទាំងឡាយ មានព្រះបុរ៍គោគា តាំង-ខេនស៊ុយជាដើម ពុទ្ធបរិស័ទទាំងឡាយនោះ លុះមើលឃើញរបៀបធម៌នេះសព្វគ្រប់ហើយ ក៏កើតចិត្តជ្រះថ្លា បានចំណាយបញ្ញាតិគ្រប់ៗគ្នា តាមលំដាប់ទិសសីមាទាំង ៨ ទិស ។ ហើយបាននិមន្តខ្ញុំព្រះករុណា អាត្មាភាព ឲ្យចាត់ការបោះពុម្ពផ្សាយ

ចែកជាធម្មទាន ក្នុងឱកាសបុណ្យសីមាវត្តនោះ នៅថ្ងៃដូចជាមកខាងលើស្រាប់ តែសម័យនេះស្រុកត្រូវជាសពន់ពេក ហើយខ្ញុំព្រះករុណាអាត្មាភាពផ្ញើមកជូនពុទ្ធសាសនបណ្ឌិត្យ ឲ្យលោកចាត់ការបោះពុម្ពឡើងក្នុងទស្សនាវដ្តីកម្ពុជសុរិយា  ឯរបៀបរៀបរៀងគាថាទាំងឡាយនោះដូច្នេះ :

១ – មង្គលសូត្រ ពួកធម៌សំដែងពីសេចក្តីចំរើនមាន ១០ គាថា

២ – បរាភវសូត្រ ពួកធម៌សំដែងពីសេចក្តីវិនាសមាន ១២ គាថា

៣ – យុគគាថា ពួកគាថាសំដែងអំពីធម៌ជាគូៗនឹងគ្នាមាន ១៦ គាថា

៤ – បកិណ្ណកគាថា ពួកគាថាសំដែងពីធម៌រាយរងមាន ៤៨ គាថា

រួបរួមគាថាទាំងអស់ត្រូវ ៨៦ គាថា ។

សូមសេចក្តីសុខ សេចក្តីចំរើនកើតមានដល់ព្រះពុទ្ធសាសនា និងលោកអ្នកសិក្សាទាំងឡាយផងតទៅ អស់កាលជាអង្វែង ។

## មង្គលសូត្រ

បទ បថ្យាវត្ត

ពហូ ទេវា មនុស្សា ច  មង្គលានិ អចិន្តយុំ
អាកង្ខមានា សោត្ថានំ  ព្រូហិ មង្គលមុត្តមំ ។

ទេវតានឹងមនុស្សទាំងឡាយបានខំយល់  គិតរកមង្គលអស់កាលអង្វែង
ប្រាថ្នាចង់ស្តាប់មង្គលនេះឯង  សូមព្រះសំដែងមង្គលឧត្តម ។

ពុទ្ធដីកា ឆ្លើយតបនឹងទេវតា

១– អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា
បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ ។
កិរិយាមិនសេពគប់ពាលទាំងឡាយ សេពគប់អ្នកប្រាជ្ញប្រាយសព្វកាលវេលា
បូជាបុគ្គលដែលគួរបូជា ទាំង ៣ ប្រការមង្គលឧត្តម ។

២– បតិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា
អត្តសម្មាបណិធិ ច ឯតម្មង្គលមុត្តមំ ។
កិរិយានៅក្នុងប្រទេសគួរសម និងធ្វើបុណ្យធំពីមុនច្រើនក្រៃ
កិរិយាតម្កល់ខ្លួនទុកប្រពៃ អំពើទាំង ៣ មង្គលឧត្តម ។

៣– ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ
សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ ។
បុគ្គលបានស្តាប់បានរៀនចេះច្រើន ចេះសិល្បសាស្ត្រចំរើនឆ្លៀវឈ្លាសក្រៃវៃ
វិន័យសិក្សាវាចាប្រពៃ ទាំង ៤ នេះនៃមង្គលឧត្តម ។

៤ – មាតាបិតុ ឧបដ្ឋានំ បុត្តទារស្ស សង្គហោ
អនាកុលា ច កម្មន្តា ឯតម្មង្គលមុត្តមំ ។
កិរិយាបំរើមាតាបិតា សង្គ្រោះភរិយានិងបុត្រអាត្មា
មិនបានធ្វេសធ្វើរាយប៉ាយការងារ ទាំង ៤ នេះជាមង្គលឧត្តម ។

៥ – ទានញ្ច ធម្មចរិយា ច ញាតកានញ្ច សង្គហោ
អនវជ្ជានិ កម្មានិ ឯតម្មង្គលមុត្តមំ ។
ការបរិច្ចាគទាននិងប្រព្រឹត្តធម៌ និងសង្គ្រោះល្អដល់ញាតិអាត្មា
និងការទាំងឡាយមិនមានទោសា ទាំង ៤ នេះជាមង្គលឧត្តម ។

៦ - អារតី វិរតី បាបា　　មជ្ជបានា ច សញ្ញមោ
　អប្បមាទោ ច ធម្មេសុ　ឯតំ មង្គលមុត្តមំ ។
　ការមិនត្រេកអរនិងវៀរចាកបាប　　សង្រួមអត្តភាពវៀរចាកស្រវឹង
　មិនមានប្រមាទស្មារតីរឹងប៉ឹង　　ទាំង៣នេះហ្នឹងមង្គលឧត្តម ។

៧ - គារវោ ច និវាតោ ច　　សន្តុដ្ឋី ច កតញ្ញុតា
　កាលេន ធម្មស្សវនំ　　ឯតំ មង្គលមុត្តមំ ។
　សេចក្ដីគោរពនិងកាំងការគោស　　សេចក្ដីសន្ដោសដឹងគុណគា
　និងការស្ដាប់ធម៌តាមកាលវេលា　　ទាំង ៥ នេះជាមង្គលឧត្តម ។

៨ - ខន្តី ច សោវចស្សតា　　សមណានញ្ច ទស្សនំ
　កាលេន ធម្មសាកច្ឆា　ឯតំ មង្គលមុត្តមំ ។
　សេចក្ដីអត់ធន់និងប្រដៅស្រួល　　និងការទទួលជួបពួកសមណា
　ការសាកសួរធម៌តាមកាលវេលា　　ទាំង ៤ នេះជាមង្គលឧត្តម ។

៩ - តបោ ច ព្រហ្មចរិយញ្ច　អរិយសច្ចាន ទស្សនំ
　និព្ពានសច្ឆិកិរិយា ច　ឯតំ មង្គលមុត្តមំ ។
　ព្យាយាមដុតបាបនិងប្រព្រឹត្តធម៌　　និងជាន់ឃើញធម៌អរិយសច្ចា
　ធ្វើព្រះនិព្វានច្បាស់ក្នុងអាត្មា　　ទាំង ៤ នេះជាមង្គលឧត្តម ។

១០ - ផុដ្ឋស្ស លោកធម្មេហិ　ចិត្តំ យស្ស ន កម្បតិ
　អសោកំ វិរជំ ខេមំ　　ឯតំ មង្គលមុត្តមំ ។
　ចិត្តនៃបុគ្គលកាលលោកធម៌　　ប៉ះមិនញាប់ញ័រមិនមានសោកា
　ប្រាសចាកនិម្រែកក្សេមក្សាន្តចិត្តា　　ទាំង ៤ នេះជាមង្គលឧត្តម ។

០ — ឯតាទិសានិ កត្វាន សព្វត្ថមបរាជិតា
សព្វត្ថ សោត្ថឹ គច្ឆន្តិ តន្តេសំ មង្គលមុត្តមំ ។

ទេវតានិងមនុស្សធ្វើនូវធម៌នេះហើយ មិនចាលចាញ់ឡើយក្នុងទីនានា
បាននូវសួស្តីសិរីសុខា ទាំងមនុស្សទេព្ដាៈមង្គលឧត្តម ។

( មង្គលសុត្តំ និដ្ឋិតំ ។ )

## បរាភវសុត្ត

### បទ បដ្យាវិត

បរាភវន្តំ បុរិសំ មយំ បុច្ឆាម គោតមំ
ភវន្តំ បុដ្ឋុមាគម្ម កឹ បរាភវតោ មុខំ ។

យើងខ្ញុំទាំងឡាយមកសូមទូលសួរ នូវហេតុជាគួរនៃវិនាស
បុរសបុគ្គលដែលដល់វិនាស ហើយនឹងវិនាសសាបសូន្យបាត់គុណ
នឹងព្រះគោតមព្រះអង្គមានបុណ្យ មេត្តានិមន្តសំដែងឲ្យទាន
ធម្មជាតិម្តេចដែលជាប្រធាន នាំសត្វឲ្យមានសេចក្តីវិនាស ។

ព្រះពុទ្ធដីកា ឆ្លើយតបនឹងទេវតាថា

១ — សុវិជានោ ភវំ ហោតិ សុវិជានោ បរាភវោ
ធម្មកាមោ ភវំ ហោតិ ធម្មទេស្សី បរាភវោ ។

អ្នកចេះដឹងល្អតែងបានចំរើន ទ្រព្យធនបុណ្យកើនកើតពីវិជ្ជា
ចំណោះអាក្រក់ឥតសិល្បសាស្ត្រា អ្នកនោះឈ្មោះជាវិនាសដោយពិត
អ្នកប្រាថ្នាធម៌ដោយល្អក្នុងចិត្ត ហើយចំប្រព្រឹត្តនឹងបានចំរើន
អ្នកទ្រុស្តក្នុងធម៌ឬស្អប់ធម៌ច្រើន អ្នកនោះចំរើនវិនាសទៅមុខៗ ។

២ - អសន្តស្ស បិយា ហោន្តិ សន្តេ ន កុរុតេ បិយំ
អសតំ ធម្មំ រោចេតិ តំ បរាភវតោ មុខំ ។

អ្នកដែលស្រឡាញ់ពេញចិត្តស្នេហា តែនឹងមនុស្សណាអសប្បុរស
តែងមិនស្រឡាញ់ពេញចិត្តទាំងអស់ នឹងអ្នកសប្បុរសមកធ្វើជាមិត្រ
សេចក្ដីស្រឡាញ់ពេញចិត្តពំនិត ហើយទៅគប់មិត្រអសប្បុរស
គាប់ចិត្តក្នុងធម៌ឬមួយរបស់ ហេតុនោះទាំងអស់នាំឲ្យវិនាស ។

៣ - និទ្ទាសីលី សភាសីលី អនុដ្ឋាតា ច យោ នរោ
អលសោ កោធបញ្ញាណោ តំ បរាភវតោ មុខំ ។

អ្នកដេកច្រើនមួយនិយាយច្រើនមួយ នឹងអ្នកពិតព្រួយគិតពិតប្រឹងប្រែង
នឹងខ្ជិលច្រអូសមិនមានខ្នះខ្នែង ទឹងច្រើនសំដែងឲ្យគេឃើញបាន ។
ហេតុធម៌ទាំងនោះមិនជាកល្យាណ នាំឲ្យខកខានខាតខូចប្រយោជន៍
មានជាប្រការតិចច្រើនដោយហោច នាំបង់ប្រយោជន៍ហើយឲ្យវិនាស ។

៤ - យោ មាតរំ វា បិតរំ វា ជិណ្ណកំ គតយោព្វនំ
បហុ សន្តោ ន ភរតិ តំ បរាភវតោ មុខំ ។

នរជនណាមានទ្រព្យធនធាន ហើយខ្លួនមិនអានចិញ្ចឹមរក្សា
មាតាបិតាដែលចាស់ជរា ហេតុនោះទៅជានាំឲ្យវិនាស។

៥ - យោ ព្រាហ្មណំ វា សមណំ វា អញ្ញំ វាបិ វណិព្វកំ
មុសាវាទេន វញ្ចេតិ តំ បរាភវតោ មុខំ ។

ជនបញ្ឆោតព្រាហ្មណ៍ឬពួកសមណៈ ពួកស្មូមឬអ្នកដទៃ
ដោយមុសាវាទបញ្ឆោតពាក្យប្រៃ នោះប្រាកដនៃសេចក្ដីវិនាស ។

៦- បហុតវិត្តោ បុរិសោ សហិរញ្ញោ សភោជនោ
ឯកោ ភុញ្ជតិ សាទ្ធូនិ(១) តំ បរាភវតោ មុខំ ។
បុរសអ្នកមានទ្រព្យធនធានច្រើន មាសប្រាក់ចំណីនិងគ្រឿងអាហារ
លបលាក់របស់ឆ្ងាញ់ពិសា តែម្នាក់ឯងជាប្រធានវិនាស ។

៧- ជាតិត្ថទ្ធោ ធនត្ថទ្ធោ គោត្តត្ថទ្ធោ ច យោ នរោ
សញាតឹ អតិមញ្ញេតិ តំ បរាភវតោ មុខំ ។
អ្នកដែលប្រកាន់ជាតិទ្រព្យត្រកូល ហើយមិនប្រមូលគាប់ញាតិសន្តាន
មើលងាយញាតិខ្លួនដោយអាងខ្លួនមាន នោះជាប្រធានសេចក្តីវិនាស ។

៨- ឥត្ថិធុត្តោ សុរាធុត្តោ អក្ខធុត្តោ ច យោ នរោ
លទ្ធំ លទ្ធំ វិនាសេតិ តំ បរាភវតោ មុខំ ។
ជនអ្នកប្រព្រឹត្តល្បែង ៣ ប្រការ ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយ
ធ្វើទ្រព្យខ្លួនមានឲ្យអន្តរាយ ការល្បែងទាំងឡាយនោះនាំវិនាស ។

៩- សេហិ ទារេហិ អសន្តុដ្ឋោ វេសិយា សុបទុស្សតិ
ទុស្សតិ បរទារេសុ តំ បរាភវតោ មុខំ ។
បុរសមិនត្រេកអរនឹងស្រីភរិយា ហើយទៅត្រេកអរនឹងស្រីពេស្យា
ទ្រុស្តនឹងប្រពន្ធអ្នកដទៃ ហេតុនោះទើបជានាំឲ្យវិនាស ។

១០- អតីតយោព្វនោ បោសោ អានេតិ តិម្ពរុត្ថនឹ
តស្សា ឥស្សា ន សុបតិ តំ បរាភវតោ មុខំ ។
បុរសមានវ័យចាស់ហួសពេក ហើយនៅនិទ្រាដោយក្តីតណ្ហា
នាំយកស្រីក្មេងមកធ្វើភរិយា ហេតុនោះទើបជានាំឲ្យវិនាស ។

---
១ ឱ. សាទូនិ ក៏មាន ។

១១- ឥត្ថី សោណ្ឌី វិកិរណី បុរិសំ វាបិ តាទិសំ
ឥស្សរិយស្មិំ ឋបេតិ តំ បរាភវតោ មុខំ ។

បុរសតាំងស្រីអ្នកលេងខ្ជះខ្ជាយ ឬស្រីតាំងឡាយតាំងបុរសនោះ
ដែលជាអ្នកលេងខ្ជះខ្ជាយដូច្នោះ អំពើទាំងនោះនាំឲ្យវិនាស ។

១២- អប្បភោគោ មហាតណ្ហោ ខត្តិយេ ជាយតេ កុលេ
សោ ច រជ្ជំ បត្ថយតិ តំ បរាភវតោ មុខំ ។

ជនណាកើតក្នុងត្រកូលក្សត្រ អ្នកខ្សត់សម្បត្តិហើយប្រាថ្នាធំ
ចង់បានជាស្តេចសោយរាជ្យស្តុកស្តម្ភ ហេតុនោះនឹងនាំឲ្យដល់វិនាស ។

១៣- ឯតេ បរាភវេ លោកេ បណ្ឌិតោ សមវេក្ខិយ
អរិយោ ទស្សនសម្បន្នោ ស លោកំ ភជតេ សិវំ ។

ជនជាបណ្ឌិតគំនិតប្រសើរ បានឃើញដំណើរនៃហេតុវិនាស
ដល់សត្វក្នុងលោកសព្វភាស គេចពីវិនាសគប់រកចំរើន ។

( បរាភវសុត្ត ចប់ ។ )

## យុគគាថា

### បទ បដ្ឋារិក

១- មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយមានចិត្តជាប្រធាន ប្រសើរក្នុងប្រាណសម្រេចបានដោយចិត្ត
បើបុគ្គលមានមនោទុច្ចរិត ពោលឬប្រព្រឹត្តធ្វើអំពើបាប ។

ទុក្ខតែងទៅតាមអ្នកនោះជាប់ ព្រោះអំពើបាបនៃបុគ្គលនោះ
ដូចកង់រទេះវិលតាមចំពោះ ស្នាមជើងគោស្មោះក្នុងទីនោះឯង ។

២- មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

ធម៌ទាំងឡាយមានចិត្តជាប្រធាន ប្រសើរក្នុងប្រាណស្រេចដោយចិត្ត
បើបុគ្គលមានមនោសុចរិត ព្រះញ្ញាប្រព្រឹត្តពោលឬធ្វើក្តី ។
សុខតែងទៅតាមអ្នកនោះប្រព្រឹត្ត ព្រោះអំពើនៃបុណ្យបុគ្គលនោះ
ដូចជាស្រមោលទៅតាមចំពោះ នៃរូបកាយនោះប្រាកដជាក់ស្តែង ។

៣- អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ ឧបនយ្ហន្តិ វេរំ តេសំ ន សម្មតិ ។

ពួកជនណាចងក្រោធទុកថា គេជេរអញគេវាយគេផ្ចាញ់
គេលួចយកទ្រព្យរបស់ផងអញ ពៀរជននោះឯងមិនរម្ងាប់ឡើយ ។

៤- អក្កោច្ឆិ មំ អវធិ មំ អជិនិ មំ អហាសិ មេ
យេ ច តំ នុបនយ្ហន្តិ វេរំ តេសូបសម្មតិ ។

ពួកជនឯណាមិនចងពៀរថា គេជេរអញគេវាយគេផ្ចាញ់
គេលួចយកទ្រព្យរបស់ផងអញ ពៀរជននោះឯងនឹងរម្ងាប់បាន ។

៥- សុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ អសំវុតំ
ភោជនម្ហិ អមត្តញ្ញុំ កុសីតំ ហីនវីរិយំ
តំ វេ បសហតិ មារោ វាតោ រុក្ខំវ ទុព្វលំ ។

មារតែងតែគ្រប់សង្កត់បុគ្គល ឃើញរូបហើយយល់អារម្មណ៍ថាល្អ
មិនសង្រួមហើយក្នុងឥន្ទ្រិយធម៌ មិនមានដឹងប្រមាណក្នុងភោជន
ខ្ជិលច្រអូសហើយមានព្យាយាមទន់ ជានដូចព្យុះធ្ងន់កាប់ឈើទ្រេតស្រាប់ ។

៦- អសុភានុបស្សឹ វិហរន្តំ ឥន្ទ្រិយេសុ សុសំវុតំ
ភោជនម្ហិ ច មត្តញ្ញុំ សទ្ធំ អារទ្ធវីរិយំ
តំ វេ នប្បសហតី មារោ វាតោ សេលំវ បព្វតំ ។

មារមិនអាចគ្រប់សង្កត់បុគ្គល ឃើញអារម្មណ៍យល់ថាមិនមានល្អ
សង្រួមស្អាតហើយក្នុងឥន្ទ្រិយធម៌ ជាអ្នកដឹងប្រមាណក្នុងភោជន
មានចិត្តជឿជាក់ព្យាយាមក៏ធ្ងន់ ដូចខ្យល់ព្យុះទន់កាប់ភ្នំមិនបាន ។

៧- យថា អគារំ ទុច្ឆន្នំ វុដ្ឋិ សមតិវិជ្ឈតិ
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ ។

ភ្លៀងតែងលេចបានផ្ទះប្រក់មិនល្អ ដូចរាគៈធម៌លេចស្រាបសន្តាន
បុគ្គលដែលមិនចំរើនកម្មដ្ឋាន រាគៈតែងរុកបានធ្លុះធ្លាយដល់ចិត្ត ។

៨- យថា អគារំ សុច្ឆន្នំ វុដ្ឋិ ន សមតិវិជ្ឈតិ
ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ ។

ភ្លៀងលេចមិនបានផ្ទះគេប្រក់ល្អ ដូចរាគៈធម៌មិនស្រាបសន្តាន
បុគ្គលដែលបានចំរើនកម្មដ្ឋាន រាគៈរុកមិនបានធ្លុះធ្លាយដល់ចិត្ត ។

៩- អនយំ នេតិ ទុម្មេធោ អធុរាយំ និយុញ្ជតិ
ទុន្នយោ សេយ្យសោ ហោតិ សម្មា វុត្តោ ច កុប្បតិ
វិនយំ សោ ន ជានាតិ សាធុ តស្ស អទស្សនំ ។

មនុស្សឥតប្រាជ្ញាតែងតែណែនាំ នូវហេតុមិនសមដោយគិតកាន់កាំង
នាំឲ្យប្រកបខាតខូចកំលាំង ធុរៈដែលកាន់មិនត្រូវតាមធម៌
ជាមនុស្សគឺគេប្រដៅដោយក្រ និយាយពាក្យល្អក៏មិនប្រែឡោតទឹង
ច្បាប់ធម៌វិន័យក៏គ្មានចេះដឹង ផលនោះយើងនឹងឈប់ឃើញប្រពៃ ។

១០– ន យំ ន យតិ មេធាវី អនុភាយំ ន យុញ្ជតិ
សុជយោ សេយ្យសោ ហោតិ សម្មា វុត្តា ន កុប្បតិ
វិនយំ សោ បជានាតិ សាធុ តេន សមាគមោ ។

មនុស្សមានប្រាជ្ញាតែងតែដឹកនាំ នូវហេតុដែលសមមិនបានទន់ទោរ
មិននាំប្រកបដោយក្តីពាលោ អំពើមោហោមិនប្រកបកាយ
ជាមនុស្សគឺគេប្រដៅដោយងាយ ពាក្យល្អនិយាយមិនប្រែឡោតរឹង
ច្បាប់ធម៌វិន័យក៏បានចេះដឹង ផលនោះយើងនឹងនៅរួមប្រពៃ ។

១១– បាបញ្ចេ បុរិសោ កយិរា ន តំ កយិរា បុនប្បុនំ
ន តម្ហិ ឆន្ទំ កយិរា ទុក្ខោ បាបស្ស ឧច្ចយោ ។

បុរសប្រុសស្រីបើបានធ្វើ នូវកម្មអំពើអាក្រក់នោះហើយ
កុំធ្វើបាបនោះថែមរឿយៗ ឡើយ កុំពេញចិត្តហើយក្នុងបាបទាំងនោ
ការសន្សំបាបនាំមកជំពោះ នៅទោសទុក្ខនោះដល់អង្គអាត្មា ។

១២– បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ
តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។

បុរសប្រុសស្រីបើធ្លាប់បានធ្វើ នូវកម្មអំពើជាបុណ្យនោះហើយ
ត្រូវធ្វើបុណ្យនោះថែមទៀតរឿយៗ ត្រូវពេញចិត្ត ហើយក្នុងបុណ្យនោះៗ
ការសន្សំបុណ្យនាំមកជំពោះ នូវក្តីសុខនោះដល់អង្គអាត្មា ។

១៣— បាបោ បិ បស្សតិ ភទ្រំ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតិ បាបំ អថ បាបោ បាបានិ បស្សតិ ។

អ្នកធ្វើអាក្រក់ក៏ឃើញជាសុខ
បាបដែលធ្វើទុកមិនទាន់ឲ្យផល
លុះបាបឲ្យផលកាលណាទើបស្គាល់
បាបបុគ្គលយល់បាបកាលនោះ ។

១៤— ភទ្រោ បិ បស្សតិ បាបំ យាវ ភទ្រំ ន បច្ចតិ
យទា ច បច្ចតិ ភទ្រំ អថ ភទ្រោ ភទ្រានិ បស្សតិ ។

អ្នកធ្វើការល្អតែមិនបានសុខ
បុណ្យដែលធ្វើទុកមិនទាន់ឲ្យផល
លុះបុណ្យឲ្យផលកាលណាទើបស្គាល់
ភទ្របុគ្គលយល់បុណ្យកាលនោះ ។

១៥— មាវមញ្ញេថ បាបស្ស ន មន្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ ។
បូរតិ ពាលោ បាបស្ស ថោកំថោកម្បិ អាចិនំ ។

បុគ្គលមិនគួរមើលងាយបាបឡើយ
ថាតិចតួចហើយមិនងាយឲ្យផល
ដូចពាងបើកមាត់រងែងតែងផល់
ពេញដោយមិនសល់នឹងដំណក់ទឹក ។
ពាលសន្សំបាបតិច ៗ ញឹក ៗ
ញយ ៗ សន្ធឹកពេញដោយបាបបាន ។

១៦— មាវមញ្ញេថ បុញ្ញស្ស ន មន្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
បូរតិ ធីរោ បុញ្ញស្ស ថោកំថោកម្បិ អាចិនំ ។

បុគ្គលមិនគួរមើលងាយបុណ្យឡើយ
ថាតិចតួចហើយមិនងាយឲ្យផល
ដូចពាងបើកមាត់រមែងតែងផល់
ពេញដោយមិនសល់នឹងដំណក់ទឹក
ប្រាជ្ញសន្សំបុណ្យរឿយ ៗ ញឹក ៗ
ញយ ៗ សន្ធឹកពេញដោយបុណ្យបាន ។

(មានត)

## ឯកោក គនៃមិលិន្ទបញ្ហា

ហ្លួងធម្មត្រី ញ៉ុក-ថែម ប្រែនិងរៀបរៀង

(តមក)

១ — ជាអ្នកត្រេកអរយ៉ាងក្រៃលែង ក្នុងសេចក្ដីសុខដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ដ៏ក្រៃលែងប៉ុណ្ណោះ ។

២ — ផ្ចង់ផ្ចិតចិត្តឲ្យរីករាយ មិនខ្ជិលច្រអូស ស្ញប់ស្ញាប់នៅក្នុងកុសលធម៌ទាំងឡាយ កើតសេចក្ដីរីករាយ ព្រោះស្វាហាប់ព្យាយាមបំពេញកុសលធម៌ទាំងឡាយ ។

៣ — មិនដែលកើតចិត្តនឿយណាយនឹងផ្ទះស្ងាត់ទំនេរនោះឡើយ ។

## អង្គ ៣ របស់សត្វទ្រាយ៖

១ — នៅក្នុងព្រៃវេលាថ្ងៃ លុះដល់យប់តែងចេញទៅនៅក្នុងទីវាល ។

២ — គេចចៀសលំពែង ឬកូនសរដែលធ្លាក់មកត្រូវលើខ្លួនផុតរបូតទៅបាន ហើយមិនដែលបង្អោនកាយទៅរកកូនសរនោះឡើយ ។

៣ — កាលបានមកប្រទះនឹងមនុស្សហើយ ក៏លាក់ខ្លួនពួនសំងំនៅក្នុងទីណាមួយ មិនឲ្យមនុស្សមើលឃើញខ្លួនឡើយ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ៖

១_វេលាថ្ងៃនៅតែក្នុងព្រៃ ដល់យប់ចេញមកនៅកណ្ដាលវាល ។

២–កាលកិលេសកើតឡើង ក៏ចៀសគេចរត់ចេញមិនបណ្ដោយចិត្ត ទៅប្រឡូកប្រឡល់នឹងកិលេសទាំងនោះឡើយ ។

៣–ឃើញជនដទៃបង្កជំលោះវិវាទ ឬទ្រុស្តសីលខ្ជិលច្រអូសក៏ គេចចៀសវាងឲ្យឆ្ងាយទៅ មិនឲ្យជនទាំងនោះឃើញ ទាំងខ្លួនឯងសោត ក៏មិនចង់ជួបប្រទះនឹងជនទាំងនោះឡើយ ។

## អង្គ ៣ របស់សត្វពាកក្រពាក:

១– មិនបោះបង់ចោលគូស្រករបស់ខ្លួនដរាបដល់អស់ជីវិត ។

២–មានស្វាភាយទឹងចកពន៍ទឹកជាអាហារ ក៏ពេញចិត្តត្រេកអរ ដោយអាហារនោះ ទុកជាត្រេកអរដោយអាហារបែបនេះ ក៏មិនរៀវពោយខ្សោយកំឡាំង នឹងសម្បុរកាយទៅឡើយ ។

៣–មិនបៀតបៀនជីវិតសត្វដទៃឡើយ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ:

១ – មិនលះបង់យោនិសោមនសិការៈ ដរាបដល់អស់ជីវិត ។

២– ជាអ្នកសន្តោស ទុកជាសន្តោសដូច្នេះ ក៏មិនសាបសូន្យចាក កុសលធម៌ទាំងពួងឡើយ គ្រប់ជាបរិបូណ៌ដោយសីល សមាធិ បញ្ញា វិមុត្តិញាណទស្សនៈ ។

៣— មានសេចក្តីខ្មាសអៀនមិនហ៊ានកន្ទង់ល្មើសអំពើដែលគួរខ្មាស មិនបៀតបៀនជីវិតសត្វទៅ មានចិត្តប្រកបដោយមេត្តាករុណាករុណាពួកសត្វទាំងពួង ។

## អង្គ ៣ របស់ពស់ៈ

១ — លូនក្ការទៅដោយដើមទ្រូង ។

២ — លូនទៅប្រទះនឹងដើមស្មៅ ក៏គេចចេញឲ្យផុតពីដើមស្មៅ ។

៣ — ប្រទះនឹងមនុស្ស ក៏កើតសេចក្តីក្តៅក្រហាយចិត្តគិតភ័យគិតតែគេចចៀសឲ្យផុតទៅ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺៈ

១ — ត្រាច់ទៅដោយប្រាជ្ញា វៀរចាករបស់ដែលមិនមែនជាលក្ខណៈចំពោះតែរបស់ដែលជាលក្ខណៈ គឺព្រះត្រៃលក្ខណ៍ ។

២ — វៀរចាកទុច្ចរិត ។

៣ — ចួនជាកើតសេចក្តីត្រិះរិះទៅគន់វិតក្កខុសហើយ ក៏កើតសេចក្តីមិនពេញចិត្តខ្លួនឯង មានសេចក្តីក្តៅក្រហាយ ស្តាយក្រោយហើយផ្លាស់ចិត្តគំនិត មកត្រិះរិះកន់កុសលវិតក្កវិញភ្លាម ជាអ្នកមិនប្រមាទ ព្រោះយប់ថ្ងៃកន្ទង់ទៅហើយ មិនត្រឡប់មកវិញឡើយ ។

## អង្គ ៣ របស់ដើមឈើ ៖

១— ទ្រទ្រង់នូវផ្លែនឹងផ្កា ។

២— ឲ្យពួកមនុស្សចូលអាស្រ័យម្លប់បាន ។

៣— មានម្លប់ផ្សាយចេញទៅជានិច្ច មនុស្សចូលទៅអាស្រ័យបានគ្រប់គ្នាមិនរើសមុខ ។

រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ៖

១— ទ្រទ្រង់នូវផលគឺវិមុត្តិ នឹងផ្កាគឺសាមញ្ញធម៌ ។

២— កាលបើមានភ្ញៀវចូលមករកក៏ទទួលរាក់ទាក់ ដោយអាមិសបដិសណ្ឋារៈនិងធម្មបដិសណ្ឋារៈ ។

៣— មានមេត្តាស្មើភាគ ប្រាសចាកអគតិ ៤ ប្រការ ចំរើនមេត្តាករុណាដល់សព្វសត្វទូទៅស្មើភាគគ្នា ។

## អង្គ ៣ របស់ឆត្រ ៖

១— សម្រាប់បាំងកំដៅលើក្បាល ។

២— ការពារក្បាលឲ្យត្រជាក់ស្រួល ។

៣— បង្ការថ្ងៃនឹងភ្លៀងបាន ។

រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ៖

១ - ជាអ្នកត្រាច់ទៅលើកិលេសទាំងឡាយ ។

២ - ទំនុកបំរុងយោនិសោមនសិការឲ្យកាន់តែច្រើនៗឡើង ។

៣ - កំចាត់នូវភ្លើង ៣ កង ភ្លើងគឺរាគៈ ភ្លើងគឺទោសៈ ភ្លើងគឺមោហៈ និងភ្លើងគឺកិលេសចេញបាន ។

## អង្គ ៣ របស់ស្រែ:

១ - បរិបូណ៌ដោយប្រឡាយទឹក សម្រាប់អ្នកស្រែកាស្រោយ បង្ហូរចូលទៅក្នុងស្រែក្រស្រែស្ងួត ។

២ - បរិបូណ៌ដោយភ្លឺ សម្រាប់អ្នកស្រែទប់ទឹកទុកចំនុក បម្រុងដើមស្រូវឲ្យមានផ្លែផ្កា ។

៣ - បរិបូណ៌ដោយពូជស្រូវ ញាំងម្ចាស់ស្រែឲ្យសប្បាយចិត្ត ព្រោះបើគេព្រោះសាបពូជតែបន្តិចបន្តួចក៏មានផលច្រើន បើព្រោះសាបពូជច្រើន ក៏កាន់តែមានផលច្រើនឡើងទៅទៀត ។

ប្រៀបដូចអ្នកប្រតិបត្តិ ប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺ:

១ - បរិបូណ៌ដោយសេចក្តីសុចរិត និងវត្តប្រតិបត្តិដូចជាប្រឡាយទឹក ។

២ - រក្សាសមណធម៌ដោយសីលដូចជាភ្លឺស្រែ ដើម្បីឲ្យបានសម្រេចសាមញ្ញផលទាំង ៤ ។

៣ — បរិបូណ៌ដោយព្យាយាមៈ បង្កើតផលចំរើនដល់ពួកទាយកទាយិកា ញុំាងសេចក្តីរីករាយឲ្យកើតឡើងដល់ពួកទាយកទាយិកា បើទុកជាឲ្យតិចក៏បានផលច្រើនជាអនេក បើបានជាឲ្យច្រើន ក៏កាន់តែមានផលចំរើនឡើងទៅទៀត ។

## អង្គ ៣ របស់កែវមណីៈ

១ — មានសាច់ម៉ដ្ឋល្អជាបំផុត ។

២ — មិនប្រឡាក់ដោយគ្រឿងសៅហ្មងយ៉ាងណាមួយឡើយ ។

៣ — ប្រភេទកែវមណីក៏នៅនឹងប្រភេទកែវមណីផងគ្នា ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៣ ប្រការគឺៈ

១ — ចិញ្ចឹមជីវិតបរិសុទ្ធហ្មត់ចត់ជាបំផុត ។

២ — មិនច្រឡូកច្របល់ដោយបាបមិត្រ ដែលមានចិត្តអាក្រក់ថោកទាប ។

៣ — នៅរួមតែនឹងអ្នកដែលមានជាតិឧត្តមប្រសើរ មានសេចក្តីបរិសុទ្ធហ្មត់ចត់ដូរផង ។

## ពួកមានអង្គ ៤

### អង្គ ៤ របស់ស្តេចចក្រពត្តិៈ

១ — ទ្រង់ថែរក្សាទឹកចិត្តរបស់ប្រជាជនដោយសង្គហវត្ថុ ៤ ប្រការ ។

២- ពួកចោរជាសត្រូវនឹងផែនដីមិនមានកើតឡើងក្នុងរាជអាណាចក្រឡើយ ។

៣- តែងទ្រង់ពិចារណាអំពីសេចក្តីល្អអាក្រក់ ទ្រង់ណែនាំប្រជានុរាស្ត្រទាំងផែនដីដ៏ទូលាយ មានមហាសមុទ្រជាទីបំផុត ឲ្យប្រតិបត្តិតាមគន្លងធម៌ ។

៤- ទ្រង់ចាត់ការគ្រប់គ្រងការពាររាជអាណាចក្រយ៉ាងម៉ឺងម៉ាត់ ឲ្យមានការរក្សាទាំងខាងក្នុងទាំងខាងក្រៅ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៤ ប្រការ ៖

១- ថែរក្សាចិត្តរបស់បរិសទ្យ អនុគ្រោះបរិសទ្យឲ្យមានចិត្តសប្បាយរីករាយ ។

២- កាមវិតក្ក ព្យាបាទវិតក្ក វិហិង្សាវិតក្ក ដូចជាខ្មាំងសត្រូវ មិនមានកើតឡើងក្នុងសន្តានចិត្តឡើយ ។

៣- តែងពិចារណាជម្រះផុតខាត់កាយកម្ម វចីកម្ម មនោកម្ម ស្អាតថ្លៃថ្លា យប់ថ្ងៃដែលកន្លងទៅ មានប៉ះពាល់ដោយហេតុទាំង ៣ នេះខ្វះឬទេ ។

៤- តាំងប្រឹងស្មារតីដូចជាឆ្មាំទ្វារឲ្យនៅចាំប្រាបប្រាម កងកិលេសទាំងខាងក្នុង ទាំងខាងក្រៅ ។

(មានត)

# ពិធីព្រះរាជទានសមណស័ក្តិ

## ទីសម្តេច និងទីភាជាគណៈវត្តបទុមវតី

នៅថ្ងៃព្រហស្បតិ៍-សុក្រ-សៅរ៍ ៣-៤-៥ កើតខែអស្សុជ ឆ្នាំវក ឆស័ក ព. ស. ២៤៨៧ ត្រូវនឹងថ្ងៃ ៥-៦-៧ ខែអុកតូប្រ៍ឆ្នាំ ១៩៤៤ វេលាម៉ោង ៨ យប់ និមន្តព្រះសង្ឃ ២៥ អង្គចំរើនព្រះបរិត្តក្នុងវិហារវត្តបទុមវតី គ្រប់ទាំង ៣ ថ្ងៃខាងលើនេះ ។

ដល់ថ្ងៃអាទិត្យ ៦ កើតខែអស្សុជ ៨ អុកតូប្រ៍ឆ្នាំនេះ វេលាម៉ោង ៩ និង ៣០ នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងលោករ៉េស៊ីដង់ស៊ុបេរីយើរ ទ្រង់ស្តេចយាង-អញ្ជើញដល់វត្តបទុមវតី មានក្រុមគ្រួព្រះអង្គនឹងក្រុមក្មេងសម្រាប់កជ្យចាំទទួល លុះព្រះករុណានឹងលោកនាយកកម្ពុជាស្តេចយាង-អញ្ជើញចូលទៅក្នុងវិហាររួចហើយ ទើបលោក (ញ៉ឹក-ឌូ) យកភួងផ្កា ១ កម្រងថ្វាយព្រះករុណា លោកឧកញ៉ាទេពពិទូរ (ក្រសេម) យកភួងផ្កា ១ កម្រងជូនលោកនាយកប្រទេសកម្ពុជា ធ្វើសក្ការបូជាព្រះរតនត្រ័យ ស្រេចហើយលោកអ្នកឧកញ៉ាអគ្គមហាសេនា (អ៊ីង-អ៊ី) សេនាបតីក្រសួងវាំង, ព្រះឃ្លាំងនិងធម្មការបានហៅនាមព្រះមហាថេរដែលត្រូវឡើងសមណស័ក្តិជាន់ខ្ពស់ ឲ្យនិមន្តចូលមួយអង្គម្តងៗ តាមលំដាប់លោកនាយកប្រទេសកម្ពុជា បានប្រគេនសញ្ញាប័ត្រព្រះករុណាទ្រង់ប្រោសព្រះរាជទានផ្លូវសមណស័ក្តិ ដែលត្រូវតាមសញ្ញាប័ត្រនោះដល់ព្រះសង្ឃទាំង ៥ អង្គគឺ៖

១- ព្រះសុធម្មាធិបតី ( អ៊ុក-ស្រី ) បានឡើងសមណស័ក្តិជាសម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តិ វត្តបទុមវតី ។

២ - ព្រះវិមលធម្ម ( កែប – កួន ) បានឡើងសមណស័ក្តិជាព្រះមង្គលទេពាចារ្យ រាជាគណៈសម្រាប់ឯក វត្តបទុមវតី ។

៣ - ព្រះញាណវិរិយ ( លឿន ) បានឡើងសមណស័ក្តិជាព្រះធម្មកវីវង្ស សម្រាប់ត្រី ចៅអធិការ វត្តទួលមណីរ័ក្ស ។

៤ - ព្រះអមរាភិរក្ខិត ( ជុំ ) បានឡើងសមណស័ក្តិជាព្រះទេពបាល-វង្សរាជាគណៈសម្រាប់ត្រី វត្តបទុមវតី ។

៥ - ព្រះវីរមេធា ( កែវ-អូច ) បានឡើងសមណស័ក្តិជាព្រះអរិយកស្សប រាជាគណៈសម្រាប់ត្រី វត្តបទុមវតី ។

កាលស្រេចកិច្ចប្រគេនសញ្ញាប័ត្រទីផ្តិតនេះហើយ ទើបព្រះករុណា, លោកនាយកប្រទេសកម្ពុជា, សម្តេចព្រះសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ. និងអស់លោក-អ្នកដែលបានអញ្ជើញមកក្នុងមហាសន្និបាតនេះទាំងអស់ បានថ្វាយស័ព្ទសាធុការពរប្រគេនចំពោះសម្តេចព្រះសុធម្មាធិបតី ដើម្បីឲ្យមានសិរីសួស្តីជ័យមង្គលតទៅ សម្តេចព្រះសុធម្មាធិបតី ក៏បានថ្វាយសុន្ទរកថាទទួលសេចក្តីអំណររបស់លោកវិញ ។

លុះប្រគេនស័ព្ទសាធុការពររួចហើយ នៅវេលាម៉ោង ១០ គេបាននិមន្តសម្តេចព្រះសុធម្មាធិបតីចេញពីក្នុងវិហារ ទៅគង់លើកន្សាំងដែល

ធ្វើលើកេយវិហារខាងមុខ មានកំពូលស្រួច ប្រដាប់ដោយក្បាច់រចនា ភ្លឺថ្លាយ៉ាងស្រស់ វេលានោះ ព្រះករុណា ទ្រង់ស្តេចយាងទៅប្រថាប់ពីខាងមុខកនមាំ ហើយទ្រង់ប្រោសព្រះកជតានស្រោចទឹកមន្តលើព្រះហស្ត សម្តេចព្រះសុធម្មាធិបតី បន្ទាប់មកលោកនាយកកម្ពុជា សម្តេចព្រះសុមេធាធិបតី ព្រមទាំងអស់លោករដ្ឋមន្ត្រីប្តូរស្រោចវៀនគ្នាជាលំដាប់ ចំណែកព្រះសង្ឃទាំងពួងដែលគង់ក្នុងវិហារក៏សូត្រធម៌ជ-យន្តោចំរើនពរជ័យមង្គល ទាំងភ្លេងផ្សេងទ្រីគំបន្ទឺស្នូរស័ព្ទកងរំពងព្រមគ្នាជាសញ្ញាសំគាល់ថាបានប្រគេនទក្ខិណោទក ចំពោះសម្តេចព្រះសុធម្មាធិបតី នៅវេលាស្រេចកិច្ចនេះហើយ ព្រះករុណា និងលោកនាយកប្រទេសកម្ពុជា ទ្រង់ស្តេចយាង-អញ្ជើញត្រឡប់ទៅវិញ នៅវេលាម៉ោង ១០ និង ២០ នាទី ។

☼

☼ ☼

ដល់ថ្ងៃចន្ទ ៩ ឧកក្កប្រំ ក្រុមឧបាសក-សិកាចំណុះវត្តបទុមវតីទាំងអស់មានព្រះសុធម្មប្រីជា ( ឧខ ) អាចារ្យសម្រាប់វត្តជាប្រធានបានតាក់តែងចង្ហាន់និមន្តព្រះសង្ឃ ៧៥ អង្គទទួលបិណ្ឌបាតនៅមុខវិ-ហារ ក្នុងវេលាម៉ោង ៨ ព្រឹកជាកិច្ចបង្ហើយពិធីបុណ្យត្រឹមប៉ុណ្ណេះ ។

មួយទៀត ក្នុងពិធីបុណ្យសម្ពោធនេះ គេសង្កេតឃើញថាជាទំរុង-រឿងដ៏ឧឡារិក ដោយមានធ្វើស៊ុំក្លោងទ្វារ ១ ចំពីខាងមុខវិហារ មានបាក់ ៤ ខ្នងនៅអមសងខាងស៊ុំទ្វារនេះ ប្រដាប់ដោយទង់ជាតិដ៏ដេរ

ដាស ជាកន្លែងសម្រាប់ទទួលអស់លោកមន្ត្រីធំ-តូច ដែលអញ្ជើញមកក្នុងមហាសន្និបាតនោះដោយសេចក្ដីរីករាយសាទរ ។

ចំណែកខាងបព្វជិតគឺ: សម្ដេចព្រះមហាសុមេធាធិបតី ( ហ៊ុន ) សង្ឃនាយកគណៈមហានិកាយ, ព្រះពោធិវង្ស (ជួន-ណាត) ចាងហ្វាងសាលាបាលីជាន់ខ្ពស់ ដែលជាចៅអធិការវត្តឧណ្ណាលោម, ព្រះមហា-ព្រហ្មមុនី (ទេព-អ៊ូ) ចាងហ្វាងរងសាលាបាលីជាន់ខ្ពស់ ដែលជាចៅអធិការវត្តស្វាយពពែ (ទីរឿនហួន), ព្រះមហាវិមលធម្ម (ហ៊ួត-តាត) អធិបតីក្រុមជំនុំព្រះត្រៃបិដកក្រសួងពុទ្ធសាសនបណ្ឌិត្យ ព្រមទាំងព្រះមហាថេរានុត្ថេរជាច្រើនអង្គទៀត ។

ផែកខាងគ្រហស្ថគឺ: (ក្រៅពីព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងលោករ៉េស៊ីដង់ស៊ុបេរីយើរកម្ពុជរដ្ឋ) មានលោក ដឺឡ្វង់ នាយកពដការក្រុមមឿង, លោកបារូ ដេឡេគេនៅអមយកផការខ្មែរ, លោកខុយ-ប៊ុនគំ អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ, លោកដេឡេគេក្នុងព្រះប-រេមកជាប់នឹងលោកគណរដ្ឋមន្ត្រីទាំងអស់ មានលោកអ្នកឧកញ៉ាអគ្គម-ហាសេនា (ភីន-អ៊ី) សេនាបតីក្រសួងក្រុងព្រះឃ្លាំងនិងធម្មការជាដើម ។

ចំណែកពួកឧបាសក-សិកាជើងវត្តបទុមវតី ក៏ព្រមព្រៀងគ្នាមួយមកជួបជុំគគ្គយបង្អៀតគក់ក្នុងទីព្រះវិហារ ស្ទើរនៅទីកលខាងមុខព្រះវិហារក៏មានមនុស្សប្រុសស្រីក្មេងចាស់ឈរកុះករជាច្រើនណាស់ដែរ ។

# កែពាក្យខុស

សៀវភៅលេខ ១០ ទំព័រ ៥១០ បន្ទាត់ ១ បរណ្ដា

ទី ៤៧ ពាក្យថា មានបន្ទា . . .

សូមកែថា មានបន្ទាជុំខ្លួន . . .

សៀវភៅៈលេខ ១០ ទំព័រ ៥២២ បន្ទាត់ ១៦

ពាក្យថា ឃើញពួកគេ . . .

សូមកែថា ឃើញពូគេ . . .

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ឹម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ក្រុមជំនុំលទ្ធិទំនៀមខ្មែរ . . . . | ប្រកាសតែងប្រកួតរឿងបុណ្យភ្ជុំបិណ្ឌ . . . | ៦០៧ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . | សេចក្ដីពន្យល់អំពីពាក្យខ្មែរខ្លះ ក្នុងសេចក្ដីរាយការជាភាសាចិន ក្នុងសតវត្សរ៍ ទី ១៣ (តាមអត្ថាធិប្បាយរបស់លោកសឺដែស). . | ៦០៩ |
| លោក ហាន់-យេង . . . . . . | រឿងកំពូលកំសត់ (តមកនឹងចប់) . . . . . | ៦២៩ |
| បុរសបណ្ណារក្ស ប៊ូ-ប៊ូ . . . . | ដំរៀលសិល្បសាស្ត្រ (តមកនឹងចប់). . . . | ៦៣៨ |

ផ្នែកសាសនា

| | | |
|---|---|---|
| លោកព្រះចៅអធិការ ឯក-ញឹម . | ធម្មបទភាសិត (តមកនឹងចប់) . . . . . . | ៦៤៨ |
| ពុទ្ធសាសនបណ្ឌិត្យ . . . . | ពិធីប្រគល់ព្រះរាជក្រឹត្យ . . . . . . . . . | ៦៦០ |
| " " | ភ្នាក់ងារពុទ្ធសាសនបណ្ឌិត្យបានទទួល ព្រះរាជទានគ្រឿងឥស្សរិយយស . . . . . . | ៦៦៣ |
| ដំណឹងអំពីក្រសួងធម្មការ . . . | សេចក្ដីរាយការសង្ខេបនៃមហាសង្ឃសន្និបាត នៅវត្តព្រះកែវ និងវត្តសារាវ័ន . . . . . . | ៦៦៥ |
| " " | អំពីតាំងចៅអធិការថ្មី . . . . . . . . . . | ៦៦៨ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . | ឯកភាពនៃមិលិន្ទបញ្ហា (តមក) . . . . . | ៦៧០ |

# KĂMPUCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Luong Nibandhamantri Nhok-Thèm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Preah kru Paññalikhito Kao-Sim, Surveillant général de l'École Supérieure de Pāli.

## *TABLE DES MATIÈRES*

**Partie littéraire:**

| | | Pages |
|---|---|---|
| Commission des mœurs et coutumes cambodgiennes | Concours littéraires sur la fête de P'chŏm-Bĕn . . . . . . . . . | 617 |
| Luong Nipoumontrei Nhok-Thêm. . . . . . | Explication de quelques mots cambodgiens contenus dans les rapports chinois du 13e siècle (d'après les travaux de M. Cœdès) | 619 |
| Monsieur Han-Yéng. . . . | Kămpul kĭmsăt, roman (suite et fin) | 628 |
| K'ŭn Pannanĭrak Bou-Po | Dĭmlĭi sĭlpăsas (suite et fin) . . | 638 |

**Partie religieuse:**

| | | |
|---|---|---|
| Vénérable Chau At'ikar Ek-Nhim . . . . . . | Tĕammĕabăt p'easĕt (suite et fin) . . | 648 |
| Institut Bouddhique . . . | Compte-rendu de la remise de titres honorifiques aux membres du personnel de l'Institut Bouddhique . . . . . . . . . . . . . | 660 |
| » » | Compte-rendu de la remise de décorations cambodgiennes aux membres du personnel de l'Institut Bouddhique et du Musée A. Sarraut . . . . . . . . . . | 663 |
| Communiqué du Département des Cultes . . . | Compte-rendu de la réunion des chefs de diocèses à Véat Prĕah Kĕv et à Vĕat Saravĕan . . . . . . . | 665 |
| » » | Nominations de nouveaux Chau At'ikar . . . . . . . . . . . . | 668 |
| Luong Nipoumontrei Nhok-Thêm . . . . . . . | Ekă'dăga-Milindapañhā (suite) . . . | 670 |

## ជូនពរសួស្ដីសាធុការចូលឆ្នាំថ្មី

គ្រិស្ដសករាជ ១៩៤៥

នៅឱកាសចូលឆ្នាំថ្មីនៃជាតិបារាំង-ខ្មែរ ដែលគណៈការទើបបានកែប្រែថ្មី ជាប់តាំងពីថ្ងៃ ១ យ៉ាំងវីយេ គ្រិស្ដសករាជ ១៩៤៥ ជាដើមទៅ ដើម្បីធ្វើតាមបែប លោកនិយម នោះកម្ពុជសុរិយាសូមជូនពរសួស្ដីសាធុការដោយស្មោះស្ម័គ្រចំពោះ គ្រប់អស់លោក-អ្នកជាវទស្សនាវដ្ដី កម្ពុជសុរិយានេះគ្រប់រូប ព្រមទាំងទេវតាជាតិ ក្នុងកម្ពុជរដ្ឋ-សហព័ន្ធឥណ្ឌូស៊ីន-មហានគរបារាំងសែស សូមឲ្យបានប្រកបដោយពរ ៤ ប្រការ គឺ៖ អាយុ វណ្ណៈ សុខៈ ពលៈ គ្រប់ទិវារាត្រីកុំបីឃ្លាតឡើយ ។

## ប្រកាសតែងប្រកួតរឿងបុណ្យភ្ជុំបិណ្ឌ

ក្រុមជំនុំលទ្ធិទំនៀមខ្មែរ នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ សូមប្រកាសដល់អស់លោក-អ្នកចេះដឹងទាំងឡាយសូមជ្រាប ។

ដ្បិតក្រុមនេះ ត្រូវការចង់ដឹងពីរបៀបធ្វើបុណ្យភ្ជុំបិណ្ឌ តាមទំនៀមទម្លាប់ដែលគេធ្វើនៅក្នុងវត្ត-ស្រុកផ្សេងៗ ក្នុងនគរកម្ពុជានេះ ជាមានរបៀបផ្សេងគ្នាដូចម្ដេចខ្លះ?

ហេតុនេះសូមលោកអ្នកចេះដឹងទាំងឡាយ មេត្តាតែងរឿងនោះ តាមរបៀបដែលធ្លាប់ធ្វើក្នុងស្រុករបស់ខ្លួនមានភស្តុការ និងរបៀបដូចម្ដេចខ្លះសុំតែងឲ្យបានពិស្ដារល្អិតល្អសព្វគ្រប់ រៀងតាំងពីដើមរហូតដល់

ចប់ កុំឲ្យមានខ្វះចន្លោះឡើយសោះ ទាំងសូមឲ្យប្រាប់ថា របៀបពិធីបុណ្យនេះធ្វើតាមគម្ពីរ-គម្រាក្ខុះទៀបក្បួនណាសំផង ឬបើមានពិធី-កិច្ចអ្វីទៀតរួមជាមួយនឹងបុណ្យនេះក៏សូមអធិប្បាយផង ហើយផ្ញើទៅឲ្យក្រុមជំនុំដូចមានការណ៍លើឲ្យបានមុនថ្ងៃ ១៥ កើតខែផល្គុណ ។

ក្រុមជំនុំទទួលហើយ នឹងពិនិត្យមើល ការឆ្លើយរបស់លោក-អ្នកណាដែលត្រឹមត្រូវល្អ នឹងជូនជារង្វាន់តាមសមគួរ ។ រង្វាន់នោះមាន ៣ ថ្នាក់ គឺរង្វាន់លេខ ១ លេខ ២ លេខ ៣ តាមលំដាប់ដែលល្អអាក្រក់ជាងគ្នា ហើយនឹងមានចុះដំណឹងផ្សាយព័ត៌មានឈ្មោះអ្នកដែលបានរង្វាន់នេះផង ។ រឿងដែលជូនទៅនោះនឹងរក្សាទុកជាសម្បត្តិនៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ជាប្រយោជន៍ដល់អ្នកសិក្សាទាំងឡាយតទៅ ។

ក្រុមជំនុំមានសេចក្ដីសង្ឃឹមជាប់ផុតថា អស់លោក-អ្នកចេះដឹងទាំងឡាយនឹងជាមេត្តាឈឺឆ្អាលតែងឲ្យបានរឿងរ៉ាវល្អដូចបានសុំមក ។

ក្រុមជំនុំលទ្ធិទំនៀមខ្មែរ

# សេចក្ដីអធិប្បាយ

ពន្យល់អំពីពាក្យខ្មែរខ្លះ ក្នុងសេចក្ដីរាយការណ៍ភាសាចិនរបស់ចៅ - តា - កួន

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក - ថែម

ស្រង់ទីនាំប្រែចេញពីទស្សនាវដ្ដីរបស់សាលាបារាំងសែស

ចុងបូព៌ាប្រទេស (BEFEO., XVIII, p.4) (១)

---

រឿងរ៉ាវរបស់អ្នកដំណើរឈ្មោះ ចៅ-តា កួន ដែលចូលមកមើលស្រុកខ្មែរ ក្នុងឆ្នាំ ១២៩៦ នោះមានជាប់ពាក្យខ្មែរជាច្រើន ក្នុងសេចក្ដីកត់ត្រាជាភាសាចិន ។ លោកអាយម៉ូនញេរ និងលោកហ្វី-ណូត៍បានធ្វើសេចក្ដីពន្យល់ពាក្យខ្មែរបន្ថែម ក្នុងសេចក្ដីប្រែរបស់លោកប៉េល្លី-យោត៍ ។ ក្នុងទីនេះ លោកសឺដេសតាំងហ្លួងសាលាបារាំងសែសនៅចុងបូព៌ាប្រទេស បានទាញពាក្យបំពេញលើសេចក្ដីអធិប្បាយទាំងនោះជាថ្មីទៀតខ្លះ ដូចមានតទៅនេះ:

### ត្រង់ពាក្យ : ចា-ណាន, ហ្វូ-ឈៀន, កាន-ប៉ាង

អំពីមាត់ពាមសមុទ្រ គេអាចទៅតាមផ្លូវទឹកបានស្រួលតាមទិសខាងជើង ក្នុងវេលា ១៥ ថ្ងៃ, ដល់ប្រទេស ១ ហៅថា ចា - ណាន

---

១. សេចក្ដីរាយការណ៍របស់ ចៅ - តា - កួន នេះយើងបានប្រែចុះផ្សាយក្នុងកម្ពុជសុរិយាខាង:នឹងឆ្នាំៗ នេះរួចមកហើយ ហៅថា "រឿងអង្គរក្នុងសតវត្សរ៍ទី ១៣" ទើបគួរចុះរឿងនេះនៅទីការសម្រេចរាប់ឆ្នាំ ១ នេះ ។

ដែលមានកងការខ្មែរកាន់កាប់គៀប ។ តអំពី តា-ណាន គេកាបចុះទូក ខ្នាតតូច ហើយធ្វើដំណើរតាមខ្សែទឹក ១០ ថ្ងៃ ឆ្លងកាត់ទៅប៉ាន-លូ-ឈៀន (ភូមិព្រះពុទ្ធ) ហើយឆ្លងសមុទ្រទឹកសាបទៅ ទើបដល់ទៅកាន់-ប៉ាង នៅចម្ងាយ ៥០ លី ពីទីក្រុង" ។

លោកអាយម៉ូញេរបានបន្ថែមប្រាប់ថា តា-ណាន នៅកំពង់ឆ្នាំង, ប៉ុន្តែលោកប៉េលីយ៉ូយល់សមខាង ក្រុងពេញជាង ។ លោកនេះពោលថា "មិនត្រូវភ្លេចថា គេធ្វើដំណើរដើមទឹក ១៥ ថ្ងៃ ទើបដល់ តា-ណាន ហើយនៅ ១០ ថ្ងៃទៀត ទើបដល់ផ្លូវចូលទៅស្ទឹងសៀមរាប; កំពង់ឆ្នាំងផុតទៅខាងចុងដំណើរពេក មួយទៀតពាក្យនឹងកំណត់ភូមិ ឬស្រុកទាំងពីរ គឺ ប៉ាន លូ-ឈៀន និងហ្វូ-ឈៀន នៅចន្លោះកំពង់ឆ្នាំង និងផ្លូវដែលចូលទៅទន្លេសាប ប្រសិនបើយើងយក តា-ណាន នៅមាត់ទន្លេបួនមុខ ប៉ាន-លូ-ឈៀន អាចជាស្រុកកំពង់ឆ្នាំង ហ្វូ-ឈៀន (ភូមិព្រះពុទ្ធ) ប្រហែលនៅត្រឹមបរិបូណ៌ ដ្បិតទីនោះធ្លាប់ជាទីមានព្រះពុទ្ធសាសនាចំរើនរុងរឿងមកគួរសមដែរ" ។

តែលោកសឺដេសយល់ថា តា-ណាន ប្រាកដជានៅក្នុងតំបន់កំពង់ឆ្នាំង ព្រោះមានស្តូបសំណៀងប្រហែលគ្នា ហើយប្រហែលជា ចៅ-តា-កួន ចេញមកពីស្រុកចិនតាមផ្លូវខ្យល់មូស្សុងទិសឦសាន ។ ហេតុនេះ ចៅ-តាកួនចូលមកក្នុងទន្លេ ក្នុងពេលសម្រក ដោយ

ហេតុតែកសម្រែកនេះហើយបានជាមិនបាច់ផ្លាស់ទូកនៅភ្នំពេញ "ប្រើទូកឆ្នាកតូច" ព្រោះទូកធំៗ អាចចេញចូលតាមដៃទន្លេសាបបានគ្រប់ផ្លូវៗ ការដែលផ្លាស់ទូកនៅកំពង់ឆ្នាំង ព្រោះគេបានចូលតាមប្រឡាយទឹកគេបានប្រើទូកតូចទើបទៅបាន ។ ក្នុងពេលដែលចៅ-តាក្វន ធ្វើដំណើរពីមាត់ពាមសមុទ្រហូតមកដល់ទន្លេសាបនោះខ្សែទឹកមិនហូរខ្លាំងទេ ទើបមិនបាច់ឲ្យនឿងធ្លាក់រាដំណើរកន្លងមាត់ពាមសមុទ្រទីងកំពង់ឆ្នាំង ជារយៈវេលា ១៥ ថ្ងៃ ហើយ ចៅ-តាក្វន ដើរផ្លូវដល់ ១០ ថ្ងៃទៀត ទើបដល់កំពង់ចូលទៅស្រុកអង្គរ ។ ត្រង់ពាក្យថា "ទ្វងសមុទ្រទឹកសាប" មិនមែនអធិប្បាយថា ពួកជើងថែរដែលនាំអ្នកដំណើរជាតិចិនសំដៅទៅកំពង់ទន្លេសាបរហូតចូលទៅតាមស្ទឹងអង្គរទេ គឺប្រាកដជាទូកទៅតាមផ្លូវដែលភ្ជាប់ប្រើញឹកញយនោះឯង ហើយសសៀរទៅឆ្នេរទន្លេខាងត្បូងរហូតដល់ពោធិ៍សាត់ មុនឆ្លងកាត់ទទឹងទន្លេសាប រួចកាត់សំដៅទៅប្រាយភ្នំក្រោម ដូច្នេះទើបឃើញថា បា-ណាន ទៅត្រឹមកំពង់ឆ្នាំង, ប៉ាន-លូ-ឈៀន និង ហ៊ូ-ឈៀន មិនមែននៅចន្លោះត្រង់កំបន់ថយមកក្រោយ នឹងកំពង់ទន្លេសាបទេ គឺនៅត្រង់មាត់ទន្លេសាបខាងត្បូង ។ ដូច្នេះ ទើបខ្ញុំ (លោក សឺដេស) ដោយកហ៊ូ-ឈៀន "ភូមិព្រះពុទ្ធ" នៅពោធិ៍សាត់ ដែលមានឈ្មោះប្រាកដមក គេតែងដឹងថាស្រុកពោធិ៍សាត់ (ពោធិសត្វ) ។

កាន់-ប៉ាំង ប្រាកដជាត្រូវនឹងពាក្យថា កំពង់ លោកបើល្ងិ-យោគ ពន្យល់ពាក្យនេះថា គេអាចប្រើសំដៅយកកំពង់ដែលពិតប្រាកដមួយ ៗ ប៉ុន្តែពាក្យនេះមិនជាការចំឡែកទេ ព្រោះទម្លាប់និយាយភាសាខ្មែរ ពីសម័យបៀរ — ការក្លួនបោតមកដល់ឥឡូវនេះ មិនទាន់ប្រែប្រួលប៉ុន្មានទេ ដូចជាទម្លាប់និយាយសព្វថ្ងៃនេះ បើលោកសួរគេដែលចេញពីផ្ទះទៅកំពង់ហ្លួង ថា "ទៅណា?" គេឆ្លើយថា "ទៅកំពង់ហ្លួង" ដូច្នេះ ក្នុង ១០ នាក់តែ ៦ ទេ ច្រើនតែនិយាយថា បើអ្នកសួរគេថា "ទៅណា" គេឆ្លើយកំបុតៗថា "ទៅកំពង់" ។ ពាក្យថា កំពង់ ដែលអ្នកដំណើរចេញចាប់ឡើងទៅនោះ ប្រាកដជាអ្នកបកប្រែភាសាសួរពួកចិនតែក្នុងវេលាដែលទូកដល់កំពង់ ពួកអ្នកចែវក៏ឆ្លើយខ្លីៗថា "កំពង់" ទៀត - ការក្លួនក៏ចាប់យកពាក្យសាធារណនាម ត្រឡប់ទៅអសាធារណ-នាមទៅវិញ (ដោយសំគាល់ថាជាឈ្មោះតំបន់) ។

## ត្រង់ពាក្យៈ ម៉ាន-ទិង ប៉ាំ-ឆា

"ចំឡាក់ទើបមកដល់ប្ដីស្មៀកសំពត់ជាទៅតែពីរដុង" ដូចម៉ាន-ទិង-ប៉ាំឆា តែចិនៈនេះមិនត្រូវគេប្ដឹងផ្ដល់ទេ ។ ម៉ាន-ទិង ប៉ាំឆា គឺអ្នកមិនស្គាល់ចំនៀមគេ" ។

'ផាំន-ទិន, លោកហ៊ុយណូត៍អធិប្បាយថា ត្រូវនឹងពាក្យថា មិនគន់ (មិនដឹង) ពាក្យនេះគេប្រើសម្រាប់ច្បាប់ផង ឯពាក្យពីរម៉ាត់ទៀត គឺប៉ា-ធា ត្រូវនឹងភាសា ។

ឯពាក្យថា "ភាសា" នេះមិនមែនសំដៅសេចក្ដីត្រឹម "សំដី" ប៉ុណ្ណោះទេ គឺគាបប្រែថា របៀប, វិធី, សេចក្ដីប្រព្រឹត្ដិ" ។ ពាក្យនេះនៅមានប្រើប្រាស់ក្នុងភាសាសៀម ដូចពាក្យថា "ភាសាដេក: គឺរបៀបឫកពារបស់ក្មេង" "ម៉ៃរូប័កភាសា : គឺមិនដឹងអ្វីទៀយ" សំនួនបែបនេះត្រូវនឹងពាក្យដែលពៀរ-តាគួនចាប់យកមកនិយាយទុះឯង ។

## ត្រង់ពាក្យៈ ស៊ឺ-ឡា-ទី (Sseu-la-ti)

"ពួកមន្ត្រីមានច្បាប់ប្រើក្លស់មាស ហៅថា ប៉ាំ-ទិន ឬ ផាំន-ទិន, ពួកផែលប្រើក្លស់ប្រាក់ហៅថា "ស៊ី-ឡា-ទី" ។

ពាក្យ "ប៉ាំ-ទិន" ប្រហែលនឹងពាក្យបារីកថា 'ម្រគាញ ឬម្រេតន៍" ។ បំណែតឯ ស៊ី-ឡា-ទី នោះខ្ញុំជឿថា ត្រូវនឹងពាក្យសំស្ក្រឹត: ត្រែច្ចិន ពាក្យនេះមាននៅក្នុងសិលាចារឹកលវៃ ។

សូរសំឡេងពាក្យចិន និងសំស្ក្រឹត: ស៊ី-ឡា-ទី និងត្រៃច្ចិន ប្រហែលគ្នា ជិតគ្នាគ្រាន់បើ ។ ឯពាក្យក្រោយនេះ ខ្ញុំមិនជឿថា សំដៅយក "អ្នកជំនួញ" ឈ្មួញទេ ។ ពៀរ-តាគួនគង់ចង់បង្ហាញពី

ជាន់ជាងរបស់ពួកនាហ្មឺនមន្ត្រីខ្ពស់–ទាបចំពួកខ្លះ ហើយពាក្យថា គ្រប៉ិននេះក៏ប៉ុនគ្នានឹងពាក្យថា ពណ៌គ្រប៉ះ (នាយកនៃវណ្ណៈគឺពួកដែលមានទៅក្នុងតារាំងប្រាសាទតាកែវនោះឯង ។

## ត្រង់ពាក្យៈ ជូ–គូ

### "ពួកលោកសង្ឃគេហៅថា ជូ-គូ"

ពាក្យនេះ លោកហ្វីណូត៍ថា ប្រហែលជាត្រូវនឹងពាក្យសៀម ថា "ចៅគូ" ដែលប្រែថា គ្រូ-គ្រូ ។

ពាក្យ "ចៅគូ" នេះគេប្រើនិយាយសំដៅយកលោកសង្ឃក្នុងពុទ្ធសាសនា ក្នុងភាសាសៀមបុរាណ តាមដែលពួកអ្នកដំណើរក្នុងសតវត្សរ៍ទី ១៧ បានពោលទុកមក ទឹងសេចក្ដីថាភាសាសៀមបុរាណ. ពាក្យនេះជាពាក្យសៀមសុទ្ធមិនមែនគ្រាន់តែប្រហែលទេ ។

ឯពាក្យថា គូ នោះ មិនមែនចេញមកពីពាក្យថា គ្រូ នោះទេ គឺពាក្យនេះជាសព្វនាម បឋមបុរស ហេតុនេះ ពាក្យថា "ចៅ" ម្ចាស់. ចៅហ្វាយ "គូ" អញ, ចៅគូ ម្ចាស់អញ ត្រូវនឹងពាក្យក្នុងសិលាចារឹកខ្មែរ ថា "កម្រតេង អញ" អញ ជាសព្វនាមបឋមបុរស[១] (Monseigneur) ។

---

(១) គឺដូចពាក្យថា អ្នកយេង (អ្នកយើង) នៃប្រើសំដៅយកលោកសង្ឃ មានក្នុង សិលាចារឹកនគរវត្ត (Aymonier, Cambodge III, p. 286).

នៅចុងសតវត្សរ៍ទី ១៣ លោកសង្ឃពុទ្ធសាសនាបានតាំងឡើង ហើយក្នុងស្រុកខ្មែរ ដោយនិយមប្រើតាមពាក្យថៃ ។

## ត្រង់ពាក្យៈ បេន-កៀ-ខ្លាន

"ពួកស្រីដែលធ្វើការបម្រើនៅក្នុងវាំង គេហៅថា បេន-កៀ-ខ្លាន" ។ អធិប្បាយៈ "លោកកាបាតុងយល់ថា ស្រិង្គារៈ គឺស្រីក្នុងរាជសំណាក់; លោកអាយម៉ូញេ ថាសំដៅយក ឃ្លាំង: គឺព្រះឃ្លាំងៈស្ដេច ហើយច្រើនតែជាវាំងផង" ។

ពាក្យដែលលោកកាបាតុងពោលនេះសមណាស់ ពាក្យជាអក្សរចិននេះ ច្បាស់ជាចេញមកពីពាក្យសំស្ក្រឹតថា ត្រិង្គារ ។ ពាក្យនេះតាមសព្ទដើមប្រែថា "គ្រឿងប្រដាប់ទីងសេចក្ដីស្នេហា" យកមកប្រើក្នុងភាសាខ្មែរច្រើនសំដៅយក "ស្រីរូបល្អ" ចំពោះក្នុងរាជសំណាក់បានដល់ពួកស្រីព្រះស្នំ ឬស្ត្រីបរិវាររបស់មហាក្សត្រ ។ មានឧទាហរណ៍ដូចក្នុងសិលាចារឹកអង្គរវត្ត ក្នុងឆ្នាំ ១៥៧៩ (Nº 6 B របស់លោកអាយម៉ូញេ Cambodge, III, p. 292) ដូច្នេះ "សូមឲ្យពួកទេវតាមកប្រជុំគ្នាជួយទំនុកបំរុងព្រះមហាក្សត្រ (ជាមហាឧបាសក) ព្រះរាជទេវី, ព្រះរាជបុត្រ ព្រះរាជមាតា, ពួកស្ត្រីជាបរិវារ (គឺត្រិង្គារបរិវារ) ពួកគ្រូពួកព្រាហ្មណ៍, ពួកមន្ត្រី, ជាដើម ..." ។

# ត្រង់ពាក្យៈ បេ–ខ្មៀ

"គាពុកធំខាងម្ដាយ ហៅថា បេ-ខ្មៀ ឬរបស់ម្ដាយធំក៏ហៅថា បេ-ខ្មៀ ដែរ" ។

ពាក្យនេះប្រាកដជាក្រនៃពាក្យ "ខ្វៃ" ដែលក្លាយយ៉ាងមកជាប្រែនគ មាននៅក្នុងសិលាចារិកនគរវត្ត នៃឆ្នាំ ១៧០១ (Nº 39 B, Aymonier, Cambodge., p. 309) នោះមាននិយាយពីមន្ត្រីម្នាក់បានទទួលងារជាគោសាថា: "លុះបានជាគោសាសោកប្ដូស្រ ២ ក្នុង ប៉ម្លួស្ស កូនក្មួយប៉ប្អូនខ្មៀ នូកូនធម៌ជាសំម៉ោរ ៧អង្គ" ។ មានសេចក្ដីក្នុងចារិក ១ទៀតនៃឆ្នាំ ១៧៤៧ (nº 41 B. de Aymonier, iluid., P. 310) ថា៖ "មានឧកញ៉ាម្នាក់ចិញ្ចឹមក្មួយប្អូនខ្លួនព្រះរាជ ប៉ប្អូនប្អូនមាតាស្រីគ្នាកេសរជាប្រពន្ធ នូនាងកិម ជាខ្វៃ នូក្មួយស្រី ២ នាំកប្ដូស្រជានាងជ្បែ ..." ។ ក្នុងសេចក្ដីចារិកទី ១ លោកអាយម៉ូញេរប្រែពាក្យ "ខ្វៀ" ជា "កូនប្រុសប្រុស" ហើយក្នុងសេចក្ដីចារិកទី ២ ប្រែជា "កូនប្រុសស្រី" ខ្ញុំមិនទាន់ទុកចិត្តនឹងពាក្យប្រែនេះទេ ដ្បិតពាក្យថា "កូនប្រុស" ដែលគេប្រើនិយាយសព្វថ្ងៃនេះ សឹងមានក្នុងវិជ្ជាចារិកតាំងពីខាងដើមសតវត្សរ៍ទី ១១ មកហើយ ។ ខ្ញុំជឿថាពាក្យថា "ខ្វៃ" ជារូបសព្ទបុរាណ ១ ឬជាពាក្យដែលក្រនៃពាក្យថា "ថ្លៃ" ដែលប្រើសព្វថ្ងៃនេះសំដៅយក "បងថ្លៃប្អូនថ្លៃ" ពាក្យនេះគេអាចសំគាល់បានថា គាពុកធំខាងម្ដាយ

និងប្តីរបស់ម្តាយមីងខាងឪពុកនោះ ចៀវ-តាកួនគាំងចិត្តប្រើពាក្យ "បេថ្លៃ" សំដៅយកជនទាំងពីរ ត្រូវជា "បងថ្លៃ" របស់ឪពុក ។

## ត្រង់ពាក្យៈ ង៉ៃ-ឡាន

"នៅខែទី ៨ មាន (បុណ្យប្រចាំខែ) ងៃ-ឡាន ងៃ-ឡានគឺកំល្ខោន" ។

ពាក្យខ្មែរមួយម៉ាត់នេះប្រែថារាំ (danser) សូម្បីក្នុងវិជ្ជាចារិកក៏ប្រើដូចជាពាក្យខ្មែរថ្មីនេះដែរ ។ ចៀវ-តាកួនគង់បានឃើញគេរាំល្ខោនក្នុងពេលនោះផង ។

## ត្រង់ពាក្យៈ ប៉ាវ—លេង—គិរ

"គេហៅ (ស្រាបែបនេះ) ប៉ាវ-លេង-គិរ ។ គឺជាអង្ករ" ។

លោកអាយមូនញ៉ែពន្យល់ថាពាក្យ "លេង-គិរ" នេះត្រូវនឹងពាក្យចារិកថា រង្គ (ឥឡូវនេះថាអង្ករ) នេះត្រូវដូច្នេះមែន ។ ឯពាក្យថា "ប៉ាវ" នោះខ្ញុំសុំលើកបង្ហាញពាក្យថា ប៉ (ប៉ាយ, បបរ) ក្នុងភាសាសៀង ហើយក្នុងភាសាខ្មែរសព្វថ្ងៃនេះ គ្រាន់តែដាក់ថែមអក្សរប មួយទៀតជាប៉បរ ។ ស្រាដែលគេធ្វើនឹងអង្ករឆ្អិនឬបាយ នេះជាឈ្មោះស្រាធ្វើពីបាយនុះឯង ។

---

លោកហាន់–យេន រៀបរៀង

(តមកទំងចប់)

បទទី ១៧

# ការតបស្នងសងគុណ

ឆ្នាំនោះកើតកាំងវិចស្រួតហួតផែនដី គ្មានទឹកមួយដំណក់ស្រក់ពីផ្ទៃមេឃមកសោះ កំដៅសុរិយាដុតស្ងួតឈើស្លឹកព្រៃឲ្យឆេះខ្លោចអស់គ្មានសល់ ឯសំណាបដែលកំពុងលាស់ទៀតស្រែស្រាត់លកលេងពេញវាលស្រែ កំពុងមានសេហ៍មុខបរិបូណ៌ ធ្វើឲ្យពួកកសិករក្រឡេកមកញញឹមក្រោយ ក៏ផ្លាស់សម្បុរទៅជាក្រហមឆេះអស់ ភ្នែកគ្រប់គ្នាក៏ព្រូកស្រ-ពងមើលអ្នកពុយល់ អ្នកចាំងអស់ស្រងុតស្រងាត់លែងនិយាយស្តី ដេកយកដៃគងថ្ពាស ដាច់ក្តីសញ្ជឹងសញ្ឈប់ដកដង្ហើមធំ ចំណែកមេផ្ទះសំឡឹងមើលដោយសេចក្តីករុណា បុត្រាថាដែលកំពុងប្រឡែងលេងជាមួយនឹងបងប្អូនវា ដោយសេចក្តីបរិសុទ្ធចិត្តពិតព្រឹកមិនមានភ័យគិតដល់អនាគតសោះ ក៏បង្អៀកភ្នែកតរែក្បាលយ៉ាងក្រៀមក្រោះអស់សង្ឃឹម បាម្ដគ្រងគេអ្វីបញ្ចមមិនបាន ដល់ពេលបាយវាទារគេបានអ្វីឲ្យ ។

នៅមាត់ស្ទឹងស្រុកកំពង់ធំ មានមនុស្សក្រណ្ដាលអាយុម្នាក់ ម្នមិនស្រស់អង្គុយជិតកុមារម្នាក់ គាត់សំឡឹងមើលទឹកហូរហោតទៅឆ្ងាយ

នាំឲ្យគាត់ប្រគ្គិដល់អ្នកដែលឃ្លាតឆ្ងាយពីគាត់ទៅ បានជាគាត់មកអង្គុយនៅទីនោះកល់ល្ងាច រង់ចាំគេត្រឡប់មកវិញ យូរៗ គាត់ដកដង្ហើមធំម្តងៗ ដែលសំដែងឲ្យឃើញថាគាត់កើតទុក្ខព្រួយណាស់ ហើយខ្សឹបៗថា "ឱកូនសំឡាញ់ឪពុកអើយ ម្តេចកូនមិនវិលមករកឪពុកវិញ ទុកឲ្យឪពុកនៅម្នាក់ឯង ប៉ាដឹងខ្លួនថាខុសមែនហើយ ធ្វើម្តេចមានគ្រោះកាចនាំឲ្យឪពុកវង្វេងបាត់ស្មារតី លែងដឹងអ្វីទាំងអស់ នាំឲ្យកូនរងលំបាកវេទនាជាច្រើនលើកច្រើនជាន់ តែទេវតាលោកសង្ស័គជួយកូនហើយ ឪពុកសព្វថ្ងៃរស់នៅតែសម្បកខ្លួនទេប៉ុណ្ណោះ ។ បើជាដឹងថាមេសុវណ្ណបុប្ផារាជាគល់គុណ៍មែនៗនោះ ឪមិនដល់ម្ល៉េះទេ ទឹកភ្នែកក៏ធ្លាក់គក់ៗលើមុខគាត់ កុមារីយកក្រមាជូតឲ្យ រួចគាត់ទំយ៉ាយតទៅទៀត មើលទៅប៉ាមិនរស់នៅយូរប៉ុន្មានទេ កូនអើយកូនមកវិញ ពីព្រោះឪកាន់តែចាស់ហើយ ស្រូវក៏ពុំបាន ជំនួញគ្រប់មុខក៏បង់ខាត មេសុវណ្ណក៏ចាស់ពេលនេះបានចំជាមេចោរចិត្តទៅ តែជានិកម្មដែរ ហើយទៅលួចប្លន់គេទៀត ហើយត្រូវប្រពន្ធដើមគេធ្វើបាបជាច្រើន . . . ។

ពេលនោះ មានបុរសម្នាក់ទៀតមានអាយុប្រហែលតាចូលមកស្រែកហៅកុមារីថា "ស្មាល៍! មេចមិនទៅសុំកែយកមកជូនលោកឪពិសា"

នាងសាលីក៏ងើបឡើងដើរទៅផ្ទះលើកតែយកមក សោភិតញ-ញឹមទទួលយក រួចគាត់ស្ទាបក្បាលនាងដោយសេចក្ដីពេញចិត្ត "កូនឪពុកពេញចិត្តនឹងកូនណាស់ តើកូនមិនគំនុំគុំគួននឹងឪពុកទេឬអ្វី ដែលឪពុកធ្វើបាបបងចិញ្ចឹមកូនឯង?

"ចា៎ះទេ" ។

"បើដូច្នោះ ឪពុកសូមផ្ញើកោនទីងឯងផងបានទេ?

"ចា៎ះ! ខ្ញុំមានចិត្តត្រេកអរណាស់" ។

"ប្រាកដឬ?

"ចា៎ះ ប្រាកដហើយ"

"មិនតែប្រែទេប្ដូរអ្វីដល់ថ្ងៃក្រោយ?

"ត្រង់ណោះសូមលោកឪពុកជឿចុះ ខ្ញុំនឹងប្រតិបត្តិតាមសេចក្ដីប្រាថ្នារបស់ខ្ញុំដល់ផុតជីវិត ពាស់តែគ្មានអ្វីជាភស្ដុតាងឲ្យលោកឪពុកជឿជាក់" ។

សោភិតបែរមុខញញឹមមើលមុខឪពុកនាងសាលី ហើយក៏ញញឹមត្រឡប់ទៅវិញទៅមក ចុងបង្អស់គាត់បញ្ចប់គំនិតរបស់គាត់ដោយពាក្យដូច្នេះ "កូន! បើប្រាកដជាព្រមឲ្យឪពុកផ្ញើកោនមែន ឪពុកអរណាស់ ព្រោះកូនស្រាប់តែទៅឪពុកនេះ ឪពុកគ្មានអ្វីសងគុណទេ មានតែសុភិន្ទមួយឪពុកប្រគល់ឲ្យឯង តើឯងព្រមយកសគុណនេះទេ?

សាលីដឹងសេចក្ដីប្រាស់ទឹកអៀនណាស់ ស្ទុះទៅឱបឪពុកបង្កើតរបស់ខ្លួនពួនមុខបាត់ ឪពុកនាងសាលីមានគំនិតឡើងថា "យើងត្រូវនៅស្រុកនេះតទៅទៀតពុំបានទេ បើដូច្នោះ គោងយើងនាំគ្នាទៅនៅឯព្រែកព្នៅឯណោះ ទើបបានប្រកបការរកស៊ីឲ្យបានស្រួលបួលនឹងគេ តើលោកបងយល់ដូចម្ដេច? ដល់ស្រួលបួលសឹមយើងរៀបចំទុកដាក់កូនឲ្យវាមានផ្ទះសម្បែងឡើង" ។

សោភិតក៏ព្រមព្រៀងតាម ទើបអ្នកទាំង ៣ នោះ នាំគ្នាលក់ផ្ទះសម្បែងដីធ្លី ជញ្ជូនរបស់ទ្រព្យមកនៅឯស្រុកព្រែកព្នៅ ប្រកបការរកស៊ីមានមុខមានមាត់ឡើង ។

ថ្ងៃមួយ សោភិតមកលេងផ្ទះប្អូនស្រីឯភ្នំពេញ ក៏បានជួបនឹងសុភិទ្រជាកូន សុភិទ្របានដឹងថាឪពុកចុះក្រក៏បានរំលែកសម្បត្តិរបស់ខ្លួន ដែលបានទទួលពីម្ដាយមកជូនឪពុកពាក់កណ្ដាល ។

ពេលក្រោយមក សោភិតមកលេងទៀតបានសាកសួរសុភិទ្រថា "កូន! កូនឯងជាប់ប្រឡងចេញពីសាលាហើយ ល្មមកូនគិតរកប្រពន្ធកូនទៅ តើកូនមានពេញចិត្តកន្លែងណាឬទេ?

"បាទ! ខ្ញុំមានពេញចិត្តដែរ តែមិនទាន់ជាប់ស្រេចនឹងចូលដណ្ដឹងនៅឡើយ ព្រោះចាំលោកប៉ាមើលសិន បើពេញចិត្តបានខ្ញុំបាទប្រថុយ" ។

"កូនឯងស្រឡាញ់ឪពុកទេ ?

"លោកប៉ា! កូនស្រឡាញ់លោកប៉ាដូចកាលខ្ញុំនៅពីតូច ពិតមែនថាប៉ាបានប្រព្រឹត្តមិនគប្បីដល់អ្នកម៉ែនឹងកូនក៏មែនហើយ ប៉ុន្តែកូននៅតែចេញពីសាច់ប៉ាដដែល កូននៅជាចំណែកមួយរបស់ប៉ា ហេតុនេះបើប៉ាពេញចិត្តឲ្យកូនធ្វើយ៉ាងណា កូនក៏ព្រមតាមទាំងអស់" ។

"កូន! ឪពុកខុសមែនហើយ តែប៉ាចង់បានឲ្យកូនឯងបានសុខជាបទៅមុខ ហើយប្រាថ្នាមួយមុខដល់រូបកូន តើកូនព្រមតាមទេ?

"តាមប៉ា ប៉ាមានប្រសាសន៍មកចុះ" ។

"ឱកូន! តាំងពីប៉ាធ្លាក់ខ្លួនមក មានគេជួយថែទាំប៉ាដោយយកចិត្តទុកដាក់ ហើយប៉ាមិនដែលបានស៊ូសងគុណគេទេ មានតែកូនជួយសងគុណជំនួសប៉ាផងចុះ ឲ្យប៉ាបានសប្បាយដោយសារឯងផង ព្រោះប៉ាកាន់តែចាស់ហើយ" ។

"មានអ្វីប៉ា! ប៉ាប្រាប់ឈ្មោះអ្នកនោះដល់កូនចុះ!!

"ប្រាកដជាឯងព្រមសងគុណជួសប៉ាឬ?

"បាទលោកឪពុក ប្រាប់ឈ្មោះគេដល់ខ្ញុំឆាប់ៗ ខ្ញុំនឹងទៅសងគុណឥឡូវនេះ" ។

"នាងសាលីណាកូន ប៉ាពេញចិត្តនឹងគំនិតមារយាទនាងណាស់ ប៉ាខជាដណ្ដឹងឲ្យឯង តើឯងយល់ដូចម្ដេច ?

ក្អែកសុក្រិទ្ធកំពុងក្រោយពន្លឺដោយសេចក្ដីចង់ដឹង - ក៏ល្អក់ចុះមួយរំពេច សំឡឹងមើលទៅមុខដូចជាប្រាសចាកវិញ្ញាណ បេះដូងរបស់គេក៏បុកអួលមួយរំពេច សំដៅសោភិតជាប់ក្រោយខេះ ហាក់ដូចជាការុធអ្វីមួយដ៏មុត ចាក់ដោតដើមទ្រូងសុក្រិទ្ធទៅហើយ ចុះសេចក្ដីតបស្នងសងគុណអើយ! មកធ្វើឲ្យសុក្រិទ្ធគួរគំនិតប្រឡាំងកាំងដូច្នេះ តើនឹងគិតម្ដេចហ្ន៎? បើគូសំឡាញ់របស់កុមារល្អម៉្លេះ ហើយកុមារស្រឡាញ់នាងខ្លាំងផង ។

ទៅពេលមួយប៉ប្រិចភ្នែកនោះ រង់ក៏ត្រដាយព្រឹកបានរះពណ្ណរាយនៅមុខសុក្រិទ្ធ ផ្កាយព្រឹកនេះឯងហើយ ដែលសុក្រិទ្ធបានតាំងចិត្តនឹងយកជាគូគ្រង ការបើរៀនសូត្របានសម្រេចដូចសេចក្ដីប្រាថ្នា ហើយនាងក៏មិនបានបញ្ចេញសញ្ញាអ្វី ដែលនាំឲ្យសេចក្ដីគិតរបស់សុ-ក្រិទ្ធអសារឥតការដែរ ចុះឥឡូវបើមកឃ្លាតឆ្ងាយពីនាងដូច្នេះ តែធ្វើម្ដេចបានជាជ្រុលប្ដេជ្ញាឲ្យឪពុកថានឹងប្រតិបត្តិតាម គង់តែកាត់ចិត្តពីទីស្រឡាញ់ចេញ ។ មួយវិញទៀត សាលក៏មានគុណលើសុក្រិទ្ធដែរ ហើយធម្មតាកូនគង់តែតបស្នងសងគុណឪពុកទើបត្រូវតាមគន្លងធម៌ ។

សោភិតឃើញកូនស្ងៀម ទើបសួរបញ្ជាក់តទៅទៀត "ម៉េចកូន! ឯងមិនពេញចិត្តឬ?

"បាឲ្យកូនស្រឡាញ់ដូចម្ដេចបាន បើសាលដូចជាប្អូនខ្ញុំបង្កើត"

"បើដូច្នោះ ឯងមិនសងគុណជួសឪពុកទេឬ?

"ខ្ញុំមិនថាដូច្នោះទេ តែពេលនេះខ្ញុំជាប់រៀន" ។

"មិនអីទេ ឲ្យតែឯងព្រម នាងនឹងរង់ចាំឯងបាន" ។

សុភ័ទ្រក៏នៅស្ងៀម ចាស់ៗក៏ព្រមព្រៀងគ្នានឹងរៀបអាពាហ៍-ពិពាហ៍ រង់សុភ័ទ្រនឹងនាងសាលីដល់ផុតឆ្នាំ ទើបរៀបចំប្រដាប់ប្រដាគ្រប់សព្វ ចំណែកញាតិខាងនាងសាលី ក៏ចង់ឃើញមុខខាងប្រុសឲ្យច្បាស់ ទើបមានសំបុត្រពីសោភិតមកឲ្យសុភ័ទ្រទៅជួបៗ ដល់ថ្ងៃអាទិត្យសុភ័ទ្រក៏ចិញ្ចៀនពីរថាលទៅផង លុះដល់ព្រែកឡៅហើយ ក្រមុំស្រុកនោះក៏ផ្អើលមកមើលគ្រប់គ្នា លាន់មាត់សរសើររូបសុភ័ទ្រគ្រប់គ្នា "នេះចំជាប្រុសគ្រប់លក្ខណ៍ ល្អបាក់ដូចទេវតាតែម្ដងអើយ តែទាស់ពុកចង្កាច្រើនណាស់ មើលតែកោរហើយគង់ឃើញខ្មៅដែរ បើជាក្លួចកោរជង់មុខជានឹងតាក់សាប់ជាមិនខាន" ។

"យើប៉ុណ្ណឹងហើយ នៅមិនត្រូវចិត្តទៀត គេរកតែពុកចង្កាច្រើនហើយថា តាក់ពុចសាច់ឲ្យតែសើបបន្តិច តែគ្នាដូចជាមិនពេញចិត្តនឹងច្រមុះស្រួចសោះ" ។

"ច្រមុះស្រួចសមនឹងថ្ពាល់ពេញៈហើយថា ចាំសាញអ៊ីទៅយកធ្វើប្ដីទៅ" ហើយក៏នាំគ្នាសើចគឹលឡើង ។

ចំណែកសុភិន្ទ្រឡើងទៅលើផ្ទះធំហើយ លើកដៃសំពះចាស់ទុំអង្គុយនៅទីសមគួរមួយ ស្រាប់តែឃើញនាងសាលីចេញមក ក៏ភ្ញាក់ខ្លួនព្រើតដោយប្លែកភ្នែកព្រោះបាត់យូរ “បងអញ្ជើញមកយូរហើយឬអី?

សុភិន្ទ្ររវល់តែមើលរូបនាង ក៏ស្រឡាំងកាំងនិយាយអេះអុះមិនបានស័ព្ទ ចាំឲ្យចាស់ៗសើចគិលឡើង ហើយញញឹមរកគ្នាជាកិច្ចជាសមគ្នាណាស់ ទើបក្មេងបំរើលើកម្ហូបម្ហាមក សាលីអង្គុយចក់ដង់បំ-រើបងរបស់នាង “បងអញ្ជើញពីសាឡាប្រចិនចុះ មានកំឡាំងជះឡានវិលទៅភ្នំពេញវិញ កុំឲ្យនារីទ្រាល់យកគេថ្ងូគមុខ ដោយចំពោះនាងបុប្ផាផ្កាក្រអូប តែជាម្ហូបដៃអ្នកស្រែមិនបានជាមានខុសជារសដូបដៃអ្នកក្រុងទេ តែជាបងគង់មិនខ្ពើមម្ហូបដៃអ្នកស្រុកកំពង់ធំឡើយ ទុកជាខ្ពើមក៏គង់ចាំបាននៅពេលនេះដែរ” ។

“បងមិនខ្ពើមទេម្ហូបស្រុកកំពង់ធំ តែក្រែងតែស្នាដៃអ្នកដទៃមិនដឹង បើពិតជាស្នាដៃប្អូននោះបងចាំគ្មានខ្ពើម សព្វថ្ងៃនឹកម៉ៃចង់ញ៉ាំម្ហូបដ៏ប្រណិតបែបនេះ មើលចុះជីរជ្រក់ត្រីស្ងោររហាន់យ៉ាងឆ្ងាញ់បានញ៉ាំកាលណាមុខជានឹងតែមុខលើសដើម ទៅវិញមុខជាបុប្ផាផ្កាក្រអូបច្រឡំហើយ ប្រយ័ត្នចុះអូន” ។

ចាស់ៗញញឹមបិទមាត់លែងដកចំអន់ថា “ប្តីប្រពន្ធគេនេះ ត្រូវដើងគ្នាអើតតែម្តងហើយ ចំជាគូព្រេងគូសំណាងផងគេ បើម្ល៉ឹងឲ្យត្រូ

កំលោះឯណោះ ក្រុមហ្លួងកំពង់ធំណាក៏បាន បើគាប់ចិត្តដល់អ្នកធ្វើថែមទៀត" ។

នាងសាលីគៀនខ្លួនតែប៉ូលកុងបាត់ ដល់ពេលសម្រាកខ្លួនសុភ័ទ្រដេកមិនលក់ចាំស្តាប់នាងសាលីនិយាយតប្រៀបមិនដាច់មាត់ ដល់ពេលល្ងាចជិះរថយន្តវិលត្រឡប់មកក្រុងពេញវិញ ក៏នឹកដល់នាងសាលីជាច្រើនរលឹកហើយអាណិតនាងឥតប្រៀបបាន ស្រណោះកាលទើបងើបពីដេកនាងយកសាប៊ូក្រអូបមកឲ្យលុបមុខ យកកន្សែងពោះគោឲ្យជូតស្រណោះសំដីនាងផ្ដាំឲ្យទៅលេងដល់ពេលសម្រាករៀន ស្រណោះផ្ដាំឲ្យយកកំណាត់សារូមកឲ្យនាងផង ស្រណោះគ្រប់ស្រណោះសព្វស្ទើរមិនចង់ត្រឡប់មកវិញសោះ ។

លុះសុភ័ទ្ររៀនច្បាប់បានសម្រេចដូចបំណងហើយ ទើបចាស់ៗហៅបងប្អូនញាតិសន្ដានទាំងក្មេងអ្នកមុខអ្នកការជាច្រើនមកប្រជុំរៀបអាពាហ៍ពិពាហ៍រវាងក្រមការសុភ័ទ្រ និងនាងសាលី យ៉ាងអឹកធឹកអ្នកទាំងពីររូបនោះក៏បានសេចក្ដីសុខសប្បាយនឹងគ្នាជាបន្តមក សោកគិតទាំងគេនាំក៏ស្រស់ស្រលនឹងគ្នាដូចដើមវិញ ។ មិនយូរប៉ុន្មានគ្រួសារនេះ បានវិលត្រឡប់ទៅនៅស្រុកកំពង់ធំវិញ ព្រោះក្រមការសុភ័ទ្រកងការដាក់ឲ្យទៅធ្វើចៅហ្វាយស្រុកៗកំពង់ធំ នាងសាលីក៏បានឡើងស័ក្តិជាលោកស្រី ។

ដោយសេចក្ដីព្យាយាមយ៉ាងមាំ លោកសុភិន្ទ្របានបុណ្យស័ក្ដិសមដូចសេចក្ដីប្រាថ្នា តែលោកមិនបានភ្លេចខ្វៃដល់កស្ត្រីឡើយ តែងមានចិត្តអធ្យាស្រ័យល្អជាដរាប អ្នកស្រុកក៏បានសេចក្ដីសុខគ្រប់គ្នាលែងភ័យដល់ការរំលោភច្បាប់អំពីពួកការដូចមុនៗ ផុតអំពីទោសទុក្ខភ័យ ព្រោះមនុស្សទុច្ចរិតត្រូវធ្វើបាបដោយឥតត្រាប្រណី លោកសុភិន្ទ្រព្រមទាំងលោកស្រីមួយអន្លើដោយញាតិមិត្តរបស់លោក ចេះតែសប្បាយរហូតដល់អវសាន មិនយូរប៉ុន្មានឆ្នាំលោកសុភិន្ទ្របានឡើងជាចៅហ្វាយខេត្តដោយសេចក្ដីយុត្តិធម៌និងគុណសម្បត្តិដ៏ឧត្តម ។

រឿងកំព្លុកកំសត់ចប់តែប៉ុណ្ណេះ ។

---

# ដំឡៃសិល្បសាស្ត្រ

(តមកនឹងចប់)

## ឃុនបណ្ណានុរក្ស ប៊ូ ប៉ូ រៀបរៀង

តែថាបើលោកបង្គាប់ឲ្យខ្ញុំដេកផ្អៀងតែម្ខាង ៧ ខែ ខ្ញុំមុខជាស្លាប់មិនខានទេ ជីវកកោមារភច្ចឲ្យសេដ្ឋីដេកផ្អៀងម្ខាងទៀត ៧ ខែ សេដ្ឋីដេកបានតែត្រឹម ៧ ថ្ងៃប៉ុណ្ណោះក៏ប្រែកន្លែងដេក ហើយជីវកកោមារភច្ចឲ្យសេដ្ឋីដេកផ្ងារ ៧ ខែទៀត សេដ្ឋីដេកបានតែត្រឹម ៧ ថ្ងៃប៉ុណ្ណោះក៏ប្រែកន្លែងដេក គ្រូពេទ្យប្រាប់ថា បើខ្ញុំមិនកំណត់យ៉ាងនេះទេ មុខជាលោកសម្រាន្តមិនបាន ៧ ថ្ងៃ ៗ ដងដូច្នេះឡើយ ដ្បិតខ្ញុំដឹងជាមុនរួចហើយថា កាលបើលោកសម្រាន្តបាន ៧ ថ្ងៃ ៗ ដងដូច្នេះហើយ ជម្ងឺក្នុងក្បាលលោកមុខជានឹងសះស្បើយពិតប្រាកដ ឥឡូវលោកជាពេកដាច់ស្រឡះហើយ ចូរលោកក្រោកឡើងចុះ សេដ្ឋីក្រោកឡើងហើយក៏ប្រគល់សម្បត្តិទ្រព្យទាំងអស់នៃខ្លួនឲ្យជីវកកោមារភច្ច ៗ មិនព្រមទទួលយក គ្រាន់តែបង្គាប់សេដ្ឋីឲ្យថ្វាយប្រាក់ ១ សែនរៀលទៅព្រះបាទពិម្ពិសារ និងឲ្យខ្លួន ១ សែនរៀលទៀតផង សេដ្ឋីក៏ទទួលព្រមតាមបង្គាប់ ។

សម័យនោះ មានកូនប្រុសសេដ្ឋីម្នាក់នៅក្រុងពារាណសី ជាអ្នកលេងល្បែងជាំដូង កើតពកដុំក្នុងពោះវៀនធំ បរិភោគបាយបបររលួលទៅមិនរលួយ បន្ទោរឧច្ចារបស្សាវៈក៏មិនស្រួលសោះ ទៅជាស្គមស្រពក់ សម្បុរអាក្រក់លឿងស្លេកស្លាំង ឡើងសរសៃពេញទាំងខ្លួន សេដ្ឋី

អាពុកដឹងថាកូនឈឺធ្ងន់ធ្ងរដូច្នោះក៏ទៅឯក្រុងរាជគ្រឹះ ចូលទៅក្រាបបង្គំទូល សូមព្រះរាជានុញ្ញាតព្រះបាទពិម្ពិសារ ឲ្យជីវកកោមារភត្យទៅមើលជម្ងឺកូន កាលជីវកកោមារភត្យបានទទួលព្រះរាជានុញ្ញាតហើយក៏ចូលទៅសង្កេតមើលអាការរោគកូនសេដ្ឋីនោះ លុះពិនិត្យដឹងច្បាស់ហើយ ក៏បណ្ដេញមនុស្សឲ្យចេញមកខាងក្រៅអស់ ចាំងរាំងននជិតហើយ ក៏ចងសេដ្ឋីបុត្តភ្ជាប់នឹងសសរ ឲ្យប្រពន្ធរបស់សេដ្ឋីបុត្តនោះឈរចាំមើលពីខាងមុខចុះ ចងរួចវះពោះស្រាវយកពោះវៀនធំចេញមកក្រៅ ហើយគាត់យកដុំនោះមកបង្ហាញឲ្យប្រពន្ធមើល ប្រាប់ថា ព្រោះតែដុំនេះហើយបានជាប្ដីនាងឈឺបែបនេះ ថា ហើយក៏បញ្ចូលពោះវៀនធំទៅក្នុងពោះវិញរួចដេរភ្ជិតលាបថ្នាំឲ្យ កូនសេដ្ឋីក៏បានជារោគដាច់ស្រឡះពីក្នុងខ្លួន សេដ្ឋីអាពុកបានជូនរង្វាន់គ្រូពេទ្យ ១៦ ពាន់រៀលគ្រូពេទ្យជីវកកោមារភត្យទទួលយករង្វាន់នោះ ត្រឡប់វិលមកក្រុងរាជគ្រឹះវិញ ។

គ្រានោះ ព្រះបាទបជ្ជោតក្នុងក្រុងឧជ្ជេនីទ្រង់ព្រះអាពាធរោគលឿង មានពួកគ្រូពេទ្យធំៗ ជាច្រើននាក់បានព្យាបាលព្រះរោគនោះមិនសះជាឡើយ ទើបទ្រង់ចាត់ព្រះរាជបម្រើឲ្យទៅសុំគ្រូពេទ្យជីវកកោមារភត្យអំពីព្រះបាទពិម្ពិសារមកព្យាបាលព្រះរោគនោះ ឯជីវកកោមារភត្យកាលបានទទួលព្រះរាជានុញ្ញាតពីព្រះបាទពិម្ពិសារ ហើយក៏ទៅឯក្រុងឧជ្ជេនី លុះដល់ហើយបានចូលទៅគាល់ព្រះបាទបជ្ជោតក្រាបបង្គំ

ទូលសួរថា ខ្ញុំព្រះអង្គនឹងស្ងោទឹកដោះគោថ្វាយទ្រង់សោយ តើព្រះអង្គនឹងសោយបានឬទេ? ព្រះមហាក្សត្រទ្រង់ត្រាស់ថា មិនបានទេ នាយជីវក អ្នកឯងផ្សំថ្នាំឯទៀតថ្វាយយើងចុះ តែក៏ប្រើបានទាំងអស់ កុំតែយកទឹកដោះគោមកធ្វើថ្នាំ ដ្បិតខ្ញុំខ្ពើមណាស់ គ្រូពេទ្យជីវកគិតថា ព្រះរោគនេះបើមិនប្រើទឹកដោះគោជាថ្នាំទេ មុខជាមិនជាសះស្បើយឡើយ បើដូច្នោះមានតែអញស្ងោទឹកដោះឲ្យដួបជាទឹកម្សៅទាំងពណ៌ទាំងក្លិននិងរស ហើយលាយជាមួយនឹងថ្នាំផ្សេងៗច្រើនមុខទៀត ដើម្បីកុំឲ្យស្ដេចទ្រង់ជ្រាប ប៉ុន្តែកាលបើស្ដេចបានសោយថ្នាំនេះទៅហើយ គង់តែទ្រង់ជ្រាប លុះបានជ្រាបហើយមុខជានឹងខ្ញាល់យកទោសសម្លាប់អញមិនខាន ហេតុនេះត្រូវតែអញធ្វើឧបាយកល ទូលសុំឱកាសទុកជាមុនឲ្យហើយ គិតឃើញដូច្នេះក៏ក្រាបថ្វាយបង្គំលាចេញទៅស្ងោថ្នាំតាមគំនិតនោះ លុះស្ងោថ្នាំបានស្រេចហើយក៏ចូលមកក្រាបបង្គំទូលសុំព្រះរាជានុញ្ញាតថា បពិត្រព្រះសម្មតិទេព ធម្មតាខ្ញុំព្រះអង្គជាគ្រូពេទ្យ តែងត្រូវការគាស់យកឫសឈើមកធ្វើថ្នាំដោយប្រញាប់ណាស់ ហេតុនេះ សូមព្រះសម្មតិទេពទ្រង់ត្រាស់បង្គាប់ពួកអ្នករក្សាដំរីនិងពួកអ្នករក្សាទ្វារថា បើពេទ្យជីវកត្រូវការយកដំរីណាជិះក៏បាន ត្រូវការចេញចូលទ្វារណាក៏បាន ចង់ចេញចូលពេលវេលាណាក៏បាន កុំឲ្យឃាត់ទាំងឡើយ ព្រះបាទបជ្ជោតក៏ទ្រង់ត្រាស់បង្គាប់តាមដែលជីវកកោមារភច្ចទូលសុំ កាលបើគ្រូពេទ្យជីវក

បានព្រះរាជានុញ្ញាតដូច្នោះហើយក៏ថ្វាយថ្នាំលាយទឹក ព្រះករនោះទៅព្រះបាទបជ្ជោតរួច ក្រាបថ្វាយបង្គំលាថយចេញមកក្រៅ រួយរំពេច ដើរយ៉ាងលឿនសំដៅទៅឯរោងដំរី យកមេដំរីឈ្មោះភទ្ទវតិកា ឡើងជិះបរចេញពីក្រុងឧជ្ជេនីទៅ ឯមេដំរីនេះដើរក្នុង ១ ថ្ងៃបាន ៥០ យោជន៍ ។

គ្រានោះ ព្រះបាទបជ្ជោតទ្រង់សោយព្រះឱសថ រឹតជ្រាបទៅក្នុងព្រះអង្គហើយក៏ទ្រង់ចង្អោរចេញមកវិញ បានជ្រាបច្បាស់ថាជាទឹកដោះ ទើបត្រាស់ប្រើពួកបុរសឲ្យរកហៅខ្ញុំជីវកកោមារភច្ចចូលគាល់ ពួកបុរសក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពេទ្យជីវកគាត់ជិះមេដំរីភទ្ទវតិកាចរចេញពីក្រុងបាត់ទៅហើយ ព្រះរាជាទ្រង់ត្រាស់ប្រើកាកៈបុរសឲ្យទៅតាមថា ម្នាលនាយកាកៈ ចូរឯងទៅតាមហៅពេទ្យជីវកឲ្យត្រឡប់មកវិញកុំខាន ១ ទៀតឯងកុំទទួលយករបស់អ្វីបន្តិចបន្តួចពីពេទ្យនោះឡើយ ដ្បិតពួកពេទ្យច្រើនតែមានឧបាយកល ឯកាកៈបុរសនោះដើរក្នុង ១ ថ្ងៃបាន ៦០ យោជន៍ដោយសារមានកំឡាំងអមនុស្សជួយផង កាលបានទទួលព្រះរាជតម្រាស់ហើយ ក៏តាមទៅទាន់ជីវក-កោមារភច្ចកំពុងបរិភោគបាយព្រឹកនៅពាក់កណ្ដាលផ្លូវជិតនឹងដល់ក្រុងកោសម្ពី ទើបនិយាយនឹងពេទ្យជីវកកោមារភច្ចថា លោកគ្រូពេទ្យ ព្រះមហាក្សត្រឲ្យលោកត្រឡប់ទៅវិញ ពេទ្យជីវកកោមារភច្ចឆ្លើយថា នែនាយកាកៈ ចូរអ្នកបង្អង់ចាំខ្ញុំបរិភោគបាយរួចសិន ចូរអ្នកមកបរិភោគ

បាយជាមួយនឹងខ្ញុំ  តាកៈបុរសឆ្លើយថា  លោកកុំព្រួយដ្បិតព្រះមហា-ក្សត្របានផ្តាំខ្ញុំថា  ឯងកុំទទួលយករបស់អ្វីបន្តិចបន្តួចពីពេទ្យនោះឡើយ ព្រោះពួកពេទ្យតែងមានកលមាយាច្រើន  ឯជីវកកោមារភច្ចយកថ្នាំដាក់ នឹងក្រចកហើយស៊ីផ្លែកន្ទួតព្រៃផឹកទឹក  ហុចផ្លែកន្ទួតព្រៃមួយចំហៀង ឲ្យតាកៈបុរសបរិភោគផងប្រាប់ថា  បើដូច្នោះអ្នកគ្រាន់តែបរិភោគផ្លែកន្ទួត ព្រៃផឹកទឹកចុះ  នាយតាកៈគិតថា  ពេទ្យនេះបានស៊ីផ្លែកន្ទួតព្រៃផឹក ទឹកខ្លួនឯង  ប្រហែលជាមិនហ៊ានធ្វើអំពើអាក្រក់អ្វីទេ  ទើបតាកៈបុរស ទទួលយកផ្លែកន្ទួតព្រៃមួយចំហៀងនោះមកស៊ីរួចផឹកទឹកផង  គ្រាន់តែ បរិភោគរួចមួយរំពេចក៏ចុះកកៈដាក់ក្នុងនោះភ្លាម  ទើបសួរពេទ្យជីវក-កោមារភច្ចថា  លោកគ្រូពេទ្យ  ខ្ញុំនៅមានជីវិតតទៅទៀតឬទេ  ជីវក-កោមារភច្ចប្រាប់ថា  នែនាយតាកៈអ្នកកុំភិតភ័យឡើយ  ខ្លួនអ្នកក្តី ស្តេចកំណាចក្តី  មុខជានឹងបានសះស្បើយរោគតាំងពីថ្ងៃនេះទៅហើយ ប៉ុន្តែស្តេចមុខជាសម្លាប់ខ្ញុំមិនខាន  ហេតុនេះខ្ញុំមិនត្រឡប់ទៅវិញទេ ថាហើយក៏ប្រគល់ដំរីឲ្យតាកៈបុរសយកទៅថ្វាយស្តេចវិញ  ទើប ចេញពីទីនោះទៅឯក្រុងរាជគ្រឹះចាំរឿងនោះចូលទៅក្រាបបង្គំទូលព្រះ បាទពិម្ពិសារ ។

ចំណែកព្រះបាទបជ្ជោតកាលបើបានសះជាព្រះរោគស្រឡះពីព្រះ អង្គហើយ  ក៏រឭកឃើញឧបការៈរបស់គ្រូពេទ្យជីវកកោមារភច្ច  ទើប

ប្រើព្រះរាជបម្រើឲ្យទៅហៅជីវកកោមារភច្ចថា សូមឲ្យពេទ្យជីវកមកកុំខានយើងនឹងឲ្យគេ ឯជីវកកោមារភច្ចតបវិញថា សូមទ្រង់ព្រះមេត្តាប្រោសកុំព្រួយព្រះរាជហឫទ័យ សូមព្រះសម្មតិទេពគ្រាន់តែទ្រង់ពេកទុក្ខបការៈរបស់ខ្ញុំព្រះអង្គបានហើយ ព្រះបាទបជ្ជោតទ្រង់ជ្រាបថាពេទ្យជីវកប្រកែកពុំព្រមចូលមកគាល់ដូច្នោះ ក៏ទ្រង់ផ្ញើសំពត់សិវេយ្យ-កៈ[1] ១ គូទៅព្រះរាជទានជីវកកោមារភច្ច ។

គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់កើតព្រះរោគទល់បានអនុញ្ញាតឲ្យគ្រូពេទ្យជីវកកោមារភច្ចចូលទៅព្យាបាលព្រះរោគនោះ គ្រូពេទ្យជីវកកោមារភច្ចបានអប់ផ្កាឧប្បល ៣ ក្ដាប់លាយនឹងថ្នាំផ្សេងៗថ្វាយព្រះដ៏មានព្រះភាគទ្រង់ហិតៗផ្កាឧប្បល ១ ក្ដាប់ៗចុះបាន ១០ ដងៗ រួមជាចុះ ៣០ ដង ទើបព្រះដ៏មានព្រះភាគបានស្រួលព្រះអង្គជាប្រក្រតីវិញ ឯជីវកកោមារភច្ចបានថ្វាយសំពត់សិវេយ្យកៈ ១ គូនោះដល់ព្រះដ៏មានព្រះភាគៗទទួលហើយទ្រង់អនុញ្ញាតឲ្យភិក្ខុសង្ឃប្រើគហបតីចីវរតាំងពីពេលនោះដរាបមក ។

---

១— ជានព្វមកថាពួកមនុស្សក្នុងនគរកុរុទ្វីបតែងរុំសាកសពដោយសំពត់នោះឯង ហើយយកទៅចោល មានសត្វបក្សីមានប្រមោយដូចដំរីរកសំពាល់នូវសំពត់នោះថាជាដុំសាច់ហើយចាបនាំយកទៅដាក់ទុកលើកំពូលភ្នំ ហើយពារបកសំពត់ នោះចោលចេញរកស៊ីសាច់សពនោះ ។ វេលានោះពួកអ្នកដើរព្រៃបានឃើញសំពត់នោះ ហើយក៏នាំយកមកថ្វាយស្ដេច ។ សំពត់នេះហើយដែលព្រះបាទបជ្ជោតបានមកដោយហេតុយ៉ាងនេះឯង ។ សំពត់សិវេយ្យកៈនេះមួយៗមានដំឡៃរាប់ពាន់ច្រើនសែនរៀល ។

គ្រូពេទ្យជីវកកោមារភច្ចបានឡើងស័ក្តិយសជាមន្ត្រីជាន់ខ្ពស់ព្រម ទាំងមានសម្បត្តិទ្រព្យច្រើនដូចបានថ្លែងមកហើយនោះ ដោយសារ តែការរៀនវិជ្ជាពេទ្យហ្មត់ចត់មុតមាំក្នុងខ្លួន ។

ឯគុណវិសេសរបស់ចំណេះវិជ្ជានេះ គឺថាឲ្យអ្នករៀនដឹងច្រើន ដល់ម្ល៉េះ សូម្បីរៀនវិជ្ជាតែមួយមុខប៉ុណ្ណោះតែឲ្យច្បាស់ប្រាកដក៏អាចឲ្យ សម្រេចផលប្រយោជន៍ដល់ខ្លួនជាច្រើនបាន ដូចមាន :

## រឿងបុរសចេះមន្ត

កាលពីព្រេងនាយ មានកុមារម្នាក់លាមាតាបិតាចេញពីស្រុកទៅ នៅរៀនសិល្បសាស្ត្រក្នុងសំណាក់អាចារ្យម្នាក់នៅស្រុកឆ្ងាយអស់ចំនួន ពីរបីឆ្នាំ ក៏ពុំបានរៀនចាំវិជ្ជាណាមួយឡើយ ខំប្រឹងទន្ទេញចាំណាស់តែ ប៉ុន្តែភ្លេចអស់ទៅវិញ ឯគ្រូនឹកអាណិតអាសូរសិស្សនោះពេកណាស់ ថ្ងៃមួយបាននាំសិស្សនោះ ចូលទៅក្នុងព្រៃជ្រៅនៅស្ងាត់តែពីរនាក់ ហើយប្រាប់ឲ្យទន្ទេញមន្តមួយបទថា "ឃដេសិ ឃដេសិ កឹការណា ឃដេសិ អហំបិ តំ ជានាមិ" ប៉ុណ្ណេះ សិស្សនោះខំប្រឹង ទន្ទេញមន្តតាលតែចាំស្ទាត់រត់មាត់លែងភ្លេច ទើបអាចារ្យនិយាយផ្តាំ សិស្សថា "មន្ត ១ បទនេះមានគុណវិសេសអស្ចារ្យណាស់ អាចការពារ អន្តរាយផ្សេងៗបាន ហេតុនេះ ត្រូវឯងតាំងព្យាយាមសូត្ររាល់ថ្ងៃ

កុំបីបណ្តែតបណ្តោយឲ្យភ្លេចឡើយ បើដល់ពេលចូលដំណេក ឯងត្រូវសូត្ររួចសឹមដេក ឯងបានមន្តនេះយកទៅចិញ្ចឹមខ្លួនរស់ ១ ជីវិតហើយ” ផ្តាំស្រេចហើយក៏ឲ្យស្បៀងអាហារ ដាក់ទៅអាស្រ័យតាមផ្លូវបើកឲ្យសិស្សនោះវិលត្រឡប់ទៅនៅស្រុកខ្លួនវិញ ឯសិស្សនោះសំពះលាអាចារ្យចេញទៅដល់ស្រុកកំណើតខ្លួនវិញ ហើយខំតាំងព្យាយាមសូត្ររំឭកមន្តមិនឲ្យភ្លេចតាមបណ្តាំគ្រូ ។

មានមួយថ្ងៃ ព្រះមហាក្សត្រក្នុងនគរនោះ ចង់ជ្រាបចរិតចិត្តរបស់បណ្តារាស្ត្រថាស្រឡាញ់ឬស្អប់ព្រះអង្គ ក៏ទ្រង់គៀសក្លែងធ្វើជារាស្ត្របន្ទំមិនឲ្យគេស្គាល់ថាជាស្តេចឡើយ ដល់ពេលអធ្រាត្រស្ងាត់ទ្រង់ចេញទៅតែមួយព្រះអង្គឯង ស្តេចតាមច្រកល្ហកផ្ទះរៀងៗ ទៅដរាបដល់ផ្ទះបុរសអ្នកចេះមន្ត ស្រាប់តែបានទតឃើញពួកចោរជាច្រើននាក់កំពុងលបកាត់តាសជញ្ជាំងផ្ទះអ្នកចេះមន្តនោះ ទើបទ្រង់អែបព្រះអង្គសម្ងំចាំមើលកិរិយាចោរ លុះយូរបន្តិចពួកចោរខ្សឹបប្រាប់គ្នាថា “កនយើង គេដេកហើយរឺ” វេលានោះទ្រង់ទតឃើញពួកចោររត់ខ្ចាត់ខ្ចាយទៅ ទ្រង់នឹកឆ្ងល់តែក្នុងព្រះទ័យ ហើយស្តេចវិលចូលព្រះរាជវាំងវិញ លុះព្រឹកឡើងស្តេចត្រាស់ប្រើពលបុរសឲ្យទៅហៅអ្នកចេះមន្តនោះមក ទើបទ្រង់ត្រាស់សួរថា នែបុរស អ្នកឯងបានរៀនសូត្រ

ចេះដឹងអ្វីខ្លះដែរឬ បុរសនោះក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំជាខ្ញុំបានចេះមន្ត ១ បទដែរ អើ បើដូច្នោះ អ្នកឯងបង្រៀនយើងផងបានឬទេ សូមទ្រង់ព្រះមេត្តាប្រោស បង្រៀនបាន ទើបព្រះមហាក្សត្រទ្រង់រៀនមន្តអំពីបុរសនោះទាល់តែចាំស្ទាត់ ទ្រង់ព្រះរាជទានរង្វាន់ដល់បុរសនោះជាច្រើន បុរសក្រាបបង្គំទូលឲ្យទ្រង់សូត្ររំឭកមន្តរាល់ថ្ងៃដើម្បីការពារសត្រូវ ។

ថ្ងៃក្រោយមក មានមន្ត្រីធំម្នាក់ជាសេនាបតីរបស់ព្រះមហាក្សត្រនោះ កើតចិត្តអាក្រក់ក្បត់ព្រះអង្គចង់សោយរាជសម្បត្តិ ទើបយកប្រាក់ ១ ពាន់រៀលសូកនាយភ្នាក់ព្រះកេសហើយបញ្ចុះឲ្យអារព្រះសុរងស្តេចក្នុងពេលដែលចូលទៅដាក់ព្រះកេសាថ្វាយ បើបានសម្រេចដូចប្រាថ្នាកាលណា នឹងលើកនាយភ្នាក់ព្រះកេសឲ្យធ្វើជាសេនាបតី ឯនាយភ្នាក់ព្រះកេសក៏ខ្វល់ធ្វើតាមបង្គាប់មន្ត្រីនោះ លុះដល់ពេលដាក់ព្រះមស្សុថ្វាយស្តេចក៏ត្រដោះកាំបិតឲ្យមុត រួចលើកផ្គងឡើងប្រុងនឹងអារព្រះសុរងស្តេចតែម្តងឲ្យដាច់ ក៏ស្រាប់តែងងឹតមុខញ័ររេចប្រប់ទប់ខ្លួនមិននឹង ក្រាបទៀបព្រះបាទ ព្រះករុណាទ្រង់ត្រាស់សួរហេតុនោះជាបសព្វគ្រប់ ហើយ ទើបបំបរបង់សេនាបតីចេញផុតពីដែន ហើយទ្រង់តាំងបុរសចេះមន្តឲ្យធ្វើជាសេនាបតីវិញ ។

បុរសកំសត់ទុគ៌តដែលបានចំរើនឡើងយសស័ក្តិជាមន្ត្រីថ្នាក់ផុតលេខយ៉ាងនេះ ដោយសារខ្លួនបានខំខ្មីញចាំមន្តតែ ១ បទប៉ុណ្ណោះ ហេតុដូច្នោះ បានជាលោកចង់សុភាសិតទុកក្នុងច្បាប់ក្រមថា "ប្រាជ្ញ បុណ្យផង កើតដោយប្រតិបត្តិ" ។

ចប់

---

# ធម្មបទភាសិត

លោកគ្រូចៅអធិការ ឯក-ញឹម រៀបរៀង

(តមកពីមុន)

## បកិណ្ណកគាថា

### បទ - បដ្ឋកវគ្គ

១ - វេរញ្ញាណសម្ពុទ្ធំ   ធម្មញ្ចេវ សុទេសិតំ
សង្ឃញ្ចសេដ្ឋសម្បុត្តំ   វន្ទាមិ ហោតុ សោត្ថិ មេ ៗ

ខ្ញុំសូមបង្គំនូវព្រះសម្ពុទ្ធ   មានញាណបរិសុទ្ធក្នុងអង្គការយេ
អោះមុខផ្ដួចពេញដិតតមន្តិលេទ   គួរឲ្យយើងគេកើតចិត្តជ្រះថ្លា ។
ព្រមទាំងព្រះធម៌ដែលព្រះសាស្ដា   ទ្រង់ត្រាស់ទេសនាទុកជាយេប្រពៃ
ព្រមទាំងព្រះសង្ឃប្រសើរពេកក្រៃ   ជាឱរសថ្លៃនៃព្រះសម្ពុទ្ធ ។
ដែលលោកជាសង្ឃទ្រង់សីលបរិសុទ្ធ   សួស្ដីល្អផុតសូមមានដល់ខ្ញុំ ។

២ - អបជ្ឈាយមលាមន្តា   អនុដ្ឋានមលាឃរា
មលំវណ្ណស្សកោសជ្ជំ   បមាទោរក្ខតោមលំ ៗ

មន្តគឺវិជ្ជាចំណេះទាំងឡាយ   បើមិនស្វាធ្យាយរលាយភ្លេចភ្លាំង
ទីផ្ទះសំបែងមិនខ្វះខ្វែងបាំង   ប្រក់ធ្វើផ្ញាំងនឹងខូចទៅបាន ។

៣- អលសស្ស កុតោ សិប្បំ   អសិប្បស្ស កុតោ ធនំ
អធនស្ស កុតោ មិត្តំ   អមិត្តស្ស កុតោ បុញ្ញំ ៗ

អ្នកខ្ជិលសិល្បសាស្ត្រសម្រាំង   មានមកពីណាដល់អ្នកខ្ជិលខ្ជាំង
ទ្រព្យធនអ្នកគ្មានសិល្បសាស្ត្រសម្រាំង   នឹងមានមុខតាំងចូលមកម្ដេចបាន ។
រាំងធនជាមិត្តអ្នកឥតធនធាន   កាលណានឹងមានគេរាប់មុខឡើយ -
ព្រោះទាំងបុណ្យស័ក្តិអ្នកគ្មានមិត្តហើយ   ធ្វើដូចម្ដេចឡើយនឹងមានពីណា ។

៤- ន តេន បណ្ឌិតោ ហោតិ  យាវតា ពហុ ភាសតិ
ខេមី អវេរី អភយោ  បណ្ឌិតោតិ បវុច្ចតិ ។
បុគ្គលនិយាយច្រើនហួសប្រមាណ  មិនទាន់ឈ្មោះថាជាបណ្ឌិតឡើយ
អ្នកមានក្ដីក្សេមគ្មានពៀរភ័យហើយ  ព្រះមានបុណ្យឲ្យឈ្មោះថាបណ្ឌិត ។

៥ ទិដ្ឋេ ធម្មេ ច យោ អត្ថោ  យោ ចត្ថោ សម្បរាយិកោ
អត្ថាភិសមយា ធីរោ  បណ្ឌិតោតិ បវុច្ចតិ ។
ប្រយោជន៍លោកនេះនិងលោកខាងណាយ  បណ្ឌិតទាំងឡាយមានប្រាជ្ញាខ្ជាប់ខ្លួន
ព្រោះដឹងប្រយោជន៍របស់ផងខ្លួន  ទាំងពីរមាំមួនឈ្មោះថាបណ្ឌិត ។

៦- លោភំ កោធំ មទំ មានំ  ថទ្ធំ ឥស្សំ បមត្តំ
សោណ្ឌំ ថិទ្ធា លុត្តំ មក្ខំ  មច្ឆេរំ ជហេ ពុធោ ។
សេចក្ដីជំពាក់និងក្រោធស្រវឹង  កាន់ខ្លួនខ្ជិលនិងប្រណែនឆ្មេសស្បែង
ឆើតច្រើនលប់គុណកំណាញ់នេះឯង  អ្នកប្រាជ្ញលោកតែងតែលះបោលចេញ ។

៧- សទ្ធា ហិរិ ឱត្តប្បំ  ពាហុសច្ចំ វិរិយំ សតិ
បញ្ញា ច សត្តធម្មេហិ  សម្បន្នោ បណ្ឌិតោមតោ ។
ជឿនិងខ្មាសខ្លាចបាបស្ដាប់ច្រើន  សង្វាតប៉ិនសតិបញ្ញា
ប្រកបដោយធម៌ ៧ ប្រការ  នេះលោកហៅថាបណ្ឌិតពិតមែន ។

៨- ចក្ខុនា សំវរោ សាធុ  សាធុ សោតេន សំវរោ
ឃានេន សំវរោ សាធុ  សាធុ ជិវ្ហាយ សំវរោ
កាយេន សំវរោ សាធុ  សាធុ វាចាយ សំវរោ
មនសា សំវុតោ សាធុ  សាធុ សព្វត្ថ សំវរោ
សព្វត្ថ សំវុតោ ភិក្ខុ  សព្វទុក្ខា បមុច្ចតិ ។

សង្រួមចក្ខុសោតៈឃានា
សង្រួមជិវ្ហាកាយវាចាចិត្ត
សង្រួមសព្វឋានឲ្យបានតាមភិក្ខុ
ជាគុណល្អពិតផុតទុក្ខទាំងពួង ។

សព្វំ សុណាតិ សោតេន សព្វំ បស្សតិ ចក្ខុនា
នច ទិដ្ឋំ សុតំ ធីរោ សព្វំ ឧជ្ឈិតុមរហតិ ៕

គេស្ដាប់សំឡេងដោយទ្វារសោតា
គេឃើញរូបាដោយសារតែភ្នែក
ជនមានប្រាជ្ញាច្រើនជាអនេក
កុំមានចិត្តបែកចង់បានរូបឡើយ ។

១០- សុស្សូសា សុតវឌ្ឍនា បញ្ញាយ វឌ្ឍំ សុតំ
បញ្ញាយ អត្ថំ ជានាតិ ញាតោ អត្ថោ សុខាវហោ ។

សេចក្ដីចេះដឹងនឹងការចំរើន
មកពីស្ដាប់ច្រើនទំលះលោភា
សេចក្ដីចំរើនដោយលះទោសា
លះចិត្តមោហាចេះផ្សំបញ្ញា ។
បញ្ញាអាស្រ័យប្រាជ្ញាល្អជា
ប្រយោជន៍ការងារចេះគិតខ្លះវែង
ប្រយោជន៍ដែលដឹងហើយប្រឹងស្វះស្វែង
ប្រយោជន៍នោះតែងនាំសុខមកឲ្យ ។

១១- សីលំ យាវ ជរា សាធុ សទ្ធា សាធុ បតិដ្ឋិតា
បញ្ញា នរានំ រតនំ បុញ្ញំ ចោរេហិ ទុហរំ ៕

សីលល្អប្រពៃទាំងក្មេងទាំងចាស់
សទ្ធាល្អណាស់ប្រជាប់តែងតាំង
បញ្ញាជាកែវនៃជនសម្រាំង
បុណ្យឲ្យកំបាំងចោរលួចពុំបាន ។

១២- ចក្ខុមាស្ស យថាអន្ធោ សោតវា ពធិរោ យថា
បញ្ញវាស្ស យថា មូគោ ពលវា ទុព្ពលោរិវ
អត្ថអត្ថេ សមុប្បន្នេ សយេយ្យមតសាយិតំ ៕

មនុស្សមានភ្នែកជាដូចភ្នែកខ្វាក់
ត្រចៀកឮជាក់តែដូចថ្លង់ខ្លាំង
មនុស្សមានបញ្ញាតែដូចគរពាំង
មនុស្សមានកំលាំងតែដូចមនុស្សខ្សោយ
កាលកើតប្រយោជន៍ត្រឡប់ប្រែក្រោយ
ប្រាសដេកបណ្ដោយដូចជាមនុស្សស្លាប់ ។

១៣- ឧស្សាវោហារិបុ មិត្តំ  អសេវោ មិត្តវោ រិបុ
វិសំ វិយ មតំ វិជ្ជា  បមាទោ អមតំ វិសំ ។
សេចក្ដីឧស្សាហ៍ហាក់ដូចសត្រូវ  តែត្រឡប់ទៅជាមិត្តយ៉ាងខ្លាំង
ក្ដីខ្ជិលហាក់ដូចជាមិត្តសម្រាញ់  តែត្រឡប់តាំងមកជាសត្រូវ
វិជ្ជាហាក់ដូចជាពិសពេកក្រៃ  តែឈ្មោះថាផ្លូវមិនស្លាប់សោះឡើយ
សេចក្ដីប្រមាទមិនស្លាប់ហើយ  ត្រឡប់ប្រែក្លាយទៅជាពិស ។

១៤- អម្ពុំ បវន្តិ នោ នជ្ជា  រុក្ខា ខាទន្តិ នោ ផលំ
មេឃោ ភក្ខតិ នោ សស្សំ  បរត្ថាយ សតំ ធនំ ។
ស្ទឹងដាក់ទឹកទុកមិនផឹកខ្លួនឯង  ទោះឈើដែលតែងតែផ្លែរាល់ប្រាំង
មិនដែលស៊ីផ្លែដែលខ្លួនផ្លែខ្លាំង  បញ្ចេញនកតាំងទុកឲ្យគេស៊ី
ទឹកភ្លៀងធ្លាក់មកឲ្យដីមានជីវ  ក៏មិនដែលស៊ីសន្ទូងអ្នកស្រែ
ទ្រព្យនរជនរកបានមកទុក  បំណងទៅឲ្យប្រយោជន៍តែគេ ។

១៥- រុក្ខា សុភូមិនិស្សាយ  បុប្ផផលំ បវឌ្ឍតិ
សប្បុរិសំ និស្សាយ  មហាបុញ្ញំ បវឌ្ឍតិ ។
ដើមឈើអាស្រ័យដីដ៏ល្អជា  តែងនឹងមានផ្កាចំរើនឡើង
អ្នកដែលអាស្រ័យសប្បុរសថ្កុំថ្កើង  ចំរើនបុណ្យឡើងទៅជាធំធាន ។

១៦- ហិតំ ករោ បរោ ពន្ធុ  ពន្ធុបិ អហិតោ បរោ
អហិតោ ទេហជោ ព្យាធិ  ហិតំ អារញ្ញមោសធំ ។
អ្នកដទៃទេគេឲ្យប្រយោជន៍  ច្រើនតិចដោយហោចជាញាតិស្និទ្ធខ្លាំង
ញាតិសាច់ខ្លួនមែនប៉ុន្តែចិត្តខ្លាំង  ញាតិនោះក៏តាំងជាអ្នកដទៃ ។
ដូចព្យាធិដែលកើតក្នុងកាយសព្វថ្ងៃ  ជារោគចង្រៃឥតប្រយោជន៍សោះ
ឈើវល្លិជាថ្នាំនៅព្រៃនោះ  ខ្លះឈឺយកកិនលាបផឹកជាបាន ។

១៧–ជិឃច្ឆា បរមា រោគា វិស្សាសា បរមា ញាតិ
សន្តុដ្ឋី បរមំ ធនំ និព្វានំ បរមំ សុខំ ។

សេចក្តីស្រេកឃ្លានជារោគយ៉ាងខ្លាំង ស្និទ្ធស្នាលខ្ទនតាំងជាញាតិប្រសើរ
សន្តោសជាទ្រព្យសមតាមដំណើរ និព្វានប្រសើរសុខយ៉ាងក្រៃលែង ។

១៨–មុទុស្សិរស្សេ បទេសេន កុដារី សរលោន ច
ខលសត្តហិ សំយោគោ បណ្ឌិតោ ប្បសីទតិ

ទុកជាអ្នកប្រាជ្ញតង់ធ្លាក់ខ្លួនបុះ ព្រោះប្រទៅទុសត្យគេកាត់លត់
ទំនៀនទំលាប់ផលស់សិស្សផែលល្ងង់ មិនអាចទ្រទ្រង់ពាក្យប្រដៅបាន
ព្រោះមានស្ត្រីអាក្រក់កប់អាន ជាទីពឹងប្រាណពំនាក់នឹក្សមៅ
ព្រោះប្រកបដោយបុគ្គលល្ងង់ខ្លៅ មានចិត្តរឹងក្តៅសត្រូវផលខ្លួន ។

១៩–អសតំ សម្បយោគេន សន្តោបិ អសន្តោ ករេ
មគ្គោ កាចរយុត្តោ ឧជុម្បិ អសាធុ ករេ ។

ស្វម្បីសប្បុរសតង់ត្រឡប់រេ ដោយសេពគប់គេអសប្បុរស
ដូចជាផ្លូវថ្មីល្អកបស្មើទាំងអស់ សម្រាមពេញសស់ត្រង់មិនល្អ ។

២០–បរោគេសតោ សុមិត្តោ ច វិញ្ញូច ឧល្លោកោ ជនោ
យថោសថញ្ច សាធុញ្ច រោគហារី ច សព្វតោ

អ្នកដែលស្វែងរកប្រយោជន៍ខពន្ធ រកកំដុចជាមានចិត្តល្អពេញពោះ
ជាអ្នកមានប្រាជ្ញមិនបាចទន់ទោះ ដោយមិនលោភោរក ក្នុងលោក ។
ដូចថ្នាំនឹងសម្រាប់រម្ងាប់រោគ មាននាំជាដោតរសធ្ងាញ់ពិសា
ប៉ះបាតរោគបានហើយធ្ងាញ់ទៀតណា ថ្នាំនោះជាការកក្រផ្លូវចន្ទា ។

៦១- លុទ្ធមត្ថេនគណ្ហេយ្យ  ថទ្ធមញ្ជលិកម្មុនា

ឆន្ទានុវត្តិយា មូឡ្ហំ  យថាភូតេន បណ្ឌិតំ ។

ផ្គាប់ចិត្តជនលោភដោយឲ្យប្រយោជន៍  ផ្គាប់រឹងត្អឹងដោយពន្លំភ្ជាប់
ផ្គាប់ចិត្តជនល្ងង់ដោយមិនភាំង  ផ្គាប់អ្នកប្រាជ្ញតាំងតាមសេចក្តីពិត ។

## មិត្តវគ្គ

៦២—អហិតេ បដិសេធេតិ  ហិតេសុ ច និយោជកោ

ព្យសនេ នាបរិច្ចត្តោ  សហាយំ មិត្តលក្ខណំ ។

ហាមប្រាមគ្នាក្នុងកាលឥតផល  នាំគ្នាឲ្យដល់ប្រយោជន៍យ៉ាងភ្ញាក់
មិនលះបង់គ្នាគ្រាក្រភាន់ភាំង  លក្ខណៈមិត្តតាំងណាទុកសង្ខេប ។

៦៣- សត្ថោ បវសតោ មិត្តំ  មាតា មិត្តំ សកេ ឃរេ

សហាយោ អត្ថជាតស្ស ហោតិ មិត្តំ បុនប្បុនំ

សយំ កតានិ បុញ្ញានិ  តំ មិត្តំ សម្បរាយិកំ ។

បក្ខពួកជាមិត្តនៃអ្នកដើរផ្លូវ  មាតាមិត្តនៅក្នុងផ្ទះខ្លួនខ្លាំង
អ្នកមានចិត្តស្មើជាមិត្តសម្រាំង  គ្រាភ័យភាន់ភាំងមានទុក្ខកើតឡើង ។
បុណ្យខ្លួនធ្វើហើយជាមិត្តថ្កុំថ្កើង  ជួយទំនុកយើងនៅក្នុងភពមុខ ។

៦៤—សព្ភិរេវ សមាសេថ  សព្ភិ កុព្ពេថ សន្ថវំ

សតំ សទ្ធម្មមញ្ញាយ  សេយ្យោ ហោតិ ន បាបិយោ ។

បុគ្គលគប្បីសេពសប្បុរស  គួរស្និទ្ធស្នាលអស់ឥតកោសា
ដោះធម៌សប្បុរសមិនមានមោហា  ចិត្តគ្មានទំនោរទៅកាន់បាបឡើយ ។

៦៥—សព្ភិរេវ សមាសេថ  សព្ភិ កុព្ពេថ សន្ថវំ

សតំ សទ្ធម្មមញ្ញាយ  បញ្ញា លព្ភតិ នាញ្ញតោ ។

បុគ្គលគប្បីសេពសប្បុរស គួរស្និទ្ធស្នាលអស់ឥតចិត្តទោសា
បេះមិនសប្បុរសមិនបានទន់ទេរ តែងបាត់ មារយាបាននូវប្រាជ្ញា ។

៦៦– សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ ញាតិមជ្ឈេ វិរោចតិ ។

បុគ្គលគប្បីសេពសប្បុរស ស្និទ្ធស្នាលឲ្យអស់អំពីចិត្តខ្លួន
ព្រោះដឹងច្បាស់ធម៌សប្បុរសមាំមួន តែងរុងរឿងខ្លួនបណ្តាលពួកញាតិ ។

៦៧– សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្តា គច្ឆន្តិ សុគតិំ ។

បុគ្គលគប្បីសេពសប្បុរស ស្និទ្ធស្នាលឲ្យអស់កុំមានចិត្តទីង
ទាំងធម៌សប្បុរសត្រូវតែចំរើន អ្នកដែលចេះដឹងតែងទៅបានសួគ៌ ។

៦៨– សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សត្តា តិដ្ឋន្តិ សាតតំ ។

បុគ្គលគប្បីសេពសប្បុរស ស្និទ្ធស្នាលឲ្យអស់កុំលាក់បិទបាំង
ទាំងធម៌សប្បុរសចេះឲ្យសម្រាំង អ្នកនោះបានតាំងសុខទៀងវែងឆ្ងាយ ។

៦៩– សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សព្ពទុក្ខា បមុច្ចតិ ។

បុគ្គលគប្បីសេពសប្បុរស ស្និទ្ធស្នាលឲ្យអស់អំពីចិត្តខ្លួន
ព្រោះដឹងច្បាស់ធម៌សប្បុរសមាំមួន រមែងរើខ្លួនរួចទុក្ខទាំងពួង ។

៧០– ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ
ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។

បុគ្គលមិនត្រូវសេពបាបមិត្ត មិនគួរចូលចិត្តជនទាប ថោកទេ
ត្រូវសេពនឹងមិត្តកល្យាណ គួរសេពនឹងគេបុរសខ្ពង់ខ្ពស់ ។

៣១. ពាលសង្គតចារី ហិ ទីឃមទ្ធាន សោចតិ
ទុក្ខោ ពាលេហិ សំវាសោ អមិត្តេនេវ សព្វទា
ធីរោ ច សុខសំវាសោ ញាតីនំវ សមាគមោ ។

អ្នកដែលនៅរួមជាមួយនឹងពាល សោយសោកអស់កាលយូរកើតពាលោ
នៅរួមនឹងពាលនាំទុក្ខពេញពោរ ដូចនៅនឹងចោរដែលជាសត្រូវ ។
នៅរួមអ្នកប្រាជ្ញបានសុខពេកក្រៃ បីដូចជានៅរួមនឹងពួកញាតិ ។

៣២. អញ្ញទត្ថុហរោ មិត្តោ យោ ច មិត្តោ វចីបរោ
អនុប្បិយញ្ច យោ អាហ អបាយេសុ ច យោ សខា ។

មិត្តណាដែលគិតតែពីចង់បាន របស់ធនធានពីមិត្តផងគ្នា
មិត្តណាដែលបានតែមានវាចា ពីរោះពីស ត្រឹមចុងមាត់លេង ។

៣៣. ឯតេ អមិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ
អារកា បរិវជ្ជេយ្យ មគ្គំ បដិភយំ យថា ។

អ្នកប្រាជ្ញដឹងច្បាស់មិត្ត ៤ ពួកនោះ មិនពិតដូច្នោះត្រូវឈប់ស្នេហា
ចៀសពីមិត្តនោះឱ្យចៀសពស់ខ្លា ដូចអ្នកត្រូវការដើរចៀសផ្លូវភ័យ ។

៣៤. ឧបការោ ច យោ មិត្តោ សុខទុក្ខោ ច យោ សខា
អត្ថក្ខាយី ច យោ មិត្តោ យោ ច មិត្តានុកម្បកោ ។

មិត្តណាអ្នកមានឧបការៈ សំឡាញ់ណាអ្នករួមសុខទុក្ខ
មិត្តណាអ្នកណែប្រយោជន៍ពេញពោរ មិត្តណាចិត្តទោរទន់អនុគ្រោះ ។

៣៥. ឯតេបិ មិត្តេ ចត្តារោ ឥតិ វិញ្ញាយ បណ្ឌិតោ
សក្កច្ចំ បយិរុបាសេយ្យ មាតា បុត្តំវ ឱរសំ ។

អ្នកប្រាជ្ញដឹងច្បាស់មិត្ត ៤ ពួកនោះ    ប្រាកដដូច្នោះថាមិត្តសម្រាំង
អង្គុយជិតមិត្តស្និទ្ធឥតបិទបាំង    ដូចមាតាតាំងចិត្តនឹងកូននោះ ។

៣៦. បាបមិត្តេ វិវជ្ជេត្វា    ភជេយ្យុត្តមបុគ្គលំ
ឱវាទេ ចស្ស តិដ្ឋេយ្យ    បត្ថេន្តោ អចលំ សុខំ ។

បុគ្គលប្រាថ្នាសុខមិនកក្រើក    គប្បីតែលើកលែងមិត្តបាបខ្លាំង
ត្រូវសេពបុគ្គលឧត្តមសម្រាំង    ហើយមនចិត្តតាំងក្នុងឱវាទគេ ។

(ចប់មិត្តវគ្គ)

៣៧. ឱវទេយ្យានុសាសេយ្យ    អសព្ភា ច និវារយេ
សតំ ហិ សោ បិយោ ហោតិ    អសតំ ហោតិ អប្បិយោ

អ្នកប្រាជ្ញគួរប្រៀនប្រដៅពួកជន    ហាមគេឲ្យវៀរចាកក្ដីពាលោ
ប្រាជ្ញនោះនឹងបានជាទីពិយោ    សប្បុរសស្នេហា ស្នេហាទាំងអស់ ។
តែមិនជាទីស្រឡាញ់របស់    អសប្បុរសទាំងឡាយនោះឡើយ ។

៣៨. ទុល្លភោ បុរិសាជញ្ញោ    ន សោ សព្វត្ថ ជាយតិ
យត្ថ សោ ជាយតី ធីរោ    តំ កុលំ សុខមេធតិ

បុរសអាជានេយ្យកម្រកបាន    មិនកើតសព្វស្ថានគ្រប់ទីកន្លែង
កើតក្នុងត្រកូលណាជួយគិតកាត់តែង    ត្រកូលនោះឯងឲ្យបានសុខា ។

៣៩. យថា បនសា បក្កា    ពាហិ កណ្ដកាមេវ ច
អន្តោ អមតបូរណា    ឯវំ គរុជនជនា

ផ្លែខ្នុរទុំខាងក្រៅបន្លារ    ក្នុងមានរសជាតិដូចអម្រឹត
ជនខ្លះ ដែលជាអ្នកមានចិត្ត    ស្អាតល្អប្រព្រឹត្តក៏ដូច្នោះឯង ។

៤០- អនាគតំ ភយំ ទិស្វា ទូរតោ បរិវជ្ជយេ

អនាគតញ្ច ភយំ ទិស្វា អភីតោ ហោតិ បណ្ឌិតោ

បណ្ឌិតឃើញភ័យមុនមកដល់កាយ ជៀសវាងពីឆ្ងាយឲ្យផុតស្រឡះ
លុះភ័យមកដល់លោកដូចប្រទះ លោកដែលស្គាល់ច្បាស់មិនតក់ស្លុតឡើយ ។

៤១- គណ្ឌិដ្ឋានេ ឯកាបនេ ជាតិមញ្ញាយ បណ្ឌិតោ

តិមកោវេឡុបព្ភារេ តិមហានិបកាណ្ហកោ

បទធម៌ណាមួយអ្នកប្រាជ្ញចងហើយ កុំមើលងាយឡើយថាខុសទេ
ដូចព្រះអាទិត្យបំភ្លឺឃើញគេ ដូចម្តេចនឹងរញ្ចាយជាឫស្សី ។

៤២- គុណតោសេសុនេកោន អត្ថិកោ ច វិវជ្ជិតោ

សុខុមាលបទុមស្ស ឆទ្យំ ករតិកាត្តទ្យំ

អ្នកណាមួយវៀរចាកគុណនឹងទោស គំរូវនឹងខុសតែមួយពុំបាន
ប៉ុនជាតិផ្កាល្អក់ដែលគេរាប់អាន ថាល្អតង់មានទងនៅគ្រោតគ្រាត ។

៤៣- អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ

យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ

យោ ច សព្វទទោ ហោតិ យោ ទទាតិ ឧបស្សយំ

អមតន្ទទោ ច សោ ហោតិ យោ ធម្មំ អនុសាសតិ

ការឲ្យបាយដូចឲ្យកំលាំង ឲ្យគ្រឿងបិទបាំងដល់គេស្លៀកពាក់
ដូចឲ្យសម្បុរពណ៌ដល់នាងអ្នក ព្រោះគ្រឿងស្លៀកពាក់ឲ្យល្អស្មើមុខ ។
ឲ្យយានជិះដូចឲ្យក្ដីសុខ ឲ្យប្រទីបចុះដូចឲ្យបានភ្នែក
អ្នកឲ្យទីនៅ ដូចឲ្យបំណែក របស់គ្រប់បែករបស់ទាំងនោះ ។
អ្នកប្រដៅធម៌ដោយអនុគ្រោះ ចិត្តស្មោះចំពោះឲ្យគេបានត្រូវ
ដូចដឹកដៃទាក់ឲ្យដើរត្រង់ផ្លូវ អ្នកនោះលោកហៅថាឲ្យនិព្វាន ។

៤៤- តិណទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ
ស្រែស្រែមានស្មៅជាទោសឲ្យអាក់ សត្វមានរាគៈជាទោសដល់ប្រាណ
ទានជនឲ្យហើយក្នុងលោកដែលគ្មាន រាគៈនោះបានផលច្រើនពេកក្រៃ ។

៤៥- តិណទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ
ស្រែស្រែមានស្មៅជាទោសឲ្យអាក់ សត្វមានទោសៈជាទោសដល់ប្រាណ
ទានជនឲ្យហើយក្នុងលោកដែលគ្មាន ទោសៈនោះបានផលច្រើនពេកក្រៃ ។

៤៦- តិណទោសានិ ខេត្តានិ មោហទោសា អយំ បជា
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ
ស្រែស្រែមានស្មៅជាទោសឲ្យអាក់ សត្វមានមោហៈជាទោសដល់ប្រាណ
ទានជនឲ្យហើយក្នុងលោកដែលគ្មាន មោហៈនោះបានផលច្រើនពេកក្រៃ ។

៤៧- តិណទោសានិ ខេត្តានិ ឥច្ឆាទោសា អយំ បជា
តស្មា ហិ វិគតិច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ
ស្រែស្រែមានស្មៅជាទោសណាស់ណា សត្វមានឥច្ឆាជាទោសដល់ប្រាណ
ទានជនឲ្យហើយក្នុងលោកដែលគ្មាន ឥច្ឆានោះបានផលច្រើនពេកក្រៃ ។

យំកិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម
កាយេន វាចាមនសា តិទសេ សុគតំ កតំ
យេ សត្តា សញ្ញិនោ អត្ថិ យេ ច សត្តា អសញ្ញិនោ
កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ

យេ តំ កតំ សុវិហិតំ ទិន្នំ បុញ្ញផលំ មយា
យេ ច តត្ថ ន ជានន្តិ ទេវា គន្ត្វា និវេទយុំ
សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា
មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសា ។

កុសលកម្មតិចតួចឯណា ដែលខ្ញុំដ៏ះថ្វាហើយខ្ញុំបានធ្វើ
ដោយកាយវាចាចិត្តខ្ញុំអើពើ គួរនាំទៅលើកើតស្ថានត្រៃត្រិង្ស ។
សត្វមានសញ្ញាឯណាបានដឹង បុណ្យដែលខ្ញុំប្រឹងធ្វើនេះក្ដី
សូមឲ្យពួកសត្វផងអសញ្ញី ក៏ខ្ញុំតប្បីចែកបុណ្យនេះឲ្យ ។
ថាបើពួកសត្វនោះមិនដឹងហើយ ក៏ខ្ញុំសូមឲ្យទេព្ដាមានឫទ្ធិ
អញ្ជើញទៅប្រាប់ទៅដាស់តឿនចិត្ត ដោយក្ដីអាណិតសត្វក្នុងលោក ។
ឲ្យបានដឹងនេះហើយដោយចិត្តមេត្តា ត្រេកអរត្រប់គ្នាក្នុងលោកទាំងមូល
សូមមានអាហាររស់នៅដោយស្រួល ដោយបានទទួលផលបុណ្យនេះហោង ។

# ពិធីប្រគល់ព្រះរាជក្រឹត្យ

## ដល់ព្រះសង្ឃនិងគ្រហស្ថដែលបានទទួលយសស័ក្តិថ្មី

កាលនៅថ្ងៃ២៩ ខែណូវែម្ប៊្រ ឆ្នាំ ១៩៦៤ វេលារសៀលម៉ោង ១៦ (ម៉ោង ៤) លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ (ញៀរ. ទុយប៊ុនង៉ែត) បានធ្វើសន្និបាតប្រជុំព្រះសង្ឃក្រុមជំនុំប្រែព្រះត្រៃបិដក ព្រះសង្ឃជាអាចារ្យសាលាបាលីជាន់ខ្ពស់ និងក្រុមអ្នកធ្វើការក្រសួងពុទ្ធសាសនបណ្ឌិត្យទាំងអស់ ព្រមទាំងអ្នកសាមីខ្លួនដែលត្រូវបានទទួលយសស័ក្តិ ឲ្យមកជួបជុំគ្នានៅទីស្នងធំចំកណ្តាល លុះជួបជុំហើយ លោកអគ្គលេខាធិការមានប្រសាសន៍ថា :

“ដោយហេតុដែលព្រះករុណាគ្រប់អង្គ និងអស់លោក-អ្នកពល់គ្នា ខំយកចិត្តទុកដាក់ធ្វើការឲ្យបានចំរើន ដល់ក្រសួងពុទ្ធសាសនបណ្ឌិត្យមកពីឆ្នាំមុនៗ នោះហើយបានជាមកដល់ថ្ងៃនេះ យើងទើបបានឃើញភស្តុតាងដ៏ជាក់ស្តែងចំពោះមុខ គឺព្រះករុណាអម្ចាស់ជីវិតលើត្បូង និងលោកនាយកអាណាព្យាបាលក្រុងកម្ពុជា ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានសមណស័ក្តិនិងយសស័ក្តិ ដល់ព្រះករុណាអង្គខ្លះ និងលោក-អ្នកខ្លះដើម្បីជាបំណាច់ដល់កំឡាំងព្យាយាមនេះ ”

វេលានេះ ខ្ញុំសូមលើកជាថ្មីទៅមុខទៀតថា ក្រសួងពុទ្ធសាសនបណ្ឌិត្យនេះ ដែលនឹងបានលូតលាស់ចំរើនច្រើនៗ ឡើងនោះ មិនមែនដោយកំឡាំងមនុស្សតែម្នាក់ៗ ទេ អាស្រ័យដោយការរួបរួម

កំឡាំងទាំងអស់គ្នា គឺម្នាក់ៗ ប្រឹងធ្វើឲ្យបានសម្រេចតាមមុខការរៀនខ្លួនមិនបណ្តែតបណ្តោយ មិនអាងតែគេ មិនប្រចាំគ្នា យ៉ាងនេះទើបបានចំរើន ប្រសិនបើមានអ្នកខ្លះខំធ្វើ អ្នកខ្លះទម្រន់ខ្ជិលធ្វើ ដូច្នេះមិនជាយូរប៉ុន្មានទេ ក្រសួងពុទ្ធសាសនបណ្ឌិត្យមុខជានឹងរអិលថយក្រោយវិនាសសាបសូន្យទៅវិញមិនខាន តពីនេះទៅ ត្រូវយើងពួតដៃគ្នាខិតខំធ្វើការឲ្យម៉ឺងម៉ាត់ ឲ្យរឹតតែបានកើនជឿនទៅមុខទ្វេឡើងទៀត ដើម្បីនឹងជួយដឹកនាំប្រទេសជាតិឲ្យស្ទុះទៅដល់ថ្នាក់ដ៏ខ្ពង់ខ្ពស់ ។

នៅទីបំផុតនេះ ខ្ញុំមានចិត្តត្រេកអរជាពន់ពេក ក្នុងការដែលព្រះករុណា និងអស់អ្នកទាំងឡាយ មានព្យាយាមបានបំពេញកិច្ចការរៀនខ្លួន យ៉ាងពេញលេញមកហើយនេះ ។

កាលលោកអគ្គលេខាធិការមានប្រសាសន៍ចប់ហើយ ក៏បានប្រគេនព្រះរាជក្រឹត្យដល់ព្រះសង្ឃ ៣ អង្គ និងឲ្យដល់គ្រហស្ថ ៩ នាក់ដូចបញ្ចេញនាមតទៅនេះ;

## ខាងព្រះសង្ឃ ៣ អង្គ

១— លោកគ្រូ មាស–សុវណ្ណ ជាក្រុមជំនុំប្រែព្រះត្រៃបិដក អាយុ ៤៣ ឆ្នាំ វស្សា ២២ ត្រូវតាំងជាព្រះគ្រូ "ធម្មកោសល" ទីឋានា គណធម្មយុត្តិ វត្តស្វាយពពែ (ភ្នំពេញ) ។

២— លោកគ្រូ ឡុង-ថាន ជាអាចារ្យសាលាបាលីជាន់ខ្ពស់ អាយុ ៤១ ឆ្នាំ វស្សា ២០ ត្រូវតាំងជាទីព្រះគ្រូ "បញ្ញាវិទូ" ទីឋានា គណមហានិកាយ វត្តសាកវ៉ន (ភ្នំពេញ) ។

៣— លោកគ្រូ យ៉ាញ់-អ៊ុន ជាក្រុមជំនុំប្រែព្រះត្រៃបិដក អាយុ ៣១ ឆ្នាំ វស្សា ១១ ត្រូវតាំងជាទីព្រះគ្រូ "ជម្ពូរក្ខិត" ទីឋានា គណធម្មយុត្តិ វត្តស្វាយពពែ (ភ្នំពេញ) ។

## ខាងគ្រហស្ថ ៩ នាក់

៤– ព្រះនាយកមន្ត្រី យៀន-ប៊ឹម ជាគូឈ្មួយនៃលោកអគ្គលេខាធិការ ត្រូវឡើងជាទី "ឧកញ៉ានាយកមន្ត្រី" ស័ក្តិ ៧ ហ៊ូពាន់ ។

៥— លោកញូង-សៀង ក្រុមជំនុំប្រែព្រះត្រៃបិដក ត្រូវតាំងជាទី "ឃុនសុន្ទរមេធី" ស័ក្តិ ៤ ហ៊ូពាន់ ។

៦– លោក ឈឹម-ណាក ស្មៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុនបរិក្សបរិកណ្ណ" ស័ក្តិ ៤ ហ៊ូពាន់ ។

៧ — លោក គី-គិមស៊ីវ ស្មៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុនសមត្ថប្រិជា" ស័ក្តិ ៤ ហ៊ូពាន់ ។

៨—លោក ស-សឿន រៀនសាលាបាលីជាន់ខ្ពស់ ត្រូវតាំងជាទី "ឃុនវិចិត្រវេទី" ស័ក្តិ ៤ ហ៊ូពាន់ ។

៩— លោក អ៊ុម-គន រៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុនសោភ័ណភ័ក្តិ" ស័ក្តិ ៤ ហ៊ូពាន់ ។

១០— លោក ហង់-ឡឿ គ្រូបង្រៀនសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់ ត្រូវតាំងជាទី "ឃុនសកជានុសិដ្ឋ" ស័ក្តិ ៤ ហ៊ូពាន់ ។

១១— លោក មាស-យុត រៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុន-សុមេធមន្ត្រី" ស័ក្តិ ៤ ហ៊ូពាន់ ។

១២—លោក ដិត-ប៊ុន រៀនពុទ្ធសាសនបណ្ឌិត្យ ត្រូវតាំងជាទី "ឃុនវោហារវិចិត្រ" ស័ក្តិ ៤ ហ៊ូពាន់ ។

---

## ភ្នាក់ងារនៃពុទ្ធសាសនបណ្ឌិត្យ

### បានទទួលព្រះរាជទានគ្រឿងឥស្សរិយយស

កាលពីថ្ងៃ ៨ ណូវែមប្រ៍ឆ្នាំ ១៩៤៤ : នៅឱកាសដែលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះសីហនុ-វរ្ម័នស្តេចយាងទៅទ្រង់ទស្សនាការមន្ទីរអាល្យែរសារ៉ូត៍ នោះទ្រង់ព្រះរាជទានគ្រឿងឥស្សរិ-

យយស (មេដៃយ៍) ផល់ភ្នាក់ងារពុទ្ធសាសនបណ្ឌិត្យ ដូចមាននាម-ខាងក្រោមនេះ:

## អស្សរិទ្ធិនៃក្រុងកម្ពុជា

ឃុនវរៈក្សេត្រកណ្ឌ ឈឹម-ណាក ភ្នាក់ងារពុទ្ធសាសនបណ្ឌិត្យ ធ្វើការនៅក្រមន្ទីរការផ្សាយសោរ៉ូត ។

ឃុនមេឈមន្ត្រី មាស-យុក " " ។

បញ្ញាសាគណ គាំ-ទុំ " " ។

## អស្សរិទ្ធិសុរិត្តា

ឧកញ៉ា នាយកមន្ត្រី យឿន-ចឹម គួឈួយពុទ្ធសាសនបណ្ឌិត្យ ។

## មណីសារភ័ណ

លោក សារ-សឿន ជាឆ្មាំទ្វារនៅមន្ទីរការផ្សាយសោរ៉ូត ។

ឃុនមគ្គប្រឹជា គី-គឹមស៊ីវ ភ្នាក់ងារពុទ្ធសាសនបណ្ឌិត្យធ្វើការនៅមន្ទីរការផ្សាយសោរ៉ូត ។

ខ្សែរនាវ៉ាត្តិកម្ពុជសុរិយា សូមជូនពរស័ព្ទសាធុការដល់អស់លោកដូចមានឈ្មោះនាមខាងលើនេះ សូមឲ្យបានទទួលសេចក្តីសុខ-ចំរើនជាគំរយក្រាភាពទៀតទៅកុំបីឃ្លាតឡើយ ។

# សេចក្តីរាយការណ៍សង្ខេប

## នៃមហាសង្ឃសន្និបាតនៅវត្តព្រះកែវមរកតសុវណ៌

កាលពីថ្ងៃ ១១ ណូវ៉ែមប្រ៍ ១៩៤៤ វេលាម៉ោង ៩ កន្លះ មានការប្រជុំធំ អស់ទាំងលោកមេគណ និងអនុគណ ព្រមទាំងសម្តេចសង្ឃនាយក គណមហានិកាយ និងធម្មយុត្តិ ព្រះរាជាគណៈផ្សេងៗនៅក្រុង សុទ្ធបាន និមន្តទៅជួបជុំនៅព្រះវិហារព្រះកែវ ។ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះបរមរាជបិតា, សម្តេចព្រះវររាជជននីនាថ ព្រមទាំងសេនាបតីក្រសួងធម្មការ និងពួកមន្ត្រីក្នុងព្រះរាជសំណាក់ ក៏បានស្តេចយាងទៅនិងអញ្ជើញទៅជួបជុំក្នុងឱកាសនោះផង ។

លុះស្តេចយាងមកដល់មន្ទីរព្រះសុធម្ម ដែលមានគណសង្ឃគង់រង់ចាំនោះហើយ នោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ថ្លែងព្រះរាជបន្ទូលអំណរគុណ និងសេចក្តីសោមនស្សរបស់ទ្រង់ ចំពោះព្រះសង្ឃដែលបាននិមន្តមកជួបជុំជាមហាសន្និបាត ។ រួចទ្រង់មានព្រះរាជបន្ទូលចំពោះគណសង្ឃមហានិកាយថា ទ្រង់មានព្រះរាជហឫទ័យរីករាយណាស់ ដែលព្រះសង្ឃគណៈនេះបានស្រុះស្រួលព្រមព្រៀងប្រតិបត្តិតាមបញ្ញត្តិ ដើម្បីឲ្យកើតសេចក្តីចំរើនដល់ទៅអនាគត ទាំងខាងពុទ្ធចក្រ និងអាណាចក្រ ។

តមកសេនាបតីក្រសួងធម្មការបានថ្លែងពាក្យ ជាតំណាងតាងនាម លោកឡេវេស៊ីដង់តិស៊ុប៉េរីយ៉េរ ដល់ព្រះករុណាជាអម្ចាស់ជីវិត និង

គណសង្ឃក្នុងមហាសន្និបាតនោះថា លោកស្ដាយណាស់ដែលមិនបានឱកាសចូលមកជំនុំ ដោយមានករណីយកិច្ច ហើយលោកបានថ្លែងអំណរអរគុណចំពោះព្រះសង្ឃព្រមទាំងមានសង្ឃមជា ព្រះសង្ឃគណៈមហានិកាយនិងព្រមព្រៀងស្រុះស្រួលប្រតិបត្តិតាមបញ្ញត្តិដែលជាហេតុដ៏សំខាន់ក្នុងការដឹកនាំអ្នកកាន់សាសនា ទាំងអ្នកបួស ទាំងគ្រហស្ថឲ្យមានការយល់ត្រូវនិងប្រតិបត្តិត្រឹមត្រូវតាមច្បាប់វិន័យ ។

លុះដល់ម៉ោង ១១ ព្រះករុណាជាអម្ចាស់ជីវិត ទ្រង់ឲ្យតាក់តែងប្រគេនចង្ហាន់ដល់ព្រះសង្ឃ ដែលបាននិមន្តមកជំនុំមានចំនួនច្រើនជាង ៨០ រូបទៀតទៅ ក្នុងឱកាសនោះផង ។

កាលពីថ្ងៃ ១០ ខែ ១១ ណូវ៉ែម្ប្រ៊ី ១៩៥៥ នៅឱកាសដែលចូលទៅថ្វាយបង្គំសម្ដេចព្រះសង្ឃនាយកនៅវត្តសារាវ៉ាន់ នោះលោកមេគណដែលនិមន្តមកអំពីតំបន់នានាក្នុងប្រទេស បានប្រជុំគ្នានៅវត្តសារាវ៉ាន់ក្រោមអធិបតីនៃសម្ដេច ព្រះមហាសុមេធាធិបតីដោយជួបជុំជាមួយនឹងព្រះរាជាគណៈទាំងពួង ។

នៅឱកាសប្រជុំទាំងពីរលើកនេះ អ្នកឧកញ៉ាអគ្គមហាសេនាសេនាបតីក្រសួងធម្មការ បានអញ្ជើញទៅជួបជុំជាមួយផងដែរ ។

នៅវេលាប្រជុំនោះ មាននិយាយពន្យល់អំពីក្រមនិងសង្ឃប្រកាស រឿងរៀបចំការសាសនាឲ្យបានល្អឡើង ដែលសម្តេចព្រះសង្ឃនាយក និងសេនាបតីក្រសួងធម្មការបានព្រាងរៀបរៀងឡើង ។

លោកគ្រូព្រះពោធិវង្ស ជួន-ណាត មានថេរដីកាបញ្ជាក់មកទៀត អំពីបំណងរបស់សម្តេចព្រះសង្ឃនាយក ដើម្បីរំលឹកអស់លោកមេគណ និងអនុគណ អំពីមុខក្រសួងនិងកិច្ចការរបស់ចៅអធិការ ក្នុងការត្រួតត្រាវត្តរបស់ខ្លួនៗ តាមរបៀបដែលសម្តេចព្រះសង្ឃនាយករៀបចំទុក ។

មុនបិទប្រជុំលើកក្រោយនេះ ព្រះសង្ឃដែលសន្និបាតបាននាំគ្នាសូត្រធម៌ "ជយន្តោ" សុំឲ្យមហានគរបានគង់វង្ស ត្រឡប់មានវឌ្ឍ-នុភាពឡើងវិញដោយឆាប់រហ័ស ។

នៅឱកាសនោះ ព្រះសង្ឃបានសូត្រធម៌ជូនពរសព្ទសាធុការ ដល់លោកនាយកកងនាវា សង់ដឺគួស អធិបតីសហរដ្ឋឥណ្ឌូស៊ីន និងជាភ្នាក់ងារជាន់ខ្ពស់នៅសមុទ្រប៉ាស៊ីហ្វិក ។ ថ្វាយព្រះសព្ទសាធុការពរ ដល់ព្រះករុណាព្រះបាទសម្តេចព្រះសីហនុ-វរ្ម័ន ព្រះចៅក្រុងកម្ពុជាធិបតី និងជូនពរសព្ទសាធុការ ដល់លោកឡឺរេស៊ីដង់ស៊ុបេរីយើរ នាយកក់ដការអាណាព្យាបាល សូមឲ្យទ្រង់ព្រះករុណាជាអម្ចាស់ជីវិត និងអស់លោកឲ្យបានប្រកបដោយពរគឺ: អាយុ: វណ្ណ: សុខ: ពល: តរៀងទៅ ។

# អំពីចៅអធិការដែលទើបតាំងថ្មី

ក្នុងរវាងខែសេបតម្ប៊ី — ឆ្នាំគ្រិស្ត ១៩៥៥

១– សញ្ញាប័ត្រលេខ ៩៩ ចុះថ្ងៃ ២២-៩-៥៥ តាំងលោកគ្រូ គីម-វើត កើតឆ្នាំច អាយុ ៣៩ វស្សា ១៣ នាមឆាយា បញ្ញាថេរ ជាចៅអធិការ វត្តអង្គុយ ឃុំកំពែង ស្រុកគិរីវង្ស ខេត្តតាកែវ ។

២– សញ្ញាប័ត្រលេខ ១០០ ចុះថ្ងៃ ២២-៩-៥៥ តាំងលោកគ្រូ ថែន សាម កើតឆ្នាំថោះ អាយុ ៥៥ វស្សា ៣២ នាមឆាយា សុវណ្ណបញ្ញោ ជាចៅអធិការវត្តឃោសិកើម ឃុំកមអណ្ដើក ស្រុកគិរីវង្ស ខេត្តតាកែវ ។

៣– សញ្ញាប័ត្រលេខ ១០១ ចុះថ្ងៃ ២២-៩-៥៥ តាំងលោកគ្រូ នឹម-ហម កើតឆ្នាំខាល អាយុ ៣២ វស្សា ១២ នាមឆាយា ព្រហ្មជោត-ត្ថេរ ជាចៅអធិការវត្តអង្គនោម ឃុំកមអណ្ដើក ស្រុកគិរីវង្ស ខេត្តតាកែវ ។

៤– សញ្ញាប័ត្រលេខ ១០២ ចុះថ្ងៃ ២៩-៩-៥៥ តាំងលោក គ្រូខេត-បេស កើតឆ្នាំម្សាញ់ អាយុ ២៩ វស្សា ៧ នាមឆាយា សុវណ្ណ-បញ្ញោ ជាចៅអធិការវត្តពោធិអង្គជុំ ឃុំកមអណ្ដើក ស្រុកគិរីវង្ស ខេត្តតាកែវ ។

៥– សញ្ញាប័ត្រលេខ ១០៣ ចុះថ្ងៃ ២៩-៩-៥៥ តាំងលោក គ្រូអ៊ំ-ឡុង កើតឆ្នាំខាល អាយុ ៥៥ វស្សា ៣៤ នាមឆាយា សុវណ្ណ-ត្ថេរ ជាចៅអធិការវត្តគោកគោ ឃុំកមអណ្ដើក ស្រុកគិរីវង្ស តាកែវ ។

៦ – សញ្ញាប័ត្រលេខ ១០៤ ចុះថ្ងៃ ២៩-៩-៤៤ តាំងលោកគ្រូឈិម-ហ៊ឹម កើតឆ្នាំជូត អាយុ ៣២ វស្សា ១១ នាមឆាយា ឯកគ្គបញ្ញោ ជាចៅអធិការវត្តព្រៃវែង ឃុំកំពែង ស្រុកគិរីវង្ស (តាកែវ) ។

៧ – សញ្ញាប័ត្រលេខ ១០៥ ចុះថ្ងៃ ២៩-៩-៤៤ តាំងលោកគ្រូជុំ-នុត កើតឆ្នាំខាល អាយុ ៤៤ វស្សា ១៣ នាមឆាយា ឯកគ្គបញ្ញោ ជាចៅអធិការវត្តអង្គស្វាយក្រោម ឃុំកំពែង ស្រុកគិរីវង្ស (តាកែវ) ។

៨ – សញ្ញាប័ត្រលេខ ១០៦ ចុះថ្ងៃ ២៩-៩-៤៤ តាំងលោកគ្រូអ៊ុក-ជឹម កើតឆ្នាំមមែ អាយុ ៣៨ វស្សា ១៦ នាមឆាយា ព្រហ្មបញ្ញោ ជាចៅអធិការវត្តពែង ឃុំកំពែង ស្រុកគិរីវង្ស (តាកែវ) ។

៩ – សញ្ញាប័ត្រលេខ ១០៧ ចុះថ្ងៃ ២៩-៩-៤៤ តាំងលោកគ្រូគង់-ស៊ុំ កើតឆ្នាំកា អាយុ ៣៦ វស្សា ១៥ នាមឆាយា ព្រហ្មកេរ ជាចៅអធិការ វត្តសរៃស ឃុំអង្កាញ់ ស្រុកត្រាំង (តាកែវ) ។

១០ សញ្ញាប័ត្រលេខ ១០៨ ចុះថ្ងៃ ២៦-១០-៤៤ តាំងលោកគ្រូ ចាស-ធាន កើតឆ្នាំថោះ អាយុ ៤២ វស្សា ២២ នាមឆាយា អាកសុរ-ណ ជាចៅអធិការ វត្តតាឡកឃុំពួក ស្រុកពួក សៀមរាប ។

---

ឯកកាគមិសិក្ខព្យញ្ញា

# ហ្លួងនិពន្ធមន្ត្រី ញ៉ុក ថែម ប្រែនិងរៀបរៀង

(តមក)

## អង្គ ៤ របស់គោ:

១- មិនលះបង់គោលគ្រោល ដែលខ្លួនធ្លាប់នៅ ។

២- លីតែទឹម អូសទាញតែទឹមទៅ ទុកជាធ្ងន់ក៏ដោយ ស្រាលក៏ដោយ ។

៣- ប្រើធ្មេញទំពាអៀនស្មៅ ឆ្អែតហើយក៏ផឹកទឹក ។

៤- កាលម្ចាស់បង្ហាត់ឲ្យធ្វើយ៉ាងណាៗ ក៏ធ្វើតាមពាក្យគ្រប់យ៉ាងៗ

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៤ ប្រការគឺ:

១- មិនលះបង់គោលនៃកាសាវៈរបស់ខ្លួន សម្រាប់ពិចារណារឿយៗ ថាកាយនេះមិនទៀងទេ មានការប្រែក្លាយខ្ចាត់ខ្ចាយទៅជាធម្មតា ។

២- សមាទានព្រហ្មចរិយធម៌ ប្រព្រឹត្តព្រហ្មចរិយឲ្យបរិសុទ្ធដូរផង ដរាបដល់អស់ជីវិត ប្រកបដោយសុខទុក្ខ ទុក្ខទោសកង្វល់ណាៗផ្សេងៗគ្នា ។

៣- ទទួលយកឱវាទានុសាសន៍របស់ឧបជ្ឈាយ៍អាចារ្យដោយពេញចិត្ត ជ្រះថ្លាទាំងតាំងចិត្តស្តាប់ធម៌ ។

៤- តាំងចិត្តទទួលយកឱវាទានុសាសន៍របស់កល្យាណជនគ្រប់ជាន់គ្រប់ថ្នាក់ ទាំងជាថេរៈ មជ្ឈិមៈ ឬនវកៈ ទាំងជាគ្រហស្ថដែលជាពួកឧបាសកឧបាសិកា ។

## អង្គ ៤ របស់ព្រានព្រៃ

១– កាលចេញទៅស្វែងរកនេសាទសត្វព្រៃ មិនមានងងុយដេក ។

២– តាំងចិត្តទុកតែក្នុងការនេសាទសត្វព្រៃប៉ុណ្ណោះ ។

៣– ដឹងកាលវេលាក្នុងការនេសាទសត្វព្រៃ ។

៤– ឃើញសត្វព្រៃហើយក៏កើតចិត្តត្រេកអរដ៏ក្រៃលែង ថានឹងបានសត្វព្រៃនោះមក ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៤ ប្រការគឺ:

១– ប្រាសចាកថីនមិទ្ធៈ គឺមិនមានចិត្តស្រពោនស្រពន់ងោកងក់ ។

២– ចងចិត្តទុកក្នុងអារម្មណ៍តែមួយ ដែលអាចឲ្យលុះបានធម៌វិសេសដ៏ទៀងទាត់ ។

៣- ដឹងកាលនឹងចំរើនសមាធិ នឹងកាលដែលចេញចាកសមាធិ ។

៤– ដល់ប្រទះនឹងអារម្មណ៍ជាទីរីករាយហើយ ក៏កើតសេចក្ដីសប្បាយចិត្តថានឹងបានសម្រេចគុណវិសេសដ៏ក្រៃលែងឡើងទៅទៀត ។

## អង្គ ៤ របស់នាយខ្មាន់ធ្នូ

១– កាលនឹងបាញ់កូនសរទៅ ក៏ចប់ជើងឲ្យជាប់នឹងផ្ទៃផែនដី តាំងគ្នងជង្គង់ឲ្យនឹងមិនឲ្យកម្រើកញ័រ លើកធ្នូឡើងតាំងស្មើនឹងត្រចៀក

ស្រលៀននៃគ្រូកបួញមាត់សំដៅឲ្យត្រង់ទៅ ទើបកើតចិត្តជាទីដៅបាញ់ទៅ ។

២- ថែរក្សាឈើដំពាមទុក សម្រាប់ពត់កូនសរដែលវៀចកោងឲ្យត្រង់បាន ។

៣- សំឡឹងផ្ចង់ឲ្យចំទៅទីលំដៅ ។

៤- ហាត់បាញ់តាំងក្នុងវេលាព្រឹកតាំងក្នុងវេលាល្ងាច ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គ ៤ ប្រការ គឺៈ

១- តាំងខំប្រឹងគឺវីរិយៈ (សេចក្តីព្យាយាម) ទុកលើផែនដីគឺសីលឲ្យខ្ជាប់ បំពេញខន្តីនឹងសោរច្ចៈមិនឲ្យទ្រេតទ្រោត ដំកល់ចិត្តទុកក្នុងសំវរៈ (សេចក្តីសង្រួម) កំចាត់បង់នូវទោមនស្សនឹងសោមនស្សក្តី យោនិសោមនសិការៈទុកក្នុងចិត្ត ផ្គុំផ្គងសេចក្តីព្យាយាម បិទទ្វារទាំង ៦ ដំកល់ស្មារតីឲ្យខ្ជាប់ ញុំាងសេចក្តីតក្កយឲ្យកើតឡើង ជាអញ្ញនឹងសម្លាប់កងកិលេសដោយញាណគឺកូនសរ ។

២- ចំរើនសតិបដ្ឋានដូចនាយខ្មាន់ធ្នូ ថែរក្សាឈើដំពាមទុក ពត់ចិត្តដែលវៀចកោងឲ្យត្រង់ល្អ ។

៣- ពិចារណាកាយនេះ តាមផ្លូវព្រះត្រៃលក្ខណ៍ ។

៤- ដំកល់ចិត្តទុកក្នុងអារម្មណ៍ ១ ស្រាប់ពិចារណាកាលពេលព្រឹកពេលល្ងាច ។

(មានត)

# សេចក្តីជូនដំណឹង

ពុទ្ធសាសនបណ្ឌិត្យសូមជូនដំណឹង ដល់អស់លោក-អ្នកជាវទស្សនាវដ្តី កម្ពុជសុរិយា សូមជ្រាប ។

ឥឡូវដល់វេលាផុតឆ្នាំចាស់ (ឆ្នាំ១៩៤៤) ចូលមកកាន់ឆ្នាំថ្មី (ឆ្នាំ១៩៤៥)ហើយ ពុទ្ធសាសនបណ្ឌិត្យ សូមរំលឹកអស់លោក-អ្នកជាវទស្សនាវដ្តីនេះ ទាំងអ្នកជាវចាស់ទាំងអ្នកជាវថ្មី បើអស់លោក-អ្នកត្រូវការទស្សនាវដ្តី ឆ្នាំ ១៩៤៥ សូមមេត្តាចុះឈ្មោះ-ទីលំនៅ-ដំឡៃជាវ ផ្ញើទៅពុទ្ធសាសនបណ្ឌិត្យជាប្រញាប់កុំបីខាន ដើម្បីជាឱកាសឲ្យពុទ្ធសាសនបណ្ឌិត្យ ចាត់ការផ្ញើសៀវភៅមកជូនអស់លោក-អ្នកតាមកាលវេលា ។

ដូច្នេះ សូមអស់លោក-អ្នកជាវទាំងឡាយ កុំបីបង្អែបង្អង់ឡើយ ដើម្បីនាំគ្នាជួយកសាងអក្សរសាស្ត្ររបស់ជាតិ ឲ្យបានចំរើនរុងរឿងទាន់កាលសម័យដូចជាប្រទេសជិតខាងឡើង ។